

កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍

## ភាគទី ២

# វប្បធម៌និងអត្តសញ្ញាណ ៖ ប្រទេសកម្ពុជាក្នុងបរិបទអាស៊ីអាគ្នេយ៍

បកប្រែពីភាសាអង់គ្លេសដោយ
តាន់ សូដានី, ប៉ុង ភក្តី បូរាមី, យិន សំបូរ និង សុខ លាំង

## Cultures and Identities: Cambodia in the Southeast Asian Context

Translated from English by Tan Sodany, Pong Pheakdeyboramy, Yin Sombo, and Sok Leang

ជំពូកទី ១ ៖ តួអង្គក្បត្រាលោតនេតើ! ៖ ការសម្តែងភាពជាបុរសនៅម៉ាង់ដាលេ

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **ប្រទេសភូមានៅពេលឈានចូលក្នុងសតវត្សរ៍ទី ២១** (*Burma at the Turn of the Twenty-first Century*) ។

រក្សាសិទ្ធិ គ. ស. ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។

**Copyright © 2005 by University of Hawai'i Press.**

ជំពូកទី ២ ៖ ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ អារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមសៀម

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **ភេទភាវៈនិងអារម្មណ៍ផ្លូវភេទ នៅប្រទេសថៃនាសម័យទំនើប** (*Genders and Sexualities in Modern Thailand*) ។

រក្សាសិទ្ធិ គ.ស. ១៩៩៩ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយសិលក៍វ៉មប៊ុក្ស (ឈៀងហ្មៃ) ។

**Copyright © 1999 by Silkworm Books (Chiang Mai).**

ជំពូកទី ៣ ៖ ជំរឿន ការកូសផែនទី និងការតាំងបង្ហាញ

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **សហគមន៍ដែលគេស្រមើស្រមៃ ៖ ការត្រិះរិះពិចារណាអំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម** (*Imagined Communities: Reflections on the Origin and Spread of Nationalism*) ។

រក្សាសិទ្ធិ គ.ស. ២០០៦ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយវែរសូ (ឡុងដ្រ៍) ។

បោះពុម្ពលើកទី ១ គ. ស. ១៩៨៣ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយវែរសូ ។

**Copyright © 2006 by Verso (London).**

**First published in 1983 by Verso.**

ជំពូកទី ៤ ៖ រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០–១៩៣០

អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖ **ការបំបាត់បំបបចក្រភព ៖ ពូជសាសន៍ ភេទភាវៈ និងជីវិតគ្រួសារក្នុងសម័យអាណានិគមនិយមបារាំងសែសនិងហូឡង់** (*Domesticating the Empire: Race, Gender and Family Life in French and Dutch Colonialism*) ។

រក្សាសិទ្ធិ គ.ស. ១៩៩៨ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យវីរហ្ស៊ីនៀ (ឆាឡុត្តស៍វិល្ល និង ឡុងដ្រ៍) ។

**Copyright © 1998 by The University Press of Virginia (Charlottesville and London).**

រក្សាសិទ្ធិក្នុងការបកប្រែនិងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០០៨ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

**Copyright © 2008 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ** ◢ **Cover picture**

អ្នកស្រី តាន់ សូដានី (រក្សាសិទ្ធិ) គ.ស. ២០០៨ **Copyright © 2008 Tan Sodany.**

ការបកប្រែនិងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ក្ហ៊ីហ្វេល្ល័រ នៅញូយ៉ក ។

**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-០៦-៨ ISBN-13: 978-99950-51-06-8

បោះពុម្ពនៅប្រទេសកម្ពុជា ។ **Printed in Cambodia.**

## សារបណ្ណ


*កថាមុខ* ៥

*កំណត់អំពីនិយមន័យ បញ្ញត្តិ និងការបកប្រែពាក្យ «យេនឌ័រ»* ៩

**ជំពូកទី ១ ៖ តួអង្គក្បត់លោកធេធេ ! ៖ ការសម្តែងភាពជាបុរសនៅម៉ាន់ដាលេ** **១៣**

*ការសម្តែងភេទភាវៈ* ១៦

*ការសម្តែងទស្សនីយភាពសិល្បៈបែបភូមា (បុណ្យផ៉ាន«ហ្សាក់ពៃ»)* ១៧

*ការបើកឆាក* ១៧

*ល្ខោនច្រៀង* ១៨

*ការប្រគំតន្ត្រីបែបសម័យ* ១៩

*ល្ខោន «ប្យាហ្សាក់»* ១៩

*ការច្រៀងឆ្លើយឆ្លង* ២០

*លក្ខណៈសំខាន់នៃសម្លៀកបំពាក់* ២១

*ភាពជាបុរសច្រើនប្រភេទ ដែលអាចជ្រើសរើសបាន* ២៣

*ការសម្តែងតាមបែបបុរាណ* ២៧

*ការសម្តែងជាតួអង្គទេវតា និងការគ្មានអំណាច* ៣០

*ការធ្លាក់ចុះរបស់ស្ត្រី* ៣៣

*ភាពជាបុរស សម្ពន្ធភាពផ្លូវភេទ និងព្រះសង្ឃ* ៣៦

**ជំពូកទី ២ ៖ ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ អារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមសៀម** **៣៩**

*ព្រះរាមទី ៦ និងបញ្ហាអត្តសញ្ញាណជាតិ* ៤២

*ស្ត្រីនិងការប្រែក្លាយឲ្យទៅជាបែបបស្ចិមប្រទេស* ៤៥

*ការស្នេហាជាតិ* ៥០

*សេចក្តីសន្និដ្ឋាន* ៥៣

**ជំពូកទី ៣ ៖ ជំនឿន ការគូសផែនទី និងការតាំងបង្ហាញ** **៥៥**

*ជំនឿន* ៥៨

*ការគូសផែនទី* ៦២

*ការតាំងបង្ហាញ* ៦៧

**ជំពូកទី ៤ ៖ រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០-១៩៣០** **៧៣**

*ការធ្វើឲ្យឥណ្ឌូចិនមានសភាពជាស្រី ៖ រឿងប្រតិដ្ឋជាតិ ហើយនិងការរស់នៅរួមគ្នាក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០-១៩៣០* ៧៥

*ការធ្វើអាណានិគមទៅលើប្រទេសកម្ពុជា៖ ពួកអ្នករុករក ពួកម៉ាដាម (លោកស្រី) និងឱនភាព* ៧៧

*លោក រ៉ូឡង់ ម៉េយែរ និងហានិភ័យនៃការឆ្លងរបាំងវប្បធម៌* ៨៦

*លោក ហ្សិក ក្រោលីយ៉េរ៍ និងហានិភ័យនៃភាពទំនើប* ៩០
*សេចក្ដីសន្និដ្ឋាន* ៩៦
**កំណត់ចំណាំ** ***៩៩***
*ជំពូកទី ១* ៩៩
*កំណត់ចំណាំ* ៩៩
*ឯកសារពិគ្រោះ* ១០០
*ជំពូកទី ២* ១០២
*កំណត់ចំណាំ* ១០២
*ឯកសារពិគ្រោះ* ១០៤
*ជំពូកទី ៣* ១០៦
*កំណត់ចំណាំ* ១០៦
*ជំពូកទី ៤* ១១២
*កំណត់ចំណាំ* ១១២

# កថាមុខ

ចាប់តាំងពីឆ្នាំ ២០០៤ មក មជ្ឈមណ្ឌលខេមរសិក្សាបានដំណើរការកម្មវិធីបណ្តុះបណ្តាលដ៏សំខាន់មួយ សម្រាប់គ្រូបង្រៀនថ្នាក់ឧត្តមសិក្សាវ័យក្មេង ។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ឧត្តមសិក្សានេះ ជួយឲ្យនិសិត្សខ្មែរ ដែលជិតបញ្ចប់ការសិក្សា ឬគ្រូបង្រៀនតាមសាកលវិទ្យាល័យនានា ពង្រីកការស្រាវជ្រាវ និងការបង្រៀនរបស់ពួកគេ នៅក្នុងវិស័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ ។ ដោយបានទទួលការឧបត្ថម្ភពីមូលនិធិរ៉ុក្ខីហ្វេល្ល័រ កម្មវិធីនេះមាននូវវគ្គបណ្តុះបណ្តាលរយៈពេល ៦ ខែជាច្រើនវគ្គ ដឹកនាំដោយសាស្ត្រាចារ្យដែលបានទទួលការអញ្ជើញមួយរូបៗ ។ នៅក្នុងវគ្គសិក្សានីមួយៗ មានប្រធានបទផ្សេងៗគ្នា ហើយប្រធានបទនីមួយៗ ផ្តោតលើទិដ្ឋភាពមួយនៃសង្គមកម្ពុជាសម័យទំនើប ។ យើងខ្ញុំបានធ្វើការជាមួយអ្នកតំណាងមកពីសកលវិទ្យាល័យនៅកម្ពុជា ដើម្បីកំណត់ប្រធានបទសម្រាប់វគ្គនីមួយៗ ក្នុងគោលបំណងទាក់ទាញអ្នកចូលរួមដែលមានជំនាញផ្សេងៗគ្នា ។ ប្រធានបទនីមួយៗ មានបញ្ចូលទស្សនវិស័យប្រៀបធៀប ដែលក្នុងនោះ មានការសិក្សាអំពីប្រទេសកម្ពុជាជាមួយប្រទេសជិតខាងដទៃទៀត ដូចជា ប្រទេសថៃ វៀតណាម ឡាវ ភូមា និងប្រទេសដទៃទៀតនៅក្នុងតំបន់ ។ ក្នុងរាល់វគ្គសិក្សានីមួយៗ យើងខ្ញុំមានសកម្មភាពជាច្រើន ដូចជា ការសិក្សានៅក្នុងថ្នាក់សិក្ខាសាលា ការចុះកម្មសិក្សានៅតាមបណ្តាប្រទេសជិតខាង ការចុះស្រាវជ្រាវរបស់អ្នកចូលរួមម្នាក់ៗ ជាដើម ។ សកម្មភាពបន្តទៀត ធ្វើឡើងជាទម្រង់សន្និសីទអន្តរជាតិ ដែលផ្តោតលើមូលបទរបស់វគ្គសិក្សានីមួយៗ ។ បន្ទាប់មក យើងខ្ញុំមានការជ្រើសរើសអត្ថបទសិក្សាជាច្រើន ដោយសាស្ត្រាចារ្យដែលបានបង្រៀននៅក្នុងវគ្គនីមួយៗ ។ ក្រោយមក អ្នកសិក្សា បកប្រែអត្ថបទទាំងនោះជាភាសាខ្មែរ ដើម្បីយកទៅបោះពុម្ពផ្សាយ ។ គោលបំណងនៃការងារបកប្រែនិងបោះពុម្ពផ្សាយនេះ គឺដើម្បីបង្កើនចំនួនឯកសារសិក្សាជាភាសាខ្មែរ ដែលនៅតែមានកង្វះខាតនៅក្នុងវិស័យមនុស្សសាស្ត្រ–សង្គមសាស្ត្រ និងដែលជាតម្រូវការរបស់គ្រូបង្រៀននិងនិស្សិត នៅតាមសាកលវិទ្យាល័យ ។

ក្នុងសៀវភៅវគ្គទីពីរនេះ មានអត្ថបទចំនួន ៤ បានជ្រើសរើសដោយលោកស្រីបណ្ឌិត ផេន្នី អេដ្វឺដ្ស ជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យកាលីហ្វរនៀនាក្រុងប៊ឺរឃ្លេយ៍ ។ អត្ថបទទាំងនេះបានឆ្លុះបញ្ចាំងពីប្រធានបទនៃកម្មវិធីសិក្សាវគ្គទី ២ ស្តីពី **វប្បធម៌និងអត្តសញ្ញាណ ៖ កម្ពុជានៅក្នុងបរិបទអាស៊ីអាគ្នេយ៍** ។ អត្ថបទទាំងអស់នោះ មានដូចជា អត្ថបទមួយដកស្រង់ចេញពីសៀវភៅ **សហគមន៍ស្រមើស្រមៃ ៖ ការត្រិះរិះពិចារណាអំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម** របស់លោកសាស្ត្រាចារ្យបេនីឌិកត៍ អាន់ដឺរសុន, អត្ថបទមួយទៀតរបស់លោក វ៉ីដ គីល័រ ដែលមានចំណងជើងថា «តួអង្គក្សត្រាលោតទេតើ ! ៖ ការសម្តែងភាពជាបុរសនៅម៉ាន់ដាលេ», អត្ថបទរបស់អ្នកស្រី ថាម៉ូរ៉ា ហ្វ៊ីស្ទែល ស្តីអំពី «ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ អារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមសៀម» ហើយនិងអត្ថបទមួយទៀត និពន្ធដោយលោកស្រី ផេន្នី អេដ្វឺដ្ស ផ្ទាល់ មានចំណងជើងថា «រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០-១៩៣០» ។

អត្ថបទទី ៣ មានចំណងជើងថា « ជំរឿន ការគូសផែនទី និងការតាំងបង្ហាញ» ដកស្រង់ចេញពីសៀវភៅរបស់លោកបេនីឌិកត៍ អាន់ដឺរសុន ស្តីពីប្រវត្តិនៃគំនិតជាតិនិយមនៅអាស៊ីអាគ្នេយ៍ ដើម្បីបង្ហាញដល់និស្សិតអំពីទ្រឹស្តីថ្មីៗ នៃគំនិតជាតិនិយម និងអាណានិគមនិយមនៅក្នុងបរិបទតំបន់អាស៊ីអាគ្នេយ៍ និងផ្តល់ជាគំនិតដល់និស្សិតទាំងអស់នោះ អំពីចំណេះដឹងជាសកលនៃគំនិតជាតិនិយម តាមរយៈចំណេះដឹងពីអតីតកាលនិងបច្ចុប្បន្នកាលនៃការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍នេះ ។ នៅក្នុងការបង្រៀនរបស់គាត់ លោកស្រី អេដ្វឺដ្ស បានផ្តោតលើប្រទេសភូមានិងថៃ ជាគំរូប្រៀបធៀប ដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រនិងវប្បធម៌នៃប្រទេសកម្ពុជា ។ អត្ថបទចំនួន ៣ ទៀត ត្រូវបានជ្រើសរើស ដោយសារតែអត្ថបទទាំងនោះមានការសង្កត់ធ្ងន់ជាទូទៅទៅលើ « យេនឌ័រ» មានការពិនិត្យអំពីការវិវត្តរបស់ « យេនឌ័រ » និងដោយសារតែមានភាពខុសគ្នាខាងវិធីសាស្ត្រស្រាវជ្រាវ (អត្ថបទ ២ ទៀត និយាយអំពីកម្ពុជានិងសៀមនៅអំឡុងទសវត្សរ៍ឆ្នាំ ១៩០០ ដល់ ១៩៣០ ហើយអត្ថបទមួយទៀត និយាយអំពីភូមាក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០) ។ អត្ថបទរបស់អ្នកស្រី ថាម៉ូរ៉ា ហ្វ៊ីស្ទែល ច្រើនតែប្រើការវិភាគបែបអក្សរសិល្ប៍ស្ទើរតែទាំងស្រុង ប្រទាក់ជាមួយសេចក្តីយោងបែបជីវប្រវត្តិ ។ អត្ថបទរបស់លោក វ៉ីដ គីល័រ ផ្តោតលើការសិក្សាបែបនរវិទ្យា ដោយប្រើវិធីសាស្ត្រចូលរួមស៊ើបអង្កេត សន្ទនាជាមួយនឹងអ្នកផ្តល់ព័ត៌មានជនជាតិភូមា ហើយនិងចូលទស្សនាការប្រគំដន្ត្រីនៅភូមា ។ ចំណែកឯអត្ថបទរបស់លោកស្រី អេដ្វឺដ្ស វិញ មានរួមការវិភាគទៅលើស្នាដៃរឿងប្រឌិត និងកំណត់ហេតុអាណានិគម

ជាមួយនឹងការស្រាវជ្រាវអត្ថបទតម្កល់ទុកនៅប្រទេសបារាំងសែស ។

នៅក្នុងសិក្ខាសាលា លោកស្រី អេដ្វីដ្ស បានប្រើប្រាស់អត្ថបទទាំងនេះ ដើម្បីគូសបញ្ជាក់អំពីសភាពនៃអត្តសញ្ញាណ ដែលបានបង្កើតឡើង ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីគោលគំនិតទាំងឡាយស្តីពី «ជាតិ» និង «ប្រទេសជាតិ» និងជាមធ្យោបាយគូសបញ្ជាក់អំពីសភាពជាតិនិយមទំនើប ។ គាត់ក៏បានប្រើប្រាស់អត្ថបទទាំងអស់នេះ ដើម្បីជំរុញឲ្យមានការពិភាក្សាស្តីអំពីអត្ថន័យនិងគន្លងប្រភេទ «យេនឌ័រ» ដែលបានផ្សព្វផ្សាយនិងនាំចូលប្រទេសកម្ពុជានៅក្នុងស្ថានការណ៍នៃកិច្ចអន្តរាគមន៍របស់អង្គការសហប្រជាជាតិ និងការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលនានា ។ ការដែលពាក្យ «យេនឌ័រ» ជាពាក្យដែលខ្មែរខ្ចីយកពីភាសាអង់គ្លេសតែម្តងតាមការបញ្ចេញសម្លេងជាភាសាអង់គ្លេសនេះ បានឆ្លុះបញ្ចាំងអំពីបរាជ័យនៃសេចក្តីបរិយាយរបស់អន្តរជាតិ ទាក់ទងវាក្យស័ព្ទថ្មីដែលចង់បញ្ចូលក្នុងវាក្យស័ព្ទខ្មែរដែលមានស្រាប់ ហើយក៏បានឆ្លុះបញ្ចាំងអំពីបរាជ័យក្នុងការបង្កើតពាក្យថ្មីមួយតាមរបៀបដែលខ្មែរធ្លាប់បង្កើតពាក្យថ្មីតាមតម្រូវការ ។ ការចាប់អារម្មណ៍របស់សិស្សមួយចំនួន គឺថា នៅក្នុងអត្ថបទចំនួនបីនេះ ជាពិសេសនៅក្នុងអត្ថបទរបស់លោក គីល័រ គេបានប្រើពាក្យ «យេនឌ័រ» ជាក្របខ័ណ្ឌដើម្បីវិភាគអំពីអត្តសញ្ញាណបុរសភេទនិងស្ត្រីភេទ ។ ដោយការដាក់អត្ថបទទាំងនេះតាមលំដាប់លំដោយ អ្នកគ្រូ អេដ្វីដ្ស សង្ឃឹមថា អ្នកអាននឹងបានទទួលគំនិតដើម្បីប្រឈមនិងគិតម្តងទៀត ចំពោះការបែងចែករបៀបនេះ ។ អ្នកគ្រូ អេដ្វីដ្ស ក៏សង្ឃឹមដែរថា អ្នកអាននឹងមើលឃើញអំពីគុណតម្លៃនៃការសិក្សាអំពីអតីតកាលថ្មីៗ នៃវប្បធម៌និងប្រទេសដទៃទៀតនៅក្នុងតំបន់ រួមទាំងកម្ពុជា ដែលអាចបំភ្លឺដល់ការសិក្សាអំពីព្រឹត្តិការណ៍បច្ចុប្បន្ន ហើយនិងដើម្បីពង្រីកការងារស្រាវជ្រាវរបស់គេទៀត ។ សូមអានផងដែរនៅទំព័របន្ទាប់ នូវការពិចារណានៃអ្នកពិនិត្យផ្ទៀងផ្ទាត់របស់មជ្ឈមណ្ឌលខេមរសិក្សាម្នាក់ ស្តីពីបញ្ហាការបកប្រែពាក្យ «យេនឌ័រ» និងរបៀបគេបានដោះស្រាយបញ្ហានេះនៅក្នុងប្រទេសជិតខាងមួយ ពោលគឺ ប្រទេសថៃ ដែលមានវប្បធម៌ជិតដិតនឹងវប្បធម៌ខ្មែរ ។ ការពិចារណាបែបនេះសមស្របនឹងគោលដៅទស្សនវិស័យប្រៀបធៀបរបស់កម្មវិធីនេះ ។

ដោយព្យាយាមរក្សានូវគោលបំណងគរុកោសល្យនៃកម្មវធីបណ្តុះបណ្តាលនេះ យើងខ្ញុំសង្ឃឹមយ៉ាងស្មោះស្ម័គ្រថា អត្ថបទបកប្រែទាំងនេះនឹងបម្រើដល់សាស្ត្រាចារ្យ និស្សិត នៅក្នុងផ្នែកប្រវត្តិសាស្ត្រ សង្គមសាស្ត្រ សេដ្ឋកិច្ច នរវិទ្យា វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ និងផ្នែកដទៃជាច្រើនទៀត ។ យើងខ្ញុំក៏សង្ឃឹមថា អត្ថបទនេះនឹងជួយជំរុញឲ្យអ្នកអាន ស្រាវជ្រាវបន្ថែម ហើយវិភាគរិះគន់ ដោយប្រើនូវទស្សនៈប្រៀបធៀបនិងទស្សនៈប្រើសាខាទាំងឡាយក្នុងវិស័យចំណេះវិជ្ជា ។

ខ្ញុំសូមបញ្ចប់សេចក្តី ដោយសូមថ្លែងអំណរគុណចំពោះ លោកស្រីបណ្ឌិត ផេន្នី អេដ្វីដ្ស ចំពោះការប្រឹងប្រែង ដោយគ្មានខ្លាចនឿយហត់ទាំងការបង្រៀននិងណែនាំដល់អ្នកចូលរួមកម្មវិធីនេះ ។ រីឯលោក ម៉ែន ឈានរិទ្ធី នាយកកម្មវិធីបណ្តុះបណ្តាលក៏ដូច្នេះដែរ ភាពស្វាហាប់នឹងការទទួលធ្វើការងាររបស់គាត់ មានសារៈសំខាន់ណាស់សម្រាប់ជោគជ័យរបស់កម្មវិធីយើងខ្ញុំទាំងមូល ។

សូមអរគុណជាពិសេសចំពោះក្រុមការងារបកប្រែវ័យក្មេង ដែលមានលោក សុខ លាំង លោក យិន សំបូរ លោក ប៉ុង ភក្តី បូរាមី ក្រោមការដឹកនាំដ៏ម៉ត់ចត់របស់អ្នកស្រី តាន់ សូដានី ដែលជាអ្នកសម្របសម្រួលកម្មវិធីបកប្រែរបស់មជ្ឈមណ្ឌលយើងខ្ញុំ ។ ខ្ញុំសូមសម្តែងសេចក្តីកតញ្ញូយ៉ាងជ្រាលជ្រៅដល់លោក មីស្ហែល បុទ្ធី អង់តែល្ម ដែលបានចំណាយពេលវេលាយ៉ាងសម្បើមក្នុងការស្វែងរកទិន្នន័យនិងព័ត៌មាន រកឯកសារនិងពាក្យដើមជាភាសានិងអក្សរសៀមនិងភូមា ជួយពិនិត្យពិច័យអត្ថបទទាំងនេះ និងរៀបចំទំព័រទាំងអស់សម្រាប់ការបោះពុម្ព ។ ខ្ញុំសូមសម្តែងការដឹងគុណចំពោះការជួយជ្រោមជ្រែងរបស់លោក ខេង ពិទូកេត្យា ដែលជាអ្នកសម្របសម្រួលការងារទំនាក់ទំនងនិងបោះពុម្ពផ្សាយ និងចំពោះអ្នកស្រី លេស្លៃយ៍ ផឹលមែន នាយិការងរបស់មជ្ឈមណ្ឌល ដោយគាត់ទាំងពីរនាក់ ជាអ្នកក្របខ័ណ្ឌសម្រាប់ការរៀបចំនិងបោះពុម្ពសៀវភៅនេះរបស់ក្រុមយើងខ្ញុំឡើង ។ ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់មនុស្សទាំងឡាយ ដែលបានផ្តល់ជំនួយនិងព័ត៌មាន តិចក្តី ច្រើនក្តី គឺ លោក ថាច់ ដែត អ្នកស្រី នុត សុប្បិយ៉ា លោក ប៉ាទ្រិក ម៉ាក់ខរមិក លោកស្រី បេណេឌិកត៍ ប្រាក់ដឺឡាប៉េរីយ៉ែរ លោក ម៉ក់ ភឺន អ្នកស្រី ម៉ារី ហេឡែន ការឌីណូដ៍ លោក រ៉ូបឺត ហ្វេឡឺរ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ វ៉ារីវឌ្ឍន៉ាមុនីពុង្ស អ្នកស្រី សាបេស្វេ ដឺម៉ារីយ៉ា លោក ហៀប ច័ន្ទវិចិត្រ លោក ហ្វ្រេត្ហ្គូរី មីកាអេលីយ៉ង់ លោក ហ្វ្រង់ស្វា តាំងទុយរីយ៉េរ៍ លោក ហ្សីល ដឺលូស្ហ និងលោក ឥន្ទនោ ធីរពង្ស ។

ហ្វីលីព្ព ប៊ីកាំ នាយកមជ្ឈមណ្ឌលខេមរសិក្សា ។

## PREFACE

Since 2004, the Center for Khmer Studies has conducted a major training program for young aspiring Cambodian university faculty. The Junior Faculty Training program (JFT) helps those Cambodians in the final stages of higher education, or in the formative years of their university teaching career, to expand their research and teacher training in the fields of the humanities and social sciences. Funded by the Rockefeller Foundation, the JFT program comprises a series of semester-long research and training seminars led by an international Visiting Professor. Each seminar has a different theme, and each focuses on one aspect of modern Cambodian society. Seminar topics were defined in coordination with representatives of Cambodian universities so as to attract participants from diverse disciplinary backgrounds, and employing a comparative perspective, where Cambodia is studied alongside its neighbors, Thailand and Vietnam, as well as Burma, Laos and other countries in the region. Each semester session combines lectures, interactive seminars, field visits to Thailand or Vietnam, an individual research project carried out by each participant. Follow-up takes the form of an international conference on the semester's topic, and the selection of key seminar texts chosen by the session's Visiting Professor and translated into Khmer by the Cambodian participants for publication. The objective of this latter task is to increase the otherwise extremely limited corpus of reading materials available in Khmer in the social sciences and humanities needed for both university faculty and students.

This second volume consists of 4 reading texts selected by Dr. Penny Edwards, University of California, Berkeley, illustrating the theme covered by the program's second session, *Cultures and Identities: Cambodia in the Southeast Asian Context*. These include an article by Ward Keeler "But Prince's Jump!: Performing Masculinity in Mandalay" (2005), an article by Thamora Fishel "Romances of the Sixth Reign: Gender, Sexuality and Siamese Nationalism" (1999), a chapter from *Imagined Communities: The Origins and Spread of Nationalism* by Professor Benedict Anderson, and an essay by Penny Edwards, "Womanizing Indochina: Fiction, Nation, and Cohabitation in Colonial Cambodia" (1998).

The third text "Census, Map, Museum," taken from Benedict Anderson's pathbreaking work on the histories of nationalism in Southeast Asia, was designed both to introduce students to modern theories of nationalism and colonialism in Southeast Asian context, and to inspire students by emphasizing the past, current and potential contributions of scholarship on Southeast Asian studies to global scholarship on nationalism. In her seminar, Edwards focused on Burma and Thailand as comparative models for understanding Cambodian history and culture. The other three readings were selected for their common emphasis on gender, for their diachronic examination (two focused on Cambodia and Siam in the 1900s to the 1930s, and one on Burma in the 1990s), and for their methodological difference. Thamora Fishel's article draws mostly on literary analysis, intertwined with biographical references. Ward Keeler's article, anthropological in focus, draws on participant observation, conversations with Burmese informants, and attendance at musical performances in Burma. Penny Edwards' own essay couples analysis of works of colonial fiction and memoir with archival research in France.

In her seminar, Edwards used these texts to underscore the constructed nature of identity, as a lens on concepts of "nation," and as a way of underscoring the modern nature of nationalism. She also used these texts to stimulate discussion on the meanings and precedents for the category of "gender" as circulated, predominantly among urban educated spheres, today, and introduced into Cambodia in the wake of UN intervention and NGO participation. The fact that the term "gender" has been transliterated into Khmer as "yéndoe," an empty echo of the English term, reflects at once a

failure of international discourse to relate new vocabulary to precedents in the Khmer language, and the lack of a specific pre-existing synonym in Khmer. Of particular interest to some students was the fact that, in three of the articles, but primarily in Keeler's, "gender" was used as a frame of analysis for both male and female identity. Through her juxtaposition of these works, Edwards hopes that readers will be similarly inspired to challenge and rethink such categories; to appreciate the light that studies of other regional countries and cultures, as well as on Cambodia's recent past, can shed on current circumstances, and to expand their methodological approaches. See also on the following page the reflection of one of our copy editors on the word "gender" and the way it was translated in a neighboring and culturally close country—Thailand—in this comparative perspective of our program.

In keeping with the pedagogical objectives of the JFT, we sincerely hope that these translated texts will be of use to both professors and students in the fields of history, sociology, economics, anthropology, political sciences, international relations, and other fields. We also hope that they will encourage readers to further investigate, critically, using a comparative and interdisciplinary approach.

I will end this short word to thank Dr. Edwards for her tireless efforts, both as a teacher and as a mentor for the program participants. No less important is the work of Chean Men, Director of the JFT, whose energy and enterprise were critical to the success of our entire program.

Special thanks to the young team of translators, particularly Sok Leang, Yin Sombo and Pong Pheakdeyboramy, who worked under the careful supervision of Tan Sodany, CKS Translation Coordinator. I would like to express my deep gratitude to Michel Rethy Antelme who spent a tremendous amount of time looking for data and information, original documents and words in Thai and Burmese scripts, edited the manuscript and spent time on the final layout. I want also to acknowledge the contributions of Kheng Pytou Kethya, CKS Communications and Publishing Coordinator, and Lesley Perlman, CKS Deputy Director, for their excellent work in managing the editorial and publishing aspects of this truly collective undertaking. To finish I would like to thank all the following people for their help: Bénédicte Brac de la Perrière, Marie-Hélène Cardinaud, Gilles Delouche, Robert Fowler, Hiep Chan Vicheth, Patrick McCormick, Grégory Mikaelian, Mak Phoeun, Nut Suppya, Sabai Shwe Demaria, Sisowath Ravivadhana Monipong, François Tainturier, Thach Deth and Inthano Theeraphong.

Philippe Peycam, PhD., Director
Center for Khmer Studies.

# កំណត់អំពីនិយមន័យ បញ្ញត្តិ និងការបកប្រែពាក្យ « យេនឌ័រ »

តាមការកំណត់អត្ថន័យនៅក្នុង **សទ្ទានុក្រមយេនឌ័រ** របស់ក្រសួងកិច្ចការនារី (គ.ស. ២០០៦) « យេនឌ័រ » គឺសំដៅយកតួនាទី ឥរិយាបថ និងគុណតម្លៃនានា ដែលវប្បធម៌និងសង្គម ដាក់កំណត់ឲ្យបុរសនិងស្ត្រីអនុវត្តដោយឡែកពីគ្នា ។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះ កំណត់នូវអាកប្បកិរិយានិងទំនាក់ទំនងរវាងបុរសនិងស្ត្រី ។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះ ត្រូវបានបង្កើតឡើងនិងថែររក្សាដោយស្ថាប័នសង្គមនានា ដូចជា គ្រួសារ រដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និងសារព័ត៌មាន ។ល។ ដោយសារយេនឌ័រនេះហើយ ទើបបានជាតួនាទីនិងលក្ខណៈសម្គាល់មួយចំនួន ត្រូវបានកំណត់ឡើងផ្សេងពីគ្នា និងតឹងរ៉ឹង សម្រាប់បុរសនិងស្ត្រី ។

ជាការគួរឲ្យងឿងឆ្ងល់ ពាក្យថា « យេនឌ័រ » ជាពាក្យយកពីភាសាអង់គ្លេសតែម្តង ដោយពុំសូវមានអ្នកណាបានត្រិះរិះពិចារណាអំពីអត្ថន័យរបស់ពាក្យនេះ និងអំពីរបៀបដែលយើងអាចបកប្រែពាក្យនេះជាភាសាខ្មែរ ។ មានតែអ្នកចេះនិយាយភាសាអង់គ្លេស ទើបអាចក្រសោបយល់នូវខ្លឹមសាររបស់ពាក្យនេះបាន ។ ក៏ប៉ុន្តែ ទោះជាយុវជនមួយចំនួនធំនៅប្រទេសកម្ពុជាខិតខំរៀនភាសាអង់គ្លេស តាំងពីពេលយើងឈានបានចូលក្នុងសម័យសាកលភាវូបនីយកម្ម ដែលមានភាសាអង់គ្លេសជាភាសាយានទូទាំងពិភពលោកក៏ដោយ ក៏ន័យរបស់ពាក្យនេះនៅតែមិនច្បាស់លាស់ ។ ចុះប្រទេសជិតខាង ដែលបានទទួលឥទ្ធិពលយ៉ាងសន្ធឹកសន្ធាប់របស់វប្បធម៌អាមេរិកយូរជាងប្រទេសកម្ពុជា បានដោះស្រាយបញ្ហាបកប្រែពាក្យនេះយ៉ាងដូចម្តេច ?

ឧទាហរណ៍នៅក្នុងភាសាថៃ ដើម្បីពន្យល់អំពីបញ្ញត្តិ (គំនិត) ដែលបង្កប់ក្នុងពាក្យ « យេនឌ័រ » នេះ ភាសាថៃបានបង្កើតថ្មីៗនេះ នូវពាក្យថា « ភេទភាវៈ » « ភេទសភាវៈ » « ភេទសភាព » និង « ភេទស្ថានៈ » ដែលសុទ្ធតែជាសមាសនាមសំស្ក្រឹត-បាលីប្រកបដោយខ្លឹមសារដ៏ជ្រាលជ្រៅគួរឲ្យចាប់អារម្មណ៍ ។ ពាក្យ « ភេទ » សម្រាប់សំដៅសេចក្តីថា « ភាព, បែបភាព, ភាពផ្សេងគ្នា » ដូចជា ភេទបុរស, ភេទស្ត្រី ; ភេទគ្រហស្ថ, ភេទបព្វជិត ភាសាសៀមសរសេរ « ពេគ » តែអានថា /ផេត/ ។ អក្ខរាវិរុទ្ធនេះប្លែកណាស់ ព្រោះមកពីពាក្យសំស្ក្រឹត « វេគ » ដែលមានន័យជាច្រើន ដូចជា « អ្នកស្រែចម្ការ ; អ្នកជិតខាង ; អ្នកក្នុងចំណុះ ; កន្លែងចូល ; ផ្ទះលំនៅ ; ផ្ទះបន » ។ ហាក់ដូចជាន័យក្នុងភាសាសៀម មិនសូវមានទំនងនឹងន័យដើមក្នុងភាសាសំស្ក្រឹត ។ តែប្រហែលមកពីពាក្យ « ពេម » វិញ អានថា /ផេត/ ដែរ មកពីពាក្យសំស្ក្រឹត « វេម » មានន័យថា « កិច្ចការ, សកម្មភាព ; សម្លៀកបំពាក់, គ្រឿងតុបតែង, សំបកក្រៅ » ។ ឬក៏អាចមកពីពាក្យថា « ភេទ » វិញ ដែលមានន័យដើមថា « ដំណើរផ្លាយ, ការទម្លាយ ; ដំណើរបែក, ការបំបែក ; ការចែក ; ប្រភេទ, សេចក្តីផ្សេង » ។ ពាក្យ « ពេគ » « ពេម » និង « ភេទ » ភាសាសៀមបញ្ចេញសម្លេងដូចតែគ្នា ។ ចំណែកឯពាក្យ « ភាវៈ » មានន័យដូចគ្នានឹងពាក្យ « ភាព » មិនបាច់ពន្យល់ន័យទេ ។ ពាក្យ « ស្ថានៈ » មានន័យដូចគ្នានឹងពាក្យ « ឋានៈ » ក៏មិនបាច់ពន្យល់ដែរ ព្រោះជាពាក្យងាយស្រួលយល់សម្រាប់ខ្មែរ ។ ពាក្យចុងក្រោយ គឺពាក្យ « សភាវៈ » ជាគូនឹងពាក្យ « សភាព » ជាពាក្យបាលី មានន័យថា « ដំណើរកើតឯង, ធម្មតា, ធម្មជាតិ » ។

នៅប្រទេសថៃ បញ្ញវន្តមួយចំនួននិយមប្រើពាក្យ « ភេទសភាវៈ » ឬ « ភេទសភាព » តែក្រោយមក មានបញ្ញវន្តមួយចំនួនទៀត បានជំទាស់មិនចង់ប្រើពាក្យនេះ គួរប្រើ « ភេទភាវៈ » វិញ ព្រោះថា « ភេទភាវៈ » ឬ « យេនឌ័រ » នេះ ជាការបណ្តុះគំនិតផ្លូវសង្គម ឬដូចក្រសួងកិច្ចការនារីប្រទេសកម្ពុជាបានផ្តល់និយមន័យថា ជា « តួនាទី ឥរិយាបថ និងគុណតម្លៃ [...] [ដែល] ត្រូវបានបង្កើតឡើងនិងថែររក្សាដោយស្ថាប័នសង្គមនានា» ពុំមែនជាដំណើរកើតឯងឬមកពីធម្មជាតិឡើយ ។ រីឯមនុស្សខ្លះទៀតនិយមប្រើពាក្យ « ភេទស្ថានៈ » វិញ ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងអាចឃើញបានថា នៅប្រទេសថៃ គេបានរិះគិតពីពាក្យទាំងនេះ ដើម្បីឲ្យសមស្របនឹងបញ្ញត្តិនិងនិយមន័យរបស់ពាក្យ « យេនឌ័រ » ឲ្យដាច់ស្រេចបំផុត ។

ក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ លោក អៀវ កើស (គ.ស. ១៩០៤-១៩៥០) បានសរសេរថា ៖ «[...] កាលបើយើងរកពាក្យថ្មីក្នុងភាសាខ្មែរពុំបាន យើងត្រូវរកក្នុងភាសាបាលី-សំស្ក្រឹត ។ ក្នុងភាសាអឺរ៉ុប គេតែងតែប្រើទំនងនេះមកហើយ ។ ពាក្យក្នុងអក្សរសាស្ត្រ គេច្រើនយកមកពីភាសាឡាតាំង, ពាក្យក្នុងវិទ្យាសាស្ត្រ ច្រើនយកមកពីភាសាក្រិក ។ ខាងវិទ្យាសាស្ត្រ បារាំងបានចំរើនមុនគេក្នុងលោក ។ បារាំងបានជ្រើសពាក្យក្រិកជាច្រើន យកមកតុបតែងប្រើមុនគេ ។ ភាសាជាតិឯទៀត ដូចជា

អង់គ្លេស អាល់ឡឺម៉ង់ រុស្ស៊ី បានចំរើនក្រោយតមក ក៏តោងបែរទៅរកពាក្យក្រិកមកប្រើដូចគ្នា ។ កាលបើទៅដងទឹកយកពីអណ្ដូងតែមួយដូច្នេះ ទឹកនោះក៏តោងតែដូចគ្នា ។ ហេតុនេះបានជាពាក្យក្នុងភាសាអឺរ៉ុបមានដូចគ្នាជាច្រើន ។ ក្នុងសុវណ្ណភូមិ អណ្ដូងសំរាប់ជាតិខ្មែរ, លាវ, សៀម, ភូមា មានតែមួយគឺអណ្ដូងបាលី-សំស្ក្រឹត ។ ក្នុងអណ្ដូងនេះ សៀមមានទៅដងមុនយើងមកហើយ ក្នុងសម័យថ្មីនេះ ។ កាលយើងទៅដងក្រោយ បើប្រាថ្នាឲ្យបានទឹកខុសគ្នានោះ ឃើញជាមិនងាយទេ ។ មានតែយើងកុំប្រើទឹកអណ្ដូងនេះតែម្ដងបើចង់ឲ្យខុសគ្នា ។ ប៉ុន្តែបើក្នុងអណ្ដូងភាសាខ្មែរ យើងរកទឹកដែលត្រូវការពុំបាន យើងក៏មិនដឹងទៅដងក្នុងអណ្ដូងឯណា ក្រៅពីអណ្ដូងបាលី-សំស្ក្រឹត ។ នឹងទៅដងពីអណ្ដូងឡាតាំង-ក្រិកមកប្រើដូចអ្នកអឺរ៉ុបក៏មិនស្រួល ព្រោះឱជារសខុសគ្នា ; មិនស្រួលប្រើ ដូចនំប៉័ងមិនស្រួលបរិភោគជានិច្ចសំរាប់មាត់យើង ដែលជាអ្នកធ្លាប់បរិភោគបាយទៅហើយ ។ សេចក្ដីសន្និដ្ឋានគឺថា យើងជៀសមិនឲ្យយកពាក្យថ្មីដែលមកពីបាលី-សំស្ក្រឹត ដូចគ្នានឹងពាក្យដែលសៀមប្រើទៅហើយមិនរួចជាដរាបទេ ។ នៅអឺរ៉ុប អង់គ្លេស អាល់ឡឺម៉ង់ រុស្ស៊ី អ៉ីតាលី... កាលយកពាក្យរបស់បារាំងដែលមកពីក្រិក-ឡាតាំងទៅប្រើ ឬបារាំងកាលយកពាក្យចំពូកនេះពីជាតិឯទៀតក្នុងអឺរ៉ុបមកប្រើវិញ គេគ្មានគិតខ្លាចថោកទាបដល់ជាតិគេសោះ ។ ម្ដេចឡើយ យើងមករសើបអីត្រង់នេះខ្លាំងម្លេះ ?» (**ភាសាខ្មែរ ការសាកល្បងពិនិត្យដោយរកហេតុផល** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៩ គ.ស. ១៩៩៥, ការបោះពុម្ពលើកទី ១ គ.ស. ១៩៤៧ ចំពោះភាគទី ១, ព.ស. ២៥០៩ គ.ស. ១៩៦៧ ចំពោះក្បាលទី ១-២ ទំព័រទី ៣៤២-៣៤៤) ។

ដូច្នេះ យើងខ្ញុំក៏ស្នើសុំដាក់ពាក្យ «ភេទភាវៈ» នេះ ជាវេវចនៈនឹងពាក្យ « យេនឌ័រ » ក្នុងវង់ក្រចក អមពាក្យ « យេនឌ័រ » ទម្រាំដល់ថ្ងៃដែលរាជបណ្ឌិតសភាកម្ពុជានឹងបង្កើតពាក្យជាផ្លូវការសម្រាប់សំដៅលើ « យេនឌ័រ» នោះ ។

មីស្សែល ប៊្ញទី អង់តែល្ម ។

## Note on the Definition, Concept, and Translation of "Gender"

According to the definition in Khmer given in the *Gender Lexicon* (2006) of the Ministry of Womens' Affairs, "gender" is the differenciation of the duties, attitudes and values assigned separately to men and women as defined by culture and society. These duties, attitudes and values are created and maintained by various social institutions such as the family, government, community, school, church and mass media, etc. Because of gender, a number of acknowledged duties and characteristics are differently and strictly defined for men and women.

Surprisingly, the word in Khmer is the mere trancription of English *gender*: *yéndoe*. It seems to have entered usage with hardly any consideration of its significance and how it might have been translated into Khmer. Only those who speak English can grasp its intrinsic meaning. However, although young Cambodians have been massively and enthusiastically learning English since the time Cambodia entered a globalized world whose common language is English everywhere you go, the sense of the word "gender" remains somewhat obscure to them. What did neighboring countries – which have absorbed American culture for a longer time than Cambodia – do with this English word, and how did they succeed in translating it?

Thailand is an interesting example. In order to convey the concept embedded in the word "gender," the Thais recently coined the terms *phét-phawa'*, *phét-saphawa'*, *phét-saphap*, and *phét-sathana'*, all of them Sanskrit-Pāli compounds, with *phét* standing for "sex" in Thai (derived, according to spelling, from Sanskrit *veśa*: "small farmer, tenant, neighbor, dependant, vassal ; entrance, ingress ; house, dwelling ; prostitution or a house of ill fame, brothel"; perhaps a misspelling for *veṣa*: "work, activity, management ; dress, apparel, ornament, artificial exterior, assumed appearance"; or Skt-Pā. *bheda*: "separation, division, distinction, difference, kind, etc."). *Phawa'* (Skt-Pā. *bhāva*) means: "state (of affairs), condition, status, state of being, nature ; aspect ; character ; form, manner, way ; the Buddhist doctrine of 'coming into existence'." *Saphawa'* which is synonymous with *saphap* (both from Pā. *sabhāva*), means "own condition or state of being, natural state or constitution, innate or inherent disposition, nature, impulse, spontaneity." *Sathana'* comes from Skt *sthāna*, and has taken the meaning of "position, status, state, condition, situation." Separately, all these words are in common usage in Khmer (though with a slight difference in the spelling of *phét*, as the Khmer form is based on *bheda*, and Khmer would rather use *thana'* from Pā. *ṭhāna* as a final component when Thai uses *sathana'* based on the Sanskrit form).

Some Thai intellectuals use the words *phét-saphawa'* or *phét-saphap* for "gender," but others have then objected that "gender" being a social construct or, as the Cambodian ministry of Womens' Affairs puts it, being made up of "duties, attitudes and values [...] created and maintained by various social institutions," *saphawa'* and *saphap*, being related to a natural state or an inherent disposition, are improper, and then prefer to use *phét-phawa'*. Others again prefer the usage of *phét-sathana'*. Be that as it may, we can see that the Thais have thought over these terms to try and find the most appropriate way to match the definition and concept of "gender."

Thai *phét-phawa'*, when transposed into Khmer (using the word *bheda* for "sex"), is meaningful, though not yet attested: *phét-pheavea'* (*bhedabhāva*).

In the 1940s, Iêu Kœus (1904-1950) wrote: "[...] when we cannot coin a new word from the Khmer language stock, we need to look at Pāli and Sanskrit. In European languages, you find a similar tendency: words in the field of literature are often taken from Latin, and for the sciences from Greek. In the field of science, the French have been the world leaders here. They were often the first to develop and to choose Greek words and adapt them for their use. Other languages such as English, German, and Russian have followed suit and used the same Greek words. When you draw water from the same well, the water is the same. This is the reason why so many words are identical in these European languages. In the land of Suvarṇabhūmi, there is only one well for the Khmers, the Thais, the Laos and the Burmese, it is the well of Pāli and Sanskrit. In our day and age the Thais are ahead of us in drawing

from this well. We follow behind, and, while wanting to draw from this well, we want the water to be different, which proves to be no easy thing. If we wish it to be different, we should not draw it from this well at all. But if in the well of the Khmer language we cannot find the water we need, we do not know from which well, apart from the Pāli-Sanskrit one, we could choose to draw. To draw from the Greek and Latin well, as the Europeans do, is not so easy. It is like bread, which we cannot eat everyday as it does not correspond to our taste in the way that rice does. The conclusion is that we cannot always avoid, nor should we try to, creating neologisms from Pāli and Sanskrit as the Thais have done before us. In Europe, when the English, Germans, Russians, Italians ... borrow a word from French which is originally Greek or Latin, or when the French borrow these kinds of word from some other nation, they never feel it disreputable for their own nation. So, when it comes to us, why do we have to feel so ticklish?" (*La Langue cambodgienne. Un essai d'étude raisonné* [in Khmer], Phnom Penh, Buddhist Institute, 1995, 1st edition for Vol. 1: 1947, for Vol. 1-2: 1967, p. 342-344).

That is why we would also like to suggest the word *phét-pheavea'* as a synonym for *yéndoe*, escorting in parenthesis the latter, until the day comes when the Royal Academy of Cambodia chooses an official term to mean "gender."

Michel Rethy Antelme.

# ជំពូកទី ១

## តួអង្គក្សត្រាលោតទេតេ! ៖ ការសម្តែងភាពជាបុរសនៅម៉ាន់ដាឡេ

*ដោយ វ៉ដ គីល័រ*

*ច្បាប់ដើមនៃអត្ថបទនេះបានសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* “But Princes Jump !’ : Performing Masculinity in Mandalay’” *។*
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖* **ប្រទេសភូមានៅពេលឈានចូលក្នុងសតវត្សរ៍ទី ២១** *(Burma at the Turn of the Twenty-first Century) ។*
*រក្សាសិទ្ធិ គ.ស. ២០០៥ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។ បោះពុម្ពលើកទី ១ គ.ស. ២០០៥ នៅសហរដ្ឋអាមេរិក ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។*

# CHAPTER 1:

“ ‘But Princes Jump !’ : Performing Masculinity in Mandalay”

Ward Keeler

(*Burma at the Turn of the Twenty-first Century*)

**Copyright © 2005 by University of Hawai‘i Press.**

**First published in 2005 by University of Hawai‘i Press.**

បកប្រែដោយ ប៉ុង ភក្តី បូរាមី

## ជំពូកទី ១ ៖
## តួអង្គក្សត្រាលោតទេតើ! ៖ ការសម្ដែងភាពជាបុរសនៅម៉ាន់ដាលេ

តួឯកប្រុស ក្នុងក្រុមសម្ដែងល្ខោនភូមា ត្រូវគេប្រសិទ្ធនាមថា «ក្សត្រា» (မင်းသား «មង៉ះសាះ» ជាភាសាភូមា អានថា /មេន-ត្សា/ មានន័យថា «ក្សត្រា» ឬ «តារា (ល្ខោន ឬ ភាពយន្ត)») ។ នៅក្នុងឆាកខ្លះនៃការសម្ដែងពេញមួយយប់របស់ក្រុមល្ខោននោះ តួក្សត្រាបានស្លៀកសម្លៀកបំពាក់ និងសម្ដែងអាកប្បកិរិយាសមជាអភិជនភូមា ។ ប៉ុន្តែ វាជាការពិបាកសម្រាប់អ្នកទស្សនាជនជាតិអាមេរិកាំង (ខ្ញុំគិតថា ជនជាតិលោកខាងលិចដទៃទៀត ក៏មានការលំបាកដូចគ្នានេះដែរ) ក្នុងការមើលឲ្យស្គាល់តួឯកសម្ដែងថា ជាក្សត្រា បើសិនជាពួកគេមិនមានការយល់ដឹងអំពីសញ្ញាណភេទ (លក្ខណៈសម្គាល់ថា ជាភេទប្រុសឬស្រី ។ល។) របស់ភូមានោះ ។ និយាយឲ្យស្មោះត្រង់ទៅ សម្រាប់ពួកយើង (ពួកបស្ចិមប្រទេស) តួឯកក្សត្រាប្រៀបដូចជាមនុស្សខ្ទើយ ហើយបើតាមការសន្មតរបស់មនុស្សនៅប្រទេសលោកខាងលិច មនុស្សខ្ទើយ គឺជាមនុស្សប្រុសដែលរួមភេទជាមួយនឹងមនុស្សប្រុសគ្នាឯង ។ ការសន្និដ្ឋានអំពីតួឯកល្ខោនយ៉ាងនេះ មិនមែនជាបញ្ហាសំខាន់នោះទេ ហើយជាការសន្និដ្ឋានខុសភាគច្រើន[១] ។ ផ្ទុយទៅវិញ បញ្ហាស្ដីពីតួនាទី រូបរាងខាងក្រៅ និងសិល្បៈសម្ដែងនៃភេទនីមួយៗ បានលាយចូលសាច់គ្នាដោយរបៀបណានៅក្នុងបុណ្យង៉ានប្រជាប្រិយនាពេលយប់ៗ (ហៅ ဇာတ်ပွဲ «ជាតិប្វៃ» ជាភាសាភូមា អានថា /ហ្សាក់ព្វែ/ ; ဇာတ် «ជាតិ» អានថា /ហ្សាក់/ មានន័យថា «ជាតក» និង ပွဲ «ប្វៃ» អានថា /ព្វែ/ មានន័យថា «បុណ្យ») របស់ជនជាតិភូមាឯនោះទេ ទើបជាបញ្ហាមួយគួរឲ្យចាប់អារម្មណ៍ ។ ហើយបញ្ហានេះបានក្លាយទៅជាចំណុចសំខាន់បំផុតនៃការសម្ដែង និងមូលហេតុដែលការសម្ដែងទាំងនេះ បានវិវត្តទៅតាមគន្លងដែលមានជាង ៤០ ទៅ ៥០ ឆ្នាំមកហើយ ។

ប្រសិនបើជនបរទេសធ្លាប់គិតស្មានថា តួ «មេនស្សា» (តួក្សត្រា ឬ តារាល្ខោន) ជាមនុស្សខ្ទើយ[២] នោះជាធម្មតាវាមិនមែនដោយសារតែកំណាត់សំពត់ភ្លឺផ្លេកៗ (ដូចជា ជាយគ្រែង បាំងមុខ បាំងក្រោយ ស្រងក ជាដើម) ខ្សែកជាច្រើនខ្សែ រយ៉ាដាំទៅដោយត្បូងពេជ្រ បបូរមាត់ដ៏ក្រហមឆ្អើត និងក្រចកដៃដ៏វែងលើសលោងនោះទេ បើទោះបីជាគ្រឿងលម្អទាំងនេះ ទំនងជាអាចបណ្ដុះគំនិតរបៀបនោះ នៅក្នុងចំណោមមនុស្សមួយចំនួនក៏ដោយ ។ ក្បាច់រាំ ដូចជាកាយវិការដៃដ៏ល្វត់ល្វន់ និងការបង្ហាញទឹកមុខស្រងូតស្រងាត់និងអណ្ដែតអណ្ដូង ក៏ជាហេតុដែលនាំឲ្យមានការសង្ស័យថា ជាលក្ខណៈមនុស្សស្រី ។ ការវិភាគអំពីកាយវិការរបស់ក្សត្រា គឺជារឿងភាន់ច្រឡំមួយ ។ ប៉ុន្តែវាបានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់នៅពេលបាននិយាយជាមួយនឹងមិត្តភក្តិភូមារបស់ខ្ញុំ ស្ដីពីកាយវិការនិងលក្ខណៈយេនឌ័រ (ភេទភាវៈ) នៅក្នុងការសម្ដែងរបស់តួឯកក្សត្រានោះ ។ នៅពេលដែលខ្ញុំនិយាយថា ក្នុងនាមជាអ្នកទស្សនាជនជាតិអាមេរិកាំងម្នាក់ ខ្ញុំមើលឃើញនូវកាយវិការបែបស្ត្រីភេទនៅក្នុងការសម្ដែងរបស់ក្សត្រា ។ ពួកគេហាក់ដូចជាមានការភ្ញាក់ផ្អើល ហើយនិយាយមកវិញថា «តួអង្គក្សត្រាលោតទេតើ!» តាមការពិតទៅ ក្សត្រាពិតជាលោតមែន ÷ របាំជាច្រើនរបស់តួក្សត្រាជានិច្ចកាល តែងតែរួមបញ្ចូលយ៉ាងហោចណាស់នូវការលោតខ្លះៗ ដែរ រីឯតួក្សត្រីវិញ មិនដែលលោតទេ[៣] ។ បន្ថែមលើនេះទៅទៀត មិត្តភក្តិរបស់

ខ្ញុំបានចង្អុលបង្ហាញបន្ថែមទៀតថា សម្លៀកបំពាក់របស់ក្សត្រា ពិតជាមានលក្ខណៈខុសប្លែកពីសម្លៀកបំពាក់របស់ក្សត្រីប្រាកដមែន ។ សម្លៀកបំពាក់ដែលពោរពេញទៅដោយការតុបតែងរបស់ក្សត្រានោះ បានយកលំនាំតាមសម្លៀកបំពាក់របស់ពួកអភិជនបុរស ដែលជាព្រះរាជវង្សានុវង្សតាំងពីដើមរហូតមកដល់ឥឡូវនេះ ។ គ្មាននរណាម្នាក់ដែលដឹងពីរឿងនេះហើយយល់ច្រឡំចំពោះការតុបតែងកាយរបស់តួក្សត្រាក្សត្រីឡើយ ។

ដូច្នេះ ការយល់ច្រឡំថា អាកប្បកិរិយារបស់តួក្សត្រាមានលក្ខណៈជាមនុស្សខ្ទើយ របស់ជនជាតិអាមេរិកាំងនោះឆ្លុះបញ្ចាំងពីទ្រឹស្ដីប្រាកដនិយមរបស់នរវិទ្យា ដែលថា មនុស្សមាននិន្នាការក្នុងការវិភាគខុសនូវអាកប្បកិរិយារបស់អ្នកដទៃ ដោយសារតែការពិចារណារបស់ពួកគេឋិតនៅលើលក្ខខណ្ឌវប្បធម៌របស់ខ្លួន ។ ប៉ុន្តែ សំណួរដែលសំខាន់ហើយគួរឲ្យចាប់អារម្មណ៍មួយនោះ គឺថា តើមនុស្សគិតយ៉ាងដូចម្ដេចចំពោះបុគ្គលិកលក្ខណៈជាបុរសនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ? ហើយហេតុអ្វីបានជានៅក្នុងការសម្ដែងជាច្រើន ពួកគេគិតយ៉ាងខ្លាំងអំពីបញ្ហាទាំងនេះម៉្លេះ នៅខណៈដែលបុគ្គលិកលក្ខណៈរបស់មនុស្សស្រីបែរជាមានការគិតគូរតិចជាងទៅវិញ ?

ចម្លើយដ៏ខ្លីអំពីមូលហេតុតួឯកល្ខោនក្សត្រាកម្ពុជាស្លៀកពាក់ និងសម្ដែងដូចដែលបានឃើញនោះ គឺពួកគេមិនមែនសម្ដែងជាបែបមនុស្សប្រុសតែងខ្លួនជាមនុស្សស្រីនោះទេ ប៉ុន្តែគេសម្ដែងជាមនុស្សប្រុសដែលមានចំណេះដឹងខ្ពង់ខ្ពស់និងសុភាពរាបសាយ៉ាងពិតប្រាកដ ។ ដោយបានទទួលឥទ្ធិពលពីប្រពៃណីរបស់ពួកអភិជននោះ ការតាក់តែងខ្លួនរបៀបនេះ នៅតែទទួលបានកិត្តិសព្ទនៅក្នុងប្រទេសកម្ពុជានៅឡើយ បើទោះបីជាវណ្ណៈអភិជនត្រូវបានគេរំលាយចោលតាំងពីសម័យអង់គ្លេសបានវាយដណ្ដើមកាន់កាប់កម្ពុជាប៉ែកខាងជើងនៅចុងសតវត្សរ៍ទី ១៩ ក៏ដោយ ។ ប៉ុន្តែ អ្វីដែលខ្ញុំចង់បង្ហាញនាពេលបន្តិចទៀតនេះ គឺថា តើការបកស្រាយផ្សេងៗទៀតអំពីលក្ខណៈរបស់មនុស្សប្រុសបានមកបង្គ្រប់ ឬមកជំនួសគំនិតស្ដីពីឥរិយាបថមនុស្សប្រុសនោះ បានធ្វើឡើងដោយរបៀបណា ។ អំណះអំណាងដែលខ្ញុំយកមកប្រើនៅពេលនេះ គឺបានមកពីការទស្សនាល្ខោនហ្សាក់ព្វៃ (ទស្សនីយភាពសិល្បៈបែបកម្ពុជា) រៀងរាល់យប់នៅទីក្រុងម៉ាន់ដាលេ (မန္တလေး « មន្តលេះ ») នារដូវវស្សាក្នុងឆ្នាំ ២០០២ រួមនឹងការសន្ទនារបស់ខ្ញុំជាមួយនឹងអ្នកសម្ដែងនិងមិត្តភក្តិផ្សេងៗទៀតនៅទីក្រុងម៉ាន់ដាលេនៅពេលនោះផងដែរ ។

## ការសម្ដែងភេទភាវៈ

ការសម្ដែងសិល្បៈផ្សេងៗ គឺជាកន្លែងមាននូវអំណោយទានយ៉ាងពិសេស សម្រាប់ពិនិត្យមើលថា តើមនុស្សគិតអំពីភេទភាវៈយ៉ាងដូចម្ដេច ។ ពីព្រោះវាដូចទៅនឹងអ្វីដែលអ្នកស្រី ជូឌីថ ប៊ីត្លឺរ (១៩៩០) បានពន្យល់អ៊ីចឹង ជានិច្ចកាល ភេទភាវៈ (យេនឌ័រ) គឺជាការសម្ដែង ។ នៅក្នុងចំណុចនេះ អ្នកស្រី ប៊ីត្លឺរ ចង់ពន្យល់ថា ពុំមានការកំណត់ជាក់លាក់ណាមួយអំពីភាពជាបុរសនិងជាស្ត្រីនោះទេ ។ មនុស្សប្រុសនិងមនុស្សស្រី (ឬភាពជាមនុស្សប្រុសនិងជាមនុស្សស្រី) អាចកំណត់បាន ដោយសារតែការសន្មតទៅវិញទៅមកថា នេះជាមនុស្សប្រុសឬមនុស្សស្រីតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ការសន្មតស្ដីពីភាពខុសគ្នារវាងមនុស្សប្រុសនិងមនុស្សស្រីនោះ ក៏មានលក្ខណៈផ្សេងៗគ្នាទៅតាមវប្បធម៌និងសម័យកាលផងដែរ ។ ប៉ុន្តែ ភាពខុសគ្នាទាំងនោះ នៅតែមាននិងមានបន្តទៅមុខតទៅទៀត ដោយសារតែពួកយើងរាល់គ្នាបានសម្ដែងចេញរាល់ពេលវេលា បើទោះបីជាទទួល ឬសន្មតឡើង ឬក៏ធ្វើតាមដោយមិនដឹងខ្លួនក្ដី ។ យើងអាចគិតពីលក្ខណៈរបស់មនុស្សប្រុសនិងមនុស្សស្រីថា « ជារឿងកើតឡើងតាមធម្មជាតិ » ។ ការគិតបែបនេះកើតឡើង ដោយសារតែយើងបន្តទទួលស្គាល់ថា ជាការពិត

ដែលស្ដែងចេញតាមរយៈសកម្មភាពរបស់យើង និងការមើលឃើញសកម្មភាពរបស់អ្នកដទៃ ។ តែតាមការពិត លក្ខណៈនេះមិនមែនកើតឡើងដោយឯកឯងតាមបែបធម្មជាតិនោះទេ ប៉ុន្តែកើតឡើងដោយសារតែឥទ្ធិពលវប្បធម៌និងប្រវត្តិសាស្ត្រ ។ ដូចនេះហើយ គ្មាននរណាម្នាក់អាចជាមនុស្សប្រុសឡើយ ប៉ុន្តែគេគ្រាន់តែអាច «សម្ដែងអាការៈជាមនុស្សប្រុសប៉ុណ្ណោះ» ។ ប្រុសនិងស្រី គឺគ្រាន់តែជាតួនាទីដែលយើងទទួលយក ដូច្នេះហើយភេទភាវៈ គឺគ្រាន់តែជាការសម្ដែង ។

ដោយទាញតាមរយៈការអះអាងដ៏សាមញ្ញនេះ នៅពេលប្រជាជនទៅទស្សនាការសម្ដែង ភេទភាវៈហាក់ដូចជាជ្រាបចូលទៅក្នុងការគិតរបស់ពួកគេ នៅពេលគេកំពុងសង្កេតមើលអ្នកសម្ដែងទាំងនោះ ។ តាមរយៈការអះអាងដូចគ្នានេះដែរ នៅពេលអ្នកសម្ដែងប្រាថ្នាធ្វើឲ្យអ្នកទស្សនាចាប់អារម្មណ៍នោះ ជាញឹកញាប់ពួកគេបានសម្ដែងចេញនូវតួនាទីភេទភាវៈ ដោយបញ្ចូលអត្តសញ្ញាណមនុស្សប្រុសមនុស្សស្រីនៅក្នុងសាច់រឿង ។ បើយើងពិនិត្យមើលទៅលើប្រភេទនៃការសម្ដែងរបស់ប្រទេសលោកខាងលិច ទាំងរឿងវីរជន និងរឿងប្រជាប្រិយ ដែលមានតួអង្គស្រីត្រូវក្លែងខ្លួនជាបុរសភេទ ឬ តួអង្គប្រុសដែលត្រូវក្លែងខ្លួនជាស្ត្រីភេទ ដូចជារឿងល្ខោន «យប់ទី ១២» របស់កវីបណ្ឌិតជនជាតិអង់គ្លេស ធិកស្ពារ រឿងល្ខោន «អាពាហ៍ពិពាហ៍របស់ពូហ្វីហ្គារ៉ូ» (ជារឿងរាំនិងច្រៀងអូប៉េរ៉ារបស់លោក ម៉ូហ្សារត៍) «កម្មវិធីរបស់មិលតុន ប៊ែល» (លោក មិលតុន ប៊ែល [Milton Berle] ជាពិធីករវិទ្យុនិងទូរទស្សន៍ជនជាតិអាមេរិកាំងដ៏ល្បីល្បាញ ១ រូប) និងរឿងកុន «អ្នកខ្លះចូលចិត្តភាពស្រើបស្រាល» (Some Like It Hot) (ដែលមានតារាភាពយន្តអាមេរិកាំងដ៏ល្បីឈ្មោះ គឺកញ្ញា ម៉ារីលីន មន្រោ បានដើរតួ) បានបញ្ជាក់ពីប្រសិទ្ធភាពជាប់គ្នាមិនដាច់នៃគំនិតខាងលើ ទៅតាមទីកន្លែង ប្រភេទនៃរឿង និងដំណាក់កាលផ្សេងៗ គ្នា ។

នៅក្នុងដំណាក់កាលដូចគ្នានេះដែរ វាមានសារៈសំខាន់ណាស់ក្នុងការពិចារណាថា តើបញ្ហាភេទភាវៈ (បញ្ហាយេនឌ័រ) មានលក្ខណៈយ៉ាងដូចម្ដេចនៅក្នុងការសម្ដែងល្ខោនហ្សាក់ព្វៃ នៅពេលបច្ចុប្បន្ននេះ ។ ដាកិច្ចចាប់ផ្ដើមខ្ញុំនឹងពិព័ណ៌នាពីការសម្ដែងនោះ ដែលបានធ្វើឡើងនៅក្នុងខែកក្កដា ឆ្នាំ ២០០២ ដោយក្រុមល្ខោនមួយក្រុមដែលមានតួឯកប្រុសឈ្មោះថា គោន៏អ៊ួ (ကိုနော်ဝေ « កុនៅវេ » អានថា គោ-ន-អ៊ួ ; ကို កុ អានថា គោ មានន័យថា « បងប្រុស ») ។ ល្ខោននោះបានសម្ដែងនៅក្បែរអមរបុរៈនៅក្នុងវាលមួយខាងមុខវត្តមួយ ។ ព្រះសង្ឃជាច្រើនអង្គ ដែលនិមន្តមកពីវត្តនេះ ជាអ្នកឧបត្ថម្ភការសម្ដែងនេះ ដើម្បីជាការរលឹកទៅដល់ព្រះសពចៅអធិការវត្តនេះ ដែលបានទទួលអនិច្ចធម៌ជាច្រើនឆ្នាំមកហើយ និងដើម្បីជាពិធីអបអរសាទរដល់សមណសិស្សនិស្សិតដែលបានប្រឡងជាប់វិញ្ញាសាបាលីដែលរដ្ឋាភិបាលភូមាបានបង្កើតឡើង ។

## ការសម្ដែងជនស្បជីយភាពសិល្បៈបែបភូមា (បុណ្យដ៉ាង « ហ្សាក់ព្វៃ »)

### ការបើកឆាក

គេបានរៀបចំឆាកមួយជាពិសេស សម្រាប់ឲ្យក្រុមសិល្បករសម្ដែងនៅខាងលើនោះ ។ នៅប្រហែលម៉ោង ៩ និង ១៥ នាទីយប់ ការសម្ដែងក៏បានចាប់ផ្ដើម ។ ផ្ទាំងវាំងននបានបង្ហួតឡើង ពេលនោះ យើងមើលឃើញនូវផ្ទាំងគំនូរព្រះពុទ្ធអង្គ និងមានមនុស្សមួយក្រុមដែលជាតួសម្ដែង ម្នាក់ជាតួព្រះសង្ឃ ម្នាក់ជាតួយក្ស និងម្នាក់ជាតួមនុស្សស្រី កំពុងធ្វើពិធីថ្វាយបង្គំចំពោះព្រះពុទ្ធអង្គ ។ បន្ទាប់មក មានស្រីរបាំម្នាក់ ដែលក្រោយមកសម្ដែងជាតួឯកស្រី មាននាមថា ម៉ាស្សឺដា (မသီတာ « មសីតា » អានថា /ម៉ាស្សឺដា/ ; မ « ម » អានថា ម៉ា មានន័យថា

« បងស្រី ») បានរាំថ្វាយទៅដល់អារុក្ខអារក្សអ្នកតា (ភាសាភូមាហៅថា နတ် « នត៑ » អានថា /ណាក់/ ក្លាយមកពីពាក្យបាលី « នាថ ») ។ ស្រីរបាំនោះបានកាន់ថាសមួយដែលពោរពេញទៅដោយគ្រឿងរណ្តាប់សម្រាប់ថ្វាយដល់អ្នកតា ដែលការណ៍នេះបញ្ជាក់ថា វាជាអត្ថន័យនៃរបាំនោះហើយ ។ គួរឲ្យគត់សម្គាល់ដែរថា រាល់ការសម្តែងជនជាតិភូមាទាំងអស់សុទ្ធតែចាប់ផ្តើមជាមួយនឹងការគោរពប្រណិប័តន៍ដល់អ្នកតា ។ វាគឺជាគំនិតច្នៃប្រឌិតថ្មីមួយដើម្បីប្រាប់បញ្ចូលជំនឿលើអ្នកតាជាមួយនឹងព្រះពុទ្ធសាសនា ដោយសម្តែងការគោរពចំពោះព្រះពុទ្ធអង្គមុននឹងប្រណិប័តន៍អារក្សអ្នកតា ។

នៅម៉ោង ៩:៣០ នាទីយប់ រាំងននក៏បានបង្ហូតបិទវិញ ហើយអ្នកសម្តែងជាច្រើនបាននាំគ្នាឡើងច្រៀងដោយមានឧបករណ៍តន្ត្រី ដូចជាស្គរធំរួមជាមួយនឹងឧបករណ៍តន្ត្រីសម័យផ្សេងៗទៀត លេងជាភ្លេងកំដរផង ។ នៅពេលដែលរាំងននបង្ហូតបើកម្តងទៀត ស្ត្រីបីនាក់បានចាប់ផ្តើមរាំដោយផ្លាស់ប្តូរចង្វាក់ជាច្រើនលើក តាំងពីចង្វាក់ភូមា រហូតដល់ចង្វាក់ខ្លះទៀតមានលំនាំទៅនឹងចង្វាក់ចម្រៀងសម័យថ្មីរបស់ភូមានិងពួកលោកខាងលិច ។ បន្ទាប់មកទៀត តួឯកក៏បានចេញមកដោយតុបតែងជាក្សត្រា ដោយមានសម្លៀកបំពាក់ភ្លឺចែងចាំង មានសក់វែងបួងនៅពីលើក្បាល ពាក់ទៅដោយគ្រឿងពេជ្រមានតម្លៃ និងមានតុបតែងមុខមាត់ផង ។ តួសម្តែងក្សត្រានោះក៏ចាប់ផ្តើមច្រៀងចម្រៀងមនោសញ្ចេតនារបស់ភូមា បន្ទាប់មកក៏រាំ ហើយក៏ច្រៀងវិញទៀត ។

នៅម៉ោង ៩:៤៥ នាទី តួសម្តែងទីមួយក៏បានចេញមកលើឆាក គាត់ គឺជាបុរសវ័យក្មេងម្នាក់ស្លៀកសារុងសូត្រ (ភាសាភូមា គេហៅថា လုံချည် « លុំខ្យញ្ជិ » អានថា លោងហ្សី) និងអាវកាក់ពីខាងក្រៅអាវយឺតជារបៀបភូមា ។ អ្នកមកទស្សនាស្គាល់គាត់យ៉ាងច្បាស់ ក៏បានទះដៃឲ្យគាត់ ចំណែកឯគាត់វិញ ក៏បានញញឹមនិងបក់ដៃមករកអ្នកទស្សនាវិញដែរ ។ គាត់មានឈ្មោះថា គោប៉ាលី (ကိုဘလိ « កុិភលី » អានថា /គោប៉ាលី/) គឺជាអ្នកសម្តែងវ័យក្មេង ជាអ្នកចម្រៀង និងជាអ្នកកំប្លែងដ៏មានទេពកោសល្យម្នាក់ ដែលបានសម្តែងស្ទើរតែគ្រប់ឆាកក្នុងសាច់រឿងនេះ ។ នៅពេលនោះ គាត់បានច្រៀងបទចម្រៀងសម័យជាច្រើនបទ ដោយមានអមដោយឧបករណ៍ភ្លេងភូមានិងឧបករណ៍សម័យផងដែរ ។ បន្ទាប់ពីគោប៉ាលីទៅ មានអ្នកសម្តែងជាច្រើនបានឡើងមកតាមក្រោយ ក្នុងនោះ ក៏រួមមានស្ត្រីពីរនាក់ផងដែរ ។ ប៉ុន្តែ ពួកគេ ច្រើនឡើងមកច្រៀងតែម្នាក់ៗឯង ហើយដូចគោប៉ាលីអ៊ីចឹង ម្នាក់ៗ ច្រើនតែស្លៀកសម្លៀកបំពាក់ដែលមានតម្លៃ ហើយច្រើនច្រៀងចម្រៀងសម័យរបស់ភូមា ដែលមានអាយុតាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មកម៉្លេះ ។

## ល្ខោនច្រៀង

នៅម៉ោង ១០:៣០ នាទីយប់ ការសម្តែងល្ខោនច្រៀង ក៏បានចាប់ផ្តើម ។ ល្ខោន គឺជាការសម្តែងខ្លីៗនិយាយអំពីរឿងនិទានមួយដែលអប់រំអំពីសីលធម៌ខ្លះៗ ។ ជាធម្មតា សាច់រឿងរៀបរាប់អំពីអតីតកាលដ៏យូរលង់របស់ភូមា ឬក៏នៅកន្លែងល្បីល្បាញណាមួយ ។ នៅក្នុងរឿងនិទាននោះ បាននិយាយអំពីបុរសបីនាក់ (ដែលសម្តែងដោយក្រុមតួល្ខោននោះមាន គោនំអួ គោប៉ាលី និងបុរសវ័យក្មេងម្នាក់ទៀត) ដែលបានត្រឡប់មកផ្ទះវិញ បន្ទាប់ពីបានទៅក្រេបយកចំណេះវិជ្ជានៅឯសកលវិទ្យាល័យមួយរួចមក ដែលជាទីកន្លែងដែលពួកគេបានទទួលជំនាញរៀងៗខ្លួន ខាងឆ្ងាក់ គូរ និងជប់ឲ្យមានជីវិត ។ អ្នកសម្តែងបានស្លៀកសម្លៀកបំពាក់បុរាណ (គោនំអួស្លៀកសម្លៀកបំពាក់ជាក្សត្រា ចំណែកឯគោប៉ាលីនិងកូនសិស្សម្នាក់ទៀតនោះ ស្លៀកសម្លៀកបំពាក់ដូចជាតួក

អ៊ីចឹង) ហើយភាសាដែលគេប្រើ គឺជាភាសាសមញ្ញរបស់ភូមាសព្វថ្ងៃនេះ ។ ការសម្ដែងនេះជាការសម្ដែងដ៏វិសេសមួយនៅប្រទេសភូមាសព្វថ្ងៃ ដោយសារគេប្រើឧបករណ៍តន្ត្រីបុរាណភូមាប៉ុណ្ណោះ ។ គេសម្ដែងរឿងនេះជាបឋម ក្នុងន័យតែសម្រាប់កំដរអារម្មណ៍ឲ្យមានការសើចសប្បាយ ។ ប៉ុន្តែ រឿងនេះក៏បានបណ្ដុះគំនិតសីលធម៌នៅក្នុងពេលដូចគ្នានោះដែរ ÷ គឺថា គេមិនត្រូវរមិលគុណចំពោះអ្នកជួយខ្លួននោះទេ ។ ចំណុចនេះ ជាញឹកញាប់យើងឃើញមាននៅក្នុងសិល្បៈភូមានិងនៅក្នុងការប្រាស្រ័យទាក់ទងគ្នានៅប្រទេសភូមាផងដែរ ។

## ការប្រគំតន្ត្រីបែបសម័យ

ល្ខោនបានបញ្ចប់នៅប្រហែលជាពាក់កណ្ដាលអធ្រាត្រ ហើយបន្ទាប់ពីសម្រាកបានបន្តិចមក ការសម្ដែងមួយទៀតដែលជាការប្រគំតន្ត្រី បានចាប់ផ្ដើមឡើង ។ ការប្រគំតន្ត្រី មានការលេងភ្លេងបែប «ហេវីរ៉ុក» (heavy rock) (មានចង្វាក់ញាប់រន្ទាន់ ឮសូរថ្ងង់ណាស់) ដែលមានឧបករណ៍តន្ត្រីចម្រុះដូចជា ហ្គីតារ បាស អកស្គរមួយវង់ និងបាសធំៗ ។ គោប៉ាលីបានចេញសម្ដែងមុនគេម្ដងទៀត ហើយគាត់និងអ្នកសម្ដែងតាមក្រោយគាត់ បានច្រៀងចម្រៀងម្នាក់ពីរបទ ។ បើទោះបីជាមានម៉ាស៊ីដា ចេញមកសម្ដែងដោយស្លៀកខោស្ទាប់ជង្គង់និងអាវវែងក៏ដោយ ក៏អ្នកចម្រៀងភាគច្រើនសុទ្ធតែជាមនុស្សប្រុស ។ ចុងក្រោយបំផុតនោះ គោនឹ៍អ្ហូ បានចេញមកច្រៀងចម្រៀងមួយបទយ៉ាងវែង ដែលជាញឹកញាប់ តែងមានក្រុមប្រុសៗ មួយចំនួនជាអ្នកច្រៀងបន្ទរតាមក្រោយ ឬ រាំកំដរ ។

គោនឹ៍អ្ហូ សម្ដែងជាលើកដំបូង ដោយស្លៀកខោខៅប៊យរីបពាងពណ៌ខៀវ និងមានសក់វែង ។ គាត់បានប្ដូរសម្លៀកបំពាក់របស់គាត់ជាប្រចាំ ដូចជាពាក់បន្ថែមមួកកីឡាបាល់បោះ (ជាញឹកញាប់ពាក់យកមុខទៅក្រោយ) ប្ដូរទៅពាក់អាវរៀលក្លៀកបញ្ចេញសាច់ដុំ (តែងតែមានម៉ាក) និងពាក់វ៉ែនតាខ្មៅ ។ គាត់ដើរបញ្ចេញរាងនៅលើឆាក គ្រវីសក់ទៅមក ហើយស្រែកខ្លាំងៗ មើលទៅដូចជាខឹងនៅខណៈដែលគាត់ខំស្រែកច្រៀងស្ទើរតែផុតដង្ហើមម្ដងៗ ។ ស្ទើរតែគ្រប់ផ្នែកទៅហើយដែលការប្រគំតន្ត្រីបានសឲ្យឃើញពីកំហឹងនិងហិង្សា គឺដូចតែការរាំចង្វាក់ហ៊ីបហប់ និងរ៉ុកមួយចំនួននៅប្រទេសលោកខាងលិចសព្វថ្ងៃនេះអ៊ីចឹង ។ ប៉ុន្តែ ពេលខ្លះការសម្ដែងបែបនេះត្រូវបានកាត់សង្វាក់ ដោយសារការសម្ដែងកាយវិការកំប្លែងរបស់គោប៉ាលីផងដែរ ។ សម្លេងនៃការប្រគំនោះ ឮខ្លាំងណាស់ ដែលទាមទារឲ្យអ្នកសម្ដែងប្រើប្រាស់ថាមពល ក៏កាន់តែច្រើនផងដែរ ។ ការសម្ដែងនោះបានបន្តរហូតដល់ម៉ោងពីរយប់ ។ អ្នកទស្សនាបានមើលដោយមិនដាក់ភ្នែក បើទោះបីជាពួកគេមិនបានទះដៃនៅពេលអ្នកចម្រៀងច្រៀងចប់បទចម្រៀងនីមួយៗក្ដី ។ នៅប្រទេសលោកខាងលិច ការមិនទះដៃបន្ទាប់ពីចប់បទចម្រៀងនីមួយៗ នៅក្នុងការប្រគំដន្ត្រីនោះ គឺជាការប្រមាថ ។ រីឯអ្នកវង់ភ្លេងភូមាបុរាណវិញ បានផ្ដុំគ្នានៅម្ខាងឆាក ហើយបានសម្ងំក្នុងពេលគេលេងភ្លេងរ៉ុក ។

## ល្ខោន « ប្យាហ្សាក់ »

បន្ទាប់មកទៀតនោះគឺការសម្ដែងល្ខោន (ភាសាភូមាហៅ ပြဇာတ် « ប្រជាតិ » អានថា ប្យាហ្សាក់ ; ပြ « ប្រ » អានថា ប្យា មានន័យថា « សម្ដែង ») ។ រឿងនេះរៀបរាប់អំពីបុរសម្នាក់ ដែលសម្ដែងដោយគោនឹ៍អ្ហូ និងប្រពន្ធរបស់គាត់សម្ដែងដោយម៉ាស៊ីដា ដែលជីវិតជាប្ដីប្រពន្ធរបស់គាត់ ត្រូវបានបំផ្លាញដោយសារអ្នកជិតខាង ដែល

មានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ បានលួងឲ្យនាងជាប្រពន្ធផឹកស្រាស្រវឹង រួចហើយពង្រត់គ្នាជាមួយនឹងគាត់ ។ កូនស្រីរបស់នាងជាមួយនឹងប្តីដើមនោះ បានស្លាប់នៅខណៈដែលអ្នកបម្រើប្តីចុងរបស់ម្តាយ ព្យាយាមចាប់យកមកកូនស្រីនេះឲ្យនៅជាមួយនាងជាម្តាយនោះ ។ ដូច្នេះ ម៉ាស៊ីដា បានសម្លាប់ប្តីចុងរបស់នាង ដើម្បីជាការសងសឹកឲ្យកូនស្រីរបស់នាង ប៉ុន្តែប្តីដើមរបស់នាងបានសម្លាប់នាងវិញ ដោយសារតែចោទថា នាងមានជាប់ពាក់ព័ន្ធនឹងការស្លាប់របស់កូនស្រី ។ ជាចុងបញ្ចប់ ប៉ូលិសក៏បានមកដល់ ហើយចាប់ប្តីដើមនោះដាក់គុកទៅ ។ ការសម្តែងនោះបានផ្តល់ឱកាសឲ្យគោនអ៊ួ ថ្លែងពីបណ្តាំចុងក្រោយដែលប្រកបដោយសីលធម៌ និងការរំដើបរំជួលដ៏វែងអន្លាយមួយ (ការសម្តែងនោះគេបានតែងជាប៉ារ៉ូលឲ្យអ្នកសម្តែងនិយាយតាម ប៉ុន្តែ គោនអ៊ួ បានប្រាប់ខ្ញុំក្រោយមកទៀតថា គាត់តែងតែបន្ថែមសម្តីខ្លះរបស់គាត់ទៅលើប៉ារ៉ូលនោះ នៅពេលគាត់សម្តែងម្តងៗ) ។ នៅក្នុងល្ខោនបាសាក់នេះ អកអគ្គិសនីបានផ្តល់ជាស្គរតន្ត្រី ដែលបានធ្វើឲ្យការសម្តែងនោះ ដូចជាកុនបុរាណភាគដ៏រំដើបរំជួលនៅតាមទូរទស្សន៍អ៊ីចឹងដែរ ។

## ការច្រៀងឆ្លោះឆ្លង

*ការសម្តែងចុងក្រោយនោះ គឺជាការច្រៀងឆ្លោះឆ្លង* (ដែលភាសាភូមាហៅថា ႏွစ္ပါးသြား « ហ្នចិបាះស្វា:» អានថា /ហ្និកប៉ាត្វា/) *ដែលមានអ្នករបាំប្រុសម្នាក់ស្លៀកពាក់ជាក្សត្រា បានឡើងមកលើឆាក ហើយច្រៀងចម្រៀងប្រជាប្រិយសម័យជាច្រើនបទ និងរាំផង ហើយបន្ទាប់មក ក៏មានម្នាក់ផ្សេងទៀតមកបន្ត ។ ក្រុមស្ត្រីមានគ្នាចំនួន ៦ នាក់ បានអង្គុយបុរាំជាលក្ខណៈពាក់កណ្តាលរង្វង់ពីក្រោយក្សត្រាទាំងពីរ ហើយមានត្លុកប្រុស ៣ នាក់ផ្សេងទៀត (រួមទាំងគោប៉ាលីផងដែរ) ឈរនៅកៀន ដើរតួជាអ្នកបម្រើក្សត្រាទាំងពីរនោះ ។ នៅពេលដែលក្សត្រានីមួយៗ ច្រៀង ពួកគេកាន់ក្បាលមេក្រូហុចទៅឲ្យគ្នាទៅវិញទៅមក នៅពេលដែលពួកគេរៀបនឹងរាំ ។ នៅផ្នែកជាច្រើន ត្លុកតែងតែចូលមកធ្វើកាយវិការកំប្លែងដាក់តួក្សត្រា ដោយពេលខ្លះ នាំតួក្សត្រាទៅឈរនៅម្ខាងនិងសម្រាកមួយភ្លែត ហើយពេលខ្លះលេងកំប្លែង បុចំអកដាក់ក្សត្រានោះ ។ តួក្សត្រាទីមួយច្រៀងមិនសូវពិរោះប៉ុន្មានទេ ហើយច្រើនតែត្រូវគោប៉ាលីកំប្លែងដាក់ ។ ក្សត្រាទីពីរ គឺជាបុរសវ័យចំណាស់ម្នាក់ប្រហែលជាអាយុខ្ទង់ ៤០ ។ គាត់ហាក់ដូចជាបានឡើងមកច្រៀងចម្រៀងប្រជាប្រិយពីក្បាលព្រលប់ម្តង និងច្រៀងម្តងទៀតនៅក្នុងវគ្គប្រគំតន្ត្រី (គាត់ស្លៀកសម្លៀកបំពាក់ពណ៌សខ្មៅផ្ទេកៗ ពាក់រយ៉ាអន្តែអន្តាយ និងវ៉ែនតាខ្មៅ) ប៉ុន្តែឥឡូវគាត់ស្លៀកពាក់និងរាំជាតួក្សត្រា ។ ជាចុងបញ្ចប់ គោនអ៊ួ បានឡើងមកសម្តែងដោយស្លៀកសម្លៀកបំពាក់ជាក្សត្រាផ្សេងមួយទៀត ដែលមានពណ៌ក្រហមចាំង ។*

*គោនអ៊ួ រាំតែបន្តិចៗ ប៉ុន្តែពោរពេញទៅដោយការសប្បាយរីករាយនិងភាពស្វាហាប់ ។ ប៉ុន្តែ គាត់មិនសូវបង្ហាញភាពស្និទ្ធស្នាលប៉ុន្មានទេ ជាមួយនឹងអ្នកសម្តែងដទៃទៀតនោះ ហើយគាត់ក៏ចូលទៅក្នុងឆាកវិញបន្តិចក្រោយមក ។ នៅពេលនោះ គឺពេលព្រឹកម៉ោង ៥ ជាងទៅហើយ ហើយអ្នកទស្សនាក៏កាន់តែតិចទៅៗ ដែរ ។ ក្សត្រាដែលមានវ័យចំណាស់នោះ ក៏បានធ្វើសេចក្តីថ្លែងការណ៍ទៅកាន់អ្នកទស្សនា ហើយបន្ទាប់មកនៅពេលដែលរាំងននបិទប្រហែលជាជិតម៉ោង ៥:៣០ នាទីនោះ គាត់បានដឹកនាំក្រុមសម្តែងទាំងអស់ លើកលែងតែគោនអ៊ួ ចេញសូត្រធម៌ជាភាសាបាលីយ៉ាងវែងនៅលើឆាក ។ ព្រះអាទិត្យបានរះឡើងបន្តិចក្រោយម៉ោង ៥ ហើយឥឡូវនេះភ្លឺហើយ ។ កន្លែងសម្តែងពោរពេញទៅដោយថង់ប្លាស្ទិកនិងសំរាម ។*

## លក្ខណៈសំខាន់នៃសម្លៀកបំពាក់

នៅប្រទេសលោកខាងលិចនិងប្រទេសផ្សេងទៀតនៅក្នុងពិភពលោក សម្លៀកបំពាក់ប្រុសនៅលើឆាករបស់អ្នកចម្រៀងរ៉ុក ខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះពីសម្លៀកបំពាក់ដែលពួកយុវជនស្លៀកពាក់ស្ទើរគ្រប់ពេលនោះ ។ ពួកយុវជនបានស្លៀកសម្លៀកបំពាក់តាមពួកអ្នកចម្រៀងរ៉ុក ទៅតាមទីកន្លែងផ្សេងៗ ជាច្រើន ។ អាវរឹបរាងបញ្ចេញសាច់ដុំ ខោខៅប៊យដាច់រយ៉េវរយ៉ៃ ឬក៏ខោខ្លីត្រឹមជង្គង់ ស្បែកជើងវត់កីឡា ឬប៊ូត ជាដើម ដែលអ្នកសម្ដែងក្មេងៗ ពាក់នៅលើឆាក ឥឡូវនេះបានក្លាយទៅជាសម្លៀកបំពាក់ធម្មតានៅគ្រប់ទីកន្លែងទៅហើយ ។ ប៉ុន្តែ នៅប្រទេសភូមា សម្លៀកបំពាក់ទាំងនេះត្រូវគេកត់សម្គាល់ខ្លាំងណាស់ ។ ប្រជាជនភូមា(៤) ជាទូទៅ បានយល់ឃើញថា រដ្ឋាភិបាលហាក់ដូចជាមិនសូវជឿជាក់ទៅលើយុវជនដែលស្លៀកខោ ដូចអ្នកស្លៀកសារុងនោះទេ (ហ្វ៊ិន្ក ២០០១, ១៣៣) ។ ពួកគេជឿថា អតីតមេដឹកនាំផ្ដាច់ការ ណេវិន (နေဝင်း « នេវង៉ិះ») មានគំនិតដូចនេះឯង ហើយគេក៏ជឿថា មេដឹកនាំទាំងឡាយដែលឡើងកាន់អំណាចជំនួសគាត់តាំងពីឆ្នាំ ១៩៨៨ មក ក៏មានគំនិតដូចគ្នានេះដែរ ។ (ប៉ុន្តែពួកមេដឹកនាំខ្លួនឯងក្នុងនាមជាពួកទាហានក៏ស្លៀកខោជាឯកសណ្ឋានគ្រប់ពេលដែរ(៥) ។) ដូច្នេះ មានការមិនពេញចិត្តខ្លះៗ ក្នុងការស្លៀកខោ ។ ប៉ុន្តែ បើមើលទម្លាប់នៃការស្លៀកខោថា ជាសកម្មភាពប្រឆាំងខាងផ្នែកនយោបាយ គឺគ្រាន់តែជាការពិនិត្យមើលទៅលើបញ្ហានេះសើៗ ប៉ុណ្ណោះ ។ ការស្លៀកលោងហ្ស៊ី (សារុង) ព័ណ៌មរកត ដែលមានក្បាច់តាមបែបជនជាតិកាឈិន គឺជាសកម្មភាពនយោបាយមួយយ៉ាងជាក់ស្ដែងដោយសារការស្លៀកសារុងបែបនេះ បានផ្សារភ្ជាប់នៅក្នុងគំនិតរបស់ប្រជាជនជាមួយនឹងគណបក្សប្រឆាំង ដែលមានឈ្មោះថា សម្ព័ន្ធជាតិអ្នកប្រជាធិបតេយ្យ របស់លោកស្រី អោងសានស៊ូឈី (ဒေါ်အောင်ဆန်းစုကြည် « ទៅ អោង៉ឆនិចុក្រញ្ញ៉ិ» អានថា ដ អោងសានស៊ូឈី ; ဒေါ် « ដៅ» អានថា ឌ មានន័យថា « លោកស្រី ») ។ ក្នុងការធ្វើដំណើរថ្មីៗទៅកាន់ប្រទេសភូមា ខ្ញុំបានសម្គាល់ឃើញថា យុវជនក្មេងៗ បានស្លៀកខោខៅប៊យរឹបរាង និងអាវវៀលក្លៀកច្រើនជាងនៅទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ។

ប៉ុន្តែ គឺមានតែពួកយុវជនដែលចង់ហ៊ឺហាទេ ដែលស្លៀកសម្លៀកបំពាក់បែបនេះ ។ បុរសភូមាភាគច្រើននៅម៉ាន់ដាលេ (និងនៅកន្លែងផ្សេងទៀតនៅក្នុងប្រទេសភូមា រួមទាំងទីក្រុងរ៉ង់ហ្គូនផង) នៅតែស្លៀកសារុង លុះត្រាតែពួកគេជាទាហាន ទើបស្លៀកខោ ។ អ្នកបើកបរម៉ូតូនៅម៉ាន់ដាលេ ក៏ចូលចិត្តស្លៀកខោជាងសារុង ។ ខ្ញុំសង្ស័យថា ពួកគេស្លៀកខោដើម្បីទាក់ទាញថា គេមានម៉ូតូ និងដូចគ្នានោះដែរ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការជិះម៉ូតូ ។ ប៉ុន្តែបុរសដែលមានអាយុពាក់កណ្ដាលមនុស្ស នៅតែស្លៀកសារុង បើទោះបីជាពួកគេជិះម៉ូតូក្ដី ។ នេះបានន័យថា ប្រុសៗ ស្លៀកសម្លៀកបំពាក់ស្ទីលលោកខាងលិចក្នុងប្រទេសភូមា គឺគេចង់បង្ហាញពីរបៀបដែលពួកគេចង់កំណត់អត្តសញ្ញាណរបស់ពួកខ្លួន ។ ការស្លៀកសម្លៀកបំពាក់ស្ទីលលោកខាងលិច គឺពួកគេចង់អះអាងថា ពួកគេជាសមាជិកនៃសហគមន៍អន្តរជាតិ ជាជាងជាសមាជិកសហគមន៍ក្នុងស្រុក ។ ក្នុងន័យមួយទៀត បានន័យថា ពួកគេជាមនុស្សទំនើបទាន់សម័យ ។

តួឯកនៅក្នុងក្រុមសម្ដែងទាំងឡាយ ដែលសម្ដែងនៅក្នុងវគ្គប្រគំតន្ត្រី ជាញឹកញាប់បានស្លៀកសម្លៀកបំពាក់ណាមួយដែលជាម៉ូតថ្មីៗ នៅក្នុងប្រទេសភូមា បើទោះបីជានៅក្នុងភ្នែករបស់អ្នកខ្លះ វាមានលក្ខណៈអវិជ្ជមានក្ដី ។ នៅក្នុងវគ្គល្ខោនប្យាហ្សាក់ ពួកគេស្លៀកពាក់សម្លៀកបំពាក់ព័ណ៌ស្រអាប់ជាង ប៉ុន្តែគេនៅតែស្លៀកខោអ៊ីចឹង ។ ប៉ុន្តែ ចំពោះប្រភេទនៃខោ គឺអាស្រ័យទៅលើតួនាទីដែលតម្រូវឲ្យតួស្លៀកពាក់សម្ដែងតែប៉ុណ្ណោះ ។

តួជាពួកបងធំ ដែលជាអ្នកមាន នឹងពាក់អាវធំៗ តាមរបៀបលោកខាងលិច; តួជាឪពុកដែលស្ថិតនៅក្នុងវណ្ណៈកណ្តាល ស្លៀកខោខៅប៊ិយ និងយុវជនដែលដើរតួរជាកូនប្រុសសុភាពរាបសា អាចស្លៀកខោព៌ណ៌ស និងពាក់អាវព៌ណ៌ក្រហមចាំងបាន ។ តួឯកមិនដែលស្លៀកសារុងទេ ។ តួរង ៗ ដូចជាតួបងប្រុស អ្នកបម្រើ និងបុរសផ្សេងៗទៀត ដែលមិនមែនជាតួឯក ស្លៀកសារុងនេះ ។ នៅក្នុងឈុតខ្លះទៀត នៅក្នុងការសម្តែង តួឯកបានស្លៀកសម្លៀកបំពាក់ជាតួក្សត្រា ។

ជាទូទៅ យើងអាចសន្និដ្ឋានបានថា សម្លៀកបំពាក់របស់តួឯក មានតែពីរប្រភេទប៉ុណ្ណោះ ។ ទី ១ គឺជាសម្លៀកបំពាក់តាមបែបអន្តរជាតិ ឬលោកខាងលិច ដែលមានខោនិងអាវ ។ ប្រភេទទី ២ គឺជាសម្លៀកបំពាក់អភិជនភូមាដែលមានលោងហ្សីនិងអាវភូមា ។ ភាពស្រដៀងគ្នាជាច្រើនរវាងសម្លៀកបំពាក់ ដែលតួឯកស្លៀកពាក់នៅក្នុងអំឡុងពេលប្រគំតន្ត្រី និងសម្តែងល្ខោនប្យាហ្សាក់ បានចង្អុលបង្ហាញយ៉ាងពិតប្រាកដនូវភាពស្រដៀងគ្នាកាន់តែខ្លាំងទៅៗ រវាងអត្តចរិតនៃអ្នកចម្រៀងរ៉ុក និងអត្តចរិតនៃតួឯកនៅក្នុងល្ខោនប្យាហ្សាក់ ។ តួឯករ៉ុកហាក់ដូចជាបុរសដែលឆាប់ឆេវឆាវ និងចូលចិត្តនៅម្នាក់ឯង ដោយប្រើអារម្មណ៍យ៉ាងពុះកញ្ជ្រោល និងរៀបៗតែបញ្ចេញអំពើហិង្សា ។ នៅក្នុងការសម្តែងល្ខោនប្យាហ្សាក់ស្ទើរតែភាគច្រើន ផ្តោតជាសំខាន់ជុំវិញតួឯកប្រុសដែលសម្តែងអាកប្បកិរិយាហិង្សាដោយប្រយោលតិចជាងអ្នកចម្រៀងរ៉ុក ប៉ុន្តែពេលខ្លះ ជាបុរសដែលខុសប្លែកពីគេពីឯង ឬចូលចិត្តនៅឯកោ ។ ជាឧទាហរណ៍ គាត់គឺជាកូនកំព្រា (ដែលឪពុកម្តាយមិនបានទុកកេរមរតកឲ្យ) ហើយបានក្លាយទៅជាបងតួចបងធំ ដើម្បីជួយផ្គត់ផ្គង់បងប្អូនបង្កើតរបស់គាត់ ។ ឬក៏គាត់ជាបុរសវ័យក្មេងដែលលង់ស្រឡាញ់អ្នកបម្រើ ហើយទទួលរងនូវការលំបាក ដោយសារតែម្តាយរបស់គាត់មានការខឹងសម្បាយ៉ាងខ្លាំង ។ ឬមួយ ក៏ដូចជានៅក្នុងការសម្តែងរបស់គោនំអ្ហអ៊ីចឹង គាត់គឺជាបុរសម្នាក់ ដែលប្រពន្ធរត់ចោល ហើយក្រោយមក បានដាក់ទោសនាងជំនួសឲ្យច្បាប់ ។ នៅក្នុងករណីនីមួយៗ តួឯកបានក្លាយទៅជាអ្នកដែលត្រូវតែធ្វើអ្វី ទៅតាមសេចក្តីប្រាថ្នារបស់ខ្លួនឯង ដោយប្រឆាំងទៅនឹងសេចក្តីប្រាថ្នារបស់អ្នកដទៃទៀត ។

លក្ខណៈតួអង្គនៃតួឯកនៅក្នុងល្ខោនប្យាហ្សាក់ ហាក់ដូចជាស្រដៀងៗ គ្នានឹងការសម្តែងដ៏ឆ្នើមៗ ជាច្រើនទៀត រួមទាំងហូលីវូដផងដែរ ។ មិនដូចនៅក្នុងវប្បធម៌ប្រជាប្រិយនៅលោកខាងលិចទេ សកម្មភាពរបស់វីរ-បុរស ច្រើនតែបង្ហាញឲ្យឃើញពីភាពស្មោះត្រង់ចំពោះគ្រួសារ ច្រើនជាងសេចក្តីស្នេហា ឬក៏ការធ្វើពលិកម្មប្រឆាំងទៅនឹងអំពើអាក្រក់នោះ ។ ប៉ុន្តែផ្ទុយទៅវិញ វីបុរសនោះត្រូវតែធ្វើអ្វីទៅតាមបំណងរបស់ខ្លួនគាត់ ប្រាសចាកពីបទដ្ឋានសង្គម (នេះមានន័យម្យ៉ាងទៀតថា គាត់មានភាពម្ចាស់ការលើខ្លួនគាត់) ដើម្បីបង្ហាញពីភាពស្មោះត្រង់ចំពោះគ្រួសាររបស់គាត់ ។ ប៉ុន្តែ រូបភាពនៃបុរសម្ចាស់ការខ្លួនឯង ដែលបានសម្តែងនៅក្នុងការប្រគំតន្ត្រីនោះ គឺនៅតែមានលក្ខណៈដូចគ្នានឹងតួឯកនៅក្នុងល្ខោនប្យាហ្សាក់អ៊ីចឹង បើទោះបីជាលក្ខណៈនៃការសម្តែងជាតួអង្គម្ចាស់ការនៅក្នុងការប្រគំតន្ត្រី មានលក្ខណៈប្រាកដនិយមច្រើនជាងក៏ដោយ ។ នៅក្នុងករណីទាំងពីរនេះ តួឯកត្រូវបានធ្វើឲ្យមើលឃើញប្លែកថា ជាបុរសម្នាក់ដែលមានភាពឯករាជម្ចាស់ការ សកម្ម និងមានលក្ខណៈជាបុថុជ្ជន និងទំនើប ។ ដូច្នេះ ពួកគេត្រូវតែស្លៀកខោ ។

ខ្ញុំហាក់ដូចជាសង្កត់ធ្ងន់ទៅលើបញ្ហាសម្លៀកបំពាក់នៅក្នុងការសម្តែងទាំងនេះច្រើនពេកហើយ ប៉ុន្តែជាការច្បាស់ណាស់ សម្លៀកបំពាក់ទាំងនោះ ពិតជាគួរឲ្យចាប់អារម្មណ៍មែនទែន ចំពោះទាំងអ្នកសម្តែងនិងអ្នកទស្សនាជាតិភូមាផងដែរ មិនមែនត្រឹមតែចំពោះខ្ញុំនោះទេ ។ តួឯកម្នាក់ត្រូវចំណាយពេលច្រើនណាស់ក្នុងការ

ផ្លាស់ប្តូរសម្លៀកបំពាក់នៅពេលសម្តែង ។ សម្លៀកបំពាក់តួក្សត្រានីមួយៗ មានជាច្រើនជាន់ រួមទាំងអលង្ការនិងមកុដទ្រង់គ្រឿង ហើយតួឯកនៅក្រុមសម្តែងនោះ ត្រូវស្លៀកសម្លៀកបំពាក់ ដែលរៀបរាប់ខាងលើនោះជាច្រើនបន្ទាស់ក្នុងពេលសម្តែង ។ ប៉ុន្តែ ជាញឹកញាប់ នៅពេលដែលតួឯកឡើងមកលើឆាកដោយប្តូរសម្លៀកបំពាក់តួក្សត្រាមួយឈុតទៀត ដែលមានពណ៌និងការតុបតែងដ៏ឆើតឆាយនោះ គាត់នឹងទទួលការស្វាគមន៍ដោយការទះដៃអបអរសាទរ ។ សម្លៀកបំពាក់នៅក្នុងការប្រគុំតន្ត្រី បានធ្វើឲ្យទស្សនិកជនចាប់អារម្មណ៍ច្រើន ឬច្រើនជាងសាច់រឿងដែលមានតួឯកសម្តែងជាក្សត្រាទៅទៀត ។ នៅក្នុងការច្រៀងចម្រៀងមួយបទៗ អ្នកចម្រៀងបានប្តូរសម្លៀកបំពាក់ផ្សេងៗ ។ ពេលខ្លះ គេប្តូរតែអាវប៉ុណ្ណោះ ។ ប៉ុន្តែ ជារឿយៗ គេប្តូរខោ អាវ មួក វ៉ែនតាខ្មៅ និងស្បែកជើង ។ ជាញឹកញាប់ អ្នកចម្រៀងបានប្តូរអាវសម្រាប់បទចម្រៀងមួយវគ្គៗ ។

សមាជិកដទៃទៀតនៃក្រុមសម្តែង ត្រូវតែស្លៀកពាក់ចាំរួចជាស្រេច ដើម្បីចេញសម្តែងភ្លាមៗ ពីព្រោះនៅពេលណាដែលអ្នកចម្រៀងចេញសម្តែង គេនឹងមិនរង់ចាំឲ្យពួកគាត់ផ្លាស់សម្លៀកបំពាក់នោះទេ ។ សមាជិកក្រុមសម្តែង ត្រូវប្តូរវេនគ្នាដើម្បីសម្តែង ប៉ុន្តែអ្នកចម្រៀងជាធម្មតាមិនប្តូរវេនគ្នាច្រៀងនោះទេ ។ ផ្ទុយទៅវិញ អ្នកចម្រៀងនីមួយៗ ចេញមកឆាក ហើយច្រៀងបទចម្រៀងមួយចំនួនជាប់គ្នា ។ បន្ទាប់មក គាត់ស្រែកហៅទៅកាន់អ្នកចម្រៀងដទៃឲ្យចេញមកច្រៀងបន្ត ។ បើទោះបីជាអ្នកចម្រៀងខ្លះចេញម្តងម្នាក់ៗ នៅលើឆាកក្តី (ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរសម្លៀកបំពាក់នៅក្នុងពេលច្រៀង) ក៏តួឯកចម្រៀងនឹងចេញនៅជុំចុងក្រោយនៃការប្រគុំតន្ត្រីនេះ ហើយច្រៀងចម្រៀងជាច្រើនបទ ។ នៅពេលតួឯកចំណាយពេលយូរប៉ុណ្ណាក្នុងការផ្លាស់ប្តូរសម្លៀកបំពាក់ អកអេឡិចត្រូនិកនិងឧបករណ៍តន្ត្រីផ្សេងទៀត ត្រូវតែលេងផ្តើមបទយូរប៉ុណ្ណោះដែរ ដើម្បីរង់ចាំទាល់តែតួឯកចម្រៀងឡើងមកលើឆាក ។

## ភាពជាបុរសច្រើនប្រភេទ ដែលអាចជ្រើសរើសបាន

ការសម្តែងពេញមួយយប់ មានអ្នកសម្តែងប្រុសៗ ជាច្រើននៅលើឆាក ហើយតួនាទីផ្សេងៗ របស់ពួកគេ បានស្នើឡើងនូវប្រភេទនៃមនុស្សប្រុសជាច្រើន ដែលមនុស្សម្នាក់ៗ ប្រកាន់យកនៅក្នុងប្រទេសភូមានាពេលបច្ចុប្បន្ននេះ[៦] ។ តួនាទីជាបុរសបានសម្តែងដោយត្លុក និងតួដែលគេហៅថា «ក្សត្រាធំៗ» (ឬ ក្សត្រាចំណាស់ៗ) សម្រាប់សំដៅទៅលើ «តារាប្រុសល្បីៗ» (မင်းသားကြီး «មង៉ះសាះក្រ៊ី» អានថា /មេន-ត្សាជី/ ; ကြီး «ក្រ៊ី» មានន័យថា «ធំ») បានបង្ហាញនូវភាពផ្ទុយគ្នាយ៉ាងច្បាស់ទៅនឹងតួនាទីរបស់តួឯក ។ ក្រុមសម្តែងប្រុសៗ ទាំងនោះ បានតំណាងឲ្យភាពជាបុរសធម្មតា ប៉ុន្តែមិនមែនជាប្រភេទដ៏ល្អឥតខ្ចោះនៃភាពជាបុរសភូមានោះទេ ។

អ្នកកំប្លែង (ត្លុក) បានចូលរួមសម្តែងជាតួរងនៅក្នុងការសម្តែងល្ខោនប្យាហ្សាក់ និងការច្រៀងឆ្លើយឆ្លង ។ តួរងជាធម្មតា គឺជាអ្នកមានឋានៈទាបៗ ដូចជាអ្នកបម្រើនៅតាមផ្ទះ ឬជាបរិពារហែហមក្សត្រាប៉ុណ្ណោះ ។ នៅពេលដែលគេសម្តែងជាតួកំប្លែង ពួកគេស្លៀកសម្លៀកបំពាក់បុរាណ រួមទាំងសារុង ដែលប្រើកំណាត់សំពត់អស់ច្រើនជាងសព្វថ្ងៃនេះ ។ ពួកគេបានធ្វើកាយវិការកំប្លែង និយាយកំប្លែងដោយប្រើពាក្យអាសគ្រាម និងសម្តែងល្បិចកំប្លែងផ្សេងៗ ទៀត ។ ហើយគេនិយាយភាសាសាមញ្ញជាងតួឯក ។ ពួកគេខុសប្លែកពីតួឯកយ៉ាងខ្លាំង នៅក្នុងកម្រិតដែលពួកគេរួបរួមគ្នាសម្តែងជាក្រុម ។ ពួកគេកម្រឡើងឆាកណាស់ លើកលែងតែការសម្តែងជាក្រុម ពន្យុះគ្នា ចំអកឲ្យគ្នា ប្រើល្បិចដាក់គ្នា និងធ្វើជាប្រតាយប្រតប់គ្នាដូចជាឆ្កួតៗ អ៊ីចឹង ។ ពួកត្លុកនោះធ្វើ

កាយវិការរួសរាយ រាក់ទាក់ និងឡប់ៗ ផ្ទុយទៅនឹងភាពថ្លៃថ្នូរបស់តួឯកដែលជាអ្នកឋានៈខ្ពស់ខ្ពស់ ។ ហើយពួកគេ ច្រើនពឹងផ្អែកទៅលើក្រុមរបស់ពួកគេទៅវិញទៅមក ផ្ទុយគ្នាទៅនឹងបុគ្គលិកលក្ខណៈរបស់តួឯក ដែលពឹងផ្អែកតែទៅលើគុណតម្លៃនិងសមត្ថភាពរបស់ខ្លួនឯង ។

ជាការពិត តួអ្នកបម្រើប្រាស្រ័យទាក់ទងជាមួយនឹងអ្នកទស្សនាដោយផ្ទាល់ នៅពេលសម្ដែង ជាឧទាហរណ៍ នៅពេលពួកគេជម្រាបអ្នកទស្សនានូវមូលហេតុអ្វី ដែលបណ្ដាលឲ្យមានការសម្ដែង ឬពួកគេធ្វើការប្រកាសជូនដំណឹងអំពីរឿងអ្វីមួយ ។ នៅក្នុងការសម្ដែងមួយ ខ្ញុំបានឃើញពួកគេប្រកាសផ្សាយពាណិជ្ជកម្មហាងសម្លៀកបំពាក់មួយ ដែលតួឯកនៃក្រុមសម្ដែងនោះទើបតែបើកនាពេលថ្មីៗ នេះ នៅក្នុងផ្សារដ៏ធំជាងគេនៅម៉ាន់ដាលេ ។ នៅក្នុងការសម្ដែងមួយទៀត ពួកយុវជនដែលមកទស្សនា បានប្រជ្រៀតគ្នាយ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យក្រុមអ្នកសម្ដែងល្ខោនប្យាហ្យាក់បដិសេធមិនព្រមចេញមកសម្ដែងបន្តទៀត ។ បន្ទាប់មក នៅពេលការសម្ដែងបានចាប់ផ្ដើមឡើងវិញហើយបញ្ចប់ទៅនោះ ក្រុមប្រុសៗ ដែលដើរតួជាអ្នកបម្រើនោះ បានផ្ដល់នូវមេរៀនសីលធម៌ទៅដល់ទស្សនិកជនទាំងឡាយ អំពីរបៀបដែលពួកគេគួរប្រកាន់ខ្ជាប់ ។ ការធ្វើដូច្នេះ ពួកគេបានធ្វើផ្ទុយទៅនឹងតួអង្គរបស់ពួកគេហើយ ។ ប៉ុន្តែ បញ្ហាគឺថា ពួកគេត្រូវតែធ្វើរបៀបនេះ ដោយសារគម្លាតរវាងពួកគេដែលជាតួកំប្លែងនិងទស្សនិកជននោះ មិនធំប៉ុន្មានទេ ប៉ុន្តែការធ្វើបែបនេះមិនសមទេសម្រាប់តួឯក ។

ជានិច្ចកាល «ក្សត្រាធំៗ» ភាគច្រើន តែងតែបានសម្ដែងជាតួអង្គអាក្រក់÷ ពួកគេគ្មានមេត្តា ស៊ីសំណូក ឬប្រកាន់វណ្ណៈ ឬក៏ពួកគេជាមនុស្សចាស់ល្ងីល្ងើដើរទ្រេតទ្រោតៗ ។ អ្នកដែលធ្លាប់ជាតួឯកពីម្សិលក្នុងជំនាន់មុន ត្រូវតែឈប់ដើរជាតួឯក ហើយដើរតួជាក្សត្រាធំវិញ ទោះមានអាយុនៅក្មេងក៏ដោយ ។ កាលពីអតីតកាល ទស្សនិកជនមានភាពរីករាយក្នុងការមើលការសម្ដែងរបស់តួឯកប្រុសដែលមានអាយុ ៤០ ឬលើសនេះ ប៉ុន្តែ សព្វថ្ងៃនេះ គឺគ្មានតួឯកប្រុសណាម្នាក់ដែលមានអាយុលើសពី ៣០ ឆ្នាំ អាចសង្ឃឹមនឹងទទួលបាននូវការគាំទ្រពីទស្សនិកជនទៀតនោះទេ ។

មិនដូចការសម្ដែងជាតួប្រុសធម្មតារបស់តួកនិងក្សត្រាធំៗ (ក្សត្រាចំណាស់ៗ) នោះទេ លក្ខណៈរបស់តួឯកនៅក្នុងការប្រគំតន្ត្រី ល្ខោនប្យាហ្យាក់ និងតួឯកជាក្សត្រា អាចធ្វើឲ្យគេយល់ថា មានប្រភេទផ្សេងៗគ្នានៃភាពជាបុរសឧត្ដម ។ ប៉ុន្តែ សូម្បីតែនៅក្នុងចំណោមតួជាបុរសឧត្ដមនេះ ក៏មានភាពផ្ទុយគ្នាយ៉ាងខ្លាំងផងដែរ ជាពិសេសគឺការផ្ទុយគ្នាយ៉ាងខ្លាំងរវាងអ្នកចម្រៀងរ៉ុកនិងតួឯកក្សត្រា ។ អ្នកចម្រៀងរ៉ុកបានសម្ដែងជាកាយវិការហិង្សានិងសាហាវ ប៉ុន្តែក្សត្រាសម្ដែងជាកាយវិការញញឹមយ៉ាងរួសរាយរាក់ទាក់ ឬអឹមអៀន ឬក៏អណ្ដែតអណ្ដូង ។ អ្នកចម្រៀងរ៉ុកសម្ដែងជាកាយវិការញាក់ញ័រ និងច្រងេងច្រងាង ដូចជាគ្រប់គ្រងខ្លួនឯងមិនបាន ហើយពោរពេញដោយកំហឹងទៀតផង ។ ចំណែកតួក្សត្រាវិញ បានសម្ដែងនូវកាយវិការឈានជំហានដើររាំយឺតៗ ប៉ុន្តែយ៉ាងស្ទាត់ជំនាញ ដោយបង្ហាញនូវទស្សនីយភាពយ៉ាងជក់ចិត្តជិតអារម្មណ៍ ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺតួអង្គទាំងពីរនេះសម្ដែងដោយមនុស្សតែម្នាក់ប៉ុណ្ណោះ ។

មានការសន្និដ្ឋានមួយថា វត្តមាននៃលក្ខណៈតួអង្គផ្សេងៗ គ្នាដែលអ្នកសម្ដែងបានសម្ដែងនៅលើឆាកនោះបានបញ្ជាក់ថា មានប្រភេទជាច្រើននៃភាពជាបុរសឧត្ដមនៅក្នុងការសម្ដែងនៅប្រទេសភូមា ។ ហើយបើទោះជាប្រភេទផ្សេងគ្នាទាំងនេះ មាននូវភាពខុសគ្នាក៏ដោយ ក៏មានលក្ខណៈស្មើគ្នាក្នុងនាមជាបុរសឧត្ដមដែរ ។ ប៉ុន្តែការទាញសេចក្ដីសន្និដ្ឋានបែបនេះ ហាក់ដូចជាសុទិដ្ឋិនិយមបន្តិចហើយ ។ បើយើងពិនិត្យមើលទៅលើរយៈពេល

ដែលបែងចែកឲ្យសម្ដែងតាមឆាកនីមួយៗ និងការផ្លាស់ប្ដូរពេលនៃការសម្ដែងនោះ យើងនឹងមិនគិតដូចការសន្និដ្ឋានខាងលើនេះទេ ។

ជាទូទៅ តួឯកនៃក្រុមសម្ដែងបានចេញមកសម្ដែងនៅឈុតដំបូង ដោយស្លៀកសម្លៀកបំពាក់ជាតួក្សត្រា ។ ជាធម្មតា គាត់នឹងស្លៀកសម្លៀកបំពាក់ដដែល ឬស្រដៀងគ្នានៅក្នុងពេលសម្ដែងល្ខោនដោយសារសម្លៀកបំពាក់នោះ ត្រូវស្លៀកពាក់ដើម្បីលេងពីរឿងបុរាណខ្លះ ឬក៏យ៉ាងហោចណាស់ រឿងដែលកើតឡើងនៅក្នុងពេលនិងទីកន្លែងបុរាណ ។ ការសម្ដែងល្ខោនបានបញ្ចប់នៅប្រហែលជាម៉ោង ១១ ឬពាក់កណ្ដាលយប់ ។ ហើយក្នុងរយៈពេលជាច្រើនម៉ោងបន្តទៅទៀត តួឯកនឹងសម្ដែងជាអ្នកចម្រៀងរ៉ុកនិងរ៉េប នៅក្នុងការប្រគំតន្ត្រីបន្ទាប់មក ជាវីរបុរសនៅក្នុងល្ខោនបុរាហប្រាក់ ។ នៅក្នុងអំឡុងពេលច្រៀងឆ្លើយឆ្លង គាត់បានសម្ដែងជាក្សត្រាវិញ ប៉ុន្តែ នៅទីនេះ គាត់បានសម្ដែងជាមួយនឹងតួក្សត្រាពីរបីនាក់ផ្សេងទៀត ។ តួឯកមិនទាន់ចេញមកសម្ដែងភ្លាមៗ នោះទេ ពីព្រោះគាត់ត្រូវចាំរហូតទាល់តែតួដទៃៗ ទៀតបានឡើងមកលើឆាក និងប្ដូរវេនគ្នាម្ដង ឬច្រើនដង ច្រៀងនិងក្បាច់ដំហានដើងសិន ។ នៅក្នុងឈុតនៃការសម្ដែងនេះ គាត់នៅតែជាអ្នកដ៏គួរឲ្យទាក់ទាញបំផុត ។ ប៉ុន្តែ ការឡើងមកសម្ដែងរបស់គាត់ គឺមានរយៈពេលខ្លីណាស់ ។ គោនអ៊ូ បានសម្ដែងអស់រយៈពេលប្រហែលជា ២០ នាទីប៉ុណ្ណោះក្នុងរយៈពេល ១ ម៉ោងកន្លះ ដែលគេបានផ្ដល់ទៅដល់ក្រុមសម្ដែងរបស់គាត់ ។ ពីអតីតកាល តួឯកនិងបន្តដើរតួជាក្សត្រានៅ «ឈុតចុងក្រោយ» (နောက်ပိုင်း « នោកិប៉ិង៉ះ » អានថា /នក-ប៉ៃន៍/) មួយទៀត បន្ទាប់ពីការសម្ដែងចម្រៀងឆ្លើយឆ្លង ។ «ឈុតចុងក្រោយ» នេះនិទានពីរឿងប្រវត្តិសាស្ត្រ ឬរឿងទាក់ទងនិងសីលធម៌ព្រះពុទ្ធសាសនា ឬរឿងព្រេងមួយចំនួនផ្សេងទៀត ដែលផ្ដល់ជាគតិសីលធម៌ ។ ប៉ុន្តែ ការសម្ដែងរបៀបនេះ គឺកម្រសម្ដែងណាស់នៅពេលបច្ចុប្បន្ននេះ ។ ដូច្នេះ គោនអ៊ូ បានសម្រាកបន្ទាប់ពីការសម្ដែងចុងក្រោយ ២០ នាទីរបស់គាត់ ។ គាត់បានផ្លាស់សម្លៀកបំពាក់ជាក្សត្រារបស់គាត់ចេញ ហើយបានព្យួរនៅលើបន្ទប់ប្ដូរសម្លៀកបំពាក់នៅខណៈដែលក្សត្រាដទៃទៀតបន្តសម្ដែងឲ្យទស្សនិកជនដែលនៅសេសសល់ ទស្សនា ។

ពេលដែលតួឯកបានដើរតួជាក្សត្រាកាន់តែតិចទៅៗ បានបង្ហាញថា ទំនាក់ទំនងរវាងតួឯកនិងបុគ្គលិកលក្ខណៈដ៏ល្អឥតខ្ចោះនៃវណ្ណៈអភិជន បានឃ្លាតឆ្ងាយពីគ្នាកាន់តែច្រើនឡើងៗ ដែរ ។ ម្យ៉ាងវិញទៀត ដោយសារប្រជាជនភូមា ក៏ដូចជាអ្នកដទៃទៀត គិតថា ការស្លៀកពាក់និងការរាំក្បាច់ដំហានដើងរបស់ក្សត្រា ដែលប្រកបទៅដោយកាយវិការនិងរូបរាងសមរម្យ សុភាពរាបសានោះ តំណាងឲ្យអត្តសញ្ញាណនៃបុគ្គលិកលក្ខណៈអភិជននោះ[៧] យើងក៏អាចទាញសន្និដ្ឋានបានថា នៅពេលដែលតួឯកក្សត្រារាំតិចជាងច្រៀងនោះ បុគ្គលិកលក្ខណៈដ៏ល្អឥតខ្ចោះនៃវណ្ណៈអភិជនបានបាត់បង់សារៈសំខាន់របស់វាជាច្រើនហើយ ។ ការសម្ដែងដោយម្ដងកាន់ក្បាលអូប៉ាល័រច្រៀង និងម្ដងទៀតបានដាក់ក្បាលអូប៉ាល័រចុះ ដើម្បីរាំនោះ ជាការពិត តួឯកបានរំកិលនៅចន្លោះលក្ខណៈតួអង្គពីរដែលមានភាពខុសគ្នាបន្តិចមែន ។ នៅក្នុងនាមជាអ្នករបាំ គាត់សម្ដែងម្ដងហើយម្ដងទៀតយ៉ាងល្អបំផុត តាមដែលគាត់អាចសម្ដែងទៅបាននូវប្រពៃណីរបាំភូមាដ៏យូរលង់មួយ ដែលប្រជាជនគិតថា មានប្រភពនៅក្នុងព្រះបរមរាជវាំងតាំងពីមុនសម័យអាណានិគមមកម្ល៉េះ ។ ប៉ុន្តែ ក្នុងនាមជាអ្នកចម្រៀង គាត់មិនដែលច្រៀងចម្រៀងបុរាណណាមួយដែលមានប្រភពដូចគ្នានោះទេ ហើយគាត់ក៏ទំនងជាមិនច្រៀងបទចម្រៀងនៅសតវត្សរ៍ទី ២០ ដែលមានទំនាក់ទំនងជាមួយនឹងអ្នកចម្រៀងល្បីៗ នៅអតីតកាលនោះដែរ ។ ប៉ុន្តែ គាត់ច្រៀងចម្រៀងសម័យ ដែលយករបៀបច្រៀងថ្មសំឡេងតាមស្ទីលយ៉ាងស្រទន់របស់អ្នកចម្រៀងឈ្មោះថា ស៊ីណាត្រា ។ ម្យ៉ាងវិញទៀត ពេលវេលាដែលគាត់

ចំណាយក្នុងការច្រៀង មានរយៈពេលច្រើនជាងពេលដែលគាត់ចំណាយក្នុងការរាំ ។ ដូចលោក ស៊ីណាត្រា និងអ្នកចម្រៀងប្រុសល្បីៗ នៅលើឆាកអន្តរជាតិ តាំងពីជំនាន់គាត់មកអ៊ីចឹង តួឯកនៅក្នុងឈុតនេះ បានសម្តែងនូវលក្ខណៈតួអង្គមនុស្សប្រុស ដែលគួរឲ្យទាក់ទាញនិងរំភើបញាប់ញ័រណាស់ ។ គាត់អាចធ្វើដូច្នេះបាន ក៏ព្រោះតែក្បាលអូប៉ាល័រជួយឲ្យគាត់ច្រៀងបានពុខ្លាំង និងបង្កើតភាពស្និទ្ធស្នាលទៅកាន់ទស្សនិកជនរាប់ពាន់នាក់ ។

ក្រុមអ្នកសម្តែងវ័យចំណាស់ៗ នៅម៉ាន់ដាលេ ច្រើនតែផ្តល់ជាចំណាប់អារម្មណ៍ដល់ខ្ញុំ ថា អ្នកចម្រៀងពីអតីតកាល អាចស្រែកច្រៀងបានខ្លាំងៗណាស់ ។ ជាការពិត ពួកយុវជនដែលចង់ក្លាយទៅជាអ្នកសម្តែង ត្រូវបានគេប្រាប់ថា ពួកគេត្រូវតែអាច «ស្រែកបានខ្លាំងៗ» ប្រសិនបើគេចង់ក្លាយទៅជាតួឯកនៅពេលខាងមុខនោះ ។ ឥឡូវនេះ ក្រុមអ្នកចម្រៀងក្មេងៗ មិនអាចស្រែកច្រៀងខ្លាំងៗ បាននោះទេ ។ ពួកអ្នកចម្រៀងជំនាន់មុនៗ បានបន្ទោសបញ្ហានេះទៅលើក្បាលអូប៉ាល័រ ដោយលើកឡើងថា ពួកក្មេងៗ ដឹងថា ពួកគេអាចពឹងផ្អែកលើក្បាលអូប៉ាល័រ ដើម្បីធ្វើឲ្យសំឡេងពួកគេពុច្បាស់បាន ក៏មិនខំប្រឹងប្រែងហ្វឹកហាត់កម្លាំងសួតរបស់ពួកគេ ឲ្យដូចជាអ្នកជំនាន់មុនៗ ដែលហ្វឹកហាត់បានសម្រេច និងមានអំនួតយ៉ាងខ្លាំងនោះ ។ ប៉ុន្តែ អ្វីដែលពួកគេលើកមកនេះ ក៏បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលផងដែរ ដោយសារវាជារឿងពីរផ្សេងគ្នា ។ «ការស្រែក» អាចនឹងសមរម្យក្នុងការច្រៀងចម្រៀងបុរាណ ។ ប៉ុន្តែ វាប្រហែលជាទៅមិនរួចទេ ក្នុងការច្រៀងចម្រៀងសម័យនៅក្នុងឈុតក្សត្រាសព្វថ្ងៃនោះ ។ ក្បាលអូប៉ាល័រមិនត្រឹមតែជួយដល់អ្នកមានសំឡេងខ្សោយ ដើម្បីកាន់ច្រៀងនោះទេ ប៉ុន្តែវាបានជួយបង្កើតឲ្យមាននូវភាពស្និទ្ធស្នាលទាំងខាងរូបរាងនិងទាំងខាងអារម្មណ៍ នៅក្នុងចំណោមទស្សនិកជនដ៏ច្រើននោះដែរ ។ អ្នកចម្រៀងមានឱកាសច្រើនជាងមុន ដោយកាន់ក្បាលអូប៉ាល័រនៅក្បែរមាត់របស់គេ និងបញ្ចេញនូវទឹកដមសំនៀងយ៉ាងជឿជាក់បំផុត ។

ទំនាក់ទំនងរវាងទស្សនិកជននិងអ្នកសម្តែង បានផ្លាស់ប្តូរនៅក្នុងការច្រៀងឆ្លើយឆ្លងសព្វថ្ងៃនេះ ដោយសារតែក្សត្រាលែងច្រៀងទៅកាន់ និងរៀបរាប់អំពីក្សត្រីទៀតហើយ ។ ឈុតនេះ ហៅថា ការច្រៀងឆ្លើយឆ្លងគ្នា ក៏ដោយសារពីអតីតកាល មានតួក្សត្រានិងព្រះនាងម្ចាស់ រាំម្នាក់ៗ ឬជាគូនៅលើឆាក ហើយច្រៀងរៀបរាប់អំពីអារម្មណ៍របស់ពួកគេ ដូចជារៀបរាប់អំពីសេចក្តីស្នេហាគ្នាទៅវិញទៅមក ភាពសោកសង្រេង និងភាពអន្ទះសាចង់ត្រឡប់ទៅស្រុកកំណើត ជាដើម ។ នៅក្នុងការសម្តែងល្ខោនតុក្កតាអាយ៉ង នៅតែមានការសម្តែងជាលំនាំបុរាណនៅឡើយទេ ។ ប៉ុន្តែ ជាច្រើនខែច្រើនឆ្នាំកន្លងផុតទៅ នៅក្នុងល្ខោនហ្សាក់ពៃ្វ ឈុតដែលគេហៅថា ការច្រៀងឆ្លើយឆ្លងនោះ ឈប់មានការសម្តែងជាគូដូចមុនទៀតហើយ ។ ផ្ទុយទៅវិញ ក្សត្រានីមួយៗ សម្តែងតែម្នាក់ឯង នៅខណៈដែលក្រុមស្ត្រីៗ ជាច្រើន ដែលជាក្សត្រីនោះអង្គុយ ឬឈរជារាងពាក់កណ្តាលរង្វង់ពីក្រោយគាត់ទៅវិញ ។ ស្ត្រីទាំងនោះអាចច្រៀងបន្ទរតាមក្រោយក្សត្រា ឬស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំងនោះ អាចយកក្បាលអូប៉ាល័រនិងច្រៀង នៅពេលដែលក្សត្រាដាក់វាចុះ ដើម្បីរាំពីរបីជំហាននោះ ។ ជារឿយៗ ក្រុមក្សត្រីទាំងនោះ ទះដៃទៅតាមចង្វាក់ភ្លេងផងដែរ ហើយប្រសិនបើពួកគេឈរ ពួកគេអាចរាំជាកាយវិការធម្មតា ។ ប៉ុន្តែ តួនាទីរបស់ពួកគេ គឺជាអ្នកហែហមក្សត្រាច្រើនជាងជាដៃគូនៅក្នុងការច្រៀងឆ្លើយឆ្លងគ្នានោះ ។ ពួកគេមានតួនាទីជាកណ្តាលរវាងអ្នកសម្តែងនិងជាទស្សនិកជនផងដែរ ម្តងជាអ្នកច្រៀងបន្ទរ និងម្តងទៀតជាទស្សនិកជនគាំទ្រដល់ក្សត្រា ។ ពួកគេបានត្រូវទម្លាក់តំណែងពីដៃគូតួឯកមកត្រឹមជាតួនាទីបន្ទាប់បន្សំ គឺជាក្រុមច្រៀងបន្ទរដែលស្លៀកសម្លៀកបំពាក់យ៉ាងសាមញ្ញ ។

នៅពេលដែលក្សត្រានិងក្សត្រីសម្ដែងការច្រៀងឆ្លោះឆ្លងរួមគ្នា ពួកគេបានយកចិត្តទុកដាក់គ្នាទៅវិញទៅមក ហើយយើងជាអ្នកទស្សនា គឺគ្រាន់តែជាអ្នកមើលពួកគេសម្ដែងប៉ុណ្ណោះ ។ ប៉ុន្តែ ឥឡូវនេះ ក្សត្រារាំតិចណាស់ ហើយមិនបានចាប់អារម្មណ៍ទៅលើព្រះនាងម្ចាស់ប៉ុន្មាននោះទេ អ្វីដែលឋិតនៅក្នុងចិត្តរបស់គាត់នោះ គឺការបង្កើតទំនាក់ទំនងជាមួយនឹងអ្នកទស្សនាទៅវិញទេ ។ ដូចដែលខ្ញុំបានផ្តល់ជាយោបល់នៅខាងលើអ៊ីចឹង ទំនាក់ទំនងនេះកើតឡើងដោយសារភាពជិតស្និទ្ធ រួសរាយ រាក់ទាក់ នៅពេលតួឯកច្រៀងថ្នាក់ថ្នមបំពេពួកយើង ដែលជាទស្សនិកជនរបស់គាត់ ហើយធ្វើដូចជាគាត់ជាតួឯកតែម្នាក់ឯងអ៊ីចឹង ។

ការបង្ហាញនូវភាពស្និទ្ធស្នាលនិងការយកចិត្តទុកដាក់គ្នាទៅវិញទៅមកនេះ អាចមើលឃើញកាន់តែច្បាស់ជាងមុន តាមរយៈសកម្មភាពជាធម្មតាមួយ ដែលទស្សនិកជនបានទៅជិតឆាក រួចបំពាក់កម្រងផ្កាទៅលើក្បាលតួឯក ឬប្រគល់បាច់ផ្កាឲ្យគាត់ ឬក៏ដោតលុយជាប់នឹងសម្លៀកបំពាក់របស់គាត់ ។ ទស្សនិកជនបានចាប់ផ្តើមឲ្យប្រាក់រង្វាន់តាំងពីដើមដំបូងនៃការសម្ដែងមកម្ល៉េះ គឺនៅក្នុងឈុតសម្ដែងតន្ត្រីសម័យ ដែលលេងបន្ទាប់ពីការសម្ដែងចាប់ផ្តើមបានបន្តិចមកនោះ ហើយពេលខ្លះទៀត នៅពេលសម្ដែងការប្រគំតន្ត្រីផងដែរ ។ ពួកគេមិនមែនត្រឹមតែផ្តល់រង្វាន់ ឬបាច់ផ្កាដល់តែតួឯកប៉ុណ្ណោះទេ ក្នុងនោះរួមមានទាំងអ្នកសម្ដែងដទៃទៀតផងដែរ ។ (ប៉ុន្តែចង្វាក់ភ្លេងនិងការសម្ដែងយ៉ាងកន្ត្រាក់អារម្មណ៍នៅក្នុងការប្រគំតន្ត្រី បានបង្អាក់ទស្សនិកជនមិនឲ្យមានឱកាសក្នុងការផ្តល់ប្រាក់រង្វាន់បាននោះទេ ។ ពេលខ្លះ ប្រសិនបើគេចង់ផ្តល់ប្រាក់រង្វាន់នៅពេលសម្ដែងនោះ គេក៏អាចធ្វើបានដែរ ប៉ុន្តែមិនសូវសមរម្យទេ ពីព្រោះតួឯកសម្ដែងកំពុងតែសម្ដែងជាតួដែលកំពុងបញ្ចេញកំហឹងយ៉ាងខ្លាំងក្លា ប៉ុន្តែបែរជាចំកោងខ្លួនចុះនិងឱនក្បាលឲ្យគេបំពាក់កម្រងផ្កាម្លិះឲ្យគាត់ទៅវិញនោះ ។) ជាធម្មតា ប្រាក់រង្វាន់ភាគច្រើន គេផ្តល់នៅពេលសម្ដែងការច្រៀងចម្រៀងឆ្លោះឆ្លងគ្នា ហើយតួឯកជាអ្នកដែលទទួលបានចំណែកច្រើនជាងគេទាំងអស់ ។ អ្នកសម្ដែងខ្លះបានបង្ហាញពីការដឹងគុណយ៉ាងខ្លាំងចំពោះអ្នកផ្តល់អំណោយទាំងនោះ ។ រីឯអ្នកខ្លះទៀតវិញ ហាក់ដូចជាគ្រាន់តែទទួលយកប៉ុណ្ណោះ ។ ប្រាក់រង្វាន់ជាទូទៅ គឺគេបានយកទៅប្រគល់ឲ្យដោយផ្ទាល់នៅលើឆាក ដែលសកម្មភាពនេះពុំសូវមានឃើញនៅក្នុងទម្លាប់អ្នកសម្ដែងនៅក្នុងរង្គសាលនៅប្រទេសលោកខាងលិច ។ ការធ្វើយ៉ាងនេះ ឃ្លាតពីរបៀបលេងល្ខោនតាមបែបបុរាណ ហើយផ្ទុយមកវិញ ធ្វើឲ្យការសម្ដែងនេះមានភាពជិតស្និទ្ធ «ពិតប្រាកដ» ដែលប្រកបដោយអនាមិកភាពដែរ ។

## ការសម្ដែងតាមបែបបុរាណ

ការផ្លាស់ប្តូរពីការសម្ដែងតាមបែបបុរាណដ៏យូរលង់មកហើយ ទៅកាន់ការសម្ដែងដូចសព្វថ្ងៃ ដែលខ្ញុំបានរៀបរាប់មកនោះ ក៏បានន័យថា ជាការផ្លាស់ប្តូរពីប្រពៃណីអភិជន ដែលមាននៅក្នុងព្រះបរមរាជវាំង ទៅកាន់ប្រពៃណី «ថ្មី» មួយ ដែលភាគច្រើនមាននៅក្នុងប្រព័ន្ធឃោសនានោះ[៨] ។ ភាពផ្ទុយគ្នានេះមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ។ ការសម្ដែងចំនួនបី ដែលខ្ញុំបានឃើញនៅក្នុងឆ្នាំ ២០០២ បានផ្តល់នូវបច្ច័យខ្លះថា តើការសម្ដែងតាមបែបប្រពៃណីបុរាណពីមុនមានលក្ខណៈយ៉ាងដូចម្ដេច ឬវិវត្តមកសព្វថ្ងៃយ៉ាងដូចម្ដេច ។ នាយកដ្ឋានវិចិត្រសិល្បៈនៃក្រសួងវប្បធម៌មានក្រុមសម្ដែងមួយក្រុម ដែលយើងអាចជួលមកសម្ដែងបាន ហើយយប់មួយនោះ ខ្ញុំបានឃើញពួកគេសម្ដែងនៅក្បែរវត្តមហាមុនីនៅម៉ាន់ដាលេ ។ ខ្ញុំមិនសូវភ្ញាក់ផ្អើលប៉ុន្មាននោះទេ នៅពេលពួកគេបានព្យាយាមជៀសវាងមិនសម្ដែងនូវអ្វីដែលជនជាតិភូមាហៅថា បទចម្រៀង «ញាក់កន្ត្រាក់អារម្មណ៍» នោះ

(ប្រជាជនបានបង្ហាញពីភាពខុសគ្នារវាងបទចម្រៀង «ញាក់កន្ទ្រាក់អារម្មណ៍» ដែលមានហ្គីតារ បាស និងចង្វាក់ញាប់ៗ និងបទចម្រៀងសម័យដែលលេងបញ្ចូលគ្នានូវឧបករណ៍តន្ត្រីភូមានិងអេឡិចត្រូនិក ដែលមិនសូវកន្ទ្រាក់ញាប់ញ័រប៉ុន្មានទេ បើទោះបីជាមានសំឡេងបាសខ្លាំងៗ ក៏ដោយ ។) ។ ពួកអ្នកចម្រៀង ច្រៀងចម្រៀងសម័យថ្មីៗ របស់ភូមាជាច្រើនបទ ប៉ុន្តែ ជាធម្មតា បន្ទាប់ពីការសម្តែងល្ខោនចប់ គេនឹងសម្តែងការប្រគំតន្ត្រី ។ ប៉ុន្តែ ពេលនោះ ក្រុមសម្តែងនេះបែរជាទៅជំនួសឲ្យការសម្តែងសៀកទៅវិញ ។ បន្ទាប់មក ចាប់ពីម៉ោង ២ រហូតដល់ម៉ោង ៤ ភ្លឺ ពួកគេបានសម្តែងរឿងរាមាយណៈ (រឿងរាមកេរ្តិ៍) ។ ក្រុមសម្តែងនោះរាំស្អាតណាស់ ។ ក៏ប៉ុន្តែ ដើម្បីសម្តែងរឿងរាមាយណៈទាំងស្រុងក្នុងរយៈពេលតែ ២ ម៉ោងនោះ ពួកគេត្រូវតែសម្តែងយ៉ាងលឿន ។ ខ្ញុំមើលឃើញពីភាពតានតឹងរវាងរបាំប្រពៃណីដែលត្រូវសម្តែងឡើងទៅតាមជំនាញនៅក្នុងលក្ខណៈបុរាណពិតប្រាកដទៅតាមចង្វាក់ភ្លេងមួយៗ និងគំនាបពេលដើម្បីឲ្យស្របទៅនឹងផែនការដែលកំណត់ឲ្យសម្តែងទៅតាមឈុតនីមួយៗ ។ នៅភូមាក៏ដូចជានៅកន្លែងផ្សេងទៀតដែរ ការផ្លាស់ប្តូរពីចង្វាក់ប្រពៃណីបុរាណដែលសម្តែងតាមក្បួនខ្នាតត្រឹមត្រូវតាមចង្វាក់ភ្លេង ទៅកាន់ការសម្តែងលឿនៗ នាពេលបច្ចុប្បន្ននេះ ដើម្បីធ្វើឲ្យស្របទៅតាមពេលកំណត់នោះ បានបង្ហាញនូវភាពខុសគ្នាយ៉ាងខ្លាំងរវាងការសម្តែងបែបបុរាណនិងទំនើប ។

គំនាបពេលដែលបានធ្វើឲ្យចង្វាក់ភ្លេងលឿនខុសពីមុននៅក្នុងការសម្តែងនោះ មិនមែនបានន័យថា ការសម្តែង ខ្លីជាងមុននោះទេ ។ ការលេងល្ខោនហ្សាក់ពៃ្វ ភាគច្រើននៅតែចំណាយពេលរហូតដល់ថ្ងៃរះ ។ ដូច្នេះ រយៈពេលនៃការសម្តែងអាស្រ័យទៅលើពេលណាព្រះអាទិត្យរះប៉ុណ្ណោះ ។ បើព្រះអាទិត្យកាន់តែឆាប់រះ គេក៏កាន់តែលេងឲ្យលឿនទៅតាមនោះដែរ ។ ប៉ុន្តែ ប្រសិនបើការសម្តែង សម្រាប់ឲ្យអ្នកទេសចរទស្សនានោះ នឹងមានភាពខុសគ្នា ។ ក្រុមសម្តែងតុក្កតាអាយ៉ងដែលសម្តែងសម្រាប់ទេសចរនៅក្នុងរោងល្ខោនតូចមួយនៅក្បែរសណ្ឋាគារសេដូណានៅម៉ាន់ដាលេ បានលេងរឿងជាតកមួយរឿងអស់តែរយៈពេល ៤៥ នាទីប៉ុណ្ណោះ[៩] ។ (ពួកអ្នកឧបត្ថម្ភជប៉ុនជាអ្នកកំណត់ពេលឲ្យពួកគេលេង ពីព្រោះពួកគេចង់អញ្ជើញពួកអ្នកសម្តែងទាំងនោះទៅធ្វើទស្សនកិច្ចទៅប្រទេសជប៉ុន នៅក្នុងឆ្នាំនេះ និងសុំឲ្យអ្នកសម្តែងទាំងនេះ លេងនៅប្រទេសជប៉ុនក្នុងពេលដូចគ្នានេះដែរ) ។ រឿងនេះនិយាយអំពីព្រះមហេសីមួយអង្គ ដែលសុំឲ្យព្រះស្វាមីរបស់ព្រះនាងទៅយកបេះដូងរបស់អាចារ្យដ៏ល្បីម្នាក់ នាមវិធុរបណ្ឌិត ។ ក្រុមសម្តែងបានច្រៀង «ចម្រៀងលន្ទង់លន្ទោច» (បែបពោល) ខ្លីៗ ដែលរៀបរាប់អំពីភាពសោកសៅយ៉ាងខ្លាំងក្លា ។ ចម្រៀងលន្ទង់លន្ទោចនោះ (ជាភាសាភូមាហៅថា ငိုချင်း « ងិុខ្យង៍ះ » អានថា /ងោឈិន/) គឺជាប្រភពនៃមោទនភាពនិងការរីករាយយ៉ាងពិសេស នៅក្នុងចំណោមអ្នកចូលចិត្តសិល្បៈបុរាណភូមា ។ បទចម្រៀងទាំងនោះ ពិរោះនិងគួរឲ្យរំភើបណាស់ ។ ប៉ុន្តែ គ្មាននរណាម្នាក់ដែលមានអាយុក្រោម ៤០ ឆ្នាំចាប់អារម្មណ៍រៀនចម្រៀងទាំងនោះទេ ។

ខ្ញុំពិតជាមានឱកាសបានជួបតួឯកក្នុងក្រុមល្ខោនហ្សាក់ពៃ្វ ចំណាស់ពីរនាក់ ដែលចេះច្រៀងបទចម្រៀងទាំងនោះ ។ តួឯកល្បីម្នាក់នៅទសវត្សរ៍ឆ្នាំ ១៩៨០ នោះ មានឈ្មោះថា គោទេនអ៊ោង (ကိုတင်အုန်း « កុិតង៑អុនិះ » អានថា /គោទេនអោង/) ដែលលែងចេញសម្តែងទៀតហើយ ។ គាត់មានអាយុ ៤០ ឆ្នាំជាងហើយ ដូចដែលខ្ញុំបានរៀបរាប់ពីខាងលើរួចមកហើយ សព្វថ្ងៃនេះ ទស្សនិកជនមិនមានចំណាប់អារម្មណ៍ក្នុងការទស្សនាអ្នកសម្តែងអាយុលើសពី ៣០ ឆ្នាំនោះទេ ។ ដូច្នេះ គោទេនអ៊ោង បានចំណាយកម្លាំងរបស់គាត់ ដើម្បីបណ្តុះបណ្តាលក្មួយរបស់គាត់ ឈ្មោះ គោយែម៉ាន់ (ကိုရဲမာန် « កុិរែមានិ » អានថា /គោយែម៉ាន់/) ដែលសព្វថ្ងៃនេះ

ជាអ្នកគ្រប់គ្រងក្រុមសម្ដែង ។ ប៉ុន្តែ គោទេនអ៊ោងរីករាយនឹងសម្ដែង «នៅឈុតចុងក្រោយ» ប្រសិនបើខ្ញុំទៅមើលក្លួយគាត់សម្ដែងនៅទីក្រុងសាគៀន (၈၆ကိုင်း « ចចិកុំង ») ។ ម៉ោង ៤ ព្រឹកជាងទៅហើយ មុនពេលការសម្ដែងឈុតចុងក្រោយបានចាប់ផ្ដើម ។ គោទេនអ៊ោង និងដៃគូរបស់គាត់ ម៉ាមួនមួន (မမွန်မွန် « មម្វនិ ម្វនិ » អានថា /ម៉ាមួនមួន/) សម្ដែងគួរឲ្យទាក់ទាញណាស់នៅក្នុងតួជាប្ដីប្រពន្ធមួយគូ ដែលព្រះឥន្ទ្រាធិរាជបានបណ្ដាលឲ្យមានកូនជាមួយគ្នា បើទោះបីជាគំនិតរបស់ពួកគេផ្ទាល់ គ្រាន់តែចង់រស់នៅជាមួយគ្នាក្នុងនាមជាបងប្អូនប៉ុណ្ណោះ ។ ក្រៅពីការសម្ដែងតុក្កតាអាយ៉ង ការសម្ដែងរបស់ពួកគាត់ ខុសពីការសម្ដែងរបស់អ្នកដទៃទៀត ដែលខ្ញុំបានឃើញ ដោយសារការសម្ដែងរបស់ពួកគាត់ទាំងពាក្យសម្ដី កាយវិការ និងមនោសញ្ចេតនាធ្វើឲ្យយើងមើលទៅដឹងថា គេគ្រាន់តែសម្ដែងប៉ុណ្ណោះ ។ ការសម្ដែងរបស់ពួកគាត់ មិនមានលក្ខណៈដូចជាការសម្ដែងកុន ឬការសម្ដែងល្ខោនប្យាហ្សាក់ដែលបានលេងពីព្រលប់នោះទេ ពីព្រោះការសម្ដែងកុនឬល្ខោនប្យាហ្សាក់ បើទោះបីគ្រាន់តែជាការសម្ដែងក្ដី ក៏មានគេគិតថា «ពិត» ដែរ ។ ប៉ុន្តែ ការសម្ដែងរបស់គោទេនអ៊ោងគឺមានលក្ខណៈបុរាណនិងបរិយាយយ៉ាងល្អិតល្អន់ ។ ម្យ៉ាងវិញទៀត អ្នកសម្ដែង គឺជាអ្នកដែលចេះចាំនូវប្រពៃណីរបស់ពួកគេ តាមរយៈការសិក្សានិងសម្ដែងអស់រយៈពេលជាយូរមកហើយទៀតផង ។ គឺរបៀបសម្ដែងនេះហើយដែលមានលក្ខណៈដូចគ្នានៅក្នុងប្រពៃណីនៃការសម្ដែងអាយ៉ង ហើយដែលហាក់ដូចជាបាត់បង់នៅក្នុងប្រទេសភូមាសព្វថ្ងៃនេះទៅហើយ ។

នៅក្នុងការសម្ដែងនាពេលបច្ចុប្បន្ន តួឯកនៅស្ទើរតែគ្រប់ក្រុម បើទោះបីជាដើរតួជាក្សត្រាក្សត្រីក៏ដោយក៏សម្ដែងជាអ្នកចម្រៀងសម័យ ច្រើនជាងអ្នកចម្រៀង ឬរបាំ ដែលរៀនតាមបែបបុរាណដែរ ។ ម្យ៉ាងវិញទៀតនៅពេលតួឯកទាំងនោះឡើងសម្ដែងជាតួក្សត្រាក្សត្រីនោះ ពួកគេសម្ដែងតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ ដូច្នេះករណីទាំងពីរនេះបានផ្ដល់ជាសំណើថា ភាពទាក់ទាញដែលធ្លាប់ប្រើភ្ជាប់ជាមួយនឹងបុរសអកិជនបានបាត់បង់អស់ជាច្រើនហើយ ។ បើតាមយើងមើលនោះ យើងនឹងឃើញថា តួក្សត្រាហាក់បីដូចជាបានដាក់ជំនួសមកវិញដោយអ្នកចម្រៀងមនោសញ្ចេតនាខកចិត្តរឿងស្នេហា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹង «បុរសសម័យថ្មីឆាប់រំភើបញាប់ញ័រ» នៅប្រទេសលោកខាងលិចដែរ ។

ទោះបីជាយ៉ាងណា ក៏យើងអាចមើលឃើញពីភាពស្រដៀងគ្នាមួយចំនួន រវាងបុគ្គលិកលក្ខណៈរបស់ក្សត្រនិងអ្នកចម្រៀងមនោសញ្ចេតនាដ៏ស្រទន់នោះដែរ ដូចជាអារម្មណ៍និងកាយវិការសុភាពរាបសារម្យទមរបស់ក្សត្រាមានលក្ខណៈដូចគ្នាទៅនឹងអារម្មណ៍និងកាយវិការរបស់អ្នកចម្រៀងមនោសញ្ចេតនាដ៏សែនស្រទន់នោះដែរ ។ ភាពខុសគ្នា គឺស្ថិតត្រង់តែតួឯកចម្រៀងមនោសញ្ចេតនាដ៏សែនស្រទន់ បានផ្ដល់នូវរូបភាពថ្មីមួយទៀតនៃភាពជាបុរសសម័យថ្មី មិនមែនជាបុរសអភិជនសម័យបុរាណនោះទេ ÷ ឋានៈរបស់គាត់មិនមែនបានមកពីភាពចំណាននៅក្នុងអាកប្បកិរិយាសុភាពរាបសា តាមបែបភូមាជាក់លាក់ណាមួយនោះទេ ប៉ុន្តែ បានមកពីភាពចំណានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ គឺធ្វើដូចពិត និងតម្រូវទៅតាមចិត្តទស្សនិកជន ។ ភាពចំណានរបស់គាត់ គឺដូចទៅនឹងអ្វីដែលយើងបានមើលឃើញនៅក្នុងរឿងហូលីវូដអ៊ីចឹង ។ ដូច្នេះ ភាពខុសប្លែកគ្នារវាងតួឯកក្សត្រានិងអ្នកចម្រៀងរ៉ុក គឺនៅតែមានអ៊ីចឹង គឺនៅក្នុងភាពផ្ទុយគ្នារវាងអាកប្បកិរិយាសុភាពរាបសានិងឆាប់ឆេវឆាវ ។ អាកប្បកិរិយាទាំងពីរនេះ នៅតែមានភាពទំនើបមួយដែលដាក់ឲ្យតួឯកឃ្លាតឆ្ងាយចេញអំពីអ្វីទាំងឡាយដែលមានលក្ខណៈបុរាណ និងដែលមើលឃើញមានជាប្រចាំថ្ងៃនោះ ។

កំប៉ុន្តែ លក្ខណៈតួអង្គក្សត្រា បើទោះបីជាប្តូរទៅជាលក្ខណៈតួអង្គអ្នកចម្រៀងមនោសញ្ចេតនាដ៏ស្រទន់ក៏ដោយ ក៏ហាក់ដូចជាស្ថិតនៅក្នុងលំដាប់លេខពីរ បន្ទាប់ពីតួអ្នកចម្រៀងរ៉ុកប៉ុណ្ណោះ ។ គេផ្តល់ម៉ោងសម្តែងយ៉ាងច្រើនដល់ការប្រគំតន្ត្រី ហើយការសម្តែងដែលចាប់ផ្តើមប្រហែលជាពាក់កណ្តាលអធ្រាត្រ នៅពេលដែលមានមនុស្សម្នានៅច្រើន គឺច្រើនជាងពេលសម្តែងចម្រៀងឆ្លោះឆ្លងគ្នានៅម៉ោងប្រហែលបីបួនទៀបភ្លឺនោះទៅទៀត បានធ្វើឲ្យការសម្តែងនេះមានភាពល្បីល្បាញកាន់តែខ្លាំងឡើងៗ នៅក្នុងចំណោមទស្សនិកជនជាច្រើន ។ ដូច្នេះហើយ ទើបបានជាតួឯកសព្វថ្ងៃ តែងតែជ្រើសសម្តែងជាតួនេះនៅម៉ោងពេលនោះឯង ។

នៅពេលតួអង្គក្សត្រានៅក្នុងការច្រៀងឆ្លោះឆ្លងគ្នា បានក្លាយទៅជាអ្នកចម្រៀងសម័យ គាត់មានលក្ខណៈតួអង្គថ្មីៗជាច្រើនទៀត ស្រដៀងគ្នាទៅនឹងតួឯករ៉ុកផង និងជាវីរបុរសនៅក្នុងរឿងល្ខោនផង ។ តាមការយល់ឃើញមួយរបស់ខ្ញុំ ហេតុផលក្នុងការឲ្យតម្លៃផ្សេងគ្នាទៅដល់តួនាទីទាំងនេះ គឺស្ថិតនៅក្នុងតួនាទីដ៏ច្រើនរបស់តួឯក ។ ប្រសិនបើតួនាទីរបស់ព្រះនាងម្ចាស់នៅក្នុងការសម្តែងចម្រៀងឆ្លោះឆ្លងគ្នា បានធ្លាក់ចុះ នោះតួនាទីរបស់តួឯកប្រុសនឹងកើនឡើង ។ គេបានប្រាប់ខ្ញុំថា នៅអតីតកាល បុរសម្នាក់សម្តែងតួជាក្សត្រានៅក្នុងការសម្តែងចម្រៀងឆ្លោះឆ្លងនិងឈុតចុងក្រោយ ប៉ុន្តែ តួផ្សេងទៀត សម្តែងជាតួឯកនៅក្នុងល្ខោនប្យាហ្យាក់ ។ នេះមានន័យថា តួឯកនីមួយៗ ខំប្រឹងហ្វឹកហាត់ជំនាញតែក្នុងប្រភេទនៃការសម្តែងតែមួយប៉ុណ្ណោះ គឺរឿងល្ខោនសម្រាប់តួម្នាក់ ហើយរបាំនិងភ្លេងបុរាណសម្រាប់តួម្នាក់ផ្សេងទៀត ហើយគេអាចសម្រាកបាននៅពេលឈុតផ្សេងទៀតដែលមិនតម្រូវឲ្យពួកគេឡើងសម្តែងនោះ ។ ប៉ុន្តែ សព្វថ្ងៃ ការបែងចែកនូវការទទួលខុសត្រូវបែបនេះ លែងមានទៀតហើយ ។ តួឯកលេចឡើងគ្រប់ឈុតនៃការសម្តែង ហើយដាក់ឈ្មោះរបស់គាត់ទៅកាន់ក្រុមសម្តែងនោះ (គឺជារឿងដែលគេមិនសូវធ្វើនៅក្នុងអតីតកាលទេ) ។ ការដាក់បញ្ចូលតួនាទីជាច្រើនចូលទៅក្នុងតួឯកតែម្នាក់ មានន័យថា តួណាមួយដែលតួឯកខំប្រឹងសម្តែងជាងគេ តួនោះនឹងកំណត់ថា តើបុរសទំនើបប្រភេទណាសំខាន់ជាងគេ (ហើយសព្វថ្ងៃ វាលេចឡើងថា តួឯកដែលទទួលបានជោគជ័យភាគច្រើន គឺអ្នកដែលអាចច្រៀងចម្រៀងប្រជាប្រិយសម័យបាន) ។ បើទោះបីជាដើរតួច្រើនជាងពីអតីតកាលក្តី ក៏ការដាក់បញ្ចូលតួនាទីនេះ បានបញ្ជាក់ផងដែរថា តួអង្គប្រុស គឺនៅតែទទួលបាននូវការចាប់អារម្មណ៍យ៉ាងពិតប្រាកដ និងដូចមុនដដែលទេ ។

## ការសម្តែងជាតួអង្គឆេវឆាវ និងការគ្មានអំណាច

សមាជិកម្នាក់នៃក្រុមសម្តែងរបស់គោនឹ៍អួ ហើយត្រូវជាបងប្រុសគាត់ផងនោះ បានប្រាប់ខ្ញុំថា ក្រុមរបស់គាត់ល្បីឈ្មោះ ដោយសារតែមានការសម្តែងការប្រគំតន្ត្រីល្អបំផុតនៅម៉ាន់ដាលេ ។ ខ្ញុំជឿជាក់ថា ប្រាកដជាមានមនុស្សបដិសេធចំពោះការអះអាងនេះជាមិនខាន ប៉ុន្តែ ជាការពិត ក្នុងចំណោមក្រុមសម្តែង ៤ ដែលខ្ញុំបានឃើញនៅឆ្នាំ ២០០២ ក្រុមសម្តែងរបស់គោនឹ៍អួ គឺជាក្រុមសម្តែងការប្រគំតន្ត្រីដ៏គួរឲ្យចាប់អារម្មណ៍បំផុត ។ អ្នកចម្រៀងជាច្រើន ពិតជាសម្តែងបានល្អមែន ពួកគេបានយកតម្រាប់យ៉ាងចំណានតាមស្ទីលរបស់អ្នកចម្រៀងរែប ដែលពោរពេញទៅដោយកំហឹង ភាពឆេវឆាវ និងចិត្តដាច់ ។ ការសម្តែងរបស់គោនឹ៍អួ គួរឲ្យយកចិត្តទុកដាក់មែន ។ គាត់បានទម្លាក់សក់ក្បាលយ៉ាងក្រាស់របស់គាត់ចុះមកក្រោម ។ គាត់បានដើរមកមុខ ហើយឈរស្រែកច្រៀងដាក់ក្បាលអូប៉ាល័រ ។ បន្ទាប់មក គាត់ដើរយ៉ាងលឿនជុំវិញឆាកមើលទៅពោរពេញដោយកំហឹង ។ អ្នកស្រែកច្រៀង

បន្ទរបស់គាត់ ដែលជាយុវជនវ័យក្មេងបីនាក់ (ក្នុងចំណោមពួកគេនោះ ពីរនាក់ជាអ្នកកំប្លែង ធ្លាប់សម្តែងនៅក្នុងឈុតផ្សេងទៀត) គឺជាអ្នកជំនាញខាងរៀបចំឆាក ហើយពួកគេធ្វើកាយវិការប្រកបដោយភាពឆេវឆាវនិងហិង្សាផងដែរ ។ សរុបមកវិញ ពួកគេរៀបចំការសម្តែងតន្ត្រីរ៉ុកដ៏គួរឲ្យកន្ត្រាក់អារម្មណ៍ណាស់ ។

នៅប្រទេសភូមា ក៏ដូចជានៅប្រទេសលោកខាងលិចដែរ គេបានចាត់ទុកថា អាកប្បកិរិយាឆេវឆាវយ៉ាងខ្លាំងនេះ តំណាងឲ្យអាកប្បកិរិយារបស់មនុស្សប្រុស ។ អ្វីដែលមានន័យថា ជាបុរសនៅក្នុងប្រភេទនេះ គឺចចេសសាហាវ និងមានកម្លាំងខ្លាំង គឺជាបុគ្គលដែលម្ចាស់ការលើខ្លួនឯងយ៉ាងខ្លាំង ។ តួឯកបានត្រាប់តាមអត្តចរិតអ្នកចម្រៀងរ៉ុកនៅពេលសម្តែងការប្រគំតន្ត្រី ដោយដើរតួជាអ្នកមានកំហឹងឆាប់ឆេវឆាវ និងមានសេរីភាពទាំងកាយ-វិការនិងរូបរាង ។ គាត់មិនស្ថិតនៅក្រោមឥទ្ធិពលនៃក្រមសុជីវធម៌ប្រចាំថ្ងៃ ឬច្បាប់របស់រដ្ឋាភិបាលនោះទេ ។ អាកប្បកិរិយានេះហើយ បានបង្កើតឲ្យមាននូវប្រភេទនៃភាពជាបុរសមួយ ដែលពេញនិយមយ៉ាងខ្លាំងនៅក្នុងប្រទេសភូមា ក៏ដូចជានៅកន្លែងផ្សេងទៀតនាពេលបច្ចុប្បន្ននេះ ។ យើងទំនងជាស៊ាំទៅនឹងបុគ្គលិកលក្ខណៈនេះដោយពុំបានដឹងខ្លួនទាល់តែសោះ ។ ប៉ុន្តែ វានឹងជាកំហុសមួយដែលមិនបានពិចារណាទៅលើផលប៉ះពាល់ឬលទ្ធផលមិនល្អនៃការអនុញ្ញាតឲ្យបុគ្គលិកលក្ខណៈនេះកើតមាននៅក្នុងប្រទេសភូមា ។

ជាការពិត បុរសភាគច្រើននៅក្នុងប្រទេសភូមាសព្វថ្ងៃ ជាពិសេស ពួកយុវជនដែលបានទៅមើលការសម្តែងល្ខោនជាច្រើននោះ ពុំមានសិទ្ធិអំណាចអ្វីនោះទេ ។ សេដ្ឋកិច្ចភូមាបានឆ្លងកាត់នូវដំណាក់កាលដែលមានសង្ឃឹមនិងជឿជាក់មួយចំនួន តាំងពីរបបយោធាបានគ្រប់គ្រងប្រទេសនៅក្នុងឆ្នាំ ១៩៦២ មក ។ តាំងពីដើមរហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ របបនេះបានបើកចំហទីផ្សារគ្រប់គ្រាន់ ដើម្បីធ្វើឲ្យមានការបណ្តាក់ទុនបរទេសកើនឡើង ។ ប៉ុន្តែ ភាពទាល់ច្រកនៃនយោបាយដែលកំពុងតែបន្ត រួមទាំងអំពើស៊ីសំណូកពុករលួយ ការមិនមានជំនាញ និងផែនការខាងផ្នែកការិយាធិបតេយ្យច្បាស់លាស់ផងនោះ បានបណ្តាលឲ្យមានអំពើទុច្ចរិតជាទូទៅនៅក្នុងចំណោមអ្នកវិនិយោគទុនដ៏មានសក្តានុពល (និងក្នុងចំណោមពួកដែលប្រព្រឹត្តរួចហើយ ហើយបានឈប់រកស៊ីនិងចាកចេញទៅបាត់នោះ) ។ ចាប់តាំងពីការសរសេរអត្ថបទនេះមក គឺនៅដើមឆ្នាំ ២០០៣ សេដ្ឋកិច្ចស្ថិតនៅក្នុងស្ថានភាពមិនល្អទាល់តែសោះ ដោយរូបិយវត្ថុភូមាលុយក្យាត (ក្យាប « ကျပ် » អានថា /ចាក/) បានធ្លាក់ចុះមកដល់កម្រិតទាបបំផុត ហើយកង្វល់កាន់តែកើនឡើងថែមទៀត នៅពេលអតិផរណានៃតម្លៃលុយនេះ បានធ្វើឲ្យគ្រឿងហូបចុកទាំងឡាយបានឡើងថ្លៃយ៉ាងឆាប់រហ័ស ដែលអាចនឹងធ្វើឲ្យមានការក្រោកប្រឆាំងពីសំណាក់ប្រជាជនទៀតផង ។

ដំណើរការសេដ្ឋកិច្ចនៅទ្រឹង មានន័យថា មានអត្រាអត់ការងារធ្វើច្រើនសម្រាប់ជនជាតិភូមា ។ នៅពេលដូចគ្នានេះដែរ របបគ្រប់គ្រងបានបិទមហាវិទ្យាល័យអស់រយៈពេល ១៥ ឆ្នាំ ។ ក្រោយមក របបនេះបានអនុញ្ញាតឲ្យវិទ្យាស្ថានចាស់ៗ មួយចំនួន បើកទ្វារឡើងវិញ សម្រាប់និស្សិតក្រោយបរិញ្ញាបត្រសិក្សា ប៉ុន្តែ ភាគច្រើនរបបនេះបានផ្តល់ការឧបត្ថម្ភច្រើនជាងសម្រាប់មហាវិទ្យាល័យថ្មីៗ ដែលកសាងនៅឆ្ងាយពីតំបន់ទីក្រុង ដើម្បីធានាឲ្យបានថា គេអាចទប់ស្កាត់ការបះបោររបស់និស្សិតបានយ៉ាងងាយស្រួល ។ ពួកយុវជនភូមា ដែលមានបរិញ្ញាបត្រនិងលុយកាក់ខ្លះ អាចប្រកបរបរជាអ្នកបើករថយន្តឈ្នួល (តាក់ស៊ី) ដើម្បីចិញ្ចឹមជីវិតបាន ។ ប៉ុន្តែ ដោយសារតម្លៃប្រេងនៅទីផ្សារងងឹត បានឡើងយ៉ាងខ្ពស់នោះ ពួកគេបានជួបប្រទះនូវការលំបាកច្រើនឡើងក្នុងការរកកម្រៃពីមុខរបរនេះណាស់ ។ គិតទៅ ចាប់តាំងពីការក្រោកបះបោរ និងចាត់វិធានការរក្សាស្ថិរភាពនយោបាយនៅឆ្នាំ

១៩៨៨ មក មានតែកន្លែងមួយទេដែលសេដ្ឋកិច្ចនៅតែរឹងមាំនោះ គឺហាងតែ ។ ឥឡូវ គេឃើញមានហាងតែកើនឡើងច្រើនជាងពីមុន ពីព្រោះបុរសដែលអត់ការងារធ្វើ និងអ្នកមានការងារធ្វើមួយម្ពាលជាច្រើននាក់ បានចំណាយពេលរាប់ម៉ោងនៅតាមហាងទាំងនោះ ។ ដូចមិត្តភក្តិរបស់ខ្ញុំម្នាក់ដែលមានអាយុ ៣០ ឆ្នាំបានប្រាប់ខ្ញុំ ថា «សម្រាប់ខ្ញុំ រាល់ថ្ងៃ គឺជាថ្ងៃលំហែ[១០]» ។

វិបត្តិសេដ្ឋកិច្ចដែលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនភូមាជាច្រើននោះ បានបង្កឲ្យមានការមិនពេញចិត្តកាន់តែច្រើនឡើងៗ ដោយសារពួកគេមើលឃើញថា មានតែមនុស្សមួយក្តាប់តូចតែប៉ុណ្ណោះ ដែលមានទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ នៅរ៉ង់ហ្គូននិងម៉ាន់ដាលេ គេអាចមើលឃើញចំនួនឡានបានកើនឡើងច្រើនជាងពី ៥ ឬ ១០ ឆ្នាំមុន ។ ជាការពិត ឡានជាច្រើនមិនមែនជាឡានជជុះដែលមានតម្លៃថោកៗ នាំចូលមកពីប្រទេសចិននិងជប៉ុននោះទេ ប៉ុន្តែសុទ្ធតែជាឡានថ្មីក្លីរលោងធុនឡែនដ៍គ្រូស័រ ។ ឡានទាំងនោះ បើកដោយគ្រួសារយោធាដែលមានតួនាទីជាថ្នាក់ដឹកនាំ ឬដោយប្រជាជនដែលទទួលបានផលប្រយោជន៍ពីការបើកចំហផ្នែកសេដ្ឋកិច្ចទីផ្សារសេរី តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ មកម្ល៉េះ ។

ជាការពិត យុវជនភូមាភាគច្រើនមានសង្ឃឹមតិចតួចណាស់ក្នុងការទទួលបាននូវឱកាសមានបាននឹងគេនោះ ព្រោះអ្វីៗ ទាំងអស់ គឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់ជនមួយក្តាប់តូចប៉ុណ្ណោះ ។ ចំណែកឯសិទ្ធិអំណាចនិងសេរីភាពដែលនិយាយក្នុងន័យម្យ៉ាងទៀតថា ភាពឯករាជម្ចាស់ការនោះ ក៏ពួកគេមានតិចតួចដែរ ។ ប៉ុន្តែពួកគេអាចរីករាយជាមួយនឹងការសម្តែងរបស់តួឯករ៉ុកដែលតំណាងឲ្យបំណងប្រាថ្នារបស់ពួកគេបាន ។ ការសម្តែងរបស់តួរឯករ៉ុក បានបង្ហាញទាំងរូបភាពដ៏ឧត្តមរបស់ពួកគេថា ជាបុរសមានអំណាចនិងអាចរិះគន់ខ្លាំងៗចំពោះគម្លាតខាងសេដ្ឋកិច្ចខុសគ្នាឆ្ងាយខ្លាំងពេកនៅក្នុងប្រទេសភូមា ។ តួឯករ៉ុក គឺជាអ្នកមានទំនួលខុសត្រូវក្នុងន័យមួយ និងមិនអាចគ្រប់គ្រងខ្លួនឯងក្នុងន័យមួយទៀត ។ រឿងនេះបានបង្កើតនូវសេចក្តីស្រមើស្រមៃដ៏មានឥទ្ធិពលមួយសម្រាប់យុវជន ដើម្បីប្រឈមមុខជាមួយនឹងស្ថានភាពមួយដែលពួកគេមិនអាចកែប្រែបាន ។

មានលក្ខណៈផ្សេងគ្នាជាច្រើនក្នុងការកំណត់ថា អ្វីមួយមានភាពទំនើបឬអត់ ។ ទាំងជនជាតិភូមានិងអ្នកក្រៅផ្សេងទៀត ប្រហែលជាអាចយល់ស្របក្នុងការបញ្ចូលទៅក្នុងបញ្ជីលក្ខណៈនៃភាពទំនើប នូវចំណុចរួមមួយចំនួន ដូចជាស្ថិរភាពសេដ្ឋកិច្ច ដែលប្រហែលជាអាចទទួលបានតាមរយៈការចូលរួមចំណែកយ៉ាងជោគជ័យនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការបំពេញតួនាទីយ៉ាងល្អរបស់រដ្ឋាភិបាល ការយល់ដឹងពីតួនាទីនយោបាយ ការផ្តល់នូវឱកាសក្នុងការទទួលបាននូវការអប់រំ សេរីភាពក្នុងការបញ្ចេញមតិ ឬការរស់នៅនៅតាមទីក្រុងនានា ។ ប៉ុន្តែគ្មានចំណុចណាមួយដែលរៀបរាប់មកនេះ អាចសម្រេចទៅបានដោយងាយស្រួលនៅក្នុងប្រទេសភូមាសព្វថ្ងៃនេះទេ ។ សូម្បីតែអ្នករស់នៅក្នុងទីក្រុងទាំងឡាយយូរមកហើយនៅប្រទេសភូមា ក៏អាចនឹងត្រូវគេបង្ខំឲ្យរើចេញភ្លាមៗ ពីទីក្រុង នៅខណៈដែលស្ថិរភាពសេដ្ឋកិច្ច និងការបំពេញតួនាទីយ៉ាងល្អរបស់រដ្ឋាភិបាល មិនអាចកើតឡើងបាននោះ ។

ប៉ុន្តែ លក្ខណៈមួយនៃភាពទំនើបដែលមនុស្សជាច្រើនអាចទទួលយកបាននោះ គឺការតុបតែង ដូចជារបៀបគេស្លៀកពាក់ របៀបគេធ្វើដំណើរ និងរបៀបគេបង្ហាញខ្លួនជាសាធារណៈ ។ យ៉ាងហោចណាស់ ការសម្តែងដែលតំណាងឲ្យអ្នកទំនើប បានធ្វើឲ្យជនជាតិភូមាជាច្រើន ជាពិសេសពួកយុវជន មានការចាប់អារម្មណ៍យ៉ាងខ្លាំង បើទោះបីជាគេមានឬមិនមានមធ្យោបាយ ឬក៏សេចក្តីក្លាហានក្នុងការធ្វើត្រាប់តាមក៏ដោយ ។ លោក ហ្វ្រឹត

បាននិយាយថា សុបិន គឺជាការបង្ហាញដ៏អាថ៌កំបាំងនៃសេចក្តីប្រាថ្នា និងជាតំណាងដ៏អាថ៌កំបាំងឲ្យការបំពេញសេចក្តីប្រាថ្នានោះហើយ យើងអាចនិយាយដូចគ្នានេះចំពោះការសម្តែងល្ខោនភូមាផងដែរថា ការសម្តែង គឺជាការបង្ហាញដ៏អាថ៌កំបាំងនៃភាពជាបុរសទំនើប ដែលគេស្រមើស្រមៃចង់បាន និងការបង្ហាញដ៏អាថ៌កំបាំងនៃកំហឹងរបស់ប្រជាជនទៅលើការបដិសេធរារាំងមិនឲ្យភាពជាបុរសទំនើបនោះកើតឡើងចំពោះពួកគេ ។

## ការធ្លាក់ចុះរបស់ស្ត្រី

ខ្ញុំបានរៀបរាប់អំពីភាពផ្ទុយគ្នារវាងការសម្តែងតាមបែបបុរាណ ដែលសព្វថ្ងៃមិនសូវមានការយកចិត្តទុកដាក់ច្រើនពីក្រុមសម្តែងល្ខោន និងការសម្តែងបែបថ្មីមួយទៀត ដែលតួឯកក្រុមសម្តែង យកមកលេងនិងកំពុងតែទទួលបាននូវការពេញនិយមនោះ ។ ខ្ញុំបាននិយាយថា ភាពទំនើបដែលជាការសម្តែងបែបថ្មីនោះ បានវាយលុកមកលើអ្នកសម្តែងជនជាតិភូមានិងទស្សនិកជន យ៉ាងហោចណាស់អ្នកសម្តែងនិងទស្សនិកជនដែលយើងអាចមើលឃើញនៅក្នុងការសម្តែងនាពេលបច្ចុប្បន្ននេះ[(១១)] ។ ដូច្នេះ គេអាចនឹងសួរថា តើការគូសបញ្ជាក់របស់ខ្ញុំទៅលើភេទភាវៈ (យេនឌ័រ) មានលក្ខណៈសមស្របដែរឬទេ ហើយថា តើការគូសបញ្ជាក់របស់ខ្ញុំថា អ្វីដែលសំខាន់បំផុតនៅក្នុងការសម្តែងទាំងឡាយ គឺមិនមែនជារបៀបក្លាយខ្លួនទៅជាមនុស្សប្រុសនោះទេ តែជារបៀបក្លាយខ្លួនទៅជាអ្នកទំនើបនោះពិតដែរឬទេ ។ ប៉ុន្តែ រឿងដែលគួរឲ្យចាប់អារម្មណ៍អំពីការសម្តែងសព្វថ្ងៃ ដូចដែលខ្ញុំរៀបរាប់ខ្លះៗ រួចមកហើយ គឺស្ត្រីត្រូវបានគេបញ្ចុះតម្លៃមកត្រឹមតួដែលមានលំដាប់ទី ២ ប៉ុណ្ណោះ ។ ប្រសិនបើការសម្តែងសង្កត់ធ្ងន់ទៅលើភាពទំនើបនោះ គេសំដៅភាគច្រើនទៅលើតែភាពទំនើបៗ របស់តួប្រុសៗ ដែលបានបញ្ចេញមកប៉ុណ្ណោះ មិនមែនរបស់តួស្ត្រីៗ នោះទេ ។ ប្រសិនបើការសម្តែងទាំងនោះបានបង្ហាញនូវភាពជាបុរសជាច្រើនប្រភេទនោះ ភាពជាស្ត្រីគេហាក់ដូចជាមិនបានយកចិត្តទុកដាក់ទេ ។ ដោយហេតុនេះហើយ ភាពទំនើបបានក្លាយទៅជាការបកស្រាយអំពីភាពជាបុរសតែម្យ៉ាងគត់[(១២)] ។

ជាការពិត ស្ត្រីក៏បានសម្តែងនៅក្នុងល្ខោនហ្សាក់ព្វៃផងដែរ ។ ពួកគេបានរាំនៅក្នុងឈុតដំបូងនិងនៅក្នុងការសម្តែងចម្រៀងឆ្លើយឆ្លងគ្នា នៅពេលជិតចប់ការសម្តែងទាំងអស់ ។ ពួកគេបានដើរតួសំខាន់ល្មមដែរនៅក្នុងល្ខោនប្យាហ្សាក ។ ពួកគេច្រៀងនៅអំឡុងពេលលេងតន្ត្រីសម័យបន្តបន្ទាប់គ្នានៅក្នុងការសម្តែងឈុតដំបូង ហើយជាញឹកញាប់ ពួកគេច្រៀងយ៉ាងហោចណាស់ពីរបីបទដែរនៅពេលសម្តែងការប្រគំតន្ត្រី ។ ប៉ុន្តែ ការដាក់កម្រិតព្រំដែនខ្លះ បានបង្កឲ្យមានការលំបាកចំពោះពួកគេ ក្នុងការទទួលបាននូវការគាំទ្រពីទស្សនិកជនក្នុងអំឡុងពេលយូរ ។ ជាដំបូង ពួកគេមិនអាចសម្តែងជាតួកំប្លែងបានទេ ។ បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការសម្តែងសិល្បៈប្រពៃណីនៅកោះជ្វានិងបាលី ជាកន្លែងដែលស្ត្រីជាញឹកញាប់សម្តែងនូវរឿងកំប្លែងគួរឲ្យអស់សំណើច នៅក្នុងតួជាអ្នកបម្រើស្ត្រី និងតួដែលមានឋានៈតូចតាច ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដឹងថា នៅក្នុងប្រទេសភូមា ពុំមានការសម្តែងបែបនេះទាល់តែសោះ ។ នៅក្នុងការសម្តែងល្ខោនប្យាហ្សាក់និងល្ខោនច្រៀង ស្ត្រីបានសម្តែងជានារីគ្រប់លក្ខណ៍ ដែលមានការអៀនខ្មាស ឬក៏យាយផាន់ ឬក៏ជាស្ត្រីរកស៊ីផ្លូវភេទ ។ នៅក្នុងការសម្តែងតន្ត្រីសម័យនិងការប្រគំតន្ត្រី ពួកគេអាចស្លៀកសំពត់ខ្លីនិងស្បែកជើងកវែង ឬសម្លៀកបំពាក់ដទៃទៀត ដែលអ្នកដទៃគិតថា មិនសមរម្យដោយសាររបៀបរាងឬបញ្ចេញសាច់នោះ ។ ហើយនៅក្នុងការសម្តែងពេលដំបូង និងការច្រៀងឆ្លើយឆ្លងគ្នានោះ ពួកគេគឺជាអ្នករាំអម ។ ពួកគេមានសមត្ថភាពគ្រប់គ្រាន់ដូចគ្នានឹងពួកប្រុសៗ ដែរ ។

*ប៉ុន្តែ នៅពេលប្រុសៗ ដើរតួជាអ្នកបម្រើ ពួកគេរីករាយនឹងសេរីភាពជាច្រើន ដូចជាសេរីភាពដែលមើលទៅហាក់ដូចរួសរាយរាក់ទាក់ បើទោះបីជាមិនល្បីឈ្មោះក្តី ប៉ុន្តែស្ត្រីពុំមានសេរីភាពបែបនេះទេ ។*

*បើទោះបីជាយើងចាត់ទុកថា ការណ៍ដែលស្ត្រីមិនអាចសម្តែងជាតួកំប្លែងនៅក្នុងការសម្តែងទស្សនីយភាពសិល្បៈ ដោយសារតែបញ្ហាប្រពៃណីក៏ដោយ ក៏យើងមិនអាចចាត់ទុកដូចគ្នានេះចំពោះការសម្តែងចម្រៀងឆ្លើយឆ្លងគ្នា ដែលក្នុងនោះគេបានទម្លាក់តួនាទីរបស់ក្សត្រីយ៉ាងខ្លាំងនោះទេ ។ ខ្ញុំនឹងលើកយកនូវសម្មតិកម្មពីរមកពិភាក្សាស្តីពីមូលហេតុមានការផ្លាស់ប្តូរបែបនេះនោះ ។ សម្មតិកម្មទី ១ នឹងរៀបរាប់ដោយសង្ខេប នូវអ្វីដែលមិត្តភក្តិភូមាមួយចំនួនបានផ្តល់ជាយោបល់ ដោយពន្យល់ពីមូលហេតុដែលតួនាទីក្សត្រីបានធ្លាក់ចុះ ហើយសម្មតិកម្មទី ២ គឺជាការពន្យល់របស់ខ្ញុំ ប៉ុន្តែមិនសូវជាក់លាក់ប៉ុន្មានទេ*[១៣] *។*

*មិត្តភក្តិជាតិភូមាបានផ្តល់យោបល់ថា អ្នកទស្សនាល្ខោនហ្សាក់ព្វៃ ភាគច្រើនជាស្ត្រី ។ ដោយសារស្ត្រីមានចំណាប់អារម្មណ៍ចង់មើលការសម្តែងរបស់បុរស មិនមែនការសម្តែងរបស់ស្ត្រីគ្នាឯងនោះ ពួកគេបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើតួអគ្គក្សត្រា ប៉ុន្តែតិចតួចប៉ុណ្ណោះទៅលើក្សត្រី ។ ដូច្នេះ ស្ត្រីបានក្លាយទៅជាតួរាយរងប៉ុណ្ណោះនៅក្នុងការសម្តែងការច្រៀងចម្រៀងឆ្លើយឆ្លងគ្នានៅពេលសព្វថ្ងៃនេះ ។ ម្យ៉ាងវិញទៀត មិត្តភក្តិរបស់ខ្ញុំបានបង្ហាញពីភាពផ្ទុយគ្នា រវាងការសម្តែងល្ខោនហ្សាក់ព្វៃជាមួយនឹងការសម្តែងល្ខោនអញៀន (*အငြိမ့် **«អង្រិម្ភ»** អានថា /អញៀន/ មានន័យថា «ទន់, ស្លូតបូត»*) ដែលជាការសម្តែងសិល្បៈដ៏ប្រជាប្រិយផ្សេងមួយទៀត ដែលស្ត្រីបានរាំនិងច្រៀង ប៉ុន្តែប្រុសៗ គ្រាន់តែសម្តែងជាតួកំប្លែងប៉ុណ្ណោះ ។ ខ្ញុំបានឮគេនិយាយថា ការសម្តែងនេះបានទាក់ទាញទស្សនិកជនប្រុសៗ បានយ៉ាងច្រើន ដែលបានជួយពន្យល់ពីមូលហេតុមានតែស្ត្រីជាអ្នករាំ ខណៈពេលដែលប្រុសៗ គ្រាន់តែជាអ្នកលេងកំប្លែងកំដរអារម្មណ៍ ហើយគ្មានតួឯកប្រុសទេ ។*

*មានប្រយោជន៍យ៉ាងច្រើនក្នុងការវិភាគការសម្តែងល្ខោនហ្សាក់ព្វៃ ដោយប្រៀបធៀបទៅនឹងការសម្តែងផ្សេងទៀត ជាពិសេស ការសម្តែងអញៀន ។ ដូចលោក បួរឌីយើ (១៩៩៣) បានចង្អុលបង្ហាញនៅក្នុងការវិភាគរបស់គាត់ថា អក្សរសិល្ប៍ជា «ផ្នែកនៃការបង្កើតវប្បធម៌» អ៊ីចឹង គ្មានការអភិវឌ្ឍនៅក្នុងប្រភេទរឿងមួយកើតឡើងដាច់ដោយឡែក ពីការអភិវឌ្ឍនៅក្នុងប្រភេទរឿងដទៃទៀតនោះទេ ហើយការអះអាងនេះត្រូវទៅនឹងការសម្តែងល្ខោនអញៀន និងការសម្តែងល្ខោនហ្សាក់ព្វៃផងដែរ ។ ប៉ុន្តែ ខ្ញុំមិនទទួលយកគំនិតដែលថា ទស្សនិកជនដែលមកមើលល្ខោនហ្សាក់ព្វៃ គឺជាមនុស្សស្ត្រីភាគច្រើននោះទេ ។ នៅពេលសម្តែងដូចដែលរៀបរាប់ខាងលើនោះក៏មានក្រុមយុវជនទៅទស្សនាយ៉ាងកកកុញដែរ បើទោះបីជាមានទស្សនិកជនអង្គុយនៅក្បែរឆាកភាគច្រើនជាស្ត្រីនិងកុមារក៏ដោយ ។*

*ផ្ទុយទៅវិញ ខ្ញុំគិតថា ស្ត្រីបានបាត់បង់នូវតួនាទីសំខាន់ខ្លះរបស់ខ្លួននៅក្នុងការសម្តែង ដោយសារតែសំណួរថា តើត្រូវរៀបរាប់យ៉ាងដូចម្តេចថា ស្ត្រីភូមាណាម្នាក់តំណាងឲ្យមនុស្សស្ត្រីផងនិងតំណាងឲ្យភាពទំនើបផងនោះនៅតែពុំទាន់បានទទួលចម្លើយច្បាស់លាស់ ។ ប្រសិនបើស្ត្រីភូមាម្នាក់សម្តែងអាកប្បកិរិយានិងស្លៀកពាក់ដូចជាស្ត្រីបរទេស ជាពិសេសដូចយើងឃើញនៅក្នុងខ្សែភាពយន្តនោះ ជនជាតិភូមាភាគច្រើន ប្រុសក្តីស្រីក្តី នឹងទុកនាងនោះថា ជាស្រីពេស្យាជាពុំខាន ។ ប៉ុន្តែ ជាទូទៅ នៅក្នុងផ្ទាំងទស្សនិយភាពសព្វថ្ងៃនេះ ការសម្តែងរបស់តួក្សត្រីដែលមានបុកពាសុភាពរាបសាតាមប្រពៃណីបុរាណ ប្រហែលជាមិនទទួលបាននូវការយកចិត្តទុកដាក់ច្រើនជាងការសម្តែងរបស់ក្សត្រានៅក្នុងប្រពៃណីបុរាណដ៏តឹងរ៉ឹងទេ ។ ដំណោះស្រាយសម្រាប់តួអគ្គក្សត្រា គឺត្រូវផ្ទេរ*

ទៅជាអ្នកចម្រៀងប្រជាប្រិយសម័យ ។ មានអ្នកចម្រៀងប្រជាប្រិយសម័យជាស្ត្រីភូមាជាច្រើនផងដែរ ។ ពួកគេពិតជាបានឡើងច្រៀងនៅក្នុងល្ខោនហ្សាក់ព្វៃមែន សូម្បីតែល្បីតិចជាងអ្នកចម្រៀងប្រុសៗក៏ដោយ ។ ប៉ុន្តែពួកគេមិនអាចឡើងសម្ដែងស្មើមុខស្មើមាត់ជាមួយនឹងតួឯកប្រុសនៅក្នុងការច្រៀងឆ្លើយឆ្លងគ្នាទេ ។ ផ្ទុយទៅវិញពួកគេបានធ្លាក់ចុះមកត្រឹមជាអ្នកសម្ដែងរាយរងប៉ុណ្ណោះ ។ ជាប្រចាំថ្ងៃ ស្រីភូមាត្រូវប្រឈមមុខជាមួយនឹងសំណួរថា តើគេនឹងចិញ្ចឹមជីវិតរបស់ពួកគេយ៉ាងដូចម្ដេចនៅក្នុងស្ថានភាពសព្វថ្ងៃនេះ ពួកគេមិនមែនមានការគាបសង្កត់ឬកន្ទល់តិចជាងពួកប្រុសៗ ភូមាប៉ុន្មានទេ ។ តែការតំណាងឲ្យស្ត្រីនៅលើឆាកបានបង្កឲ្យមានផលវិបាកពិសេសៗមួយចំនួន ។ ដូចបានរៀបរាប់ខាងលើរួចមកហើយ នៅពេលតួឯកនៅក្នុងការប្រគំតន្ត្រីនិងល្ខោនប្យាហ្សាក់សម្ដែងអំពីបុគ្គលិកលក្ខណៈជាបុរសនោះ គឺ គាត់បានសម្ដែងជាអ្នកដែលឯករាជម្ចាស់ការ ចូលចិត្តនៅម្នាក់ឯងនិងពេលខ្លះ មានលក្ខណៈជាបុគ្គលនិយមខុសប្លែកពីបរិដ្ឋានជុំវិញគាត់ ។ តួឯករ៉ុក ដែលពោរពេញដោយកំហឹងបានបង្ហាញរូបភាពនេះយ៉ាងពុះកញ្ជ្រោល ។ តួឯកនៅក្នុងល្ខោនប្យាហ្សាក់ធ្វើដូចគ្នានេះដែរ ប៉ុន្តែមានលក្ខណៈខ្សោយជាង ។ នៅពេលតួឯកនៅក្នុងការសម្ដែងចម្រៀងឆ្លើយឆ្លងគ្នា បានសម្ដែងតែម្នាក់ឯងជាតួអង្គក្សត្រានោះ យើងដែលជាទស្សនិកជន ហាក់ដូចជាដើរតួនាទីជំនួសឲ្យក្សត្រីវិញ ដោយសារតួឯកលែងច្រៀងទៅកាន់ព្រះនាងម្ចាស់ទៀតហើយ ប៉ុន្តែច្រៀងមកកាន់ពួកយើងដែលជាទស្សនិកជនវិញ ។ ភាពតានតឹងរវាងបំណងប្រាថ្នារបស់បុគ្គលម្នាក់ៗ (ជាញឹកញាប់ទាក់ទងនឹងសេចក្ដីស្នេហា) និងចំណងដែលផ្សារភ្ជាប់បុគ្គលម្នាក់ៗទៅកាន់រៀមច្បង គ្រួសារ សហគមន៍ និងកត្តាផ្សេងទៀត បានផ្ដល់នូវចំណោទបញ្ហាមួយដើម្បីជំរុញឲ្យមានការសម្ដែងនៅគ្រប់ទីកន្លែង៖ ជម្លោះរវាងបំណងប្រាថ្នាចង់បានភាពឯករាជម្ចាស់ការ និងបំណងប្រាថ្នាក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងក្រុមញាតិ គឺជារឿងដែលមានពិត ។ ប៉ុន្តែ ការគិតថា ភាពជាអ្នកម្ចាស់ការឯករាជល្អនោះ គឺជាលក្ខណៈសំខាន់ជាងគេនៅក្នុងវប្បធម៌ប្រជាប្រិយរបស់ពួកលោកខាងលិច ហើយនៅក្នុងការលេងល្ខោនហ្សាក់ព្វៃ យ៉ាងហោចណាស់ ការគិតរបៀបនេះបានក្លាយទៅជាផ្នែកដ៏សំខាន់នៃការយល់ដឹងអំពីអ្វីដែលមានន័យថា ទំនើប ដែរ ។ សម្រាប់មនុស្សប្រុស ការសម្ដែងនេះហាក់ដូចជាផ្ដល់នូវជម្រើសជាច្រើនដល់ពួកគេចំណែកឯសម្រាប់ស្ត្រីវិញ ជម្រើសដែលស្ថិតក្នុងចិត្តគំនិតរបស់ពួកគេ មិនត្រូវបានទទួលស្គាល់ទេ ដូច្នេះហើយទើបយើងមិនសូវឃើញមាននៅក្នុងការសម្ដែងទេ ។ ភាពទំនើបនិងភាពជាបុរស បានផ្សារភ្ជាប់គ្នាជាសាច់ឈាមមួយទៅហើយ ។ ប៉ុន្តែ ស្ត្រីនិងភាពទំនើបនៅតែមានឧបសគ្គ ដែលធ្វើមិនឲ្យរលាយជាសាច់ឈាមតែមួយបាននៅឡើយទេ ។

ប្រសិនបើនៅពេលដែលគេនិយាយអំពីភាពទំនើប គេសំដៅភាគច្រើនទៅលើសម្លៀកបំពាក់នោះ របៀបដែលស្ត្រីស្លៀកសម្លៀកបំពាក់នោះ ក៏បានបង្ហាញថា ពួកគេបានចូលរួមនៅក្នុងភាពទំនើបដូចគ្នានឹងប្រុសៗដែរ ។ តាមពិតទៅ ការទាមទារនេះមិនមែនកើតឡើងតែនៅក្នុងប្រទេសភូមាប៉ុណ្ណោះទេ ។ ដូចលោក ស្ទួត អេវ៉េន និងអ្នកស្រី អេលីហ្សាបិថ អេវ៉េន (១៩៩២) បានសរសេរថា នៅក្នុងសតវត្សរ៍ទី ២០ កម្មការិនីចំណាកស្រុកនៅក្នុងទីក្រុងញូយ៉ក បានគិតថា ពួកគេបានជាប់ផុងខ្លួននៅក្នុងរោងចក្រកាត់ដេរនានា ដែលផ្ដល់ប្រាក់កម្រៃថោក ប៉ុន្តែបានបង្ហាញនូវបំណងចង់មានឋានៈល្អនៅក្នុងសង្គម ដោយចំណាយលុយរបស់ខ្លួនទិញសម្លៀកបំពាក់ទើបនឹងចេញថ្មីជាច្រើន ។ បន្ថែមលើសនេះទៅទៀត លោក បាថ៌ះ ចាដារជី (១៩៩៣, ១១៦-១៣៤) បានសរសេរពីរបៀបដែលបុរសនៅអាស៊ីខាងត្បូងបង្ហាញថា ពួកគេបានចូលរួមចំណែកក្នុងពិភពទំនើប ដោយស្លៀកសម្លៀក

បំពាក់តាមបែបពួកលោកខាងលិច ខណៈពេលដែលបង្ហាញថា ស្ត្រីមិនបានធ្វើដូចពួកគេទេ ដោយនៅតែស្លៀកសម្លៀកបំពាក់តាម «បែបប្រពៃណី» ។ ប៉ុន្តែ សម្រាប់ស្ត្រី ការបញ្ចេញជើង ឬសូម្បីតែពាក់អាវអត់ដៃ នៅតែជារឿងដែលនាំឲ្យមានការរិះគន់ និងការប្រាសចាកសីលធម៌នៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។ សូម្បីតែនៅលើឆាក ស្រីមួយចំនួនហាក់ដូចជាមានឆន្ទៈក្នុងការបង្កើតនូវក្រុមមិនលេងខ្លួន ដោយសារការបង្ហាញនូវដងខ្លួនច្រើនពេកនៅកន្លែងសាធារណៈនោះ និងជៀសមិនផុតពីការបង្កឲ្យមានបញ្ហានោះទេ ។ ប្រសិនបើការសម្តែងទាំងឡាយអនុញ្ញាតឲ្យបុរសជាតិកូមាប្រកាន់និងកំណត់អត្តសញ្ញាណខ្លួនគេថា ជាអ្នកទំនើបយ៉ាងហោចណាស់តាមរយៈការស្លៀកពាក់និងការប្រកាន់អាកប្បកិរិយានោះ ស្ត្រីជាតិកូមាពុំមានសូម្បីតែជម្រើសនេះ ។ ហើយនៅពេលការសម្តែងបានកែប្រែឲ្យកាន់តែទំនើបឡើងៗ នោះ តួនាទីរបស់ស្ត្រីបែរជាធ្លាក់ចុះទៅៗ ។

## ភាពជាបុរស សម្ពន្ធភាពផ្លូវភេទ និងព្រះសង្ឃ

ការយល់ថា ឧត្តមគតិនៃភាពជាបុរស មានភាពស្មើគ្នាទៅនឹងភាពទំនើបនិងភាពឯករាជម្ចាស់ការ បានបង្កើតឲ្យមាននូវបញ្ហាផ្ទុយគ្នា ២ គឺ រឿងផ្លូវភេទ និងព្រះសង្ឃ ។ ការគិតថា ភាពជាបុរសទំនើប ដូចជាអ្វីដែលផ្តល់ជាឧទាហរណ៍យ៉ាងល្អបំផុត នៅក្នុងបុគ្គលឯករាជម្ចាស់ការម្នាក់ៗ នៅក្នុងល្ខោនហ្យាក់ព្លៃ ពិតជាបានបង្ហាញឲ្យឃើញថា មានការជាប់ទាក់ទងនឹងរឿងភេទតិចតួចប៉ុណ្ណោះ ។ សេចក្តីស្នេហាដែលពោរពេញទៅដោយមនោសញ្ចេតនាដែលគេគិតថា មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងវប្បធម៌ប្រជាប្រិយរបស់ពួកលោកខាងលិចនោះ ហាក់ដូចជាមិនសូវមានសារៈសំខាន់ដូចគ្នានៅក្នុងល្ខោនហ្យាក់ព្លៃទេ ។ អាចមានឈុតខ្លះ ដូចគ្នាមែន ប៉ុន្តែមិនមែនជាអត្ថន័យចម្បងនៃការសម្តែងនោះទេ ។ ចំណែកឯនៅក្នុងការប្រគំតន្ត្រី អ្នកសម្តែងកូមាក៏បានយល់ពីនិមិត្តរូបនៃហ្គីតារបាស ដូចជាប្រដាប់ភេទដែលពួកគេ ក៏ដូចជាប្រុសៗ ជាច្រើននៅលើលោក បានបញ្ឈឹកនៅពីមុខចន្លោះភ្លៅរបស់ពួកគេដែរ ។ ប៉ុន្តែ នៅក្នុងប្រទេសកូមានិងទីកន្លែងផ្សេងទៀត ដើម្បីធ្វើឲ្យភាពជាបុរសមានភាពឥតខ្ចោះដូចដែលមាននៅក្នុងភាពឯករាជម្ចាស់ការនោះ គឺគេត្រូវកាត់ផ្តាច់នូវរាល់ទំនាក់ទំនងផ្លូវភេទចេញ ។ យើងអាចមើលឃើញពីភាពផ្ទុយគ្នានៅទីនេះ ។ ជាធម្មតា ពេលណាគេនិយាយពីកម្លាំងរបស់មនុស្សប្រុស គឺគេចង់សំដៅទៅលើកម្លាំងខាងផ្លូវភេទ ។ ប៉ុន្តែ ការរួមភេទនេះទាមទារនូវដៃគូ និងពឹងពាក់គ្នាទៅវិញទៅមក[១៤] ។ តន្ត្រីរ៉ុកដែលលេងបន្ទុះបង្អាប់ពីស្ត្រី គួរតែមានប្រភពចេញមកពីការផ្ទុយគ្នានេះឯង ÷ នៅពេលមនុស្សប្រុសមានអារម្មណ៍ផ្លូវភេទចំពោះមនុស្សស្រី មានន័យថា មនុស្សស្រីមានអំណាចខ្លះៗ ទៅលើមនុស្សប្រុសនោះ ប៉ុន្តែអំណាចនោះប្រឆាំងទៅនឹងភាពឯករាជម្ចាស់ការដែលជាលក្ខណៈនៃភាពជាបុរស ។ ដូច្នេះ ស្ត្រីជាជាងការដែលត្រូវគេសរសើរឬយកចិត្តនោះ គឺត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការរំលោភតាមពាក្យសម្តី ឬដូចដែលបានកើតឡើងនៅក្នុងល្ខោនហ្យាក់ព្លៃអ៊ីចឹង គឺត្រូវបានគេបញ្ចុះមកត្រឹមតួរាយរងប៉ុណ្ណោះ ។

ជាចុងក្រោយ មានតួអង្គប្រុសសំខាន់មួយទៀតនៅក្នុងសង្គមកូមានោះគឺព្រះសង្ឃ ។ តាមទ្រឹស្តី ព្រះសង្ឃមានភាពខុសគ្នាឆ្ងាយណាស់ពីតួអង្គដែលខ្ញុំបានរៀបរាប់ខាងលើ ។ ម្យ៉ាងទៀត តួអង្គព្រះសង្ឃកម្រចូលរួមនៅក្នុងការសម្តែងល្ខោនហ្យាក់ព្លៃនោះណាស់ ។ អ្នកចម្រៀងប្រជាប្រិយ អ្នកចម្រៀងរ៉េប អ្នកកំប្លែង (ដែលលេងតួតុក្កតាឬអាមាត្យ) ឬអ្នកចម្រៀងមនោសញ្ចេតនាដ៏ស្រទន់ គ្មានភាពជាបុរសណាមួយដែលបានរៀបរាប់មកហើយនេះ មានលក្ខណៈដូចគ្នានឹងព្រះសង្ឃខាងពុទ្ធសាសនា ដែលមានភាពថ្លៃថ្នូរ លះបង់ចោលអស់នូវកិលេសតណ្ហា

និងបញ្ហាលោកិយនោះទេ ។ ថ្វីបើព្រះសង្ឃមួយចំនួន គេនិយាយថា មានភាពទំនើបបុទាន់សម័យ (ជាពិសេសព្រះសង្ឃដែលមានចំណាប់អារម្មណ៍នៅក្នុងគម្រោងអភិវឌ្ឍន៍នានា) ក៏ដោយ ក៏ភាពខុសប្លែកគ្នារវាងភាពទំនើបនិងបុរាណ ហាក់ដូចជាមានសារៈសំខាន់តិចតួចណាស់ចំពោះព្រះសង្ឃ បើប្រៀបធៀបទៅនឹងករណីរបស់គ្រហស្ថនៅក្នុងសង្គមភូមានោះ ។ ស្បង់ពណ៌លឿង ដែលព្រះសង្ឃខាងពុទ្ធសាសនានៅតែប្រើអស់រាប់ពាន់ឆ្នាំមកហើយនោះ អាចបញ្ជាក់បានថា ព្រះសង្ឃមិនបានទទួលឥទ្ធិពលពីម៉ូតសម្លៀកបំពាក់ និងការតុបតែងទៅតាមសម័យកាលនីមួយៗ នោះទេ ។ ម្យ៉ាងវិញទៀត ព្រះសង្ឃមិនត្រឹមតែមិនទទួលឥទ្ធិពលពីសម្លៀកបំពាក់ប៉ុណ្ណោះទេ តែក៏មិនទទួលឥទ្ធិពលពីអ្វីដែលមានន័យថា ជាបុរសនៅក្នុងសង្គមភូមាសព្វថ្ងៃនោះដែរ ។ ភាពផ្ទុយគ្នា ដូចជាភាពធេវធាវប្រឆាំងនឹងភាពសុភាពរាបសារម្យទម ឋានៈខ្ពង់ខ្ពស់ ប្រឆាំងនឹងឋានៈតូចតាច ការធ្វើអ្វីទៅតាមបំណងរបស់ខ្លួនប្រឆាំងនឹងការធ្វើអ្វីដោយអនុលោមទៅតាមច្បាប់គ្រួសារ គឺជាបុគ្គលិកលក្ខណៈដែលបុរសទាំងឡាយបានសម្តែងចេញនៅលើឆាកនៅក្នុងល្ខោនហ្សាក់ព្វៃ ប៉ុន្តែមិនមែនជាបុគ្គលិកលក្ខណៈរបស់ព្រះសង្ឃ ដែលជាតួអង្គដ៏សំខាន់នៅក្នុងសង្គមភូមានោះទេ ។

ប៉ុន្តែ ផ្ទុយគ្នាទៅវិញ តួអង្គព្រះសង្ឃពិតជាបានបង្ហាញនូវភាពស្រដៀងគ្នាខ្លះៗ ជាមួយនឹងភាពជាបុរសទំនើបដូចដែលតួឯកក្នុងល្ខោនហ្សាក់ព្វៃ បានសម្តែងអ៊ីចឹង ពីព្រោះព្រះសង្ឃបានបង្កើតនូវគំរូដ៏យូរអង្វែងមួយនៃភាពឯករាជម្ចាស់ការរបស់បុរស ។ ជាការពិត ព្រះសង្ឃដែលបន្តស្វែងរកការត្រាស់ដឹងតាមរយៈការលះបង់ចោលនូវគ្រឿងជាប់ជំពាក់នៅក្នុងពិភពលោកនោះ បានតំណាងឲ្យតួអង្គដែលមានលក្ខណៈផ្ទុយពីការអះអាងនេះទៅវិញ នៅពេលព្រះអង្គបានពឹងផ្អែកទាំងស្រុងទៅលើពិភពលោកដែលព្រះអង្គមិនចាប់អារម្មណ៍នោះ ។ ប៉ុន្តែ ថ្វីដ្បិតតែមានភាពផ្ទុយគ្នាក្តី ក៏ការខំប្រឹងប្រែងស្វែងរកការត្រាស់ដឹងរបស់ព្រះសង្ឃដោយភាពឯករាជម្ចាស់ការ គឺមានពិតមែនហើយ គេបានយល់ថា ការស្វែងរកការត្រាស់ដឹងដោយភាពឯករាជម្ចាស់ការនេះ ជាបុគ្គលិកលក្ខណៈផ្សេងមួយទៀតនៃតួអង្គបុរសដ៏គួរឲ្យចាប់អារម្មណ៍និងទាក់ទាញ ដែលប្រជាជនភូមាយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ។

តួនាទីរបស់ព្រះសង្ឃនិងតួឯកសម្តែងក្នុងល្ខោនហ្សាក់ព្វៃ មានភាពស្រដៀងគ្នា ដែលនឹកស្មានមិនដល់នោះបានលេចឡើងយ៉ាងច្បាស់ចំពោះខ្ញុំនៅក្នុងការសន្ទនាមួយជាមួយនឹងតួឯកនៃក្រុមល្ខោនហ្សាក់ព្វៃមួយទៀតនៅម៉ាន់ដាលេ ។ នៅក្នុងអាយុ ២០ ឆ្នាំជាង បុរសវ័យជំទង់នេះមានការងារជាអ្នកដឹកនាំក្រុមសម្តែង ដែលរីកចម្រើនយ៉ាងឆាប់រហ័ស និងមានមុខរបរបន្ទាប់បន្សំមួយទៀត ជាអ្នកលក់ដូរសម្លៀកបំពាក់នៅផ្សារធំបំផុតនៅម៉ាន់ដាលេ ។ (គាត់ប្រាប់ខ្ញុំថា គាត់ចាប់យករបរនេះ ដោយសារគិតឃើញថា គ្មានតួឯកណាម្នាក់នៅល្បីបានយូរទេនៅក្នុងការសម្តែងសិល្បៈសព្វថ្ងៃនេះ ។) ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា គាត់សប្បាយចិត្តក្នុងការបួសជាព្រះសង្ឃនៅពេលអនាគតដោយមិនខ្វល់ថា គាត់នឹងធ្វើឲ្យសង្សារគាត់ពិបាកចិត្តប៉ុណ្ណានោះទេ ។ ជាញឹកញាប់ បុរសភូមាចូលចិត្តអះអាងបែបនេះណាស់ តែគេកម្រឃើញកើតឡើងតាមការអះអាងរបស់ពួកគេភ្លាមៗ នោះទេ ។ ប៉ុន្តែ វាគួរឲ្យចាប់អារម្មណ៍ដែរ ដែលតួឯកនោះប្រកាន់យកគោលជំហរយ៉ាងនេះ (ដូច្នេះ គាត់អាចបង្ហាញថា ខ្លួនគាត់ជាអ្នកមានជំនឿមុតមាំចំពោះព្រះពុទ្ធសាសនា) ហើយនៅពេលដូចគ្នានេះដែរ និយាយកែតម្រូវវិញថា មិនអាចទៅបួសបានទេ ដោយសារការបួសនេះ នឹងធ្វើឲ្យសង្សាររបស់គាត់មានការឈឺចាប់យ៉ាងខ្លាំង ។ ដូច្នេះ បើទោះបីជាប្រកបទៅដោយគុណធម៌ក្តី ក៏បំណងប្រាថ្នារបស់មនុស្សប្រុសដើម្បីភាពឯករាជម្ចាស់ការ ជាញឹកញាប់តែងតែបំផ្លាញដោយសារការជាប់ជំពាក់ជាមួយនឹងមនុស្សស្រីដែរ ៕

# ជំពូកទី ២

# ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ អារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមសៀម

*ដោយ ថាម៉ូរ៉ា វ. ហ្វីស្ហែល*

*ច្បាប់ដើមនៃអត្ថបទនេះបានសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "Romances of the Sixth Reign: Gender, Sexuality, and Siamese Nationalism" ។

*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ៖* **ភេទភាពៈនិងអារម្មណ៍ផ្លូវភេទ នៅប្រទេសថៃនាសម័យទំនើប** *(Genders and Sexualities in Modern Thailand)* ។

*រក្សាសិទ្ធិ គ.ស. ១៩៩៩ ដោយគ្រឹះស្ថានបោះពុម្ពស៊ិលក៍វ៉មប៊ុក្ស (ឈៀងហ្មៃ)* *បោះពុម្ពលើកទី ១ គ.ស. ១៩៩៩ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ិលក៍វ៉មប៊ុក្ស ។*

## CHAPTER 2:

### "Romances of the Sixth Reign : Gender, Sexuality, and Siamese Nationalism"

Thamora V. Fishel

*(Genders and Sexualities in Modern Thailand)*

**Copyright © 1999 by Silkworm Books (Chiang Mai).**

**First published in 1999 by Silkworm Books.**

បកប្រែដោយ យិន សំបូរ

# ជំពូកទី ២

# ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ[១] អារម្មណ៍ផ្លូវភេទ[២] និងគំនិតជាតិនិយមសៀម

នៅក្នុងរជ្ជកាលនៃព្រះបាទសម្តេចព្រះមង្កុដក្លៅចៅយូហួ[៣] (ព្រះរាមទី ៦) (ព្រះមហាក្សត្រនៃស្យាមប្រទេស សោយរាជ្យ គ.ស. ១៩១០-១៩២៥) មានការផ្តួចផ្តើមឲ្យមានការផ្លាស់ប្តូរនូវបទដ្ឋានភេទភាវៈ (យេនឌ័រ) និងបទដ្ឋានអារម្មណ៍ផ្លូវភេទ ហើយការផ្តួចផ្តើមនេះបានជះឥទ្ធិពលទៅលើសង្គមថៃអស់រយៈពេលយ៉ាងវែង ។ ការជជែកវែកញែក និងការជជែកតវ៉ា បានផ្តោតលើបញ្ហាឯកពន្ធភាព (ការមានប្រពន្ធតែមួយ) ជាមួយពហុពន្ធភាព (ការមានប្រពន្ធច្រើន) គំនិតស្តីអំពីសោភ័ណភាព ហើយនិងតួនាទីរបស់បុរសនិងស្ត្រី ។ កាលនោះ បើទោះជាព្រះរាមទី ៦ និងមន្ត្រីជាន់ខ្ពស់ បានជជែកវែកញែកអំពីកំណែទម្រង់ចំណងអាពាហ៍ពិពាហ៍ក៏ដោយ ក៏ព្រះអង្គនិងពួកគេ មិនដែលបានតាក់តែងជាច្បាប់ ដើម្បីកំណត់អំពីឥរិយាបថផ្លូវភេទដែរ (ហ៊ុគ្គិង ១៩៧០, ១៦៣-២០០ និង វ៉ែល្ល៉ា ១៩៧៨, ១៥៦-១៥៧) ។ ជំនួសមកវិញ តាមរយៈអត្ថបទនិពន្ធ និងរឿងល្ខោនជាច្រើន ហើយនិងតាមរយៈតួយ៉ាង បង្កើតឡើងដោយវណ្ណៈសង្គមជិតស្និទ្ធទៅនឹងបរមរាជវាំង ព្រះមហាក្សត្រអង្គនេះបានប្រើប្រាស់សិល្បៈនៃការតែងនិពន្ធ និងការសម្តែងជំរុញបង្កើតនូវទម្រង់ទំនាក់ទំនងរវាងភេទថ្មីមួយ ។ ការផ្តោតការចាប់អារម្មណ៍ទៅលើការបង្ហាញ ជាជាងការដាក់ចេញជាច្បាប់កំហិតនេះ មានបង្កប់ទាំងនៅក្នុងរឿងល្ខោនខ្នាតតូច និងទស្សនីយភាពជាសាធារណៈដ៏អស្ចារ្យជាច្រើន ។ ហើយនេះ គឺជាវិធីសាស្ត្ររបស់ព្រះមហាក្សត្រ ដើម្បីអភិវឌ្ឍគំនិតជាតិនិយមរបស់ជនជាតិសៀម ។ កន្លងទៅ មានការសិក្សាជាច្រើន បានពិនិត្យមើលអំពីតួនាទីរបស់ព្រះអង្គក្នុងនាមជាអ្នកអភិវឌ្ឍគំនិតជាតិនិយមរបស់ជនជាតិសៀម (ហ្គ្រីន្ទ ១៩៧១ និង វ៉ែល្ល៉ា ១៩៧៨) ។ ប៉ុន្តែ មិនទាន់មានការសិក្សាណាមួយស្រាវជ្រាវរកមើលអំពីទំនាក់ទំនងរវាងគំនិតជាតិនិយមរបស់ទ្រង់ ជាមួយនឹងការប៉ុនប៉ងរៀបចំឡើងវិញ នូវសុន្ទរីយ៍ផ្លូវភេទ (សិល្បៈទាក់ទាញអារម្មណ៍ផ្លូវភេទ) អាកប្បកិរិយា និងតួនាទីភេទភាវៈរបស់ជនជាតិថៃឡើយ ។

ទំនាក់ទំនងរវាងគំនិតជាតិនិយមនិងការផ្លាស់ប្តូរការយល់ឃើញអំពីភេទភាវៈនិងអារម្មណ៍ផ្លូវភេទ នៅក្នុងរជ្ជកាលទី ៦ នេះ កម្រនឹងមានចែងដោយព្រះមហាក្សត្រ ឬមន្ត្រីរបស់ព្រះអង្គ នៅក្នុងគោលនយោបាយច្បាស់លាស់របស់រដ្ឋាភិបាលណាស់ ។ ម្យ៉ាងទៀត ឯកសាររបស់រដ្ឋាភិបាលមិនសូវមានព័ត៌មានស្តីពីបញ្ហាអត្តសញ្ញាណ បញ្ហាវេទនារម្មណ៍ ហើយនិងបញ្ហាមនោសញ្ចេតនាដ៏ស្មុគស្មាញរបស់មនុស្ស ដែលពាក់ព័ន្ធទៅនឹងគំនិតជាតិនិយមនិងអារម្មណ៍ផ្លូវភេទណាស់ ។ ផ្ទុយទៅវិញ អំណះអំណាងនៃស្នាដៃអក្សរសិល្ប៍ បែរជាមានផ្ទុកនូវភស្តុតាងដ៏ច្រើន ស្តីពីសភាពមិនច្បាស់លាស់ និងសភាពតានតឹង ដែលបង្កើតឡើងដោយសារការផ្លាស់ប្តូរទម្រង់ទំនាក់ទំនងក្នុងគ្រួសារ តួនាទីរបស់ភេទនីមួយៗ គំនិតស្តីអំពីសោភ័ណភាព ហើយព្រមទាំងបង្ហាញយ៉ាងស៊ីជម្រៅ អំពីសញ្ញាណលក្ខណៈនៃញាណនិងអារម្មណ៍ ។

អត្ថបទនេះ សិក្សាទៅលើរឿងប្រតិដ្ឋចំនួនពីរ ដែលបានផ្តល់ជាពន្លឺ សម្រាប់ឈ្វេងយល់ពីបញ្ហាភេទភាវៈអារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមក្នុងរជ្ជកាលទី ៦ ។ រឿងទី ១ មានចំណងជើងថា **ហួចៃនាយន្ទុំ** (ហ័ួចៃ

*ជាយហ៊ុម* *ហ័វចៃចាយហនុ៉ំ* *ប៉េះដួងកំលោះ) ។ រឿងនេះ គឺជាខ្សែរឿងភាគ តែងនិពន្ធដោយព្រះរាមទី ៦ ផ្ទាល់ ក្រោមរហស្សនាមថា រាមចិត្តិ* (รามจิตติ) *ក្នុងពេលដែលទ្រង់សោយរាជ្យ ។ រឿងនេះ គេបានចុះផ្សាយជាភាគខ្លីៗ ក្នុងសារព័ត៌មាន* **ឌុសិតសមិត** *(ឌុសិតសមិត) ចាប់ពីថ្ងៃទី ២៣ ខែមេសា រហូតដល់ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ១៩២១ (វីកា ១៩៧៥, ៧៤*[៤]*) ។ នៅក្នុងរឿង* **ហ្វួចៃឆាយនុំ** *មានការពិព័ណ៌នាអំពីរឿងរ៉ាវរបស់កំលោះឈ្មោះ ប្រព័ន្ធ* (ประพันธ์) *ដែលជាយុវជនសៀមម្នាក់ បានបញ្ចប់ការសិក្សានៅលោកខាងលិច ។ ប្រព័ន្ធបានវិលត្រឡប់មកប្រទេសសៀមវិញ បន្ទាប់ពីបានចំណាយពេលជាច្រើនឆ្នាំរៀននៅប្រទេសអង់គ្លេស ។ នៅក្នុងសំបុត្រផ្ដាំផ្ញើឲ្យមិត្តសម្លាញ់ម្នាក់របស់គាត់ ឈ្មោះ ប្រសើដ្ឋ (ប្រះស្រើដ្ឋ* ประเสริฐ*) ដែលរៀនមិនទាន់ចប់នៅអង់គ្លេស ឲ្យខំបញ្ចប់ការសិក្សានោះ ប្រព័ន្ធបានរៀបរាប់អំពីភាពភ័យខ្លាច និងបញ្ហាជាច្រើនក្នុងការសម្របខ្លួនទៅនឹងជីវិតក្នុងប្រទេសសៀម ។ ចំណែករឿងទី ២ មានចំណងជើងថា* **ស៊ីផែនឌិន** *(ស៊ីផែ៉នឌិន* สี่แผ่นดิน *មានន័យថា បួនផែនដី គឺបួនរជ្ជកាល) (លោក តុលាចន្ទ្រ បានបកប្រែរឿននេះជាភាសាអង់គ្លេសក្នុងឆ្នាំ ១៩៨១) ។ រឿងនេះជារឿងប្រលោមលោកបែបវីរកថា និពន្ធដោយអ្នករាជវង្ស (អ្ន.រ.វ.) គឹកប្រ៊ឹទ្ធ ប្រាមោដ្ឋ (ហ៊្មមរាជវង្ស គឹកប្រ៊ឹទ្ធ ប្រាមោដ្ឋ* หม่อมราชวงศ์ คึกฤทธิ์ ปราโมช*) (ដែលអធិប្បាយអំពីជីវិតរស់នៅក្នុងរជ្ជកាលទី ៦ អំពីទស្សនៈរបស់ស្ត្រីវណ្ណៈខ្ពស់ម្នាក់ ដែលមានស្វាមីជាមហាតលិកហ្លួងបម្រើស្ដេចព្រះរាមទី ៦ នៅក្នុងវាំង) ។ ទោះបីជាខ្សែរឿងនេះ បានចុះផ្សាយជាភាគខ្លីៗ តាមរយៈទំព័រកាសែត* **ស្យាមរដ្ឋ** (สยามรัฐ) *នៅក្នុង គ.ស. ១៩៥១ ក៏ដោយ ក៏ខ្សែរឿងទាំងមូលផ្អែកលើការធ្វើបទសម្ភាសន៍ និងការចងចាំរបស់មនុស្សមួយចំនួន ដែលបានឆ្លងកាត់ជីវិតក្នុងសម័យកាលដែលលោកយកមកបរិយាយ*[៥] *។ ជាពិសេសទៅទៀតនោះ អ្នករាជវង្ស គឹកប្រ៊ឹទ្ធ ផ្ទាល់ ក៏បានចំណាយនូវវ័យកុមារភាពរបស់លោក រស់នៅនិងលេងក្នុងព្រះបរមរាជវាំង ក្នុងអំឡុងពេលព្រះរាមទី ៦ ទ្រង់សោយរាជ្យ (ប្រវត្តិ ១៩៧១, ៤៧) ។ ការវិភាគរបស់នាងខ្ញុំទៅលើរឿងទាំងពីរនេះ មានបំណងចង់បង្ហាញឲ្យឃើញថា ការផ្លាស់ប្ដូរនូវការយល់ដឹងអំពីអារម្មណ៍ផ្លូវភេទ និងស្ថានភាពភេទភាវៈក្នុងរជ្ជកាលនៃព្រះរាមទី ៦ មានទំនាក់ទំនងទៅនឹងកិច្ចប្រឹងប្រែងរបស់ព្រះមហាក្សត្រ ដើម្បីជំរុញឲ្យមានសេចក្ដីស្រឡាញ់អត្តសញ្ញាណនិងជាតិថៃ ។*

## ព្រះរាមទី ៦ និងបញ្ហាអត្តសញ្ញាណជាតិ

*នៅក្នុងការសិក្សាអំពីគំនិតជាតិនិយម និងអារម្មណ៍ផ្លូវភេទ នៅក្នុងសង្គមសៀម ព្រះរាមទី ៦ បានទ្រង់លេចឡើងជាតួអង្គដ៏សំខាន់មួយរូប ជាអ្នកសម្ដែងនាំមុខ ជាចាងហ្វាង និងជាអ្នកនិពន្ធគំនិតជាតិនិយម ។ ទោះជារបៀបគ្រប់គ្រងរបស់ព្រះអង្គ ប្រៀបបានទៅនឹងមហាក្សត្រអង្គទំនើបមួយអង្គ ដោយសារព្រះអង្គបានបង្កើតនិងលើកតម្កើងស្ថាប័នជាច្រើន ដូចជា កងខ្លាព្រៃ (កួងស៊ើប៉ា* กองเสือป่า[៦]*) និងសម្ពន្ធ័បាល់ទាត់ ឬនិពន្ធនូវរឿងល្ខោន រឿងប្រលោមលោក និងការរិះគន់តាមស្ថាបត្យកកាជាច្រើនក៏ដោយ ក៏ព្រះអង្គបានបញ្ជ្រះគំនិតជាតិនិយមដោយផ្អែកលើគំនិតនិងទស្សនៈបស្ចិមប្រទេស ។ តាមការពិតទៅ លក្ខណៈនេះបានបង្កើតឡើងដោយព្រះវររាជបិតារបស់ព្រះអង្គ គឺស្ដេច ព្រះចុឡាលង្ករណ៍* (พระจุฬาลงกรณ์) *(ព្រះរាមទី ៥ សោយរាជ្យ គ.ស. ១៨៦៨–១៩១០) ដែលជាអ្នកបញ្ជូនព្រះអង្គម្ចាស់ វជិរាវុធ (ដែលក្រោយមក បានទទួលព្រះបរមនាមក្នុងរាជ្យថា ព្រះបាទសម្ដេចព្រះមង្កុដក្លៅចៅយូហួ គឺព្រះរាមទី ៦ នេះឯង) ទៅសិក្សានៅប្រទេសអង់គ្លេសអស់រយៈកាល ៩ ឆ្នាំ ។ ទ្រង់ វជិរាវុធ បានទទួលការហ្វឹកហ្វឺនផ្នែកកងទ័ពយ៉ាងពិសេសនៅរាជវិទ្យាល័យយោធាសានដ៍ហឺស្ត (សានដ៍ហឺស្ត*

*អាកាដេមី Sandhurst Academy) ហើយបានបន្តការសិក្សានៅសាកលវិទ្យាល័យអក់ស្វឺដ (Oxford) រហូតដល់ឆ្នាំ ១៩០៣ ។ ឆ្នាំនោះហើយ ដែលទ្រង់ត្រូវយាងវិលត្រឡប់មកមាតុប្រទេសវិញ នៅពេលព្រះរៀមរបស់ព្រះអង្គ ដែលជារជ្ជទាយាទ បានសុគត (វ៉េល្ល៉ា ១៩៧៨, ២) ។ ការអប់រំនៅបស្ចិមប្រទេស ដែលព្រះអង្គម្ចាស់ វជិរាវុធ រួមជាមួយសមាជិកបុរសជារាជវង្សានុវង្ស ព្រមទាំងបុត្រគ្រួសារវរជនជាន់ខ្ពស់ដទៃទៀត បានទទួលនោះ ពិតជាដើរតួនាទីយ៉ាងសំខាន់បំផុត នៅក្នុងការគិតអំពីតួនាទីជាស្តេចរបស់ទ្រង់ និងអំពីរបៀបដែលទ្រង់អាចធ្វើទំនើបកម្មសង្គមសៀមឲ្យបានល្អបំផុតនោះ*[៧] *។*

*ការធ្វើទំនើបនីយកម្មក្នុងរជ្ជកាលនៃព្រះចៅ ចុឡាលង្ករណ៍ គឺមានន័យថា ជាការដឹកនាំសង្គមសៀមតាមរបៀបរដ្ឋបាលនិងនយោបាយបស្ចិមប្រទេស ដោយមានការកំណត់ផែនទីព្រំដែន រចនាសម្ព័ន្ធរាជការកណ្តាល និងការបង្កើតគោលការណ៍ជេដ្ឋភាពក្នុងការស្នងរាជ្យសម្បត្តិ (ឲ្យព្រះរាជបុត្រច្បងឡើងសោយរាជ្យ គឺពុំមានការជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ) ដើម្បីធានាឲ្យមានភាពរលូនក្នុងការឡើងគ្រងរាជ្យ (ហ្គ្រីន្ទ ១៩៧១, ៨១ និង វ៉ៃយ៉ុត្ត ១៩៨២, ២២៤) ។ ដូចដែលលោក អាន់ដឺរសុន (១៩៨៣, ២១) បានកត់សម្គាល់ថា ៖*

> ប្រព័ន្ធថ្មីនេះបាននាំឲ្យក្សត្រមួយអង្គ ដែលមានអាកប្បកិរិយាខុសប្លែក និងស្រឡាញ់ប្រតិព័ទ្ធភេទដូចគ្នា អាចឡើងសោយរាជ្យបាន ។ បើពុំនោះសោត ក្សត្រាអង្គនោះត្រូវបានគេបញ្ចៀសកុំឲ្យមានលទ្ធភាពឡើងសោយរាជ្យតាំងពីពេលទ្រង់នៅក្នុងវ័យកុមារនៅឡើយ ។ ក៏ប៉ុន្តែ ការយល់ព្រមនៃព្រះរាជារបស់ប្រទេសដទៃៗ មួយចំនួនចំពោះការឡើងគ្រងរាជ្យរបស់ព្រះរាមទី ៦ នោះ ត្រូវមានភាពជាក់លាក់តាមរយៈការចូលរួមរបស់ក្សត្រមកពីអង់គ្លេស រុស្ស៊ី ក្រិច ស៊្វីស ដាណឺម៉ាក និងជប៉ុន នៅក្នុងពិធីព្រះរាជាភិសេកព្រះអង្គម្ចាស់វជិរាវុធ ។

*សារៈសំខាន់នៃការយល់ព្រមពីអន្តរជាតិ គឺជាសំណាងមួយសម្រាប់ទ្រង់ វជិរាវុធ ដែលមានព្រះទ័យចង់អនុវត្តទំនើបកម្មនៃជីវិតនិងទំនៀមទម្លាប់របស់ជនជាតិសៀម តាមរបៀបរបបអារ្យធម៌បស្ចិមប្រទេស ។ ពិតណាស់ហើយថា កិច្ចការនេះបានដឹកនាំធ្វើដំបូងឡើងដោយព្រះចៅ ចុឡាលង្ករណ៍ ដែលទ្រង់ចាប់ផ្តើមធ្វើកំណែទម្រង់ដោយលុបបំបាត់ចោលនូវទាសភាពតាមអនុក្រឹត្យរបស់ព្រះអង្គនៅឆ្នាំ ១៨៧០ ក៏ប៉ុន្តែ គឺនៅក្នុងរជ្ជកាលនៃព្រះរាមទី ៦ ទើបមានការផ្តួចផ្តើមកែប្រែបញ្ហាភេទភាវៈ និងអារម្មណ៍ផ្លូវភេទ យ៉ាងយឺតៗ និងពិតប្រាកដ នាំទៅរកការបង្កើតទម្លាប់ឯកពន្ធភាព (ទម្លាប់យកប្រពន្ធតែមួយ) ។*

*តាមលក្ខណៈចិត្តសាស្ត្រ ព្រះរាមទី ៦ ប្រហែលជាប្រើប្រាស់គំនិតជាតិនិយម ជាមធ្យោបាយដើម្បីបង្ក្រាញទាំងបញ្ហាអសន្តិសុខ ដែលកើតឡើង ដោយការចាប់យកវប្បធម៌ពីរផ្សេងគ្នា ហើយនិងដោយសារគោលជំហរមិនទៀងទាត់របស់សៀម ទាក់ទិនទៅនឹងមហាអំណាចបស្ចិមប្រទេស (ព្រះអង្គបានឃើញការគំរាមកំហែងបែបការទូតរបស់បារាំងសែសក្នុងឆ្នាំ ១៨៩៣ មុនពេលព្រះអង្គទ្រង់ចាកចេញព្រះរាជដំណើរទៅបន្តការសិក្សានៅប្រទេសអង់គ្លេស តាំងពីវ័យកុមារភាព) (វ៉េល្ល៉ា ១៩៧៨, ១២) ។ គំនិតជាតិនិយមមិនគ្រាន់តែអាចបង្រួបបង្រួមជនជាតិសៀម ដើម្បីប្រឆាំងចំពោះអ្នកណាដែលរំលោភបំពានទៅលើដែនដីរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងអាចទាក់ទាញស្មារតីស្នេហាជាតិនិងអត្តសញ្ញាណជាតិ ក្នុងការប្រឈមមុខនឹងការផ្លាស់ប្តូរសង្គម ដែលជាឥទ្ធិពលរបស់បស្ចិមប្រទេសនោះទៀតផង ។*

*បទពិសោធន៍នៃទំនាក់ទំនងរបស់ព្រះរាមទី ៦ និងក្រុមវរជនដទៃទៀត ជាមួយពួកបស្ចិមប្រទេស ហើយនិង*

បញ្ហាអន្តោប្រវេសន៍របស់ជនជាតិចិនដ៏ច្រើនលើសលប់ មកលើទឹកដីថៃ តាំងពីដើមទសវត្សរ៍ដំបូងនៃគ្រិស្តសតវត្សរ៍ទី ២០ នោះ បានចោទជាបញ្ហាអំពីអត្តសញ្ញាណកម្មផ្ទាល់ខ្លួន ដែលស្តែងឲ្យឃើញពីភាពស្មុគស្មាញនៃបញ្ហាសញ្ជាតិ បញ្ហាពូជសាសន៍ និងបញ្ហាអារម្មណ៍ផ្លូវភេទ[៨] ។ រឿងរ៉ាវទាំងអស់នេះ គឺជាមូលបទនៃសាច់រឿង **ហ្លួចៃឆាយន្ទុំ** ទាំងមូល ។ ដោយហេតុតែមានបទពិសោធន៍រស់នៅក្រៅប្រទេស ដូចទ្រង់ វជិរាវុធ ទើបតួអង្គក្នុងរឿង ដែលមានឈ្មោះថា ប្រព័ន្ធ បានចោទជាសំណួរឡើងថា «តើពួកយើងជានរណា?», «តើហេតុម្តេចយើងចាំបាច់ជាជនជាតិថៃ?», «តើខ្ញុំឈ្មោះអ្វី?» និង «តើពួកយើងចង់បានអ្វី?» ។ ក្រោយពីពួកយុវជនដែលមានបទពិសោធន៍ដូចកំលោះឈ្មោះ ប្រព័ន្ធ ទាំងនោះ បានត្រឡប់មកមាតុប្រទេសវិញ ជាមួយនឹងការផ្លាស់ប្តូរតាមរយៈបទពិសោធន៍ទាំងនេះ សំណួរនិងភាពច្របូកច្របល់យ៉ាងច្រើនសម្រាប់កែប្រែសង្គមសៀមឲ្យទៅជាសង្គមទំនើបមួយនោះ មិនទៅណាឆ្ងាយពីពួកគេឡើយ ។

នៅក្នុងរឿង **ហ្លួចៃឆាយន្ទុំ** ការបែងចែកអត្តសញ្ញាណ ៣ ផ្សេងគ្នា រវាងអត្តសញ្ញាណជនជាតិសៀមជាមួយភាពជាជនជាតិចិន និងអត្តសញ្ញាណបស្ចិមប្រទេស ត្រូវបានគេលើកឡើងជាបញ្ហានៃការទទួលស្គាល់ខ្លួនឯង និងបញ្ហានៃការប្រាថ្នាចង់បាន ។ នៅក្នុងសេចក្តីសំបុត្រទី ៣ របស់ប្រព័ន្ធ បានរៀបរាប់ពីការកកើតវិបត្តិអត្តសញ្ញាណនៅពេលបានជួបប្អូនប្រុសរបស់គាត់ នៅកំពង់ចំណតមួយនៅទីក្រុងបាងកក នាពេលប្អូនប្រុសឈ្មោះ ប្រភា នោះធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ ។ ប្រពន្ធ័បានសរសេរថា «គ្នាសុំប្រាប់ជាការសម្ងាត់ថា គ្នាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលជួបបាប្រភា ព្រោះឃើញពេលវាធំឡើង មុខមាត់ដូចអាតោហ៊ាបេះបិទ [ភាសាសៀមថា ចេ៊ក "ចិក" ជាពាក្យមិនគួរសមសម្រាប់ហៅជនជាតិចិន] ។ វាប្រាប់ថា នរណាក៏កត់សម្គាល់ថា វាកាន់តែដូចខ្លួនគ្នាផ្ទាល់ខ្លាំងឡើងៗ ធ្វើឲ្យគ្នាតូចចិត្តរហូតដល់គ្នាប្រញាប់ចូលបន្ទប់វិញ និងឆ្លុះកញ្ចក់មើលខ្លួនឯង» (វជិរាវុធ គ្មានចុះឆ្នាំ, ៧) ។ ដោយសារភាពរសាប់រសល់និងការពិនិត្យសម្លឹងមើលខ្លួនឯងនេះហើយ ទើបកំលោះប្រពន្ធ័ស្វះស្វែងរកចម្លើយពីបញ្ហាអត្តសញ្ញាណជាជនជាតិសៀមរបស់គាត់ ។ ដោយមើលឃើញប្អូនប្រុសរបស់គាត់ មានរូបរាងនិងព័ណ៌សម្បុរដូចជាជនជាតិចិន ប្រពន្ធ័ចាប់ផ្តើមជឿងឆ្ងល់ចំពោះលក្ខណៈរូបរាងបែបអឺរ៉ុបរបស់គាត់ ។ ប្រពន្ធ័មានចម្ងល់ថា ៖ «តាមពិត ប្រភាវាស្រដៀងនឹងគ្នាបន្តិចបន្តួច តែគ្នាគ្មានមុខមាត់ដូចអាតោហ៊ាទេ ។ ម្តេចក៏បានជាប្អូនគ្នាមានមុខមាត់ដូចចិនម្ល៉េះ?» (វជិរាវុធ គ្មានចុះឆ្នាំ, ៧) ។

ទោះបីព្រះរាមទី ៦ ទ្រង់ពុំបានបង្ហាញទាល់តែសោះនូវខ្សែស្រឡាយសៀមកាត់ចិនរបស់គ្រួសារប្រពន្ធ័ និងបណ្តាក្រុមគ្រួសារអភិជនសៀមដទៃទៀត ដោយរួមទាំងក្រុមរាជវង្សានុវង្សនោះក៏ដោយ ក៏រឿង **ហ្លួចៃឆាយន្ទុំ** បានបង្ហាញអំពីគំនិតអវិជ្ជមានទៅលើជនជាតិចិនរួចទៅហើយ ។ ប្រពន្ធ័បានបដិសេធមិនព្រមរៀបការជាមួយកូនស្រីពាណិជ្ជករចិន ដែលឪពុកបានផ្សំផ្គុំឲ្យ ព្រោះតែគាត់មានបំណងចង់ស្វែងរកប្រពន្ធម្នាក់ដែលមិនមានលក្ខណៈជាទម្លាប់សៀមពេក ឬអឺរ៉ុបពេកនោះ ។ ការប្រឹងប្រែងរបស់ប្រពន្ធ័ ដើម្បីរកឲ្យឃើញពីគុណតម្លៃនិងអត្តសញ្ញាណជនជាតិសៀម បង្កើតបានជាសាច់រឿងប្រលោមលោកមួយ ដែលដាក់កំហិតឲ្យជនជាតិចិនស្ថិតនៅក្រៅរង្វង់នៃសេចក្តីប្រាថ្នារបស់គាត់ទៅវិញ ។ តាមគំនិតរបស់ប្រពន្ធ័ ស្ត្រីជនជាតិចិនក្មេងៗ គ្រាន់តែចេះស្លៀកពាក់ឆើតឆាយ តុបតែងខ្លួនដោយគ្រឿងអលង្ការមានតម្លៃហួសហេតុ ដែលគេអាចហៅបានថា ជាអ្នកមានស្តុកស្តម្ភថ្មីៗ ប៉ុណ្ណោះ ។ ប្រពន្ធ័មិនត្រឹមតែចាត់ទុកជនជាតិចិនឲ្យនៅក្រៅរង្វង់នៃគំនិតរបស់គាត់ប៉ុណ្ណោះទេ ថែមទាំងមិនបានលាក់លៀមការមើលងាយរបស់គាត់ទៅលើជនជាតិចិនទាល់តែសោះ ។ តាមរយៈសំបុត្រ ដែលគាត់ផ្ញើ

*ទៅប្រទេសអង់គ្លេស គាត់បានប្រៀបធៀបរបៀបស្ត្រីជនជាតិចិនពាក់គ្រឿងពេជ្រថា ទ្រុបទ្រុលដូចដើមគ្រិស្តម៉ាសទៀតផង (វជិរាវុធ គ្មានចុះឆ្នាំ, ១៤) ។ ក្រោយមកទៀត ប្រព័ន្ធបានបញ្ជាក់ពីសេចក្តីមិនពេញចិត្តចំពោះស្ត្រីសៀមដែលមានមារយាទបែបបស្ចិមប្រទេសម្នាក់ ដែលគាត់បម្រុងនឹងយកជាប្រពន្ធ ដោយសារគាត់បានដឹងថា ជីតារបស់នាងជាជនជាតិចិន (វជិរាវុធ គ្មានចុះឆ្នាំ, ៣០) ។ មិនយូរប៉ុន្មាន អាពាហ៍ពិពាហ៍របស់គាត់ត្រូវបានលុបចោលវិញ ។ នៅក្នុងដំណើររឿងនៃការស្វែងរកសេចក្តីស្នេហារបស់គាត់ តួឯកស្រី គឺជាតំណាងឲ្យអត្តសញ្ញាណជាតិសៀម ។ ហើយក្នុងនោះ ភាពជាជនជាតិចិន ត្រូវបានគេបដិសេធមិនរាប់បញ្ចូលទេ តែអត្តសញ្ញាណជាតិកើតពីការបញ្ចូលគ្នារវាងទម្លាប់ជាជនជាតិថៃ និងលក្ខណៈបែបបស្ចិមប្រទេសទៅវិញ ។*

## ស្ត្រីនិងការប្រែក្លាយឲ្យទៅជាបែបបស្ចិមប្រទេស

*បន្ថែមទៅលើការបង្ហាញពីការប្រកួតប្រជែងអំពីអត្តសញ្ញាណ ការពណ៌នាអំពីស្ត្រីនៅក្នុងសាច់រឿង* **ហ្វាចៃនាយនុំ** *បានឆ្លុះបញ្ចាំងនូវការប្រែប្រួលនៃការរៀបចំរបៀបរបបភេទភាវៈ (យេនឌ័រ) និងអារម្មណ៍ផ្លូវភេទនារជ្ជកាលទី ៦ នេះតែម្តង ។ ម្ន.រ.វ. គឹកប្ញទ្ធិ៍ បានឆ្លុះបញ្ចាំងអំពីការប្រែប្រួលដូចគ្នានេះដែរនៅក្នុងរឿង* **ស៊ីផែនឌិន** *។ ជាពិសេសលោកបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ត្រីនាសម័យនោះ ។ នៅក្នុងរឿងទាំងពីរនេះ បញ្ហាឯកពន្ធភាព ទម្រង់បែបផែនទំនាក់ទំនងក្នុងសង្គម លក្ខណៈនៃអាកប្បកិរិយានិងចរិតមារយាទស្ត្រី គឺជាអត្តបដិរូបដ៏សំខាន់របស់ភាពទំនើបនិងការក្លាយទៅជាបែបផែនបស្ចិមប្រទេស ។ បំណងប្រាថ្នាចង់ធ្វើឲ្យសង្គមសៀមក្លាយជាសង្គមទំនើប និងឲ្យបស្ចិមប្រទេសមើលមកសៀមក្នុងលក្ខណៈវិជ្ជមាននោះ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធទៅនឹងគំនិតជាតិនិយមនៅក្នុងរជ្ជកាលទី ៦ ។ ព្រះអង្គបានខិតខំប្រឹងប្រែងបង្ហាញថា ជនជាតិសៀម គឺជាសមាជិកនៃ «ក្រុមគ្រួសារប្រជាជាតិទាំងឡាយ» ។ ការខំប្រឹងប្រែងនេះមិនត្រឹមតែធ្វើតាមរយៈការបង្ហាញអំពីគុណធម៌នៃស្មារតីស្នេហាមាតុភូមិប៉ុណ្ណោះទេ ថែមទាំងអំពីគុណធម៌នៃទំនៀមទម្លាប់សង្គម និងស្ថាប័នសង្គមទៀតផង[៩] ។ ចំពោះបញ្ហាក្រោយនេះហើយ ដែលព្រះរាមទី ៦ បានទ្រង់ប្រើប្រាស់អំណាចនៃសេចក្តីថ្លៃថ្នូររបស់ព្រះអង្គ និងយកតួនាទីជាវរជនគំរូ ដើម្បីកែប្រែនូវទម្លាប់មួយចំនួន ដែលទាក់ទងនឹងអារម្មណ៍ផ្លូវភេទនិងឋានៈរបស់ស្ត្រីភេទ ។*

*តាមការពិត ការប្រឹងប្រែងកែប្រែបែបបទទំនាក់ទំនងផ្លូវភេទ ហើយនិងបែបផែនជីវិត ទៅតាមបែបបស្ចិមប្រទេសនាពេលនោះ មិនមែនកើតឡើងដោយសារឥទ្ធិពលរបស់ព្រះរាជាមួយព្រះអង្គឯងប៉ុណ្ណោះទេ ។ វរជនសៀមមួយចំនួន រួមមានទាំងស្ត្រីខ្លះ ដែលបានទៅសិក្សានៅទ្វីបអឺរ៉ុបនិងសហរដ្ឋអាមេរិក បាននាំមកវិញនូវរបៀបរបបអស់នេះត្រឡប់មកមាតុប្រទេសវិញ ។ តាមការពិតទៅ ក្រុមនៃវណ្ណៈអភិជនបានដើរតួនាទីយ៉ាងសំខាន់រួចទៅហើយ តាមលំនាំនៃបែបផែនជីវិតរបៀបក្រុមគហបតីនៅក្នុងសង្គមសៀម ដូចដែលនាងខ្ញុំនឹងធ្វើការអធិប្បាយដូចខាងក្រោម ។ ចំពោះក្រុមវរជនជាពិសេសនេះ ការធ្វើឲ្យសេដ្ឋកិច្ចសៀមមានភាពទំនើប បាននាំឲ្យមានការបំបែកការងាររវាងបុរសនិងស្ត្រី ស្របពេលដែលណែនាំនូវគំនិតមួយដែលថា បុរសនិងស្ត្រីគួរតែរួមគ្នានៅក្នុងសង្គម[១០] ។ ការបែងចែករវាងទីសាធារណៈនិងឯកជន បានក្លាយជាបញ្ហាប្រឈមនៃការប្រែប្រួលដ៏គួរឲ្យកត់សម្គាល់មួយ ។ ពួកវរជនសៀមត្រូវប្រឈមមុខនឹងការផ្លាស់ប្តូរទំនាក់ទំនងរវាងបុរសនិងស្ត្រី ហើយនិងការជាប់ទាក់ទងរបស់ទំនាក់ទំនងនឹងអត្តសញ្ញាណជាតិផងដែរ (វ៉ៃយុត្ត ១៩៦៩, ១២៦ និង ទ្រៀង ១៩៩០, ១៥២-១៥៤) ។*

ពាល់ការបរិយាយពីតួនាទីរបស់ស្ត្រី ការផ្លាស់ប្ដូរដែលមាននៅក្នុងចិត្តគំនិតរបស់ព្រះចៅព្រះមង្កុដក្លៅ គឺជាការបង្កើតនូវភាពទំនើបទាន់សម័យ និងផ្ដោតទៅលើស្នេហារបស់បុរសនិងស្ត្រី ដើម្បីបន្ទ្រប់លើកិច្ចខំប្រឹងប្រែងកសាងជាតិនៃព្រះអង្គ ។ ដូច្នេះហើយ បានជាព្រះអង្គទ្រង់សង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការកែច្នៃសម្លៀកបំពាក់និងរបៀបតែងសក់របស់ស្ត្រី ឲ្យមានភាពទំនើបតាមគំរូបស្ចិមប្រទេស ។ ព្រះអង្គក៏បានជំរុញលើកទឹកចិត្តឲ្យស្ត្រីចូលរួមនៅក្នុងសកម្មភាពសង្គមផង ជាពិសេស ការចូលរួមក្នុងមុខការសាធារណៈ ឬទៅទស្សនាការសម្ដែងល្ខោនជាមួយស្វាមីរបស់ខ្លួន ។ ប៉ុន្តែ គួរឲ្យអស់សំណើច ព្រោះថា អ្នកហែហមរបស់ព្រះអង្គ ហើយនិងក្រុមខ្លាព្រៃសេះហ្លួង (กรมเสือป่าม้าหลวง ក្រុមស៊ឺប៉ាម៉ាហ្លួង) ដែលជាក្រុមពិសេសបង្កើតឡើងក្នុងគោលបំណងបណ្ដុះគំនិតជាតិនិយមពុំមានសមាជិកជាស្ត្រីនោះទេ ។ ស្ត្រីពិតជាមានតួនាទីនៅក្នុងសកម្មភាពជាតិនិយម ប៉ុន្តែ ពួកគេគ្រាន់តែជាអ្នកបន្ទាប់បន្សំប៉ុណ្ណោះ ។ តួនាទីតូចតាចរបស់ពួកគេ មានដូចជា ធ្វើយុទ្ធនាការរៃអង្គាសថវិកាបែបជួយជាតិ សម្រាប់គាំទ្រកងខ្លាព្រៃ ឬសម្រាប់ទិញនាវាចម្បាំង (វែល្លា ១៩៧៨, ១៥២ និង គឹកបុទ្ធី [១៩៥១] ១៩៨១, ៧៨) ។ មានសកម្មភាពមួយចំនួនទៀត បានបរិយាយនៅក្នុងបទនិពន្ធនៃព្រះអង្គ ដូចជារឿង **បទល្ខោននិយាយរឿង ទ.ត.ល. នន្ទ្រី និង មហាត្មៈ** (បទละครพูด เรื่อง ร.ต.ล. นนทรี และมหาตมะ បទល្ខោនពូតរឿង រ.ត.ល. នន្ទ្រី លេះមហាត្មះ) និងរឿង **បេះដូងអ្នកចម្បាំង** (หัวใจนักรบ ហ៊ូចៃនក់រប) ដែលក្នុងនោះ ស្ត្រីជាធុបឬជាម្ដាយដែលមានតួនាទីជាអ្នកប្រៀនប្រដៅនិងអប់រំកូនពីតម្លៃនៃគំនិតជាតិនិយមជាដើម[១១] ។

ដើម្បីសម្រេចនូវគោលបំណងរបស់ព្រះអង្គតាមផ្លូវច្បាប់ ព្រះរាមទី ៦ ទ្រង់ឈ្វេងយល់យ៉ាងមុតមាំថា ជនជាតិសៀមត្រូវមានគោត្តនាម (នាមត្រកូល) យ៉ាងពិតប្រាកដមួយ ដើម្បីក្លាយជាសមាជិកមួយនៃសង្គមជាតិទំនើប ។ មកដល់ចំណុចនេះ មានតែក្រុមគ្រួសារអភិជនសៀមមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានប្រើប្រាស់គោត្តនាម ។ ការផ្លាស់ប្ដូរបានចាប់ផ្ដើមឡើងបន្ទាប់ពីព្រះអង្គបានអនុម័តច្បាប់មួយ ដែលតម្រូវឲ្យជនជាតិសៀមទាំងអស់ត្រូវតែប្រើប្រាស់នាមត្រកូលរបស់ខ្លួនជាទូទៅ និងនៅលើឯកសារផ្លូវការនានា ។ ចំពោះស្ត្រីវិញ គោត្តនាមរបស់ពួកគេត្រូវយកតាមគោត្តនាមរបស់បុរសមេគ្រួសារ ហើយនាមត្រកូលត្រូវយកបន្តតាមខ្សែខាងឪពុក (វែល្លា ១៩៧៨, ១២៦-១២៨) ។ ព្រះរាមទី ៦ ក៏បានបង្ហាញពីការដាក់បទបញ្ញានៃព្រះអង្គក្នុងការហៅឈ្មោះរួមជាមួយនឹងងារនៅក្នុងការរៀបចំឲ្យមានការប្រើប្រាស់ងារឬបុរិសសព្វនាម ដូចជា «ណាងសាវ» (นางสาว នាងសាវ) សម្រាប់សម្គាល់នារីពុំទាន់រៀបការ ដែលដូចទៅនឹងការប្រើប្រាស់ងារសម្រាប់ពួកស្ត្រីវណ្ណៈខ្ពស់នៅបស្ចិមប្រទេស ។ ជាចុងក្រោយនោះ ព្រះរាមទី ៦ ទ្រង់ជំទាស់អំពីបញ្ហាពហុពន្ធភាព ហើយមិនយូរប៉ុន្មានទ្រង់ក៏បានធ្វើសេចក្ដីព្រាងច្បាប់មួយដែលជំរុញឲ្យមានការអនុវត្តតាមច្បាប់ឯកពន្ធភាពថ្មីមួយ ។ ប៉ុន្តែ ព្រះអង្គបានផ្អាកការព្យាយាមអនុវត្តច្បាប់នេះ ព្រោះថា នៅចុងបញ្ចប់ ព្រះអង្គផ្ទាល់ក៏មិនមានមហេសីតែមួយអង្គដែរ ។ ព្រះអង្គមានទាំងព្រះមហេសីមួយអង្គ និងព្រះស្នំឯកនិងចៅចមជាច្រើននាក់ ក្នុងគោលបំណងមានបុត្របន្តរាជសម្បត្តិ ។ ចំពោះបញ្ហាទាំងនេះ រួមមានបញ្ហាគំនិតអំពីសោភណភាព បញ្ហាតួនាទីរបស់ស្ត្រី បញ្ហាឈ្មោះ និងបញ្ហាឯកពន្ធភាព សុទ្ធតែបង្ហាញឡើងតាមរយៈសាច់រឿង **ឃ្លាំងចៃនាយន្ទុំ** និងរឿង **ស៊ីផែនឌិន** ទាំងអស់ ។

រឿង **ស៊ីផែនឌិន** បានបង្ហាញពីការផ្លាស់ប្ដូរអារម្មណ៍ផ្លូវភេទ និងជីវិតស្ត្រីដែលរស់នៅក្នុងរជ្ជកាលទី ៦ ។ ជីវនារីនៅក្នុងស្នាដៃរបស់ អ្ន.រ.វ. គឹកបុទ្ធី គឺម៉ែផ្លយ (แม่พลอย ម៉េព្លយ) ដែលជាកូនស្រីប្រពន្ធចុងរបស់អភិជនសៀមម្នាក់ ។ ចាប់តាំងពីដើមរឿងមក យើងអាចមើលឃើញពីចំណុចអវិជ្ជមានរបស់ពហុពន្ធភាពរួចទៅហើយ ដូច

ជាករណីខូចចិត្តរបស់ម្ដាយម៉ែផ្លយ ដែលពុំអាចអត់ទ្រាំនឹងស្ថានភាពជីវិតដ៏សោកសៅបាន ។ ប្អូនប្រុសរបស់នាងផ្លយត្រូវបានទុកចោលឯផ្ទះ នៅពេលដែលគេបញ្ជូនផ្លយទៅរស់នៅឯព្រះបរមរាជវាំង ជាកន្លែងដែលម្ដាយរបស់នាងធ្លាប់រស់នៅក្នុងឋានៈជា «នាងស្នងព្រះឱស្ឋ» (ស្រីស្នំក្រមការ) ។ នាងផ្លយបានចំណាយវ័យកុមារភាពរបស់ខ្លួនយ៉ាងសប្បាយរីករាយនៅក្នុងព្រះបរមរាជវាំង ។ អ្នកធ្វើការក្នុងភាគខាងក្នុងនៃវាំងជាស្ត្រីភេទសឹងតែទាំងអស់ ។ ផ្លយគឺជាបរិពាររបស់ព្រះនាងមួយអង្គ (ដែលមិនដែលបានរៀបការ ដោយសារគ្មានបុរសណាមួយរូបមានឋានៈស័ក្តិសម) ។ តាមរយៈតួអង្គនាងផ្លយនេះ យើងអាចដឹងពីរឿងរ៉ាវធាកជីវិតជាអភិជននៅក្នុងព្រះបរមរាជវាំងនារជ្ជកាលព្រះរាមទី ៥ (ព្រះចៅព្រះចុល្លចម ឬព្រះចុឡាលង្ករណ៍) ផង ជាពិសេស អំពីដំណើរជីវិតដែលប្រែប្រួលយឺតៗ និងចាប់ផ្ដើមរលុបបាត់បន្តិចម្ដងៗ ក្នុងពីររជ្ជកាលក្រោយមកទៀត ។ អ្នកប្រេម (เปรม) ដែលជាស្វាមីរបស់ផ្លយ គឺជាមហាតលិកគាល់បម្រើព្រះរាជា ។ ក្រោយមក គាត់បានឡើងឋានៈជាអ្នកធ្វើការនៅរាជការកណ្ដាលវិញ ហើយបានទទួលតំណែងកំពូលនៅក្នុងរជ្ជកាលនៃព្រះរាមទី ៦ នោះ ។ ពេលដែលម៉ែផ្លយគិតថារាជ្យនៃព្រះចៅព្រះចុល្លចម ជាគំរូដ៏ល្អ ប្រេមបែរជាស្ងើចសរសើររជ្ជកាលរបស់សម្ដេចព្រះបាទមង្កុដក្លៅវិញ ។ នៅក្រោមការឧបត្ថម្ភរបស់ទ្រង់ ប្រេមបានទទួលតួនាទីមួយនៅក្នុងក្រុមខ្លាព្រៃសេះហ្លួងហើយ (គឹកប្រ៊ុទ្ធី [១៩៥១] ១៩៨១, ១៨, ៤០-៤១) ព្រមគ្នានេះដែរ ប្រេមក៏ចាប់ផ្ដើមឈ្លក់នឹងរបៀបរបបសម័យថ្មីរបស់រាជវាំង (គឹកប្រ៊ុទ្ធី [១៩៥១] ១៩៨១, ១៨៩) ។ ផ្លយកត់សម្គាល់ថា «អ្នកប្រេមក៏ប្រែប្រួលទៅតាម [បរិយាកាសក្នុងព្រះរាជសំណាក់] ដោយមិនដឹងខ្លួន ។ ការតែងខ្លួននោះ មើលឃើញហ្មត់ចត់ធ្វើស្អាតបាតជាងមុន ។ បុកពាក៏ឃើញរហ័សរហួនទៅរកបែបបារាំង » (គឹកប្រ៊ុទ្ធី [១៩៥១] ១៩៨១, ១៨) ។

នាងបានកត់សម្គាល់យ៉ាងស្រងូតស្រងាត់អំពីចំណុចធ្លាក់ចុះរបស់ព្រះរាជវាំង ហើយនិងសភាពប្រែប្រួលដែលបានផ្លាស់ប្ដូរពីការប្រមូលផ្ដុំតែនៅក្នុងវាំងទៅភាពអ៊ូអរខាងក្រៅវាំងវិញម្ដង ។ នាងបានសម្គាល់ឃើញថា៖ «ឥឡូវនេះ កាលសម័យផ្លាស់ប្ដូរទៅហើយ រាជសំណាក់ផែនដីបច្ចុប្បន្នមិនទាន់មានខាងក្នុង [មិនទាន់មានព្រះមហេសី] ការសំខាន់ផ្សេងៗ រហូតដល់ការជំជុំហ៊ឹកហ៊ាក់ ក៏ប្រកួតប្រជែងនៅខាងមុខ [ខាងក្រៅរាជសំណាក់] ម្នាក់ៗខិតខំធ្វើខ្លួនឲ្យនៅក្នុងក្រសែភ្នែកអ្នកដទៃ» (គឹកប្រ៊ុទ្ធី [១៩៥១] ១៩៨១, ១៩) ។

ក្រោយមក អត្ថាធិប្បាយក្នុងសាច់រឿងទាំងមូល ក៏បង្ហាញអំពីការវិភាគរកមើលថា តើការប្រែប្រួលនេះជះឥទ្ធិពលយ៉ាងដូចម្ដេចទៅលើស្ត្រី? ។

នៅក្នុងអំឡុងពេលពីរបីឆ្នាំដំបូងនៃរជ្ជកាលរបស់ព្រះរាមទី ៦ នាងផ្លយមានតួនាទីជាមេផ្ទះ មើលថែរក្សាកូន ថែរក្សាស្វាមី និងមនុស្សម្នាទាំងឡាយក្នុងផ្ទះរបស់នាង ។ នាងកម្រនឹងចូលរួមក្នុងពិធីមុខការណាមួយណាស់ ។ បើនិយាយជាទូទៅ ស្ត្រីហាក់ដូចជាមានស្ថានភាពថយក្រោយ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ គឺនៅពេលដែលស្ត្រីមានកិច្ចការមមាញឹកយ៉ាងខ្លាំងនៅក្នុងវង្វង់ព្រះបរមរាជវាំង ជាពិសេស នាសម័យក្រោយពេលដែលព្រះមហេសី (ដែលនៅពេលនោះ បានឡើងឋានៈជាព្រះបរមរាជជននី) ដើរតួនាទីជារាជានុសិទ្ធិក្នុងអំឡុងពេលដែលព្រះរាជាទ្រង់ទៅធ្វើរាជទស្សនកិច្ចនៅអ៊ឺរ៉ុប ។ ពេលនេះ កម្មវិធីសំខាន់ៗ ទាំងនោះ ហាក់ដូចជាក្លាយជាកិច្ចការរបស់បុរសអស់ទៅហើយ (គឹកប្រ៊ុទ្ធី [១៩៥១] ១៩៨១, ៣៣) ។

ស្ត្រីមិនត្រឹមតែត្រូវបានកាត់ផ្ដាច់ជីវិតពីរាជវាំងនោះទេ គេថែមទាំងត្រូវប្រឈមមុខនឹងការចាប់ផ្ដើមជីវិតនៅផ្ទះបែបថ្មីមួយទៀត ។ នាងផ្លយបានក្លាយជានិមិត្តរូបនៃគ្រួសារអភិជនជាន់ខ្ពស់ក្នុងស្រុក និងគួរឲ្យគោរព ។

ផ្ទុយបញ្ជូនកូនប្រុសទាំងពីររបស់នាងឲ្យទៅសិក្សានៅអឺរ៉ុបទាំងទឹកភ្នែក ហើយចាត់ចែងការងារផ្ទះយ៉ាងយកចិត្តទុកដាក់ ។ ផ្ទុយគាំទ្រស្វាមីរបស់នាងជានិច្ច ហើយប្ដីរបស់នាង ក៏មានភក្ដីភាពយ៉ាងស្មោះស្ម័គ្រចំពោះនាងវិញដែរ ។ បញ្ហាឯកពន្ធភាពត្រូវបានលើកឡើងម្ដងហើយម្ដងទៀត នៅក្នុងសាច់រឿងទាំងមូល ។ ផ្ទុយមិនប្រាកដក្នុងចិត្តទេថា ប្រេមនឹងមិនយកស្ត្រីក្មេងធ្វើជាប្រពន្ធចុង ថ្វីដ្បិតតែអ្នកប្រេមទទូចថា គាត់មិនដែលមានគំនិតដូច្នេះទេ (គឹកប៊ុទ្ធី [១៩៥១] ១៩៨១, ២០៣) ។ ចេតនារបស់ព្រះមហាក្សត្រក្នុងការថែរក្សាទំនាក់ទំនងឯកពន្ធភាព ត្រូវបានលើកមកអធិប្បាយជាច្រើនដង រួមនឹងចំណេះដឹងដែលទទួលបានពីប្រទេសអង់គ្លេស គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលធ្វើឲ្យព្រះអង្គមានព្រះតម្រិះដូច្នេះ ។ ប៉ុន្តែ ហាក់ដូចជាគ្មាននរណាមួយភ្ញាក់ផ្អើលសោះនៅពេលដែលព្រះអង្គមានព្រះស្នំឯកច្រើននាក់នោះ (គឹកប៊ុទ្ធី [១៩៥១] ១៩៨១, ១០៦) ។ ប្រេមជឿជាក់យ៉ាងខ្លាំងលើសេចក្ដីប្រកាសនៃព្រះរាមទី ៦ អំពីទំនាក់ទំនងរវាងសម្រស់របស់ស្ត្រីនឹងតួនាទីស្ត្រី ។ ហើយរំពេចនោះ គាត់បញ្ចុះបញ្ចូលផ្ទុយឲ្យទុកសក់វែង លាងសម្អាតធ្មេញ ឈប់ស៊ីស្លាជាដើម ហើយឲ្យស្លៀកផាសុិន (ผ้าซิ่น ផាំដ៏ន គឺ សំពត់សម្ពុយ) ជំនួសឲ្យការស្លៀកផានុង (ผ้านุ่ง ផាំនុំង គឺ សំពត់ចងក្បិន) រាល់ពេលចេញទៅចូលរួមក្នុងពិធីសាធារណៈផ្សេងៗ (គឹកប៊ុទ្ធី [១៩៥១] ១៩៨១, ៩៩-១០៥) ។ មិត្តភក្ដិជិតដិតរបស់ផ្ទុយ តែងតែនិយាយលេងថា ផ្ទុយមើលទៅដូចជាស្រីបារាំងអឺចឹង (គឹកប៊ុទ្ធី [១៩៥១] ១៩៨១, ១០១) ។ អ្នកប្រេមលួងលោមប្រពន្ធឲ្យធ្វើដូច្នេះ ក៏ដើម្បីជួយឲ្យគាត់តាមទាន់សង្គមទាន់សម័យ ដែលគាត់អាចនាំប្រពន្ធទៅចូលរួមក្នុងពិធីមុខការផ្សេងៗ តាមរបៀបបស្ចិមប្រទេស (គឹកប៊ុទ្ធី [១៩៥១] ១៩៨១, ៩៩) ។

ការផ្លាស់ប្ដូរស្រដៀងគ្នានៅក្នុងសង្គម បានលើកមកបង្ហាញដូចគ្នានៅក្នុងរឿង **ហ្វូចៃនាយន៍** ។ ពេលវិលត្រឡប់មកស្រុកវិញ កំលោះប្រព័ន្ធបាននិយាយយ៉ាងពេញចិត្តពីការផ្លាស់ប្ដូរដែលបានកើតឡើងទៅលើរបៀបរបបជីវិតស្ត្រីក្នុងអំឡុងពេលដែលគាត់ជាប់រៀននៅបរទេស ។ គាត់ពិតជាចង់ឃើញស្ត្រីទាំងនោះស្លៀកសំពត់សម្ពុយជាងស្លៀកសំពត់ចងក្បិន ហើយចង់ឃើញស្ត្រីទាំងនោះទុកសក់វែងជាជាងទុកសក់ខ្លី ដែលជាម៉ូតនិយមរបស់ជនជាតិសៀមអស់រយៈពេលជាយូរមកហើយនោះ (វជិរាវុធ គ្មានចុះឆ្នាំ, ១៣) ។

ម៉ែឧរ៉ៃ (แม่อุไร ម៉េឧរៃ) ជានារីដែលលោកប្រព័ន្ធចាប់ចិត្តប្រតិព័ទ្ធ បន្ទាប់ពីបានប្រទះឃើញនាងនៅរោងល្ខោនមួយ ដោយសារនាងមាននូវលក្ខណសម្បត្តិទាំងឡាយដែលគាត់ពេញចិត្ត ។ នាងម៉ែឧរ៉ៃ ក៏ដូចជាតួអង្គសំខាន់ៗ ឯទៀតដែរ ត្រូវបានគេថែងឈ្មោះដោយមានការប្រើប្រាស់នូវនាមត្រកូលពេញលេញ ថា ជា «នាងសាវ (นางสาว កញ្ញា) ឧរ៉ៃ ពណ្ណសោភណ (อุไร พรรณโสภณ នាងសាវ ឧរៃ ពរណៃសោភណ)» (វជិរាវុធ គ្មានចុះឆ្នាំ, ១៥) ។

ពេលដែលព្រះរាមទី ៦ ចង់យកលំនាំតាមបស្ចិមប្រទេស ហើយអនុញ្ញាតឲ្យស្ត្រីចូលរួមក្នុងសកម្មភាពសង្គម ការពិពណ៌នាយ៉ាងច្បាស់របស់ព្រះអង្គអំពីនាងឧរ៉ៃ បានបង្ហាញថា តើស្ត្រីគួរតែមានសេរីភាពប៉ុណ្ណា ។ បើធៀបទៅនឹងទំនៀមទម្លាប់សៀមវិញ នាងឧរ៉ៃ ពិតជាមានសេរីភាពណាស់ ។ នាងខុសពីស្ត្រីក្រមុំផ្សេងទៀតនាសម័យនោះ ។ នាងមានសេរីភាពទៅណាមកណាតាមចិត្តចង់ដោយគ្មានការគ្រប់គ្រងពីអ្នកដទៃ ។ នាងពូកែរាំ ហើយថែមទាំងមានរបៀបរបបក្នុងការស្លៀកពាក់បានយ៉ាងស្អាតបាត (មិនដូចទៅនឹងដើមគ្រិស្ដម៉ាសនោះទេ) ហើយថែមទាំងចេះនិយាយនិងអានភាសាអង់គ្លេសបានខ្លះទៀតផង ។ ប្រព័ន្ធបាននិយាយថា ÷

> នាងមិនធ្វើខ្លួនជាខ្មៅចាក់ប្រែងដូចស្រី ៗ សៀមប៉ុន្មានឡើយ និយាយឲ្យខ្លីទៅ នាងស្រដៀងស្រីបារាំងច្រើនជាងស្រីសៀម ។ *(វជិរាវុធ គ្មានចុះឆ្នាំ, ១៧-១៨)*

*កំប៉ុន្តែ លក្ខណៈបែបទាំងនេះ បែរជាបង្កឲ្យមានបញ្ហាទៅវិញ បន្ទាប់ពីនាយប្រពន្ធ័និងនាងឧវ៉ៃបានរៀបការហើយថ្មីៗ (ក្រោមកាលៈទេសៈដ៏ប្រញាប់ប្រញាល់ និងគ្មានការយល់ព្រមពីអាណាព្យាបាល ដោយសារនាងមានផ្ទៃពោះមុនពេលរៀបការ) ។ នាងឧវ៉ៃចាប់ផ្ដើមត្អូញត្អែរ ហើយបានឈ្លោះជាមួយនឹងនាយប្រពន្ធ័នៅតាមទីសាធារណៈ ។ សម្រាប់នាយប្រពន្ធ័វិញ នាងឧវ៉ៃ ហាក់ដូចជាបានចាត់ទុកថា សេរីភាព គឺជាការមិនគោរពប្ដីមិនអាណិតប្ដី នៅពេលនាងមានសេរីភាពសព្វបែបយ៉ាងក្នុងការចាយវាយលុយកាក់របស់ប្ដីនោះ (វជិរាវុធ គ្មានចុះឆ្នាំ, ២៩) ។*

*តួនាងឧវ៉ៃ និងនាងផ្ទួយ បង្ហាញពីរូបភាពពីរផ្ទុយគ្នាស្រឡះ ។ នាងផ្ទួយបានទទួលការចិញ្ចឹមនិងថែរក្សាបានយ៉ាងល្អ ខុសពីនាងឧវ៉ៃ ដែលគ្រូសារនាងត្រូវបានគេពិព័ណ៌នាថា ជា «សាលារៀនបង្វឹកបង្ហាត់សហាយ»* (โรงเรียนฝึกหัดเจ้าชู้ *រែងរៀនផឹកហ័តចៅជូ) (វជិរាវុធ គ្មានចុះឆ្នាំ, ២៥) ។ នៅពេលដែលនាងផ្ទួយពេញចិត្តបែបអភិជនក្នុងស្រុកនឹងការរៀបចំផ្ទះឲ្យមានរបៀបដួសដុលរបស់បេររបស់ផ្ទះនាងកាលពីក្មេង នាងឧវ៉ៃមិនពេញចិត្តចំពោះគំនិតរបស់ប្រពន្ធ័ ដែលថា ពួកគេអាចធ្វើការរួមគ្នា ដើម្បីដួសដុលផ្ទះសម្បែងបាននោះឡើយ ។ នាងផ្ទួយបូជាជីវិតនាងដើម្បីស្វាមី ហើយសម្របសម្រួលទៅតាមសេចក្ដីស្នើដែលកែប្រែនាងឲ្យមានភាពទាន់សម័យ ។ រីឯនាងឧវ៉ៃវិញ មិនសូវយកចិត្តទុកដាក់ចំពោះស្វាមីទេ, ហើយចំពោះការយល់ឃើញរបស់មនុស្សប្រុសវិញ នាងគឺជាស្ត្រីទាន់សម័យម្នាក់ ដែលមានកិរិយាមារយាទមិនល្អ ។ នាងផ្ទួយគិតថា ខ្លួននាងមានសំណាងណាស់ ដែលប្ដីនាងមិនយកប្រពន្ធទៀត ។ ចំណែកនាងឧវ៉ៃវិញ ត្រូវអ្នកនិពន្ធ គឺព្រះរាមទី ៦ ទ្រង់និពន្ធបញ្ចប់ឲ្យជីវិតនាងក្លាយទៅជាស្ត្រីកំណាន់របស់បុរសម្នាក់ ដែលមានប្រពន្ធ ៧ រួចទៅហើយ ។*

*ព្រះចៅព្រះមង្កុដក្លៅ ទ្រង់បានបង្ហាញពីការមើលឃើញចេញពីជ្រុងផ្សេងៗ គ្នាទៅលើប្រធានបទស្ដីអំពីអាពាហ៍ពិពាហ៍និងឯកពន្ធភាពក្នុងរឿង* **ហ្វចៃណាយន្ទុំ** *។ ព្រះអង្គទ្រង់ចាប់ផ្ដើម ដោយរិះគន់ទៅលើបែបបទរបស់ពួកអភិជន ទាក់ទងទៅនឹងបញ្ហាស្ត្រីមានប្ដីហើយ ។ តួឯកប្រពន្ធ័បានត្អូញត្អែរថា នៅពេលដែលប្អូនស្រីរបស់គាត់ឈ្មោះ ប្រពៃ* (ประไพ) *បានរៀបការជាមួយក្សត្រមួយអង្គរួចហើយ គាត់ត្រូវតែចូលគាល់ក្សត្រនោះសិន មុននឹងអាចជួបនាងបាន ។ ប្រពន្ធ័បានសរសេរសំបុត្រទៅពួកម៉ាកគាត់ថា ៖*

> គ្នាសួរអំពីប្រពៃថា « ហេតុអីមិនមកទទួលខ្ញុំផង ? » ទាំងម៉ាក់ប៉ាបើកភ្នែកធំៗ ថា គ្នាធ្វើបារាំងមិនយល់រឿង គួរតែដឹងហើយថា « ប្អូនស្រីឡើងជាម៉ម (អ្នកម្នាង) ហើយ នឹងមកទទួលយ៉ាងណាបាន ? » ។ គ្នាបែរជាស្រឡាំងកាំង ព្រោះមិនដែលគិតថា ការណ៍ដែលស្ត្រីក្លាយជាអ្នកម្នាងរបស់អ្នកអង្គម្ចាស់អញ្ចឹង ក៏ត្រូវលែងជាមនុស្សទៀតនោះហើយ ។ *(វជិរាវុធ គ្មានចុះឆ្នាំ, ៨)*

*ពាក្យរិះគន់ខ្លាំងៗ ទាំងនេះ បានបង្ហាញពីការចាប់ផ្ដើមរបស់ទ្រង់ ដែលក្រោយមក បានបាត់បន្តិចម្ដងៗ ។ ចំពោះទស្សនៈរបស់នាយប្រពន្ធ័ ទាំងការរៀបការដែលរៀបចំដោយមេបា និងទាំងការរៀបការច្រើនដង សុទ្ធតែមិនសមរម្យ ។ គាត់មើលឃើញថា ចាំបាច់ត្រូវតែមានការថ្លឹងថ្លែង ។ គំនិតស្ដីអំពីអាពាហ៍ពិពាហ៍ឲ្យសមស្របទៅតាមសេចក្ដីប្រាថ្នាចង់បាន និងលក្ខខណ្ឌរបស់គាត់ បានកើតឡើងដោយសារការអប់រំបែបបស្ចិមប្រទេសរបស់គាត់ ។ ប៉ុន្តែ បន្តិចម្ដងៗ គាត់បានរៀនរំងាប់នូវសេចក្ដីប្រាថ្នាទាំងនេះ ហើយសម្របទៅតាមបរិបទសង្គមសៀម ដែលក្នុងនោះ «នារីទាន់សម័យ» ត្រូវបានគេចាត់ទុកថា អាត្មានិយម និងយល់តែចិត្តខ្លួនឯង ។ ព្រះមង្កុដក្លៅ*

*បានបរិយាយតាមរយៈតួសម្ដែងថា ៖*

ក្នុងសម័យនេះ ... ស្រី ៗ មិនទាន់ស្គាល់តម្លៃពិតប្រាកដនៃសេរីភាពទេ ម្ល៉ោះហើយពួកគេប្រើប្រាស់សេរីភាពក្នុងផ្លូវខុស រហូតដល់ខូចខ្លួនខូចឈ្មោះ[១២] ។ *(វជិរាវុធ គ្មានចុះឆ្នាំ, ៥១)*

*ទោះជាព្រះរាមទី ៦ បង្ហាញពីពហុពន្ធភាពក្នុងបែបអវិជ្ជមាន ព្រះអង្គបានដាក់ការទទួលខុសត្រូវក្នុងការលុបបំបាត់បញ្ហានេះទៅឲ្យស្ត្រីទៅវិញ ។ ស្ត្រីគួរតែចាប់ផ្ដើមអនុវត្តមុន ដោយជាដំបូង ពួកគេត្រូវបដិសេធមិនរៀបការជាមួយអ្នកមានប្រពន្ធរួចហើយ ។ម្យ៉ាងទៀត ពួកគេគួរតែធ្វើខ្លួន «ឲ្យទាក់ទាញជាមេផ្ទះដ៏ល្អ និងជាមិត្តសម្លាញ់របស់ស្វាមី» (វិកា ១៩៧៥, ៧៧) ។ រូបភាពនៃសេរីភាពសម្រាប់ស្ត្រីរបស់ព្រះរាមទី ៦ គឺមានប្រាកដមិនមែនគ្រាន់តែជាការដាក់កម្រិតក្នុងក្របខណ្ឌកិច្ចការផ្ទះ និងឲ្យមានការគោរពលើទំនាក់ទំនងផ្លូវភេទដោយពួកអភិជននោះទេ ជាជាងតែការមើលទៅលើបញ្ហានិងភាពផ្ទុយគ្នាក្នុងមាតិការបស់ព្រះអង្គ ហើយក៏ប្រហែលជាត្រូវពិចារណាថា តើភាពផ្ទុយគ្នាទាំងនោះត្រូវបានបង្កើតឡើងដើម្បីបម្រើដល់គម្រោងជាតិនិយមរបស់ព្រះអង្គបានយ៉ាងដូចម្ដេចខ្លះ? ។*

## ការស្នេហាជាតិ

*ការប្រឹងប្រែងរបស់ព្រះរាមទី ៦ ដើម្បីកែប្រែទម្រង់ភេទភាវៈនិងអារម្មណ៍ផ្លូវភេទ មិនមែនគ្រាន់តែមានគោលបំណងបែបសាមញ្ញក្នុងការធ្វើឲ្យសៀមក្លាយជាជាតិទំនើបក្នុងក្រសែភ្នែករបស់ពួកបស្ចិមប្រទេសប៉ុណ្ណោះនោះទេ ។ ការស្រាវជ្រាវបែបអក្សរសិល្ប៍នៃព្រះអង្គចំពោះបញ្ហានេះ បានបញ្ជាក់ថា ទ្រង់បានស្វះស្វែងបង្កើតបុគ្គលទាន់សម័យ ដែលការប្រាថ្នានិងអត្តសញ្ញាណរបស់ពួកគេ អាចភ្ជាប់ដោយផ្ទាល់ទៅនឹងប្រទេសជាតិ ។ រឿងទាំងពីរដែលនាងខ្ញុំពិនិត្យ គឺសុទ្ធតែបង្ហាញអំពីគោលរឿងដ៏ស្មុគស្មាញស្ដីពីការស្នេហាជាតិ ។ ការសិក្សារបស់អ្នកស្រីសូម្ម័រ (១៩៩១) ស្ដីពី «រឿងប្រតិដ្ឋមូលដ្ឋាន» នៅអាមេរិកឡាទីន បានផ្ដល់នូវក្របខណ្ឌដ៏មានប្រយោជន៍សម្រាប់ការវិភាគអក្សរសិល្ប៍ ។ រីឯលោក ម៉ស្ស (១៩៨៥) បានផ្ដល់នូវការយល់ដឹងយ៉ាងជ្រាលជ្រៅអំពីផែនការជាតិនិយមរបស់ព្រះមហាក្សត្រ ។*

*រឿង* **ហួចៃនាយន៍** *គឺជាប្រភេទប្រលោមលោកថ្នាក់ជាតិមួយ ដែលផ្ដល់ចម្លើយអំពីអត្តសញ្ញាណជាតិនិងការបង្រួបបង្រួម ។ ជំនួសឲ្យការប៉ុនប៉ងបង្រួបបង្រួមក្រុមជនជាតិភាគតិចផ្សេងៗ ដែលមាននៅលើទឹកដីថៃដូចទៅនឹងរឿងប្រលោមលោកថ្នាក់ជាតិនៅអាមេរិកឡាទីន ព្រះរាមទី ៦ ខិតខំលើកពីភាពខុសគ្នារវាងជនជាតិសៀមជាមួយជនជាតិចិននិងពួកអឺរ៉ុប ។ កូនសៀមដែលទៅរស់នៅបរទេស បាននាំនូវគំនិតមន្ទិលសង្ស័យជាច្រើនស្ដីអំពីបញ្ហាបុគ្គលនិយម និងសញ្ញាណស្នេហាបែបសេរី ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេចាប់អារម្មណ៍ទៅលើស្ត្រីទាំងឡាយ ដែលមានសម្រស់បែបបស្ចិមប្រទេស ។ នេះគឺបង្ហាញថា ពួកគេចាប់អារម្មណ៍ពីបស្ចិមប្រទេស កាន់តែច្រើនឡើង ។ ឧទាហរណ៍ដូចជា ការចាប់អារម្មណ៍យ៉ាងងប់ងុលរបស់ប្រព័ន្ធទៅលើអត្តសញ្ញាណប្រទេសអង់គ្លេសនិងអឺរ៉ុប ។ ភាពងប់ងុលរបស់គាត់ទៅនឹងអ្វីដែលជារបស់អង់គ្លេសនោះ សម្គាល់ដោយសារគាត់មានមិត្តស្រីជាជនជាតិអង់គ្លេសឈ្មោះ លីលី ហើយនិងចំណង់ស្រេកឃ្លាន ការកម្សាន្តសប្បាយជាទូទៅរបស់គាត់ ដូចជា នៅតាមភោជនីយដ្ឋាន ការរាំរែក និងជាពិសេសនោះ គឺការទស្សនាល្ខោន ។ ប៉ុន្តែ ការប្រាថ្នាចង់បានរបស់ទាំងនេះ*

សម្រាប់ជាតិមិនបានបាត់ទេ ។ តួល្ខោនរបស់ព្រះរាមទី ៦ បានចាប់ផ្តើមសរសេរសំបុត្រជំបូងរបស់គាត់ ដោយបង្ហាញអំពីអត្តសញ្ញាណជាតិនិងការស្នេហាជាតិ ។ ដូចមានជាអាទិ៍ ÷

> កុំយល់ច្រឡំថា គ្នាមិនស្រឡាញ់ក្រុងស្យាមឬជាតិសៀម ។ ប្រទេសជាតិរបស់គ្នា ម្តេចក៏គ្នានឹងមិនស្គាល់ ? តែជាធម្មតា មនុស្សយើងត្រូវមានសេចក្តីស្រឡាញ់ច្រើនប្រភេទច្រើនបែប ដូចជា ស្រឡាញ់ឪពុកម្តាយ ញាតិ បងប្អូន ក៏ខុសពីការស្រឡាញ់កូន ស្រឡាញ់ប្រពន្ធ មែនឬទេ ? ការស្រឡាញ់ស្រុកសៀមប្រៀបដូចស្រឡាញ់ឪពុកម្តាយ ឯការស្រឡាញ់ស្រុកអង់គ្លេស ដូចស្រឡាញ់ប្រពន្ធ ។ ហើយដល់វេលាត្រូវចាកចេញពីស្រុកអង់គ្លេសមកស្រុកសៀមវិញ នឹងមិនធ្វើឲ្យគ្នាអាឡោះអាល័យបានឬ ? *(វជិរាវុធ គ្មានចុះឆ្នាំ, ១-២)*

ប្រព័ន្ធប្រដូច ដោយឥតអៀនខ្មាស នូវការស្រឡាញ់ប្រទេសអង់គ្លេសទៅនឹងស្នេហារវាងប្តីនិងប្រពន្ធ ។ ការស្រឡាញ់ប្រទេសអង់គ្លេសរបស់គាត់មិនគ្រាន់តែត្រូវមើលឃើញថា ប្រៀបដូចកាមតណ្ហាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រឈមមុខនឹងចំណងគ្រួសារបែបបុរាណដែលបង្កើតទម្រង់មូលដ្ឋាននៃរចនាសម្ព័ន្ធសង្គមសៀម ។ ព្រះរាមទី ៦ ប្រឈមនឹងបញ្ហាថា តើព្រះអង្គអាចធានាថា ប្រជារាស្ត្រនៃព្រះអង្គស្រឡាញ់ជាតិសៀមនិងអត្តសញ្ញាណជាថៃ ដោយមិនទាត់ចោលភាពទំនើបបានយ៉ាងដូចម្តេច ? ការស្រុះស្រួលរវាងសៀមដែលទទួលការអប់រំពីបរទេស (គេហៅពួកគេថា ហួណក ៗ หัวนอก ហ៊ូន្នក មានន័យថា ក្បាលក្រៅ) និងអ្នកដែលនៅក្នុងស្រុក ឬក៏អ្នកខុសជំនាន់គ្នា បានជោគជ័យនៅចុងបញ្ចប់នៃរឿង **ហ្វួចៃនាយន្នុំ** នៅពេលដែលប្រព័ន្ធបានធ្លាក់នៅក្នុងរង្វង់ស្នេហ៍និងមានគម្រោងរៀបការជាមួយនឹងនារីសៀមម្នាក់ដែលត្រូវជាកូនមិត្តភក្តិរបស់ឪពុកគាត់ ។ សាររបស់ព្រះរាមទី ៦ គឺមានភាពច្បាស់លាស់ណាស់ ។ ដោយធ្វើការបង្រួបបង្រួម ទាំងសេចក្តីស្នេហារវាងប្រុសស្រីនិងការស្រឡាញ់គ្រួសារ ហើយដោយការដើរតាមគន្លងនៃការសម្រុះសម្រួល ជនជាតិសៀមអាចកែប្រែបញ្ហារបស់ប្រជាជនខ្លួន និងអាចប្រឈមជាមួយនឹងការគំរាមកំហែងពីខាងក្រៅ ។

ដោយគិតអំពីរឿងនេះ តាមគំនិតរបស់អ្នកស្រី សូម្ម័រ អំពីរឿងប្រតិដ្ឋមូលដ្ឋាន យើងអាចលើកជាសំណួរអំពីមូលដ្ឋានដែលព្រះរាមទី ៦ ប្រើសម្រាប់បង្កើតអត្តសញ្ញាណជាតិ ។ តើព្រះអង្គបានស្ថាបនាជាតិថៃតាមមធ្យោបាយដូចមេដឹកនាំនៅអាមេរិកឡាទីនប្រកាន់យកឬ ? បើពិនិត្យមើលលើករណីជាច្រើន វាហាក់ដូចជាមិនមែនទេ ។ ប្រទេសថៃមិនដូចជាប្រជាជាតិដទៃទៀតនៅអាមេរិកឡាទីន ដែលតស៊ូដើម្បីបង្រួបបង្រួមនិងកំណត់អត្តសញ្ញាណខ្លួនឯងប្រឆាំងនឹងអាណានិគមនិយមនោះទេ ។ ការអះអាងនៃព្រះរាមទី ៦ អំពីទឹកដីសៀម គឺអាងលើពង្សាវតារសៀម ដែលតែងមានមូលដ្ឋានលើការកែប្រែអតីតកាល ដែលជារឿងនិទានពាក់កណ្តាល ហើយនិងលើការកែច្នៃប្រពៃណីទំនៀមទម្លាប់ សូម្បីតែធ្វើដើម្បីគាំទ្រអត្តភាពដូចជាកងខ្លាព្រៃ (វេល្ល៉ា ៩៧៨, ២៩-៣០ និង ២០២-៤២) ។ ហើយបន្ទាប់មក តើយើងអាចពន្យល់បញ្ជាក់អំពីស្នេហាប្រុសស្រីក្នុងរឿង **ហ្វួចៃនាយន្នុំ** បានយ៉ាងដូចម្តេច ? ចម្លើយប្រហែលជាឋិតនៅលើលក្ខណៈពីរយ៉ាងនៃអត្តសញ្ញាណដែលទទួលឥទ្ធិពលពីបស្ចិមប្រទេស និងដែលទទួលបានពីការហូរចូលយ៉ាងច្រើនលើសលប់របស់ជនជាតិចិន ។ បើសិនជាដូច្នេះ គោលជំហរនៃព្រះរាមទី ៦ ដើម្បីរៀបរាប់ពីសេចក្តីស្នេហារបស់ប្រជារាស្ត្រទ្រង់ ដោយផ្អែកលើមូលដ្ឋានសម្ព័ន្ធភេទផ្សេងគ្នា និងចំណងបន្តពូជដែលអ្នកស្រី សូម្ម័រ ហៅថា ជា «ការអះអាងដែលអាចកើតឡើងបាន» នោះ គឺសមហេតុផល ។

បញ្ហាស្នេហាជាតិនេះ ត្រូវបានគេបង្ហាញតាមបែបផ្សេងទៀតនៅក្នុងរឿង **ស៊ីផែនឱន** គឺពេលដែលប្ដីនាងផ្ទួយព្យាយាមរៀបរាប់ប្រាប់នាងអំពីសេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះមហាក្សត្រ ។ សេចក្ដីស្រឡាញ់របស់គាត់ចំពោះព្រះចៅចុល្ចម (ព្រះចុឡាលង្ករណ៍) ប្រៀបដូចទៅនឹងការស្រឡាញ់របស់កូនចំពោះឪពុកនោះ ។ ចំណែកឯការស្រឡាញ់របស់គាត់ចំពោះស្ដេចព្រះរាមទី ៦ វិញ ត្រូវរៀបរាប់យ៉ាងហោចណាស់មួយទំព័រក្រដាស ។ ការដកស្រង់នៅទីនេះ គឺជាអត្ថន័យសំខាន់ៗ ÷

> ម៉ែផ្លួយ ... ពេលខ្លះ បងស្រឡាញ់លោកដូចជាមិនដែលស្រឡាញ់អ្វីពីមុនមក ។ បងយល់ថា សេចក្ដីស្រឡាញ់ទាំងស្រុងដែលមានចំពោះស្រុកកំណើតរហូតដល់ប្រពន្ធកូន ញាតិវង្ស ទៅរួបរួមក្នុងការស្រឡាញ់តែលោកមួយព្រះអង្គ ។ លោកនឹងប្រើឲ្យធ្វើអ្វី ក៏បងធ្វើថ្វាយបាន សូម្បីតែជីវិតក៏ថ្វាយបាន ដោយសារការដែលបងស្រឡាញ់លោកដូច្នេះ និងដោយសារសេចក្ដីស្រឡាញ់បែបនេះទៀតណា៎ ដែលធ្វើឲ្យបងមានសេចក្ដីខ្នះខ្នែងចង់ធ្វើល្អ ចង់ឲ្យមានប្រយោជន៍ដល់ប្រទេសជាតិ ... ឲ្យសមនឹងជាខ្ញុំរបស់លោក ... ។ មានពេលខ្លះដែលលោកសប្បាយព្រះទ័យ ត្រាស់លេងសើច មានព្រះបន្ទូលនិយាយលេងជាគ្នាឯងជាមួយនឹងអ្នកដែលនៅគាល់ហ្វៀវេលាទ្រង់រីករាយ វេលាដែលទ្រង់ញញឹមពព្រាយ ត្រាស់ជន្លជន្លេញមនុស្សទាំងអម្បាលម៉ាន បងក៏គ្រាន់តែអង្គុយសម្លឹងមើលលោកពីចម្ងាយ មើលប៉ុន្មានក៏មិនធុញ ។ លោកគួរជាទីស្រឡាញ់មែនទែន គួរឲ្យចាប់ចិត្តចាប់ថ្លើមមែនទែន ។ ក្នុងគ្រាអញ្ចឹង បងក៏ស្រឡាញ់លោក ចាប់ចិត្តស្នេហ៍ចំពោះលោក ដូចជាមួយស្រី ... ។ (គឹកប៊ុទ្ធី [១៩៥១], ១៥៥-១៥៦)

នៅទីនេះ យើងមើលឃើញសេចក្ដីបញ្ជាក់អំពីសេចក្ដីស្រឡាញ់គ្រួសារនិងស្នេហាប្រុសស្រី ប៉ុន្តែ រាល់សេចក្ដីស្រឡាញ់គ្រប់ប្រភេទទាំងអស់ គឺបិតនៅលើការគោរពបូជាចំពោះព្រះមហាក្សត្រ ដែលជាភេទតែមួយ តែតំណាងឲ្យជាតិ ។ ការដកស្រង់ពាក្យសម្ដីខាងលើ បង្ហាញឲ្យឃើញអត្ថន័យមួយប្លែកនៅក្នុងការបង្កើតសេចក្ដីស្រឡាញ់ប្រទេសជាតិ ទោះជាប្រើពាក្យក្នុងន័យប្រៀបទៅនឹងការស្រឡាញ់គ្រួសារ និងស្នេហាប្រុសស្រី ដូចជា «មាតុប្រទេស» ឬ «បិតុប្រទេស» ឬក៏ «ប្រពន្ធ» ក៏ដោយ ។ សេចក្ដីស្នេហាជាតិ ត្រូវបានបង្ហាញឲ្យឃើញបែបជាសង្គមឯកភេទ ដែលមានចំណងសេចក្ដីស្នេហារវាងមនុស្សប្រុសដូចគ្នាយ៉ាងជ្រាលជ្រៅ ។ នេះប្រហែលជាអារម្មណ៍ស្រឡាញ់ភេទដូចគ្នារបស់ អ្ន.រ.វ. គឹកប៊ុទ្ធី បានធ្វើឲ្យលោកបរិយាយពាក្យយ៉ាងដូច្នេះ ។ តែទោះជាយ៉ាងណាក៏ដោយ សម្ដីខាងលើបង្ហាញពីភាពត្រឹមត្រូវមួយកម្រិតដែរ ។ ដូចទៅអ្វីដែលលោក ម៉ស្ស (១៩៨៥, ៦៧-៦៩, ៨០) បានលើកឡើងអំពីសមាគមមិត្តភក្ដិ ដែលមានសុទ្ធតែមិត្តភក្ដិប្រុសៗ នៅប្រទេសអាឡឺម៉ង់ គំនិតជាតិនិយមក្នុងអំឡុងរជ្ជកាលទី ៦ បានជាប់ពាក់ព័ន្ធហើយនិងជ្រួតជ្រាបទៅដោយសេចក្ដីស្នេហារវាងមិត្តភក្ដិប្រុសៗ របស់ក្រុមស្ដេចហើយនិងអ្នករស់នៅក្នុងរាជវាំង ។

ការសិក្សានៅប្រទេសអង់គ្លេសរបស់ព្រះរាមទី ៦ បានធ្វើឲ្យព្រះអង្គមានចំណងសង្គមឯកភេទ និងស្នេហាភេទដូចគ្នាជាមួយបុរសដូចគ្នា ដូចដែលមាននៅក្នុងទូទាំងថ្នាក់ដឹកនាំប្រទេសអង់គ្លេស និងក្នុងចក្រភពអង់គ្លេសទាំងមូល (សូមអាន ហៃយ៉ាំ ១៩៩០ និង ម៉ស្ស ១៩៨៥, ៦២) ។ ក្នុងនាមជារជ្ជទាយាទ ព្រះអង្គម្ចាស់វជិរាវុធ បានបង្កើតទម្រង់នៃការទាក់ទងជាមួយក្រុមមិត្តភក្ដិប្រុសដ៏តូចមួយ ដែលពួកគេទាំងនោះភាគច្រើនជាមនុស្សសាមញ្ញជាជាងជាពួកមានវណ្ណៈជាព្រះរាជវង្សានុវង្ស (ហ្គ្រីន ១៩៧១, ៨២ និង ១៨៤-៩០) ។ ពួកគេរួមគ្នាបង្កើតក្លិបមួយដែលបោះពុម្ពផ្សាយនូវទស្សនាវដ្ដីអក្សរសិល្ប៍ មានឈ្មោះថា **ទ្វីបញ្ញា** (ទាវីប៉ាំញ្ញា) ដើម្បីផ្សាយចេញនូវការពិភាក្សា

*និងដាក់ចេញផ្សាយនូវរឿងល្ខោនជាច្រើន ។ ការអធិប្បាយរបស់លោក វ៉ែល្លា (១៩៧៨) អំពីវគ្គផ្សំសង្គមរបស់ស្តេចវជិរាវុធនិងសកម្មភាពជាតិនិយម គូសបញ្ជាក់ពីការរាប់អានគ្នានិងពីចំណងបុរសភេទទាំងអស់ ដែលបង្កើតបានជាស្នូលសំខាន់នៃពិភពរបស់ព្រះរាមទី ៦ ។*

*គ្មានអ្វីដែលគួរឲ្យឆ្ងល់ទៀតទេចំពោះបុរសជាច្រើន ដូចជា អ្នកប្រេមក្នុងរឿង* **ស៊ីផែនឌិន** *មិនថា ជាបញ្ហាផ្លូវភេទ ឬបញ្ហាទំនាក់ទំនងផ្ទាល់ខ្លួន ឬក៏ទំនាក់ទំនងផ្លូវភេទជាមួយព្រះរាមទី ៦ គាត់ត្រូវតែមានចំណងអារម្មណ៍ជ្រាលជ្រៅបែបនេះ ។ ហើយហាក់ដូចជាព្រះរាមទី ៦ ទ្រង់ប៉ុនប៉ងបំផុសសេចក្តីស្នេហាបែបនេះ ដែលបន្ទាប់មកអាចដាក់ឲ្យបម្រើដល់ជាតិបាន ។*

## សេចក្តីសន្និដ្ឋាន

*ទាំងនៅក្នុងសាច់រឿង* **ហ្វូចៃឆាយន័ទ្ធ** *និងរឿង* **ស៊ីផែនឌិន** *សេចក្តីស្រឡាញ់និងបំណងប្រាថ្នាតែងតែបានបាញ់ផ្លោះទៅរកជាតិជានិច្ចកាល ។ នៅក្នុងសាច់រឿងទាំងពីរ ប្រឌិតញាណនៃបញ្ហាផ្លូវភេទ បញ្ហាភេទភាវៈ (យេនឌ័រ) និងពាក្យថា «ជាតិ» វេញបញ្ចូលគ្នា ដែលរំលេចឡើងនៅក្នុងសាច់រឿងទាំងពីរ អាចឲ្យយើងឃើញពីភាពជាក់លាក់ស្រដៀងគ្នាយ៉ាងទូលំទូលាយមួយ ដែលគំរូនៃគំនិតមានលក្ខណៈស្រដៀងគ្នាទៅនឹងគំរូជាតិនិយមនៅបស្ចិមប្រទេស ។ ការសិក្សាប្រកបដោយគំនិតបដិវត្តរបស់លោក ម៉ុស្ស (១៩៨៥) ស្តីអំពីបញ្ហាជាតិនិយមហើយនិងអារម្មណ៍ផ្លូវភេទ បានផ្តល់នូវការវិភាគរែករញែកយ៉ាងទូលំទូលាយទៅលើគំនិតទាំងនោះ និងចំណុចពាក់ព័ន្ធផ្សេងទៀត ។ អត្ថន័យសំខាន់នៅក្នុងការវិភាគរបស់លោក ម៉ុស្ស គឺជាតឹកតាងនៃគំរូជាតិនិយមយ៉ាងសំខាន់ ដែលកើតឡើងចំពោះអ្នកជាតិនិយមសៀម ។ គំរូទាំងនោះមានជាអាទិ៍ ÷ ការចងជាក្រុមសម្ព័ន្ធរបស់បុរស និងការទោរទន់ទៅរកការគ្រប់គ្រងដោយពួកមនុស្សប្រុស ។ ជាពិសេស ទំនាក់ទំនងនៃបទដ្ឋានសង្គមនិងទំនាក់ទំនងផ្លូវភេទ ដែលមានទម្រង់ផ្តោតទៅលើភាពគួរឲ្យគោរព និង «សីលធម៌នៃវណ្ណៈថ្នាក់កណ្តាល» និងការកំណត់នូវចំណាត់ថ្នាក់នៃក្រុមពូជសាសន៍ដែលមិនមែនជាពូជសៀម ។ ការកំណត់ក្រុមនៃពូជសាសន៍មិនមែនពូជសៀមដែលអាចកំណត់ពីដែននៃជាតិរបស់ខ្លួន ។ ទោះបីយ៉ាងណាក៏ដោយ គោលរឿងសំខាន់នីមួយៗ បានឲ្យយើងឃើញពីទម្រង់នៃជនជាតិសៀមយ៉ាងពិតប្រាកដមួយ ដែលមាននៅក្នុងសាច់រឿងប្រតិដ្ឋទាំងពីរនោះ ។ ភាពស្របគ្នារវាងគំនិតជាតិនិយមរបស់ជនជាតិសៀម និងជនជាតិអឺរ៉ុប បង្ហាញពីភាពទូទៅមួយនៃគំនិតជាតិនិយមដែលបង្កើតឡើងដោយចំណងមិត្តភាពរបស់បុរសពីម្នាក់ទៅម្នាក់ដូចខ្សែបន្ទាត់ (អាន់ដឺរសុន ១៩៨៣, ១៦) និងពឹងលើប្រព័ន្ធអបរិយប័ន្ន (ការឥតគិតបញ្ចូលជនជាតិដទៃ) នៃជនជាតិសៀម ដោយសម្អាងលើភាពផ្សេងគ្នានៃពូជសាសន៍ ភេទ និងភេទភាវៈ ដូចដែលអត្ថបទនេះបានបង្ហាញពីលក្ខណៈពិសេសនៃជាតិនិយមសៀម និងរឿងរ៉ាវស្មុគស្មាញផ្សេងៗទៀត(១៣) ។*

*យើងឃើញថា នៅក្នុងរជ្ជកាលទី ៦ ព្រះរាជូបត្ថម្ភចំពោះជាតិនិយម មានបំណងថែរក្សានូវជំហរល័ក្ខខ័ណ្ឌនយោបាយរបស់ព្រះអគ្គផង (អាន់ដឺរសុន ១៩៨៣, ១០០-១០១) ។ គោលចរិតលក្ខណៈនៃក្រុមជាតិនិយមសៀមពេលនោះ ផ្តល់ការទទួលខុសត្រូវទៅលើក្រុមអភិជន និងកាត់បន្ថយផលប៉ះពាល់ពីគំនិតជាតិនិយមនេះទៅលើមជ្ឈដ្ឋានប្រជាពលរដ្ឋទូទៅ (វ៉ៃយ៉ុត្ត ១៩៨២, ២២៤) ។ ផ្ទុយទៅវិញ បំណងប្រាថ្នានិងជម្រើសប្រកបដោយគ្រោះភ័យនៃអត្តសញ្ញាណរបស់ខ្លួន ដែលរៀបចំដោយក្រុមជាតិនិយម បានក្លាយជាកង្វល់ចំពោះក្រុមបញ្ញវន្តនិងក្រុម*

ដែលកាន់កាប់សេដ្ឋកិច្ច ។ ព្រោះក្រុមមនុស្សទាំងនេះយល់ថា ពួកបស្ចិមប្រទេសនេះហើយ ដែលជាអ្នកបង្កឲ្យមានចំណោទបញ្ហា និងធ្វើឲ្យរញ៉េរញ៉ៃដល់ទម្លាប់នៃសេចក្តីគោរពរបស់ខ្លួនយ៉ាងច្រើនជាងផលប៉ះពាល់ដែលបង្កដោយជនជាតិចិនទៅទៀត ។ នៅខណៈនោះដែលជនជាតិចិនត្រូវបានទុកឲ្យនៅក្រៅដែនកំណត់នៃជាតិ ឬអាចនិយាយបានថា «ជាអ្នកដទៃ[១៤]» ដោយឡែក ពួកបស្ចិមប្រទេសបានដើរតួជាគំរូមួយសម្រាប់ជាតិនិយមសៀមទៅវិញ ។ គំរូទាំងឡាយដែលគេយកតាមលំនាំបស្ចិមប្រទេសនោះ គឺ តួនាទីភេទភាវៈ បទដ្ឋានសម្ព័ន្ធផ្លូវភេទ គំនិតពីសោភ័ណភាព ជាដើម ។ ផ្ទុយទៅវិញ លំនាំបស្ចិមប្រទេសនេះឯងដែលគំរាមកំហែងនិងគ្របដណ្តប់លើសង្គមសៀម ទាំងផ្នែកវប្បធម៌និងនយោបាយ ។ គំរូនៃបស្ចិមប្រទេសជាសរសៃនៃកង្វល់និងភាពស្រពេចស្រពិលដ៏ចាក់ស្រេះ និងជាខ្លឹមសារដ៏សំខាន់មួយលេចឡើងនៅក្នុងស្នាដៃរឿងប្រតិដ្ឋទាំងពីរនេះ ។

បញ្ហានៃសេចក្តីស្រឡាញ់និងបំណងប្រាថ្នា គឺមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងរបៀបរបបដើម្បីធានានូវទំនោរចិត្តស្រឡាញ់ជាតិ និងជំរុញសេចក្តីស្រឡាញ់ដែលផុសចេញពីមនុស្សគ្រប់គ្នាចំពោះជាតិ ។ ដែលទំនោរចិត្តស្រឡាញ់និងបំណងប្រាថ្នាចំពោះជាតិ ពុំអាចកាត់ផ្តាច់ចេញពីការបង្កើតអត្តសញ្ញាណទំនើបរបស់ជាតិមួយបានឡើយ ជាពិសេសផ្តោតលើបុគ្គលភាពដែលមានទំនាក់ទំនងទៅនឹងភេទភាវៈនិងអារម្មណ៍ផ្លូវភេទផង ។ ភាពស្រពេចស្រពិលនៃទំនាក់ទំនងរវាងគំនិតផ្ទុយគ្នា ចំពោះពួកបស្ចិមប្រទេសក្នុងការគូសសម្គាល់ដល់ជាតិនិយមសៀមនិងបញ្ហាអារម្មណ៍ផ្លូវភេទនៅក្នុងរជ្ជកាលទី ៦ បានរីករាលដាលធំហួសពីអ្វីដែលអាចកំណត់ត្រឹមអត្តសញ្ញាណនោះទៅទៀត ។ ព្រោះតាមពិតទៅ ឥទ្ធិពលពីបស្ចិមប្រទេសហុចផលពីរយ៉ាង ទាំងសេចក្តីប្រាថ្នានិងសេចក្តីភ័យខ្លាច ។ បើនិយាយជាទូទៅ រូបភាពនៃទំនើបកម្មនិងអារ្យធម៌របស់បស្ចិមប្រទេស គឺមានរូបភាពគួរឲ្យពេញចិត្តនិងគួរឲ្យប្រាសចាក ។ ព្រោះថា គេត្រូវតែបដិសេធនូវទំនើបកម្មនិងអារ្យធម៌ទាំងនេះ ដើម្បីអាចឲ្យមានលទ្ធភាពធ្វើការបង្រួបបង្រួមអត្តសញ្ញាណកម្មជាតិថៃតែមួយគត់ ដែលជាគោលដៅនៃជាតិនិយមរបស់ខ្លួន ។ ជាឧទាហរណ៍ ដំណើរស្វែងរកស្នេហ៍របស់លោកប្រពន្ធ កើតពីភាពមិនច្បាស់លាស់នៃការខ្វែងគំនិតអំពីបញ្ហានេះ ដែលមិនអាចសម្របសម្រួលបានចំពោះអត្តសញ្ញាណជាតិនិងអត្តសញ្ញាណនៃទំនាក់ទំនងសម្ព័ន្ធផ្លូវភេទ ៕

# ជំពូកទី ៣

# ជំរឿន ការគូសផែនទី និងការតាំងបង្ហាញ

*ដោយ បេនីឌិកត៍ អាន់ដឺរសុន*

*ច្បាប់ដើមនៃអត្ថបទនេះបានសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា÷* “Census, Map, Museum” ។
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **សហគមន៍ស្រមើស្រមៃ ៖ ការត្រិះរិះពិចារណាអំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម** *(Imagined Communities: Reflections on the Origin and Spread of Nationalism)* ។

*រក្សាសិទ្ធិ គ.ស. ២០០៦ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយវែរសូ (ឡុងដ៍្រ)* ។

*បោះពុម្ពលើកទី ១ គ.ស. ១៩៨៣ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយវែរសូ* ។

## CHAPTER 3:

“Census, Map, Museum”
Benedict Anderson
*(Imagined Communities : Reflections on the Origin and Spread of Nationalism)*

**Copyright © 2006 by Verso (London).**

**First published in 1983 by Verso.**

បកប្រែដោយ តាន់ សូដានី

# ជំពូកទី ៣
# ជំរឿន ការគូសផែនទី និងការតាំងបង្ហាញ

ក្នុងច្បាប់ដើមដំបូងនៃសៀវភៅ **សហគមន៍ស្រមើស្រមៃ ៖ ការត្រិះរិះពិចារណា អំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម** ដែលខ្ញុំបានសរសេរនោះ ខ្ញុំបានសរសេរថា «នៅក្នុងគោលនយោបាយស្ថាបនាជាតិរបស់រដ្ឋទាំងឡាយដែលទើបតែកកើតថ្មី យើងឃើញមានទាំងសេចក្តីស្រើបចំពោះជាតិនិយមដ៏ពិតប្រាកដនិងដ៏ពេញនិយមមួយ ហើយនិងការបំពាក់បំប៉នមនោគមវិជ្ជាប្រកបដោយប្រព័ន្ធទៀងទាត់និងរៀបរយទៀតផង តាមរយៈសារព័ត៌មាន ប្រព័ន្ធអប់រំ និងបទបញ្ញារដ្ឋបាលនានា ។ល។[១]» ។ នៅពេលនោះ ខ្ញុំបានប៉ាន់ស្មានថា គំនិតជាតិនិយមផ្លូវការនៅដែនដីអាណានិគម [២] ក្នុងទ្វីបអាស៊ីនិងអាហ្វ្រិក យកតម្រាប់តាមមនោគមវិជ្ជារបស់រាជាណាចក្រទាំងឡាយនៅអឺរ៉ុបនាគ្រិស្តសតវត្សរ៍ទី ១៩ ដោយផ្ទាល់ ។ ប៉ុន្តែ ការឆ្លុះបញ្ចាំងក្រោយៗមកទៀត បែរជាធ្វើឲ្យខ្ញុំយល់ថា ទស្សនៈនេះមិនស៊ីជម្រៅនិងជាការប៉ាន់ស្មានឆាប់រហ័សពេក ហើយដើម្បីសិក្សាពីដើមកំណើតនៃមនោគមវិជ្ជានេះ យើងគួរតែពិនិត្យតាមដានពីវត្ថុស្រមើស្រមៃរបស់រដ្ឋអំណាចអាណានិគមវិញ [៣] ។ ការសន្និដ្ឋាននេះ ប្រហែលជារឿងគួរឲ្យភ្ញាក់ផ្អើល ពីព្រោះថា ជាធម្មតា រដ្ឋាភិបាលអាណានិគមទាំងនោះ គឺសុទ្ធតែប្រឆាំងទៅនឹងអ្នកជាតិនិយម ហើយជាទូទៅ ច្រើនប្រើអំពើហិង្សាដើម្បីបង្ក្រាបអ្នកទាំងនោះផង ។ ប៉ុន្តែ ប្រសិនបើយើងពិនិត្យមើលទៅលើក្រឹត្យក្រមដែលគេប្រើ ដើម្បីផ្សព្វផ្សាយមនោគមវិជ្ជានិងគោលនយោបាយអាណានិគមរបស់គេ ចាប់តាំងពីសតវត្សរ៍ទី ១៩ មក ប្រភពដើមកំណើតនៃគំនិតជាតិនិយមនៅលើដែនដីអាណានិគមបានបង្ហាញឡើងកាន់តែច្បាស់ ។

មិនសូវមានភស្តុតាងអ្វីដែលអាចបង្ហាញឲ្យឃើញជាក់ច្បាស់ពីការអះអាងខាងលើ ក្រៅពីសកម្មភាពបីយ៉ាងដែលរដ្ឋាភិបាលអាណានិគម បានធ្វើសម្រាប់បង្កើតអំណាចត្រួតត្រារបស់ខ្លួននោះទេ ។ សកម្មភាពទាំងនោះបានកើតឡើងមុនពាក់កណ្តាល ស.វ. ទី ១៩ ហើយផ្លាស់ប្តូរទម្រង់និងតួនាទីរបស់ខ្លួន នៅពេលដែលតំបន់អាណានិគមឈានចូលទៅក្នុងយុគសម័យនៃការចម្លងវត្ថុជាចំនួនធំៗ ដោយប្រើបច្ចេកទេសនិងយន្តកម្ម ។ សកម្មភាពទាំងបីយ៉ាងនោះ មាន ជំរឿន ការគូសផែនទី និងការតាំងបង្ហាញ ។ សកម្មភាពទាំងបីរួមបញ្ចូលគ្នានេះ បានបង្ហាញពីរបៀបដែលរដ្ឋាភិបាលអាណានិគមនឹកគិតស្រមៃអំពីការត្រួតត្រារបស់ខ្លួន អំពីធម្មជាតិរបស់មនុស្សនិងតំបន់ភូមិសាស្ត្រដែលខ្លួនគ្រប់គ្រង ហើយនិងរបៀបដែលធ្វើឲ្យពូជពង្សរបស់ខ្លួនមានភាពស្របច្បាប់នៅលើដែនដីអាណានិគម ។ ដើម្បីស្វែងរកលក្ខណៈនៃភាពជំពាក់ជំពិននេះ ក្នុងជំពូកនេះ ខ្ញុំកំណត់ការសិក្សាតែទៅលើតំបន់អាស៊ីអាគ្នេយ៍មួយគត់ ពីព្រោះការសន្និដ្ឋានរបស់ខ្ញុំ គឺគ្រាន់តែជាការសាកល្បងប៉ុណ្ណោះ ហើយដោយសារខ្ញុំមានជំនាញពិតប្រាកដផ្តោតតែទៅលើតំបន់នេះ ។ លើសពីនេះ តំបន់អាស៊ីអាគ្នេយ៍ពិតជាផ្តល់នូវអត្ថប្រយោជន៍យ៉ាងពិសេស សម្រាប់ការសិក្សាប្រៀបធៀបប្រវត្តិសាស្ត្រ ព្រោះថា ដែនដីអាណានិគមនៃតំបន់នេះ ត្រូវគ្រប់គ្រងដោយពួកមហាអំណាចស្បែកសស្ទើរតែទាំងអស់ ដែលរួមមានទាំងអង់គ្លេស បារាំងសែស អេស្ប៉ាញ ព័រទុយហ្កាល់ ហូឡង់ និងសហរដ្ឋអាមេរិក ។ ខ្ញុំក៏នឹងផ្តោតទៅលើប្រទេសសៀមដែលមិនធ្លាប់រងអាណានិគមដែរ ។ ចំពោះអ្នកអានដែល

មានចំណេះដឹងទូលំទូលាយលើផ្នែកដទៃទៀតនៃតំបន់អាស៊ីនិងអាហ្វ្រិកជាងខ្ញុំនោះ អាចវាយតម្លៃបានថា តើការពិភាក្សារបស់ខ្ញុំនេះអាចយកជាការពិភាក្សាត្រឹមត្រូវបាននៅក្នុងបរិបទប្រវត្តិសាស្ត្រនិងភូមិសាស្ត្រទូលំទូលាយ ជាងតំបន់មួយនេះដែរឬទេ ។

## ជំរឿន

អត្ថបទថ្មីពីរដ៏មានតម្លៃរបស់អ្នកសង្គមវិទ្យាឈ្មោះ ឆាលស៍ ហឺរឈ្មែន (Charles Hirschman) បានសិក្សាអំពីចិត្តគំនិតអ្នកធ្វើជំរឿនរបស់រដ្ឋអំណាចអាណានិគមអង់គ្លេស នៅក្នុងជ្រោយមឡាយូ និងក្នុងទីតាំងកំពង់ផែតាមដៃសមុទ្រមឡាយូ [៤] (ស្រុកស្ទាត់ ភាសាអង់គ្លេសហៅថា ស្ត្រេតសេត្តិលមែនត៍) ហើយនិងចិត្តគំនិតអ្នកបន្តការងារក្រោយៗ មកទៀត របស់ពួកគេដែលធ្វើជំរឿនសម្រាប់រដ្ឋម៉ាឡេស៊ីឯករាជ [៥] ។ សំណៅរបស់លោក ហឺរឈ្មែន អំពីប្រភេទអត្តសញ្ញាណ នៅក្នុងទិន្នន័យជំរឿនក្រោយៗ ចាប់តាំងពីចុង ស.វ. ទី ១៩ រហូតមកដល់បច្ចុប្បន្នថ្មីៗ នេះ បានបង្ហាញអំពីការផ្លាស់ប្តូរយ៉ាងរហ័សនិងតាមអំពើចិត្ត ដែលក្នុងនោះ ប្រភេទអត្តសញ្ញាណជាច្រើន បានបន្តប្រមូលចូលគ្នា បំបែកចេញពីគ្នា បញ្ចូលគ្នាឡើងវិញ លាយចូលគ្នា និងរៀបចំឡើងវិញ (ប៉ុន្តែប្រភេទអត្តសញ្ញាណសំខាន់ៗខាងនយោបាយ តែងតែឋិតនៅដើមបញ្ជីជានិច្ច) ។ ពីសម្រង់ជំរឿននេះ គាត់ទាញបានសេចក្តីសន្និដ្ឋានគោលពីរ ។ ការសន្និដ្ឋានទី ១ នោះ គឺថា នៅពេលដែលសម័យអាណានិគមបានកន្លងផុតទៅ ប្រភេទជំរឿនមានសភាពកាន់តែច្បាស់ និងផ្តោតតែទៅលើការរាប់ពីពូជសាសន៍ [៦] ។ ម្យ៉ាងទៀត អត្តសញ្ញាណខាងសាសនា បានបាត់បង់បន្តិចម្តងៗ លែងជាការធ្វើចំណាត់ថ្នាក់សំខាន់មួយក្នុងការធ្វើជំរឿនទៀតហើយ ។ «អ្នកកាន់សាសនាហិណ្ឌូ» ដែលឋិតនៅលំដាប់ជាមួយ «ពួកក្លិង្គ» និង «ពួកបង់កាលី» ស្រាប់តែបានបាត់បន្ទាប់ពីជំរឿនលើកទី ១ ក្នុងឆ្នាំ ១៨៧១ ។ «ពួកប៉ារស៊ី [៧] » ត្រូវបានគេបញ្ចូលជាមួយ «ពួកបង់កាលី» «ពួកភូមា» និង «ពួកទមិឡ» ក្រោមប្រភេទពូជសាសន៍ធំមួយហៅថា «ពួកទមិឡនិងជនជាតិដើមឥណ្ឌាដទៃទៀត» ហើយប្រភេទជនជាតិនេះ នៅមានចុះក្នុងបញ្ជីជំរឿនត្រឹមឆ្នាំ ១៩០១ ប៉ុណ្ណោះ ។ ការសន្និដ្ឋានទី ២ របស់គាត់ គឺថា ជាទូទៅ ប្រភេទជនជាតិធំៗ ត្រូវបានគេរក្សាទុកនិងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង បន្ទាប់ពីទទួលបានឯករាជ្យ ប៉ុន្តែត្រូវបានរៀបនិងឲ្យចំណាត់ថ្នាក់ឡើងវិញជា «ជនជាតិម៉ាឡេស៊ី» «ជនជាតិចិន» «ឥណ្ឌា» និង «ជនជាតិផ្សេងៗ» ។ ការចាត់ថ្នាក់បែបមិនសមហេតុផលនេះ បានបន្តរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៨០ ។ នៅក្នុងជំរឿនឆ្នាំ ១៩៨០ «ពួកសិខ [៨] » បានក្លាយជាជនជាតិប្រភេទរាយរង (ដូចជាពួក «ម៉ាឡាយ៉ាលី» «តេលុគុ» «ប៉ាគីស្ថាន» «បង់ក្លាទេស» «ទមិឡពីស្រីលង្កា» និង «ជនជាតិដទៃមកពីស្រីលង្កា») នៅក្រោមប្រភេទជនជាតិដ៏ធំគឺ «ពួកឥណ្ឌា» ។

ប៉ុន្តែសំណៅដ៏អស្ចារ្យរបស់លោក ហឺរឈ្មែន បានជំរុញឲ្យយើងពិនិត្យមើលបន្ថែមពីលើការវិភាគរបស់គាត់ ។ យើងនឹងលើកយកស្ថិតិជំរឿននៅរដ្ឋសហព័ន្ធម៉ាឡាយូ នាឆ្នាំ ១៩១១ មកជាតួយ៉ាង ។ ស្ថិតិជំរឿននេះ បានរៀបប្រជាជនមឡាយូតាមលំដាប់ជនជាតិ ដោយមានជនជាតិ «មឡាយូ [៩] » «ជ្វា» «សាកៃ» «បាញ់ហ្សារ» «បូយ៉ាន់» «ម៉ាន់ដឹលីង» (ហៅដូច្នេះ) «គ្រីនឈី» (ហៅដូច្នេះ) «ហ្សាំប៊ី» «អាចេះ» «ប៊ុហ្គីស» និង «ផ្សេង» ។ ក្រុមជនជាតិទាំងអស់នេះ (លើកលែងតែជនជាតិមឡាយូនិងសាកៃចេញ) មានដើមកំណើតមកពីកោះស៊ុម៉ាត្រា កោះជ្វា កោះបរណេអូភាគខាងត្បូង និងកោះសេលេបស៍ (កោះស៊ុឡាវេស៊ី) ដែលកោះទាំងអស់នេះ គឺសុទ្ធតែជាដែនដីអាណានិគមឥណ្ឌាភាគខាងកើតរបស់ហូឡង់ [១០] (របស់ហូឡង់) ពុំមែនរបស់ដែនដីមឡាយូដែលនៅក្នុងចំណុះពួក

អង់គ្លេសឡើយ ។ ប៉ុន្តែ ជនជាតិទាំងនេះ មិនត្រូវបានទទួលស្គាល់ដោយអ្នកធ្វើជំរឿនដែលសម្លឹងមើលតែពីព្រំដែនអាណានិគមរបស់ខ្លួនក្នុងគោលបំណងបង្កើតជនជាតិមឡាយូនោះ (តែនៅដែនដីម្ខាងទៀត ពួកអ្នកធ្វើជំរឿនហូឡង់បានឲ្យចំណាត់ថ្នាក់ជនជាតិមឡាយូជាជនជាតិភាគតិច ផ្ទុយទៅវិញជនជាតិអាចេះ និង ជ្វា បែរជាមានចំណាត់ថ្នាក់ជាជនជាតិភាគច្រើនទៅវិញ) ។ «ហ្សាំប៊ី» និង «គ្រីនឈី» សំដៅទៅលើទីតំបន់ជាជាងសំដៅទៅលើក្រុមជនជាតិដែលកំណត់ដោយភាសានិយាយតែមួយ ។ នៅក្នុងឆ្នាំ ១៩១១ មានមនុស្សតិចណាស់ដែលបានទទួលស្គាល់ថា ពួកគេឋិតនៅក្នុងប្រភេទជនជាតិសំខាន់ និងប្រភេទជនជាតិរាយរងទាំងនោះ ។ អត្តសញ្ញាណដែលប្រតិដ្ឋឡើងដោយការបែងចែក ដែលពោរពេញទៅដោយភាពច្របូកច្របល់និងមិនច្បាស់លាស់ ក្នុងចិត្តរបស់រដ្ឋាភិបាលអាណានិគមទាំងនោះ នៅរង់ចាំការសម្រេចរបស់ពួករដ្ឋបាលចក្រពត្តិ ដើម្បីបង្កើតជាអត្តសញ្ញាណពិតប្រាកដមួយបាន ។ បន្ថែមពីលើនេះ យើងអាចកត់សម្គាល់អំពីសេចក្តីប្រាថ្នារបស់អ្នកធ្វើជំរឿន ចំពោះភាពត្រឹមត្រូវឥតខ្ចោះនិងភាពមានន័យច្បាស់លាស់ ។ ដូច្នេះហើយ ទើបយើងអាចមើលឃើញ (ទោះជាមិនសូវច្បាស់ក៏ដោយ) ពីភាពមិនអាចអត់ឱនបានរបស់ពួកគេ ចំពោះការបន្សំផ្នែកនយោបាយនិងការផ្លាស់ប្តូរអត្តសញ្ញាណ ។ ហេតុនេះហើយបានជាប្រភេទ «ផ្សេងៗ» ដែលឋិតនៅក្នុងប្រភេទរាយរង មិនអាចច្រឡំជាមួយប្រភេទធំ «ផ្សេងៗ» ទៀតបាន ។ ការប្រតិដ្ឋការធ្វើជំរឿននេះ គឺដើម្បីឲ្យមនុស្សរាល់គ្នាឋិតនៅក្នុងប្រភេទណាមួយ ហើយតែមួយគត់ ។

របៀបនៃការប្រតិដ្ឋរបស់រដ្ឋាភិបាលអាណានិគម មានដើមកំណើតមុនជំរឿននាទសវត្សរ៍ឆ្នាំ ១៨៧០ ទៅទៀត ។ ដូច្នេះ ដើម្បីយល់ឲ្យស៊ីជម្រៅអំពីហេតុអ្វីជំរឿននៅចុង ស.វ. ទី ១៩ គឺជាអ្វីដែលថ្មីហើយប្លែកនោះ យើងត្រូវក្រឡេកទៅមើលសម័យដំបូងដែលពួកអឺរ៉ុបបានជ្រៀតចូលទៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ឧទាហរណ៍ពីរអំពីករណីប្រជុំកោះហ្វីលីពីននិងឥណ្ឌូនេស៊ី ផ្តល់ព័ត៌មានមានប្រយោជន៍យ៉ាងច្រើន ។ ក្នុងសៀវភៅដ៏សំខាន់មួយក្បាល លោក វិល្លៀម ហេនរី ស្កុត្ត (William Henry Scott) បានប៉ុនប៉ងយ៉ាងផ្ចិតផ្ចង់ក្នុងការសរសេរឡើងវិញ អំពីរចនាសម្ព័ន្ធវណ្ណៈរបស់ហ្វីលីពីនមុនធ្លាក់ក្រោមការត្រួតត្រារបស់អេស្ប៉ាញ ដោយផ្អែកលើការកត់ត្រារបស់ពួកអេស្ប៉ាញនាដើមសម័យដំបូង ដែលពួកគេមកដល់[១១] ។ ក្នុងនាមជាអ្នកជំនាញខាងប្រវត្តិសាស្ត្រ លោក ស្កុត្ត ដឹងយ៉ាងច្បាស់ថា ពាក្យ «ហ្វីលីពីន» មានប្រភពចេញពីព្រះនាមស្តេច ហ្វេលីប៉េ ទី ២ របស់អេស្ប៉ាញ ។ មិនដឹងជាសំណាងល្អឬអាក្រក់ សម័យនោះ ប្រហែលជាប្រជុំកោះនេះអាចធ្លាក់ទៅក្នុងដៃរបស់ហូឡង់និងអង់គ្លេស ហើយក៏អាចត្រូវបំបែកជាតំបន់នយោបាយផ្សេងៗ ឬជាក់ភ្ជាប់នឹងដែនដីដណ្តើមដទៃទៀត[១២] ។ ដូច្នេះហើយ ប្រហែលជាមូលហេតុដែលធ្វើឲ្យលោក ស្កុត្ត ជ្រើសរើសយកប្រធានបទនេះ គឺដោយសារគាត់ធ្លាប់រស់នៅប្រទេសហ្វីលីពីនអស់រយៈពេលយ៉ាងយូរ និងថែមទាំងមានចិត្តអាណិតយ៉ាងខ្លាំងដល់មនោគមវិជ្ជាជាតិនិយមហ្វីលីពីនដែលកំពុងតាមរកស្វែងសម័យរុងរឿងដើមដំបូងអស់រយៈពេលជាងមួយសតវត្សរ៍មកហើយ ។ តែយើងក៏អាចសន្មតបានម្យ៉ាងទៀតថា មូលហេតុដែលលោក ស្កុត្ត មានប្រឌិតញាណបែបនេះ គឺមកពីប្រភពព័ត៌មានដែលគាត់បានពឹងផ្អែកលើនោះ ។ គ្រប់កន្លែងណាដែលបព្វជិត អ្នកផ្សងព្រេង និងជនជាតិអេស្ប៉ាញ បានដើរផ្សងព្រេង ពួកគេគិតថា មនុស្សដែលពួគេជួបប្រទះនោះ សុទ្ធតែជា «ព្រីនស៊ីប៉ាឡេស» (ពួកស្តេច) «ហ៊ីដាល់ហ្គោស» (ពួកអភិជន) «ប៉េរឆេរ៉ូស» (អ្នកជា, ជនសាមញ្ញ) និង «អេសក្លាវ៉ូស» (ពួកទាសករ) ។ ការបែងចែកក្រុមមនុស្សបែបនេះ យកទម្រង់តាមចំណាត់ថ្នាក់សង្គមនៃជ្រោយអ៊ីបេរៀ (អេស្ប៉ាញ) នាចុងមជ្ឈិមសម័យ ។ ឯកសារដែលពួកនោះបានបន្សល់ទុកពោរពេញដោយកស្តុតាងថែជន្យជាច្រើន ដែលបង្ហាញថា ពួកអភិជននៅលើកោះទាំង

អស់នោះ សឹងតែមិនដឹងថា មានវត្តមានរបស់អភិជនដទៃដូចខ្លួននៅក្នុងប្រជុំកោះដ៏ធំធេងនិងរាយប៉ាយនេះ ដែលពុំសម្បូរប្រជាជន ។ បើសិនជាពួកគេដឹង ពួកគេមិនដែលគិតថា អ្នកដទៃនោះ គឺជាពួកវណ្ណៈថ្នាក់ខ្ពស់ដូចខ្លួននោះទេ ផ្ទុយទៅវិញ អ្នកទាំងនោះគិតពីអ្នកដទៃថា ជាសត្រូវឬអាចជាទាសករ ។ អំណាចនៃការគិតស្រមើស្រមៃ មានសភាពខ្លាំងក្លា ដែលនេះ គឺជាមូលហេតុដែលការគិតរបស់លោក ស្កុត្ត មិនបានឲ្យតម្លៃទៅលើភស្តុតាងទាំងនេះ ។ ដូច្នេះហើយ ទើបគាត់ពិបាកនឹងយល់បានថា រចនាសម្ព័ន្ធវណ្ណៈនៅមុនសម័យអាណានិគម គឺជាការប្រេតិដ្ឋជំរឿនឡើង ដែលបង្កើតឡើងដោយពួកដើរសមុទ្រលើនាវាចម្បាំងអេស្ប៉ាញប៉ុណ្ណោះទេ ។ នៅទីកន្លែងណាដែលពួកគេធ្វើដំណើរទៅដល់ ប្រជាជនដែលពួកគេបានចាត់ថ្នាក់ជាវណ្ណៈថ្នាក់ខ្ពស់និងពួកទាសករ លេចឡើងដោយសារការប្រមូលផ្តុំដំបូងយ៉ាងយល់ច្រឡំរបស់រដ្ឋាភិបាលអាណានិគម ។

សម្រាប់ឥណ្ឌូនេស៊ីវិញ ដោយសារការស្រាវជ្រាវរបស់លោក ម៉ាសុន ហោដលេយ៍ (Mason Hoadley) ទើបយើងមានរឿងរ៉ាវលម្អិតនៃករណីវិនិច្ឆ័យសំខាន់មួយ ដែលបានសម្រេចនៅកំពង់ផែជីរេបុន នាកោះជ្វានៅចុងស.វ. ទី ១៧[១៣] ។ ជាសំណាងល្អ ការកត់ត្រារបស់ហូឡង់និងអ្នកនៅតំបន់ជីរេបុន នៅមានបន្សល់ទុកនៅឡើយ ។ ប្រសិនបើមានតែកំណត់ត្រារបស់អ្នកនៅតំបន់ជីរេបុន យើងប្រហែលជាគ្រាន់តែដឹងថា ឃាតករដែលគេបានចោទប្រកាន់នោះ គឺជាមន្ត្រីជាន់ខ្ពស់នៃរាជវាំងជីរេបុន ហើយនិងគ្រាន់តែដឹងអំពីគោរម្យងាររបស់លោក គឺ «គីអារ្យៈ ម៉ាត់ា នីងរ៉ាត» (មិនមែនជាឈ្មោះផ្ទាល់) ។ ប៉ុន្តែ នៅក្នុងកំណត់ត្រារបស់ពួកហូឡង់វិញ បានហៅមន្ត្រីនេះទាំងខឹងសម្បាថា ជាពួកចិន ហើយនេះគឺជាព័ត៌មានដ៏មានសារៈសំខាន់តែមួយគត់ដែលពួកគេបាននិយាយពីគាត់ ។ រឿងក្តីនេះបានបង្ហាញយ៉ាងច្បាស់ថា រាជវាំងជីរេបុនបានបែងចែកចំណាត់ថ្នាក់មនុស្សទៅតាមយសសក្តិ រីឯពួកហូឡង់វិញ បែងចែកចំណាត់ថ្នាក់នោះទៅតាមអ្វីម្យ៉ាងដែលមានលក្ខណៈដូចជា «ជាតិសាសន៍» ។ គ្មានភស្តុតាងត្រង់ណាដែលបញ្ជាក់ថា ឃាតករជាប់ចោទ (ដែលឋានៈដ៏ខ្ពង់ខ្ពស់របស់គាត់ បានបញ្ជាក់ពីការរួមបញ្ចូលអស់រយៈពេលយ៉ាងយូររបស់គាត់និងបុព្វបុរសគាត់ក្នុងសង្គមជីរេបុន ដោយមិនបាច់គិតពីអំបូរដើម) បានគិតថាខ្លួនគាត់ គឺជាជនជាតិចិនម្នាក់នោះទេ ។ ដូច្នេះ ហេតុអ្វីបានជាពួកហូឡង់មានការបែងចែកពូជសាសន៍បែបនេះ? ហេតុនេះបណ្តាលមកពីអ្វី ទើបពួកបរទេសមកតាមកប៉ាល់ធំៗ អាចស្រមៃពីជាតិសាសន៍ចិន? នេះគឺដោយសារពួកអ្នកដើរកប៉ាល់ ដែលឋិតនៅក្រោមបញ្ជាពីថ្នាក់លើ បានធ្វើដំណើរពីកំពង់ផែមួយទៅកំពង់ផែមួយទៀតមិនចេះឈប់ឈរ រវាងឈូងសមុទ្រម្រិត (មែរគី នៅប្រទេសភូមា) និងពាមទន្លេយ៉ាងសេ (នៅប្រទេសចិន) ។ ដោយមិនបានចាប់ភ្លឹកពីវិសមភាគប្រជាជននៃចក្រភពកណ្តាល (ប្រទេសចិន) អំពីភាសានិយាយខុសគ្នាជាច្រើនរបស់ពួកគេដែលមិនអាចយល់គ្នាបានទេ ហើយនិងអំពីប្រភពសង្គមនិងភូមិសាស្ត្រប្លែកៗ របស់អ្នកដែលចាកចេញពីស្រុកកំណើតរបស់ពួកគេ មករស់នៅរាយប៉ាយតាមឆ្នេរសមុទ្រអាស៊ីអាគ្នេយ៍នោះ ពួកអ្នកជំនួញហូឡង់នឹកស្រមៃដល់ជនជាតិចិនមិនចេះចប់ ដោយសារការធ្វើដំណើរឆ្លងសមុទ្ររបស់គេ ។ ករណីនេះដូចទៅនឹងករណីដែលពួកអ្នកផ្សងព្រេងជាតិអេស្ប៉ាញមើលឃើញអ្នកដទៃថា ជាអភិជន (ហ៊ីដាល់ហ្គោស) មិនចេះចប់មិនចេះហើយ ។ ដោយមានជំរឿនបែបប្រេតិដ្ឋនេះជាមូលដ្ឋាន ពួកហូឡង់បានចាប់ផ្តើមបង្ខំឲ្យអ្នកទាំងឡាយណា ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ហើយដែលខ្លួនបែងចែកថា ជាជនជាតិចិននោះ ត្រូវស្លៀកពាក់ រស់នៅ រៀបការ បញ្ចុះសព និងចែកទ្រព្យសម្បត្តិ ដោយយោងទៅលើជំរឿននោះ ។ វាគួរឲ្យកត់សម្គាល់ថា នៅក្នុងចិត្តគំនិតរបស់ពួកអេស្ប៉ាញនៅហ្វីលីពីនដែលមិនសូវធ្វើដំណើរឆ្ងាយៗ ហើយពុំជំនាញខាងពាណិជ្ជកម្ម បាននឹកប្រេតិដ្ឋអំពី

ប្រភេទជំរឿនខុសប្លែកពីនេះ ដោយហៅប្រភេទនេះថា ពួកសាំងឡី ។ «សាំងឡី» គឺមកពីពាក្យរបស់ចិនហុកគៀន «សេងលី» ដែលមានន័យថា «អ្នកជំនួញបុងធ្លៅ»[១៤] ។ គេអាចនឹកគិតអំពីអ្នកធ្វើជំរឿនដំបូងបង្អស់របស់ពួកអេស្ប៉ាញ សាកសួរទៅកាន់អ្នកជំនួញដែលធ្វើដំណើរតាមសំពៅចូលមកទីក្រុងម៉ានីលថា «អ្នកឯងជានរណា?» (អ្នកឯងជាជនជាតិអី?) ហើយពួកគេបានឆ្លើយតបវិញថា «យើង គឺជាអ្នកជំនួញ»[១៥] ។ អស់រយៈពេលជាងពីរសតវត្សរ៍ដែលជនជាតិអេស្ប៉ាញរស់នៅជាមួយពាក្យមិនច្បាស់លាស់នេះយ៉ាងងាយស្រួល ។ ពាក្យ «សាំងឡី» នេះបានក្លាយទៅជា «ចិន» វិញយ៉ាងយឺតបំផុត រហូតទាល់តែពាក្យនេះរលុបបាត់នាដើម ស.វ. ទី ១៩ ហើយត្រូវជំនួសដោយពាក្យ «ឈីណូ» (ចិន) ធ្វើតាមពួកហូឡង់ ដែលហៅចិនៗ ថា «ឈីណោ» ។

របៀបជំរឿនពិតប្រាកដរបស់អ្នកធ្វើជំរឿននៅទសវត្សរ៍ឆ្នាំ ១៨៧០ គឺមិនមែនដើម្បីបង្កើតការបែងចែកពូជសាសន៍នោះទេ ប៉ុន្តែ គឺជាការរាប់បរិមាណ ។ អ្នកគ្រប់គ្រងនាមុនសម័យអាណានិគមនៅក្នុងពិភពមឡាយូ-ជ្វា មានគោលបំណងរាប់ចំនួនប្រជាជននៅក្រោមការត្រួតត្រារបស់ពួកគេ ដើម្បីចុះបញ្ជីពន្ធអាករ ។ ពួកគេមានគោលបំណងច្បាស់លាស់និងជាក់លាក់ ដើម្បីតាមដានអ្នកដែលត្រូវបង់ពន្ធ និងកែនប្រជាជន ។ អ្នកគ្រប់គ្រងទាំងអស់នេះ ចាប់អារម្មណ៍តែលើបញ្ហាផលចំណេញខាងសេដ្ឋកិច្ចនិងធនធានយោធាប៉ុណ្ណោះ ។ របបគ្រប់គ្រងរបស់អឺរ៉ុបនាសម័យដំបូងៗ ក្នុងតំបន់អាស៊ីអាគ្នេយ៍ មានការចាប់អារម្មណ៍មិនខុសពីការគ្រប់គ្រងមុនៗ ឡើយ ។ ប៉ុន្តែ ចាប់ពីឆ្នាំ ១៨៥០ មក អាជ្ញាធរអាណានិគមនិយមបានប្រើប្រាស់នូវរបៀបរដ្ឋបាលដ៏ស្មុគស្មាញមួយចំនួនទៀត ដើម្បីរាប់ចំនួនប្រជាជនដែលរួមមានទាំងការរាប់ចំនួនស្ត្រីនិងកុមារ (ដែលក្រុមនេះមិនត្រូវបានអ្នកគ្រប់គ្រងមុនៗ គិតគូរឡើយ) ដោយផ្អែកលើតារាងមួយ ដែលគ្មានគោលបំណងខាងយកពន្ធឬយោធាតែម្តងឡើយ ។ កាលពីសម័យមុន អ្នកដែលត្រូវបង់ពន្ធនិងត្រូវកំណែន ដឹងជាក់ច្បាស់ពីការគណនាពួកគេ ។ ទាំងអ្នកគ្រប់គ្រងនិងអ្នកដែលត្រូវគេគ្រប់គ្រង យល់ដឹងពីគ្នាយ៉ាងច្បាស់លាស់អំពីបញ្ហានេះ ។ ប៉ុន្តែ លុះដល់ឆ្នាំ ១៨៧០ បើយកជាឧទាហរណ៍ អ្នកមិនបង់ពន្ធអាករដែលជាស្ត្រីមកពីកូសាំងស៊ីន អាចរស់នៅដោយសប្បាយឬមិនសប្បាយ នៅក្នុងស្រុកស្ងាត់ដោយមិនដឹងទាល់តែសោះថា រូបនាងត្រូវបានគេរាប់ដោយរបៀបនេះ ។ ចំណុចនេះហើយដែលលក្ខណៈពិសេសនៃការធ្វើជំរឿនបែបថ្មីបានកើតឡើង ។ ជំរឿននេះបានព្យាយាមរាប់យ៉ាងហ្មត់ចត់នូវចំនួនកម្មវត្ថុមួយ ដែលបានប្រតិដ្ឋឡើងមិនចេះឈប់ឈរ ។ ដោយយកតាមហេតុផលនៃការរាប់ចំនួនតាមប្រព័ន្ធបែងចែកដ៏ស្រមើស្រមៃនេះ អ្នកមកពីតំបន់កូសាំងស៊ីន ត្រូវបានគេចាត់ទុកថា ជាធាតុមួយនៅក្នុងចំណោមធាតុដទៃទៀត ក្នុងព្រំដែនដីរដ្ឋ ។ ផែនទីប្រជាសាស្ត្រថ្មីមួយបានចាក់ឫសយ៉ាងជ្រៅ ទៅក្នុងសង្គមនិងស្ថាប័ននៅពេលដែលរដ្ឋាភិបាលអាណានិគមមានទំហំកាន់តែធំនិងមានតួនាទីកាន់តែច្រើន ។ តាមរយៈផែនទីប្រឌិតនេះ រដ្ឋាភិបាលអាណានិគមបានរៀបចំឲ្យមានស្ថាប័នអប់រំ តុលាការ សុខភាពសាធារណៈ នគរបាល និងអន្តោប្រវេសន៍ថ្មីមួយ ដោយផ្អែកលើគោលការណ៍តាមលំដាប់ជនជាតិ ។ ការហូរចូលរបស់ប្រជាជន ដែលគេបានបែងចែកតាមសាលារៀន តុលាការ មន្ទីរពេទ្យ ស្ថានីយ៍ប៉ូលិស និងការិយាល័យអន្តោប្រវេសន៍ ខុសៗ គ្នានេះ បានបង្កើតជាទម្លាប់មួយ ដែលក្រោយមក បានធ្វើឲ្យក្លាយជាការពិតនៅក្នុងជីវិតសង្គមរហូតដល់គំនិតស្រមើស្រមៃដំបូងៗ របស់រដ្ឋ ។

ប៉ុន្តែ រដ្ឋតែងតែប្រឈមមុខនឹងបញ្ហាពិតប្រាកដជាច្រើន ។ បញ្ហាមួយក្នុងចំណោមបញ្ហាទាំងនោះ គឺសាសនាដែលជាមូលដ្ឋានរបស់សហគមន៍ប្រតិដ្ឋដ៏យូរអង្វែងនិងមានស្ថិរភាព ហើយមិនដើរស្របទៅតាមតារាងគ្រប់គ្រងរបស់អាណាចក្រ ។ កម្រិតនៃភាពខុសប្លែកមាននៅក្នុងរដ្ឋអាណានិគមផ្សេងៗ គ្នានៅតំបន់អាស៊ីអាគ្នេយ៍ ពួកអ្នកដឹកនាំរដ្ឋ

ទាំងនោះត្រូវបង្ខំសម្របខ្លួន ជាពិសេស ជាមួយនឹងអ្នកកាន់សាសនាអ៊ិស្លាមនិងពុទ្ធសាសនា ។ ព្រោះថា មនុស្សម្នាក់ៗជ្រើសរើសនិងគោរពទីសក្ការបូជា សាលារៀន និងតុលាការដោយខ្លួនគេផ្ទាល់ កាន់តែមានភាពគគ្រឹកគគ្រេងដោយមិនឋិតនៅក្នុងកំហិតនៃជំរឿនទេ ។ រដ្ឋអំណាចមិនអាចធ្វើអ្វីបានក្រៅពីព្យាយាមដាក់ចេញជាច្បាប់ រឹតបន្តឹងនិងធ្វើឲ្យកាន់តែមានស្តង់ដារ ក្នុងការដាក់ស្ថាប័នទាំងនេះឲ្យនៅក្រោមការគ្រប់គ្រងរបស់ខ្លួន[១៦] ។ ជាការពិតជាក់ស្តែងណាស់ វត្តអារាម វិហារអ៊ិស្លាម សាលារៀន និងតុលាការ គឺជាកន្លែងពិសេសខុសពីធម្មតា ដែលទីនោះ គឺជាតំបន់នៃសេរីភាព ហើយពេលខ្លះ ទីកន្លែងទាំងនេះ គឺជាបន្ទាយសម្រាប់អ្នកកាន់សាសនា ដែលក្រោយមកជាអ្នកជាតិនិយមប្រឆាំងនឹងអាណានិគមនិយម អាចទៅជ្រកកោនដើម្បីចេញច្បាំងនឹងរបបអាណានិគមនិយម ។ នៅពេលជាមួយគ្នានោះ ជាញឹកញាប់គេច្រើនមានសេចក្តីប្រាថ្នាចង់ឲ្យធ្វើជំរឿនតាមសហគមន៍សាសនា ដោយដាក់ការរាប់ទៅតាមគោលការណ៍នយោបាយនិងគតិយុត្ត អំពីចំនួនប្រជាជនតាមជាតិសាសន៍នៅបន្ទាប់ទៅវិញ ។ នៅក្នុងរដ្ឋទាំងឡាយនៃសហព័ន្ធមឡាយូជាដែនអាណានិគម ការងារនេះ គឺងាយស្រួលណាស់ ។ អ្នកដែលត្រូវបានគេចាត់ទុកថា ជាមឡាយូ គឺអ្នកដែលដើរតាមស្តេចស៊ុលតង់ ដែលជាអ្នកគ្រប់គ្រងដោយយោងតាមច្បាប់សាសនាអ៊ិស្លាម[១៧] ។ ដូច្នេះ អ៊ិស្លាម គឺជាឈ្មោះមួយទៀតរបស់មឡាយូ (បន្ទាប់ពីទទួលបានឯករាជ្យនាឆ្នាំ ១៩៥៧ ក្រុមនយោបាយខ្លះបានព្យាយាមហៅត្រឡប់វិញថា មឡាយូ គឺជាឈ្មោះមួយទៀតរបស់អ៊ិស្លាម) ។ ករណីនេះ ដូចទៅនឹងតំបន់ខ្លះជាអាណានិគមរបស់ហូឡង់ដែរ ដោយនៅចុងបញ្ចប់នៃសម័យអាណានិគម ស្ថាប័នផ្សព្វផ្សាយសាសនាជំច្រើន បានធ្វើពិធីប្តូរសាសនានៅក្នុងតំបន់ដ៏ធំ ហើយក៏ប្រឈមមុខនឹងឧបសគ្គច្រើនក្រាស់ក្រែលដែរ ។ នៅទសវត្សរ៍ឆ្នាំ ១៩២០ និង ១៩៣០ មានការកើនឡើងនូវនិកាយគ្រិស្តសាសនា (មានគណៈសង្ឃបាតាក់ គណៈសង្ឃការ៉ូ ហើយក្រោយមកទៀត មានគណៈសង្ឃដាយ៉ាក់ ។ល។) ដោយសាររដ្ឋអំណាចបានលែលកទុកតំបន់មួយចំនួនឲ្យក្រុមផ្សាយសាសនាផ្សេងៗ ដោយសម្អាងលើផែនទីជំរឿនរបស់ខ្លួន ។ តែរដ្ឋអំណាចនៅក្រុងបាតាវីយ៉ាពុំសូវមានជោគជ័យជាមួយសាសនាអ៊ិស្លាមប៉ុន្មានឡើយ ។ រដ្ឋអំណាចនេះមិនហ៊ានហាមឃាត់ការធ្វើធម្មយាត្រាទៅទីក្រុងម៉េក្កះ ទោះបីជាបានព្យាយាមរារាំងមិនឲ្យចំនួនអ្នកចូលធ្វើធម្មយាត្រាមានការកើនឡើង ហើយទោះជាបានធ្វើការត្រួតត្រាការធ្វើដំណើរ និងឃ្លាំមើលពួកអ៊ិស្លាមពីប៉ុស្តិ៍មួយនៅកំពង់ផែចេដ្ដះក៏ដោយ ។ មធ្យោបាយទាំងនេះមិនអាចរារាំងមិនឲ្យពួកមុស្លិមទាក់ទងជាមួយពិភពអ៊ិស្លាមខាងក្រៅ ហើយជាពិសេស ជាមួយចរន្តគំនិតថ្មីៗ ដែលមានកំណើតចេញពីទីក្រុងឡឺកែរ (នៅអេស៊ីប) បានឡើយ[១៨] ។

## ការគូសផែនទី

ប៉ុន្តែ នៅចន្លោះពេលមួយនោះ ទីក្រុងឡឺកែរនិងម៉េក្កះ លែងគ្រាន់តែជាតំបន់សក្តិសិទ្ធិរបស់ពួកមុស្លិមទៀតហើយ ។ ទីក្រុងទាំងពីរនេះ គឺជាចំណុចនៅលើក្រដាស ដូចទៅនឹងទីក្រុងប៉ារីស ម៉ូស្គូ ម៉ានីល និងការ៉ាកាសដែរ ។ ទំនាក់ទំនងរវាងចំណុចសក្តិសិទ្ធិនិងមិនសក្តិសិទ្ធិទាំងនេះ ត្រូវកំណត់ដោយការគណនាបែបគណិតវិទ្យា ។ ផែនទីមែរកាទរ[១៩] ដែលបាននាំចូលមកដោយពួកអាណានិគមនិយមអឺរ៉ុប បានចាប់ផ្តើមគូសទម្រង់ស្រមើស្រមៃនៃតំបន់អាស៊ីអាគ្នេយ៍នៅលើក្រដាស ។

នៅក្នុងនិក្ខេបបទដ៏អស្ចារ្យថ្មីមួយ ប្រវត្តិវិទូថៃឈ្មោះ ទង់ឆ័យ វិនិច្ចកូល បានពិនិត្យត្រឡប់វិញអំពីដំណើរការដ៏សាំញ៉ាំមួយ ក្នុងការបង្កើតព្រំដែនសៀមនៅរវាងឆ្នាំ ១៨៥០ ដល់ ១៩១០[២០] ។ របាយការណ៍របស់គាត់មានប្រយោជន៍យ៉ាងច្រើន ដោយផ្តល់ព័ត៌មានយ៉ាងច្បាស់លាស់ ព្រោះថា សៀមមិនដែលឋិតនៅក្រោមអាណានិគម

*ទេ តែជាចុងបញ្ចប់ ព្រំដែនរបស់ប្រទេសនេះត្រូវឋិតនៅក្រោមការកំណត់របស់ពួកអាណានិគមនិយមទៅវិញ ។ ដូច្នេះ នៅក្នុងករណីប្រទេសសៀមនេះ យើងអាចមើលឃើញពីសភាពមិនធម្មតានៃការកកើតរដ្ឋថ្មីក្នុងរចនាសម្ព័ន្ធចាស់នៃអំណាចនយោបាយ ។*

*រហូតមកទល់ការឡើងកាន់អំណាចរបស់ស្តេចសៀម ព្រះរាម ទី ៤ (ព្រះបាទសម្តេចព្រះចមក្លៅ) ដែលជាព្រះរាជាប្រកបដោយប្រាជ្ញាញាណ ក្នុងឆ្នាំ ១៨៥១ នៅក្នុងប្រទេសសៀម មានផែនទីតែ ២ ប្រភេទប៉ុណ្ណោះ ដោយសារនៅពេលនោះ យុគសម័យនៃការចម្លងវត្ថុជាចំនួនធំៗ ដោយប្រើបច្ចេកទេស មិនទាន់ចូលដល់ស្យាមប្រទេស ។ ផែនទីទាំងនោះសុទ្ធតែធ្វើឡើងដោយដៃ ។ ផែនទីទី ១ អាចទុកជា «ផែនទីចក្រវាល» ដែលតំណាងជាផ្លូវការនិងជានិមិត្តរូបនៃភពទាំងបីនៃពុទ្ធចក្រវាលបុរាណ (ត្រៃភូមិ) ។ ត្រៃភូមិនេះមិនបានគូសឡើងជាលក្ខណៈផ្តេកដូចផែនទីយើងសព្វថ្ងៃនេះទេ ។ ផ្ទុយទៅវិញ ផែនទីនេះ គឺជាលំដាប់ឋានសួគ៌ ឋាននរក ដែលគេបានបញ្ចូលក្នុងភពមនុស្សតាមអក្សរបញ្ឈរ ។ ផែនទីនេះគ្មានប្រយោជន៍សម្រាប់បង្ហាញផ្លូវក្នុងការធ្វើដំណើរទេ ។ ផែនទីប្រភេទទី ២ គឺជាផែនទីមិនមែនរបស់សាសនា តែជាផែនទីអាណាចក្រ ។ ផែនទីនេះ គឺជាគំនូសតាងសម្រាប់ដឹកនាំផ្លូវក្នុងយុទ្ធនាការយោធា និងសម្រាប់ការធ្វើដំណើរតាមមាត់សមុទ្រ ។ ដោយសារអ្នកធ្វើផែនទីមិនមានគោលគំនិតបច្ចេកទេសអំពីខ្នាតនិងទំហំ ពួកគេបានគូសផែនទីឡើងចោះៗ តាមតំបន់ ហើយចំណុចសំខាន់ៗ របស់ផែនទីទាំងនោះ ត្រូវសរសេរចំណាំអំពីរយៈពេលធ្វើដំណើរនិងបើកកប៉ាល់ ។ អ្នកគូសភាគច្រើន គូសផែនទីទឹកទន្លេក្នុងលក្ខណៈបញ្ឆិតមិនត្រង់ ដោយសារភ្នែករបស់អ្នកគូសបានផ្សាំទៅនឹងការមើលឃើញទិដ្ឋភាពប្រចាំថ្ងៃតាមលក្ខណៈផ្តេក ។ តែយ៉ាងណាក៏ដោយ ការគូសនេះក៏ទទួលឥទ្ធិពលច្រើនពីលក្ខណៈបញ្ឈរនៃផែនទីត្រៃភូមិដែរ ។ លោក ទង់ជ័យ បានបង្ហាញថា ផែនទីទាំងនោះជារបស់ក្នុងស្រុក ហើយមិនគូសពីបរិបទភូមិសាស្ត្រធំនិងស្ថិតស្ថេរជាងដូចសព្វថ្ងៃនេះទេ ដែលគេគិតពីចម្ងាយតាមការគូសបន្ទាត់ត្រង់ៗ ។ ដូច្នេះ ការបង្កើតផែនទីទំនើបដោយមើលទស្សនីយភាពពីលើមកនោះ គឺជារបស់ពួកបរទេសសុទ្ធសាធ ។*

*ផែនទីប្រភេទណាមិនដែលមានគូសព្រំដែនៗ អ្នកគូសផែនទីបែបបុរាណ មិនអាចយល់ពីអត្ថាធិប្បាយរបស់លោក រីឆាដ ម្យួរ ដូចតទៅ*[២១] *÷*

> នៅជាទីប្រសព្វនៃទឹកដីរបស់រដ្ឋពីរ ព្រំដែនអន្តរជាតិមានលក្ខណៈពិសេសមួយក្នុងការកំណត់បូរណភាពដែនដីនិងកំណត់ទំហំនៃតំបន់នយោបាយ ... ព្រំដែន ... កើតឡើងត្រង់កន្លែងដែលជាទីប្រសព្វបញ្ឈររវាងទឹកដីរបស់រដ្ឋពីរ ជួបជាមួយនឹងផ្ទៃផែនដី ... ក្នុងលក្ខណៈជាទីប្រសព្វបញ្ឈរ ព្រំដែនមិនអាចពង្រីកតាមផ្ទៃផ្តេកបានទេ ។

*បង្គោលព្រំដែនហើយនិងបង្គោលស្រដៀងនោះ ពិតជាមានប្រាកដ ហើយត្រូវបានគេបានដាក់ពង្រាយបន្ថែមទៀត នៅតាមព្រំដែនភាគខាងលិចនៃរាជាណាចក្រសៀម នៅពេលពួកអង់គ្លេសបានរំកិលចូលមកពីភូមាភាគខាងក្រោម ។ ប៉ុន្តែ បង្គោលព្រំដែនមិនត្រូវបានគេបោះបន្តយ៉ាងទៀតទាត់នៅតាមតំបន់ភ្នំនិងទន្លេ ហើយជាញឹកញាប់បង្គោលទាំងនោះត្រូវបានបោះយ៉ាងឆ្ងាយពីបង្គោលព្រំដែនដែលគូបដិបក្សម្ខាងទៀតបានបោះដែរ ។ បង្គោលទាំងនោះត្រូវបានគេមើលឃើញតាមបែបផ្ទៃផ្តេក (តាមកម្រិតដែលភ្នែកអាចមើលឃើញ មិនមែនមើលមកពីលើនោះទេ) ថា ជាចំណុចពង្រីកអំណាចអាណាចក្រ ។ នៅទសវត្សរ៍ឆ្នាំ ១៨៧០ មេដឹកនាំសៀមទើបតែចាប់ផ្តើមគិតអំពីព្រំដែនជាបន្ទាត់បន្តគ្នានៅក្នុងផែនទី តំណាងឲ្យភាពមើលមិនឃើញនៅលើដី ហើយបានគូសព្រំដែន*

ហ៊ុមព័ទ្ធដែនដីរបស់ខ្លួន ញែកចេញពីដែនដីអាណាចក្រដទៃទៀត ។ នៅឆ្នាំ ១៨៧៤ អ្នកផ្សព្វផ្សាយគ្រិស្តសាសនាជនជាតិអាមេរិកម្នាក់ ឈ្មោះ ហ្ស៊ី. ដាប់បឺលយូ. វ៉ាន់ ដៃក៍ (J. W. Van Dyke) បានបោះពុម្ពសៀវភៅភូមិសាស្ត្រដំបូង ដែលជាលទ្ធផលដំបូងនៃ «មូលធននិយមផ្នែកបោះពុម្ព» ជាការបោះពុម្ពផ្សាយដើម្បីអាជីវកម្ម ដែលសម័យនោះ បានហូរចូលមកក្នុងប្រទេសសៀម ។ ក្នុងឆ្នាំ១៨៨២ ស្តេចព្រះរាម ទី ៥ បានបង្កើតក្រុមធ្វើផែនទីពិសេសមួយនៅទីក្រុងបាងកក ។ នៅឆ្នាំ ១៨៩២ សម្តេចក្រុមព្រះយ៉ា តម្រង់រាជានុភាព រដ្ឋមន្ត្រីក្រសួងសិក្សាធិការ ដែលជាអ្នកបង្កើតប្រព័ន្ធអប់រំតាមបែបទំនើបសម្រាប់ប្រទេស បានធ្វើឲ្យមុខវិជ្ជាភូមិសាស្ត្រក្លាយជាមុខវិជ្ជាដែលត្រូវតែរៀនដោយខានមិនបាន នៅថ្នាក់មធ្យមសិក្សា ។ នៅប្រមាណឆ្នាំ ១៩០០ លោក ដាប់បឺលយូ. ហ្ស៊ី. ចន្សុន (W. G. Johnson) បានបោះពុម្ពសៀវភៅ **ភូមិសាស្ត្រស្យាម** ដែលក្លាយជាគំរូសម្រាប់ការបោះពុម្ពសៀវភៅភូមិសាស្ត្រនៃប្រទេសសៀមចាប់ពីពេលនោះរហូតមក[២២] ។ លោក ទង់ជ័យ បានសម្គាល់ថា ការជួបជុំគ្នានៃ «មូលធននិយមផ្នែកបោះពុម្ព» និងគំនិតថ្មីនៃភាពប្រាកដនិយមដោយបង្ហាញតាមរយៈផែនទីនេះ បានជះឥទ្ធិពលដល់ការប្រើប្រាស់ពាក្យនៅក្នុងនយោបាយសៀម ។ នៅរវាងឆ្នាំ ១៩០០ និង ១៩១៥ ពាក្យ «ក្រុង» និង «មឿង» ត្រូវបានបាត់បង់ភាគច្រើន ពីព្រោះតែពាក្យនេះ ប្រើសំដៅទៅលើរដ្ឋមួយដោយនិយាយតែពីរាជធានី (ក្រុង) ដែលជាកន្លែងពិសិដ្ឋ និងទីប្រជុំជនដាច់ៗពីគ្នា (មឿង)[២៣] ។ តែក្រោយមក ពាក្យនេះត្រូវបានគេជំនួសដោយពាក្យ «ប្រទេស» សម្រាប់កំណត់ទៅលើតំបន់ដែនដីដែលមិនអាចមើលឃើញនឹងភ្នែកទៅវិញ[២៤] ។

ដូចគ្នាទៅនឹងជំរឿនដែរ ផែនទីបែបអឺរ៉ុបបង្កើតឡើងដោយមានមូលដ្ឋានក្នុងការប្រមូលផ្តុំក្រុមពួក ហើយផែនទីប្រភេទនេះ បាននាំអ្នកបង្កើតការិយាធិបតេយ្យនិងអ្នកប្រើប្រាស់ ឆ្ពោះទៅរកគោលនយោបាយនានា ដែលមានលទ្ធផលចេញមកជាចលនាបដិវត្ត ។ តាំងពីលោក ចន ហារីសុន (John Harrison) បានបង្កើតនាឡិកាផ្សៀងពេលនៅឆ្នាំ ១៧៦១ ដែលអាចឲ្យយើងគណនារយៈបណ្តោយបានយ៉ាងច្បាស់នោះ គេបានបែងចែកផ្ទៃផែនដីទាំងមូលដែលមានរាងកោង ជាក្រឡាភូមិសាស្ត្រដែលបានដាក់តំបន់សមុទ្រនិងតំបន់មិនទាន់រុករកទៅក្នុងក្រឡាសម្រាប់វាស់វែង[២៥] ។ ការកិច្ចវាស់វែងនេះត្រូវធ្វើឡើងដោយអ្នករុករក អ្នកវាស់ដី និងកងកម្លាំងយោធា ។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ នាពាក់កណ្តាលទី ២ នៃ ស.វ. ទី ១៩ ជាយុគសម័យរុងរឿងរបស់អ្នកវាស់វែងដីយោធារបស់ពួកអាណានិគមនិយម និងក្រោយមកបន្តិច របស់សៀម ។ ពួកគេបន្តសកម្មភាពដាក់លំហដែនដីនៅក្រោមការពិនិត្យមើល ដូចទៅនឹងអ្នកជំរឿនដែលព្យាយាមពិនិត្យមើលមនុស្សដែរ ។ ការរៀបចំគូសផែនទីជាគូជាមួយការរៀបចំអំណាច បានដំណើរការឡើង ដោយរង្វាយក្រឡាត្រីកោណ (វិធីបែងផែនដីជាត្រីកោណដើម្បីគូសផែនទី) ដោយសង្គ្រាម និងដោយសន្ធិសញ្ញាជាបន្តបន្ទាប់ ។ ដូចលោក ទង់ជ័យ បានលើកឡើងថា[២៦] ៖

> ក្នុងទ្រឹស្តីទំនាក់ទំនងភាគច្រើន និងក្នុងន័យទូទៅ ផែនទី គឺជាភាពអរូបីបែបវិទ្យាសាស្ត្រតំណាងឲ្យភាពពិតប្រាកដ ។ ផែនទី គឺគ្រាន់តែជាតំណាងឲ្យអ្វីមួយដែលមាននៅទីនោះរួចហើយ ។ នៅក្នុងប្រវត្តិសាស្ត្រដែលខ្ញុំបានពិព័ណ៌នា ទំនាក់ទំនងរវាងអ្វីដែលត្រូវតំណាង និងរូបតំណាងនោះ ត្រូវបញ្ច្រាសមកវិញ ។ ដើម្បីគូសផែនទីមួយ គេបានគិតទុកជាស្រេចនូវរូបភាពពិតមួយដែលគេត្រូវគូស ។ និយាយម្យ៉ាងទៀត ផែនទីគឺជាគំនូសសម្រាប់អ្វីមួយ មិនមែនជាគំនូសនៃអ្វីមួយដែលវាបង្ហាញនោះទេ ... ផែនទីបានក្លាយជាឧបករណ៍ពិតប្រាកដមួយ ដើម្បីធ្វើឲ្យរូបភាពលើផ្ទៃដែនដីមានសភាពកាន់តែច្បាស់ ។ ផែនទីមានសារៈសំខាន់សម្រាប់យន្តការរដ្ឋបាលថ្មីមួយ និងសម្រាប់ទ័ពប្រើប្រាស់ដើម្បីការងាររបស់គេ ... ផែនទី គឺជាតួយ៉ាងដែលប្រតិបត្តិការរដ្ឋបាលនិងយោធាណែនាំឲ្យស្គាល់និងប្រើប្រាស់ ។

*នៅពេលឈានចូល ស.វ. ទី ២០ ដោយមានការកែទម្រង់របស់ព្រះអគ្គម្ចាស់ តម្រង់រាជានុភាពនៅឯក្រសួងមហាផ្ទៃ នៅទីបំផុត រដ្ឋបាលនៃព្រះរាជាណាចក្រសៀមបានយកគំរូការគូសផែនទីដែនដី ជាមូលដ្ឋានតាមការអនុវត្តមុនៗ របស់ប្រទេសអាណានិគមជិតខាង ។*

*ជាការគិតមិនប្រពៃសោះ ប្រសិនបើយើងមើលរំលងចំណុចប្រសព្វដ៏សំខាន់រវាងផែនទីនិងជំរឿន ។ ចំពោះផែនទីថ្មីដែលបច្ចេកទេសជំរឿនបានប្រតិដ្ឋឡើងដើម្បីកាត់ផ្តាច់យ៉ាងដាច់ខាតនូវលក្ខណៈមិនអាចកំណត់បាននៃក្រុមជនជាតិ «(ចិន)ខិក» «ជនជាតិពីស្រីលង្កាមិនមែនទមិឡ» និង «ជ្វា» ដោយកំណត់ដែនដីសម្រាប់ក្រុមជនជាតិទាំងនោះ ដើម្បីគោលបំណងនយោបាយជាច្រើន ។ ផ្ទុយទៅវិញ ជំរឿនបិតនៅក្នុងកន្ទេងផ្លូវការមួយនៃផែនទី តាមបែបរង្វាយក្រឡាត្រីកោណប្រជាសាស្ត្រមួយយ៉ាង ។*

*ក្រៅពីការផ្លាស់ប្តូរទាំងនេះ មានការកកើតឡើងនូវផែនទីពីរប្រភេទចុងក្រោយ (ផែនទីទាំងពីរនេះបង្កើតដោយរដ្ឋាភិបាលអាណានិគមចុងសម័យអាណានិគម) ដែលបង្ហាញជាមុននូវទស្សនៈជាតិនិយមជាផ្លូវការនា ស.វ. ទី ២០ នៅតំបន់អាស៊ីអាគ្នេយ៍ ។ ដោយដឹងយ៉ាងពិតប្រាកដអំពីឋានៈជាអ្នកជ្រៀតជ្រែកដើម្បីផលប្រយោជន៍របស់ពួកគេនៅក្នុងតំបន់ប្រទេសក្តៅដ៏សែនឆ្ងាយ ប៉ុន្តែដោយសារពួកគេមកពីតំបន់អារ្យធម៌មួយដែលការទទួលមរតកដីធ្លីស្របច្បាប់ និងការផ្ទេរសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ បានបង្កើតឡើងជាយូរមកហើយនោះ[២៧] ពួកអឺរ៉ុបតែងតែប៉ុនប៉ងធ្វើឲ្យការពង្រីកអំណាចរបស់ខ្លួន មានភាពស្របច្បាប់ ដោយប្រើប្រាស់វិធីជាច្រើន ដែលហាក់ដូចជាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ វិធីមួយក្នុងចំណោមវិធីទាំងនោះ គឺ «ការទទួលយកមរតក» ទឹកដីស្នងព្រះរាជាជនជាតិដើម ដែលពួកអឺរ៉ុបបានទម្លាក់ចោល ឬដាក់នៅក្រោមការត្រួតត្រារបស់ខ្លួន ។ អ្នកជ្រៀតជ្រែកទាំងនោះ បានប្រើវិធីផ្សេងទៀត គឺបង្កើតឡើងវិញនូវប្រវត្តិសាស្ត្ររបស់សម្បត្តិទាំងឡាយដែលជាកម្មសិទ្ធិថ្មីៗ របស់ពួកគេ ជាពិសេសដើម្បីទប់ទល់ជាតិអឺរ៉ុបដទៃទៀត ។ ដូច្នេះ រូបរាង «ផែនទីប្រវត្តិសាស្ត្រ» ជាពិសេសនៅចុង ស.វ. ទី ១៩ នោះ ត្រូវបានគេគូសវាសឡើង ដើម្បីបង្ហាញដែនដីដ៏តូចចង្អៀតនិងដ៏ចាស់បុរាណនៅក្នុងការរៀបរាប់ថ្មីតាមបែបសិល្បៈផែនទី ។ តាមរយៈការដាក់តម្រៀបផែនទីរបៀបនេះជាលំដាប់លំដោយ រឿងរ៉ាវស្តីពីរាជាណាចក្រទាំងឡាយក្នុងវិស័យនយោបាយផង ពង្សាវតារផង បានលេចជារូបរាងឡើង ហើយពេលខ្លះ រួមមានជាមួយនឹងជម្រៅប្រវត្តិសាស្ត្រដ៏ធំធេងទៀតផង[២៨] ។ បន្តបន្ទាប់មកទៀត រឿងរ៉ាវនេះត្រូវបាន «រដ្ឋជាតិ» ដែលទទួលបានឯករាជ្យនៅ ស.វ. ទី ២០ យកមកប្រើ (ទោះជាមានការកែប្រែខ្លះៗ ក៏ដោយ) ដោយបានក្លាយទៅជាអ្នកស្នងមរតករបស់រដ្ឋាភិបាលអាណានិគម[២៩] ។*

*ផែនទីប្រភេទទី ២ នោះ គឺជាផែនទីឡូហ្គោ (ផែនទីរូបតាង ឬ ផែនទីបែបនិមិត្តសញ្ញា) ។ ប្រភពដើមរបស់ផែនទីនេះ គឺជាការអនុវត្តរបស់មហាអំណាចក្នុងការលាបព័ណ៌ប្រទេសអាណានិគមរបស់គេនៅលើផែនទី ។ ក្នុងផែនទីរបស់មហាអំណាចអង់គ្លេស ប្រទេសអាណានិគមរបស់អង់គ្លេសត្រូវគេប្រើព័ណ៌ក្រហម-ផ្កាឈូក ប្រទេសអាណានិគមរបស់បារាំងសែស ព័ណ៌ស្វាយ-ខៀវ ហូឡង់ ព័ណ៌ត្នោត-លឿង ។ល។ ដោយសារការលាបព័ណ៌បែបនេះ ដែនដីអាណានិគមមានសភាពដូចជាបំណែកដាច់ៗ របស់រូបភាពផ្ទាំងធំមួយ ។ ក្នុងរូបភាពបែបនេះ បំណែកនីមួយៗ អាចផ្តាច់ចេញពីបរិបទភូមិសាស្ត្ររបស់វា ។ នៅក្នុងទម្រង់ចុងក្រោយ ការបកស្រាយពន្យល់ដូចជា ខ្សែបណ្តោយ ខ្សែទទឹង ឈ្មោះទីកន្លែង សញ្ញាអំពីទន្លេសមុទ្រ ភ្នំ និងប្រទេសជិតខាង អាចត្រូវបានគេដកចេញ ។ និមិត្តសញ្ញាបែបនេះ មិនអាចពន្យល់អំពីពិភពលោកបានទេ ។ ប៉ុន្តែ នៅក្នុងទម្រង់នេះ ផែនទី*

ផ្តើមចូលទៅរកការផលិតនូវរបស់របរជាច្រើន ក្នុងទម្រង់ដទៃទៀត ដូចជា រូបភាពផ្សាយធំៗ ត្រាផ្លូវការ ក្បាលលិខិត កម្រងទស្សនាវដ្តីនិងកម្រងសៀវភៅ កម្រាលតុ រូបភាពបិទតាមជញ្ជាំងសណ្ឋាគារ ។ ផែនទីបែបនេះបានដក់ជាប់យ៉ាងជ្រៅទៅក្នុងការនឹកគិតរបស់មនុស្សទូទៅ ដោយសារគេអាចមើលឃើញនៅគ្រប់ទីកន្លែង ហើយអាចស្គាល់រូបភាពផែនទីទាំងនេះបានភ្លាមៗ ។ រូបផែនទីទាំងនេះបានបង្កើតបានជានិមិត្តសញ្ញាដ៏មានឥទ្ធិពលសម្រាប់ការកកើតគំនិតជាតិនិយមប្រឆាំងអាណានិគមនិយម[៣០] ។

ប្រទេសឥណ្ឌូនេស៊ីទំនើប គឺជាឧទាហរណ៍ដ៏ល្អនិងដ៏ឈឺចាប់មួយនៃដំណើរការនេះ ។ ក្នុងឆ្នាំ ១៨២៨ ពួកហូឡង់បានតាំងភូមិមួយជាលើកដំបូងនៅកោះនូវែលហ្គីនេ[៣១] តែភូមិនោះត្រូវបំផ្លាញ់ដោយការចាញ់គ្រុន ។ ទោះជាពួកគេត្រូវបោះបង់ការតាំងលំនៅឋាននៅកន្លែងនេះនៅក្នុងឆ្នាំ ១៨៣៦ ក៏ដោយ ក៏ប្រទេសហូឡង់បានប្រកាសឲ្យដឹងពីការត្រួតត្រារបស់គេទៅលើទឹកដីមួយផ្នែករបស់កោះនេះ ដែលលាតសន្ធឹងទៅទិសខាងលិចលើរយៈបណ្តោយ ១៤១ អង្សា (ជាខ្សែមិនអាចមើលឃើញ ដែលមិនទាក់ទងទៅនឹងអ្វីនៅលើដីនោះទេ តែជាការកម្រិតទឹកដីដែលនៅមិនទាន់កំណត់របស់ពួកគេ) លើកលែងតែតំបន់ឆ្នេរសមុទ្រមួយផ្នែកដែលជាដែនដីរបស់ស្តេចស៊ុលតង់នៃប្រទេសទីដូរ៉េប៉ុណ្ណោះ ។ ទើបតែនៅក្នុងឆ្នាំ ១៩០១ ប៉ុណ្ណោះ ដែលពួកហូឡង់បានទិញយកដែនដីរបស់ស៊ុលតង់នោះ ហើយដាក់បញ្ចូលតំបន់នូវែលហ្គីនេខាងលិចទៅក្នុងតដែនដីត្រួតត្រារបស់ពួកហូឡង់ (ប្រជុំកោះឥណ្ឌាខាងកើតរបស់លន្ដា) ដែលស្របពេលនឹងការធ្វើឲ្យក្លាយជារូបសញ្ញាឡើង ។ តំបន់មួយភាគធំនៅតែជាសលាតនៅលើផែនទីរហូតដល់ក្រោយសង្គ្រាមលោកលើកទី ២ ។ មានតែជនជាតិហូឡង់មួយក្តាប់តូច ភាគច្រើនជាអ្នកផ្សាយសាសនា អ្នករុករករ៉ែ និងជាអ្នកយាមគុកពិសេសសម្រាប់ដាក់ពួកជាតិនិយមឥណ្ឌូនេស៊ីជាដើម ។ វាលភក់នៅខាងជើងម្រ៉ៅកេ និងនៅចុងបំផុតនៃភាគខាងត្បូងឆៀងខាងកើតនៃតំបន់នូវែលហ្គីនេរបស់ហូឡង់ ត្រូវគេជ្រើសរើសធ្វើជាតំបន់សម្រាប់សម្រួលដល់បញ្ហាខាងលើ ដោយសារតំបន់នេះនៅដាច់ស្រយាលពីផ្នែកដទៃនៃប្រទេសអាណានិគម ហើយប្រជាពលរដ្ឋមូលដ្ឋានដែលជាប្រជាជនយុគសម័យថ្មនោះ មិនមានគំនិតជាតិនិយមសោះឡើយ[៣២] ។

ដោយសារមានការឃុំអ្នកជាតិនិយមក្នុងសភាពការណ៍យ៉ាងធ្ងន់ធ្ងរនៅតំបន់ភាគខាងលិចកោះនូវែលហ្គីនេ ទើបតំបន់នេះបានក្លាយជាចំណុចកណ្តាលនៃការតស៊ូប្រយុទ្ធប្រឆាំងនឹងរបបអាណានិគម ហើយត្រូវបានចាត់ទុកជាតំបន់ពិសិដ្ឋនៅក្នុងការគិតអំពីបញ្ហាជាតិ ។ ពួកគេគិតថា ឥណ្ឌូនេស៊ីសេរីលាតសន្ធឹងពីសាបាំង (នៅចុងខាងជើងឆៀងខាងលិចនៃកោះស៊ុម៉ាត្រា) ទៅដល់ម្រ៉ៅកេ ។ គ្មានអ្វីចម្លែកនោះទេដែលថា រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៦០ ក្រៅពីអ្នកជាប់ឃុំពីរបីរយនាក់នោះ អ្នកជាតិនិយមដទៃទៀតមិនដែលបានឃើញកោះនូវែលហ្គីនេដោយផ្ទាល់ភ្នែកទេ ។ ប៉ុន្តែ ផែនទីរូបតាង (ផែនទីឡូហ្គោ) របស់ហូឡង់បានគូសបង្ហាញពីនូវែលហ្គីនេខាងលិចដោយគ្មានអ្វីនៅខាងកើត ហើយទាំងមិនដឹងខ្លួន ពួកគេបានពង្រឹងចំណងនឹកស្រមៃជាច្រើន ។ នៅពេលពួកហូឡង់ត្រូវបង្ខំឲ្យប្រគល់ដែនកោះទៅឲ្យសហរដ្ឋឥណ្ឌូនេស៊ី (បន្ទាប់ពីសង្គ្រាមប្រឆាំងអាណានិគមនិយមដ៏ជូរចត់នៅឆ្នាំ ១៩៤៥-៤៩) ពួកហូឡង់មានបំណងចង់បំបែកនូវែលហ្គីនេខាងលិចម្តងទៀត ដោយដាក់តំបន់នេះឲ្យឋិតនៅក្រោមការគ្រប់គ្រងអាណានិគមជាបណ្តោះអាសន្ន ហើយរៀបចំតំបន់នេះឲ្យក្លាយទៅជាជាតិឯករាជមួយ ។ រហូតទល់ឆ្នាំ ១៩៦៣ ទើបហូឡង់លះបង់នូវគំនិតនេះចោលដោយសារមានសម្ពាធការទូតរបស់អាមេរិក និងសម្ពាធយោធាពីឥណ្ឌូនេស៊ី ។ ហើយទើបតែដល់ពេលនោះ ទើបលោកប្រធានាធិបតី ស៊ុកាណ្ហូ បានធ្វើទស្សនកិច្ចនៅតំបន់នោះជាលើកទី ១ នៅក្នុងអាយុ ៦២ ឆ្នាំ ។ តំបន់នោះ គឺជាតំបន់ដែលលោកទាមទារមិនចេះនឿយហត់អស់រយៈពេល

ជាង ៤០ ឆ្នាំមកហើយ ។ ទំនាក់ទំនងដ៏ឈឺចាប់បន្ទាប់មកទៀត រវាងប្រជាជននៅនូវែលហ្គីនេខាងលិច ហើយនិងប្រតិភូតំណាងមកពីរដ្ឋឥណ្ឌូនេស៊ីឯករាជ អាចបង្ហាញការពិតថា ប្រជាជនឥណ្ឌូនេស៊ី បានចាត់ទុកប្រជាជននូវែលហ្គីនេទាំងនោះ ជាបងប្អូនយ៉ាងស្មោះស្ម័គ្រ ពិតក្តីមិនពិតក្តី ប៉ុន្តែប្រជាជននៅនូវែលហ្គីនេទាំងនោះ គិតខុសពីនេះវិញ[៣៣] ។

ភាពខុសប្លែកនេះ ពាក់ព័ន្ធទៅនឹងជំរឿននិងការគូសផែនទី ។ ភាពដាច់ស្រយាលនិងព្រៃភ្នំច្រើនរបស់ដែនដីនូវែលហ្គីនេ បានបង្កើតឲ្យមានភាសាខុសគ្នាជាច្រើន ។ នៅពេលដែលហូឡង់ចាកចេញពីតំបន់នេះនៅក្នុងឆ្នាំ ១៩៦៣ ពួកគេបានប៉ាន់ស្មានឃើញថា នៅក្នុងចំណោមប្រជាជន ៧០០.០០០ នាក់នេះ មាននិយាយភាសាមិនងាយយល់គ្នាជាង ២០០ ភាសា[៣៤] ។ ក្រុមមនុស្សរស់នៅដាច់ស្រយាលជាច្រើនមិនដឹងថាមានក្រុមដទៃរស់នៅក្នុងកោះនោះទេ ។ ប៉ុន្តែចាប់ពីឆ្នាំ ១៩៥០ មក អ្នកផ្សាយសាសនានិងមន្ត្រីហូឡង់បានព្យាយាមយ៉ាងខ្លាំងជាលើកដំបូង ដើម្បីបង្រួបបង្រួមពួកគេដោយធ្វើជំរឿន ពង្រីកបណ្តាញទំនាក់ទំនង បង្កើតសាលារៀន និងបង្កើតវេទនាសម្ព័ន្ធរដ្ឋបាលដែលនៅខាងលើកុលសម្ព័ន្ធ ។ ការប្រឹងប្រែងទាំងនេះបានចាប់ផ្តើមធ្វើឡើងដោយរដ្ឋាភិបាលអាណានិគម ដែលមានចំណុចពិសេសមួយ គឺប្រើភាសាមឡាយូជាភាសារាជការ មិនមែនភាសាអឺរ៉ុបនោះទេ[៣៥] ។ ដូច្នេះ ទើបនូវែលហ្គីនេខាងលិចបានប្រើប្រាស់ភាសាដូចទៅនឹងភាសាឥណ្ឌូនេស៊ី (ដែលក្រោយមក ក្លាយជាភាសាជាតិ) ។ អ្វីដែលគួរឲ្យអស់សំណើចនោះ គឺថា ភាសាឥណ្ឌូនេស៊ី (បាហាសាអិណ្ឌូនេស្យា) ក្លាយជាភាសាលាយចូលគ្នាសម្រាប់ជនជាតិនូវែលហ្គីនេនិងទស្សនៈជាតិនិយមរបស់ប៉ាពួខាងលិច[៣៦] ។

ប៉ុន្តែ អ្វីដែលតែងតែនាំឲ្យពួកអ្នកជាតិនិយមប៉ាពួខាងលិចមានជម្លោះជាមួយគ្នាជាញឹកញាប់នោះ (ជាពិសេសក្រោយឆ្នាំ ១៩៦៣) គឺរឿងផែនទី ។ ទោះបីជារដ្ឋាភិបាលឥណ្ឌូនេស៊ីបានប្តូរឈ្មោះតំបន់នេះពី នូវែលហ្គីនេខាងលិច ទៅជា អ៊ីរៀនបារ៉ាត់ (អ៊ីរៀនខាងលិច) និងក្រោយមកទៀតជា អ៊ីរៀនជ័យា ក៏ដោយ ក៏ប្រជាជនតំបន់នេះមើលតំបន់នេះតាមរយៈផែនទីរបស់ពួកអាណានិគមនិយម ។ ពួកអ្នកនរវិទ្យា អ្នកផ្សាយសាសនា និងមន្ត្រីក្នុងស្រុក ប្រហែលជាដឹងនិងគិតអំពីជនជាតិអណ្តានី អាស្មាត់ ហើយនិងដៅឌី ។ ប៉ុន្តែ រដ្ឋាភិបាលទាំងមូល (សូម្បីតែប្រជាជនឥណ្ឌូនេស៊ីទាំងមូល) ហៅជនជាតិផ្សេងៗ ទាំងនេះថា «អូរ៉ាំងអ៊ីរៀន» (មនុស្សអ៊ីរៀន) ដែលជាឈ្មោះមាននៅលើផែនទី ។ ដោយសារឈ្មោះនេះជាឈ្មោះទើបនឹងបង្កើតថ្មីៗ គេស្រមើស្រមៃពីជនជាតិអ៊ីរៀនថា មានទ្រង់ទ្រាយមុខដូចដោះពាក់បំពង់បំបាំងលិង្គ ។ល។ របៀបដែលសហគមន៍ជាតិអ៊ីរៀន (ឋិតនៅចន្លោះខ្សែស្របទី ១៤១ និងខេត្តភាគខាងត្បូងនិងខាងជើងនៃប្រជុំកោះម៉ូលុកា) កំពុងលេចឡើង អាចប្រដូចបាននឹងរបៀបដែលគេបានស្រមៃពីឥណ្ឌូនេស៊ីជាដំបូងនៅក្នុងវេទនាសម្ព័ន្ធនៃការគិតអំពីជាតិសាសន៍នាដើមស.វ. ទី ២០ នោះ ។ នៅពេលដែលអ្នកនាំពាក្យដ៏ល្បីជាងគេរបស់អ៊ីរៀនជ័យា ឈ្មោះ អារណុលដ៍ អាប់ (Arnold Ap) ត្រូវរដ្ឋអំណាចឥណ្ឌូនេស៊ីធ្វើឃាតនៅឆ្នាំ ១៩៨៤ គាត់ជាអ្នកអភិរក្សសារមន្ទីរជាតិ ដែលឧទ្ទិសចំពោះវប្បធម៌ក្នុងស្រុករបស់ភូមិភាគអ៊ីរៀន ។

## ការតាំងបង្ហាញ

ភាពទាក់ទិនគ្នារវាងមុខរបររបស់លោក អាប់ និងការសម្លាប់គាត់ មិនមែនជារឿងចៃដន្យទេ ។ ទាំងសារមន្ទីរ និងការគិតអំពីការតាំងបង្ហាញអ្វីផ្សេងៗ គឺជារឿងនយោបាយយ៉ាងជ្រាលជ្រៅ ។ សារមន្ទីររបស់គាត់ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលក្រុងហ្សាការតា បានបង្ហាញឲ្យយើងឃើញពីរបៀបដែលប្រជាជាតិឥណ្ឌូនេស៊ី ដែល

ទើបតែកើតថ្មីនេះ បានរៀនពីពួកអាណានិគមនិយមហូឡង់នោះ ។ ការរីកដុះដាលនៃសារមន្ទីរនៅតំបន់អាស៊ីអាគ្នេយ៍ បង្ហាញអំពីដំណើរការទូទៅនៃមត៌កនយោបាយមួយ ។ ដើម្បីយល់អំពីដំណើរការទាំងអស់នេះ ទាមទារឲ្យគិតពីបុរាណវិទ្យាថ្មីៗ របស់ពួកអាណានិគមនិយមនៅ ស.វ. ទី ១៩ ដែលបង្កើតឲ្យមានជាសារមន្ទីរឡើង ។

រហូតមកទល់ដើម ស.វ. ទី ១៩ ពួកអាណានិគមនិយមនៅតំបន់អាស៊ីអាគ្នេយ៍បានបង្ហាញការចាប់អារម្មណ៍តិចតួចណាស់ចំពោះបូជនីយដ្ឋានបុរាណនៃអារ្យធម៌ទាំងឡាយណា ដែលគេគ្រប់គ្រង ។ លោក ថូម៉ាស់ ស្តែមហ្វដ រ៉ាហ្វលស៍ (Thomas Stamford Raffles) ដែលជាប្រតិភូរបស់រដ្ឋាភិបាលអង់គ្លេសនៅក្រុងកល់កាត្តា ជាមន្ត្រីពួកអាណានិគមនិយមដំបូងដ៏គួរឲ្យចាប់អារម្មណ៍ម្នាក់ ដែលមិនគ្រាន់តែមានប្រមូលទុកនូវវត្ថុសិល្បៈក្នុងស្រុកដ៏ច្រើននោះទេ ថែមទាំងជាមនុស្សដំបូងបង្អស់ដែលសិក្សាអំពីប្រវត្តិរបស់វត្ថុទាំងនេះផង[៣៧] ។ ក្រោយមកទៀត ភាពអស្ចារ្យរបស់ប្រាសាទបូរ៉ូប៊ូឌួរ អង្គរ ពុកាម (បាហ្កាន) និងតំបន់បុរាណដទៃទៀត ត្រូវគេរើកកាយ កាប់ឆ្ការសម្អាតព្រៃ វាស់វែង ថតរូប និងជួសជុល ធ្វើរបង វិភាគ និងដាក់បង្ហាញ[៣៨] ។ ស្ថាប័នបម្រើវិស័យបុរាណវិទ្យារបស់ពួកអាណានិគមនិយម បានក្លាយជាស្ថាប័នដ៏មានឥទ្ធិពលនិងកិត្តិសព្ទ ហើយអំពាវនាវឲ្យពួកមន្ត្រីមានសមត្ថភាពចូលមកបម្រើការ[៣៩] ។

ដើម្បីស្រាវជ្រាវឲ្យដឹងថា ហេតុអ្វីបានជាកើតរឿងនេះឡើង ហើយកើតនៅពេលណានោះ យើងត្រូវចំណាយពេលច្រើនដើម្បីឈ្វេងយល់ ។ ប៉ុន្តែ នៅទីនេះ ប្រហែលជាគ្រប់គ្រាន់ហើយក្នុងការលើកឡើងថា ការផ្លាស់ប្តូរជាប់ទាក់ទងទៅនឹងការធ្លាក់ចុះរបបអាណានិគម-ពាណិជ្ជកម្មនៃក្រុមហ៊ុនឥណ្ឌាខាងកើតចំនួន ២ និងការលេចឡើងនូវទំនាក់ទំនងដោយផ្ទាល់រវាងដែនដីអាណានិគមទំនើបពិតប្រាកដ ជាមួយនឹងមាតុប្រទេស (មជ្ឈប្រទេស)[៤០] ។ កិត្យានុភាពរបស់រដ្ឋអាណានិគមត្រូវបានភ្ជាប់ទៅនឹងមជ្ឈប្រទេស ។ យើងអាចកត់សម្គាល់អំពីរបៀបដែលគេបានផ្តោតការប្រឹងប្រែងខាងបុរាណវិទ្យាទៅលើការជួសជុលបូជនីយដ្ឋានយ៉ាងខ្លាំងក្លា (ហើយគួរកត់សម្គាល់របៀបដែលបូជនីយដ្ឋានទាំងនេះចាប់ផ្តើមដាក់ក្នុងផែនទីសម្រាប់ចែកចាយនិងតាំងជាសាធារណៈ ។ នេះ គឺជាប្រភេទជំរឿនមួយទៀត) ។ ការគូសបញ្ជាក់នេះបានឆ្លុះបង្ហាញពីប្រជាប្រិយភាពនៃអ្វីៗ ដែលមកពីបូព៌ាប្រទេស ។ ប៉ុន្តែ ប្រាក់មូលនិធិដ៏ច្រើនសម្រាប់ការងារនេះ អាចឲ្យយើងប៉ាន់ស្មានបានថា រដ្ឋមានគោលបំណងដោយផ្ទាល់ដោយគ្មានមូលហេតុវិទ្យាសាស្ត្រអ្វីទាំងអស់ ។ មានការលើកពីមូលហេតុបីយ៉ាងព្រមគ្នា ដែលមូលហេតុចុងក្រោយហាក់ដូចជាមានសារៈសំខាន់ជាងគេ ។

មូលហេតុទី ១ គឺពេលវេលារបស់សន្ទុះផ្នែកបុរាណវិទ្យាបានស្របពេលជាមួយនឹងការតស៊ូនយោបាយ ទៅលើនយោបាយអប់រំរបស់រដ្ឋអំណាច[៤១] ។ មនុស្សដែលមានគំនិតជឿនលឿនឈានទៅមុខ ជាអ្នកអាណានិគមនិយមក្តី ពួកអ្នកស្រុកដើមក្តី ទាមទារឲ្យមានការដាក់ទុនយ៉ាងច្រើនទៅក្នុងការអប់រំបែបទំនើប ។ តែមានគំនិតប្រឆាំងពីពួកអ្នកអភិរក្ស ដែលភ័យខ្លាចលទ្ធផលរយៈពេលវែងនៃប្រព័ន្ធអប់រំនោះ ហើយមានបំណងចង់ឲ្យអ្នកស្រុកដើមនៅតែដូចដើម ។ ដូច្នេះហើយ ទើបការជួសជុលតំបន់បុរាណវិទ្យាទាំងនោះ (ក្លាមនោះ រដ្ឋបានឧបត្ថម្ភឲ្យបោះពុម្ពអត្ថបទអក្សរសិល្ប៍បុរាណ) គឺជាកម្មវិធីអប់រំបែបអភិរក្ស ដែលជាលេសប្រឆាំងទៅនឹងសម្ពាធនៃការរីកចម្រើន ។ មូលហេតុទី ២ នោះ គឺកម្មវិធីជាផ្លូវការនៃការជួសជុលបុរាណវត្ថុទាំងនេះ តែងតែដាក់អ្នកសាងបូជនីយដ្ឋានហើយនិងពួកអាណានិគមតាមឋានានុក្រមយ៉ាងជាក់លាក់មួយ ។ ក្នុងករណីខ្លះ ឧទាហរណ៍ដូចជានៅសម័យក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់ ដែលរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៣០ នៅរក្សាគំនិតមួយថា អ្នកស្ថាបនាបូជនីយដ្ឋានទាំងនោះ មិនមែនជា

ជនជាតិដើមរបស់អ្នកស្រុកសម័យនេះទេ ពួកគេ គឺជាជនអន្តោប្រវេសន៍ឥណ្ឌា[៤២] ។ ក្នុងករណីផ្សេងវិញ ដូចជានៅប្រទេសភូមា អ្វីដែលគួរឲ្យនឹកគិតនោះ គឺភាពចុះដុនដាបរបស់អាណាចក្រ ដែលបានបណ្តាលឲ្យអ្នកស្រុកសព្វថ្ងៃ ពុំអាចមានសមត្ថភាពឲ្យធ្វើដូចបុព្វបុរសរបស់គេបាន ។ ទៅតាមទស្សនៈនេះ ការសាងសង់ឡើងវិញ (ដែលនៅព័ទ្ធជុំវិញដោយភាពក្រលំបាក) បានប្រាប់អ្នកស្រុកទាំងនោះថា៖ វត្តមានរបស់ពួកយើង (ពួកអាណានិគមនិយម) សបង្ហាញឲ្យឃើញថា ពួកអ្នកឯងលែងមានសមត្ថភាពដ៏អស្ចារ្យនិងអាចគ្រប់គ្រងខ្លួនឯងបានទៀតហើយ ។

មូលហេតុទី ៣ អាចនាំយើងឲ្យចូលកាន់តែជ្រៅនិងកាន់តែជិតនិងផែនទី ។ ដូចយើងបានឃើញពីពេលមុនរួចមកហើយ នៅក្នុងការពិភាក្សាអំពីផែនទីប្រវត្តិសាស្ត្រ អំពីរបៀបដែលរបបអាណានិគមនិយមចាប់ផ្តើមភ្ជាប់ខ្លួនគេទៅនឹងបុរាណកាលក៏ដូចជាការច្បាំងដណ្តើម ។ មុនដំបូង ពួកគេធ្វើយ៉ាងនេះ ដើម្បីមូលហេតុវៀចវេរផង និងឲ្យស្របច្បាប់ផង ។ តែពេលចេះតែកន្លងទៅ ហើយការនិយាយជាសាធារណៈគ្មានសំចៃអំពីសិទ្ធិច្បាំងដណ្តើម មានកាន់តែតិចទៅៗ ហើយការប្រឹងប្រែងដើម្បីបង្កើតនូវភាពស្របច្បាប់មានកាន់តែច្រើនឡើង ។ មានជនជាតិអឺរ៉ុបកើតនៅប្រទេសអាស៊ីអាគ្នេយ៍កាន់តែច្រើន ហើយពួកគេប៉ុនប៉ងយកតំបន់នេះជាស្រុករបស់ខ្លួន ។ បុរាណវត្ថុមានទំនាក់ទំនងកាន់តែច្រើនឡើងជាមួយនឹងវិស័យទេសចរណ៍ បានធ្វើឲ្យរដ្ឋអំណាចក្លាយជាអ្នកថែរក្សាប្រពៃណីទូទៅជាមួយនឹងប្រពៃណីក្នុងស្រុក ។ រមណីយដ្ឋានពិសិដ្ឋចាស់បុរាណ បានដាក់បញ្ចូលទៅក្នុងផែនទីដែនដីអាណានិគម ហើយកិត្យានុភាពបុរាណរបស់ទីតាំងទាំងនេះឋិតនៅលើផែនទី (ប្រសិនបើទីតាំងទាំងនេះបាត់បង់ទៅហើយ រដ្ឋអំណាចនឹងធ្វើឲ្យមានជីវិតឡើងវិញ) ។ ស្ថានភាពនេះត្រូវបានគេឆ្លុះបញ្ចាំងតាមរយៈការជួសជុលបុរាណស្ថាន ដោយជាញឹកញាប់ មានដាំស្មៅដែលគេបានតម្រឹមនៅជុំវិញ ហើយតែងតែមានចារឹកសរសេរពន្យល់ថ្ងៃខែបញ្ចប់ ហើយមានដាំកូនរុក្ខជាតិនៅទីនេះបុទីនោះ ។ ជាងនេះទៅទៀត តំបន់ប្រាសាទទាំងនោះ មិនអនុញ្ញាតឲ្យមានមនុស្សនៅទេ លើកលែងតែពួកទេសចរ (គេធ្វើយ៉ាងណាកុំឲ្យមានការប្រារព្ធពិធីសាសនាដូចដែលធ្លាប់មានកន្លងទៅឡើយ) ។ តាមការដាក់តាំងបង្ហាញរបៀបនេះ បូជនីយដ្ឋានទាំងអស់ត្រូវបានគេដូរតួនាទីឲ្យក្លាយដូចជាកេតនភ័ណ្ឌ (គ្រឿងឥស្សរិយយស) សម្រាប់រដ្ឋអំណាចអាណានិគមផ្លូវលោកមួយ ។

ប៉ុន្តែ ដូចដែលបានសម្គាល់ពីលើមក លក្ខណៈសំខាន់នៃឧបករណ៍របស់រដ្ឋអំណាចក្រៅសាសនចក្រនេះ គឺជាលទ្ធភាពអាចផ្សាយបន្តបាន តាមរយៈការបោះពុម្ពផ្សាយនិងរូបថត ។ ការដែលអាចធ្វើបានបែបនេះ ក៏មកពីមូលហេតុដែលអ្នកគ្រប់គ្រងពុំមានជំនឿទៅលើភាពសក្តិសិទ្ធិនៃរមណីយដ្ឋានទាំងនេះដែរ ។ យើងអាចឃើញជំនឿននៅគ្រប់ទីកន្លែងដូចតទៅ៖ (១) មាននូវរបាយការណ៍បច្ចេកទេសដ៏ស្មុគស្មាញនិងដ៏សម្បើមខាងបុរាណវិទ្យា ដែលមានទាំងរូបថតដ៏ច្រើន ការកត់ត្រាពីដំណើរការស្តាបនាឡើងវិញ ការកត់សម្គាល់ប្រាសាទបែកបាក់ដោយឡែកពីគ្នា ។ (២) មានសៀវភៅបង្ហាញសម្រាប់សាធារណជនប្រើប្រាស់ រួមបញ្ចូលទាំងរូបតំណាងឲ្យរមណីយដ្ឋានធំៗ ដែលត្រូវជួសជុលនៅក្នុងដែនដីអាណានិគម (នឹងមានភាពប្រសើរជាងនេះ ប្រសិនបើនៅក្រោមការគ្រប់គ្រងរបស់ហូឡង់ វិហារសាសនាហិណ្ឌូនិងពុទ្ធសាសនាអាចដាក់ជាមួយវិហារអ៊ិស្លាម ដែលទើបនឹងជួសជុល)[៤៣] ។ ដោយសារមូលធនវិវត្តលើការបោះពុម្ពផ្សាយ ប្រជានុរាស្ត្រអាចបានជំរឿនបែបរូបភាពនៃបេតិកភណ្ឌជាតិមួយយ៉ាងបាន ទោះជាថ្លៃក្តី មិនថ្លៃក្តី ។ (៣) ការធ្វើជារូបតាងទូទៅ អាចដំណើរការ

ទៅបាន អាស្រ័យដោយការគូសបញ្ជាក់ពីដំណើរការខាងលើ ។ តែមប្រៃសណីយ៍ដែលមានបោះពុម្ពរូបសត្វស្លាបប្រទេសក្តៅ ផ្លែឈើ ពពួកសត្វ ហើយនិងរូបបុរាណស្ថាន គឺជាឧទាហរណ៍មួយក្នុងករណីនេះ ។ បណ្ណជូនពរនិងសៀវភៅសិក្សាមានលំនាំដូចគ្នានេះដែរនោះ គឺជាការបោះជំហានទៅរកទីផ្សារដែលមានដូចជា សណ្ឋាគារ បាហ្កាន មាន់ចៀនប្រូប៊ូឌួរ ជាដើម ។ល។

នៅពេលដែលបុរាណវិទ្យា (ការសិក្សាពីវត្ថុបុរាណ) ទាំងនោះ ដែលចាប់មានភាពចាស់ទុំនៅក្នុងយុគសម័យការចម្លងដោយបច្ចេកទេស គឺជារឿងនយោបាយនោះ វាគឺជារឿងនយោបាយក្នុងកម្រិតជ្រៅមួយដែលស្ទើរតែគ្មាននរណាម្នាក់រួមទាំងមន្ត្រីនៅក្នុងរដ្ឋាភិបាលអាណានិគម (មុនទសវត្សរ៍ឆ្នាំ ១៩៣០ មន្ត្រីក្នុងរដ្ឋាភិបាលអាណានិគម ៩០ ភាគរយ គឺជាអ្នកស្រុកអាស៊ីអាគ្នេយ៍) បានយល់អំពីការណ៍នេះ ។ រឿងនេះបានក្លាយជារឿងធម្មតារៀងរាល់ថ្ងៃ ។ នោះ គឺជាការផ្សាយគ្មានឈប់ឈរនៃកេតនភ័ណ្ឌទាំងនោះ ដែលបង្ហាញប្រាប់អំពីឥទ្ធិពលពិតប្រាកដរបស់រដ្ឋអំណាច ។

គេប្រហែលជាមិនសូវជាភ្ញាក់ផ្អើលប៉ុន្មានទេ នៅពេលរដ្ឋាភិបាលក្រោយសម័យទទួលបានឯករាជ្យជាច្រើនយកគំរូតាមទម្រង់នៃការតាំងបង្ហាញបែបនយោបាយនេះ ។ ឧទាហរណ៍ នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៦៨ សម្តេចព្រះឧភយោរាជ នរោត្តម សីហនុ ទ្រង់បានតាំងបង្ហាញរូបគ្រោងតំណាងប្រាសាទបាយ័នធ្វើពីឈើនិងក្រដាសផ្តិត នៅក្នុងពហុកីឡដ្ឋាននាទីក្រុងភ្នំពេញ ក្នុងថ្ងៃរំឭកទិវាឯករាជ្យជាតិលើកទី ១៥[៤៤] ។ រូបតំណាងនោះមានសភាពខ្ទះខ្ទាយនិងគ្រោតគ្រាតណាស់ ប៉ុន្តែការតាំងបង្ហាញនេះមានគោលបំណងជាក់លាក់មួយ គឺជំនួសឲ្យការទទួលស្គាល់ប្រវត្តិសាស្ត្រនៃការធ្វើឲ្យប្រាសាទនេះក្លាយជានិមិត្តសញ្ញាសម័យអាណានិគម នូវពាក្យថា «អា្ហ! ប្រាសាទបាយ័នរបស់យើង» វិញ ដោយបានលុបបំបាត់ចោលការចងចាំអំពីអ្នកជួសជុលបារាំងសែសនៃសម័យអាណានិគមទាំងនោះទាំងស្រុង ។ អង្គរវត្ត ដែលត្រូវបានជួសជុលដោយបារាំងសែស ក៏បានក្លាយជានិមិត្តសញ្ញាចំកណ្តាលទង់ជាតិនៃរបបរាជានិយមរបស់សម្តេចសីហនុ របបយោធានិយមរបស់ លន់ នល់ និងរបបនយោបាយជ្រុលនិយមរបស់ ប៉ុល ពត ។

ការកត់សម្គាល់បន្ថែមទៀត គឺភស្តុតាងនៃការធ្វើតាមនៅក្នុងកម្រិតមួយដ៏ពេញនិយម ។ ឧទាហរណ៍បង្ហាញមួយនោះ គឺជាគំនូរបន្តបន្ទាប់រៀបរាប់ពីហេតុការណ៍នៅក្នុងប្រវត្តិជាតិ ដែលបានប្រើប្រាស់ដោយក្រសួងអប់រំឥណ្ឌូនេស៊ីនៅទសវត្សរ៍ឆ្នាំ ១៩៥០ ។ រូបគំនូរទាំងនេះ ត្រូវបានគេបោះពុម្ពយ៉ាងច្រើន និងចែកផ្សាយទូទាំងសាលាបឋមសិក្សាក្នុងប្រទេស ។ សិស្សានុសិស្សឥណ្ឌូនេស៊ីក្មេងៗ មានរូបនេះបិទនៅតាមជញ្ជាំងថ្នាក់រៀនគ្រប់ៗគ្នា គ្រប់ទីកន្លែង បង្ហាញពីប្រទេសរបស់ពួកគេកាលពីអតីតកាល ។ ផ្ទៃរូបភាពមានទម្រង់ជារូបភាពសម្រាប់ឃោសនា មានលក្ខណៈពិព័ណ៌ធម្មជាតិតាមរចនាបថសិល្បៈពាណិជ្ជហួសសម័យនៃដើម ស.វ. ទី ២០ ហើយរូបភាពមនុស្សយកលំនាំតាមបែបសម័យអាណានិគម និងតាមរឿងល្ខោនវ៉ាយ៉ាំងអូរ៉ាំង ដែលដកចេញពីពង្សាវតារ ។ ប៉ុន្តែ រូបភាពដ៏គួរឲ្យចាប់អារម្មណ៍បំផុតនោះ គឺរូបភាពប្រាសាទបូរ៉ូប៊ូឌួរដែលគេផ្តល់ទៅឲ្យកុមារកុមារី ។ តាមពិត ប្រាសាទដែលមានព្រះពុទ្ធរូប ៥០៤ ព្រះអង្គ រូបចម្លាក់រឿង ១៤៦០ ផ្ទាំង និងផ្ទាំងក្បាច់ ១២១២ ផ្ទាំង គឺជាឃ្លាំងផ្ទុករូបចម្លាក់របស់ជ្វាបុរាណដ៏អស្ចារ្យមួយ ។ ប៉ុន្តែ ជាងគំនូរដ៏ពេញនិយមនៅ ស.វ. ទី ២០ នេះ បានស្រមៃយ៉ាងវិលខូចតែគួរឲ្យចាប់អារម្មណ៍ នូវទ្រង់ទ្រាយដ៏អស្ចារ្យនៃប្រាសាទនេះនា ស.វ. ទី ៩ ។ រូបប្រាសាទបូរ៉ូប៊ូឌួរ ត្រូវបានគេគូរជាព៌ណស ដោយមិនឲ្យឃើញមានរូបចម្លាក់ណាមួយសោះឡើយ ។ តួប្រាសាទនេះព័ទ្ធជុំវិញទៅដោយវាលស្មៅនិងរុក្ខវិថីដ៏មានរបៀបរៀប តែគ្មានរូបមនុស្សម្នាក់នៅក្នុងនោះឡើយ[៤៥] ។ យើងប្រហែលជាអាចគិតបាន

ថា ការគ្មានគូរូបមនុស្សនេះ គឺជាការបង្ហាញពីភាពមិនស្រួលចិត្តរបស់អ្នកគំនូរសាសន៍មូស្លិមបច្ចុប្បន្នក្នុងការប្រឈមនឹងប្រាសាទព្រះពុទ្ធសាសនា(៤៦) ។ ប៉ុន្តែ ខ្ញុំសង្ស័យថា អ្វីដែលយើងមើលឃើញនោះ គឺជាការទទួលយកដោយមិនដឹងខ្លួននៃបុរាណវិទ្យាអាណានិគម គឺថា ប្រាសាទបូរ៉ូប៊ូឌួរ គឺជាកេតនភ័ណ្ឌរបស់រដ្ឋអំណាច ហើយប្រាសាទនេះ គឺជានិមិត្តសញ្ញាទៀតផង ។ បូរ៉ូប៊ូឌួរ គឺជានិមិត្តសញ្ញាសម្រាប់អត្តសញ្ញាណជាតិ ដ៏មានឥទ្ធិពលដោយសារមនុស្សគ្រប់គ្នាដឹងអំពីទីស្ថាននៃប្រាសាទនេះ តាមរយៈរូបភាពនៃប្រាសាទនេះ ដែលមានចែកចាយជាចំនួនគណនាពុំបាន ។

ដោយភ្ជាប់ទំនាក់ទំនងទៅវិញទៅមករវាង ជំរឿន ផែនទី និងសារមន្ទីរ ផ្ដល់ពន្លឺអំពីរបៀបដែលរដ្ឋអំណាចអាណានិគមគិតអំពីតំបន់ត្រួតត្រារបស់ខ្លួន ។ «អំបោះអន្ទង» (ឥទ្ធិពល) នៃគំនិតនេះ គឺជាក្រឡាបំណែងចែកសម្រាប់ការយល់ដឹងដែលអាចអនុវត្តក្នុងសភាពបត់បែនមិនចេះចប់ ទៅលើអ្វីដែលឋិតនៅក្រោមការគ្រប់គ្រងពិតប្រាកដក្ដី ឬការគ្រប់គ្រងដែលគ្រោងទុកក្ដី របស់រដ្ឋអំណាច ដូចជា ប្រជាជន តំបន់ សាសនា ភាសា ផលិតផល បុរាណស្ថាន ។ល។ ក្រឡាបំណែងចែកនេះធ្វើឲ្យគេអាចនិយាយអំពីអ្វីជារបស់នេះ មិនមែនរបស់ផ្សេងទេ, ជាកម្មសិទ្ធិទីនេះ មិនមែនជាកម្មសិទ្ធិរបស់កន្លែងផ្សេងទេទៀតនោះ ។ ក្រឡាបំណែងចែកត្រូវគេចង់បញ្ចូលនិងកំណត់ ដូច្នេះហើយទើបយើងអាចរាប់បាន ។ «អំបោះចាក់» (លទ្ធផល) គឺជាអ្វីដែលមនុស្សម្នាក់អាចផ្សាយបន្តបន្ទាប់នូវការប៉ាន់ស្មានថា ពិភពលោក គឺបង្កើតឡើងដោយពហុវចនៈនៃវត្ថុដែលអាចចម្លងបានជាបន្តបន្ទាប់ ។ អ្វីក៏ដោយ គឺជាតំណាងឲ្យប្រភេទជាភាគតៗ គ្នាមួយឈុត ហើយត្រូវតែតាមរបៀបនេះ ។ នេះជាហេតុដែលរដ្ឋអំណាចអាណានិគមស្រមៃប្រភេទជនជាតិចិនជាភាគតៗ គ្នា មុនមានជនជាតិចិនមកតាំងលំនៅឋាន និងស្រមៃប្រភេទជាតិនិយមមុនការកកើតនូវអ្នកជាតិនិយម ។

គ្មាននរណាម្នាក់អាចគិតឃើញឧបមាកថាដ៏ប្រសើរសម្រាប់ចិត្តគំនិតនេះ ជាងអ្នកនិពន្ធប្រលោមលោកឥណ្ឌូនេស៊ីដ៏អស្ចារ្យម្នាក់ ឈ្មោះ ប្រាមូទ្យៈ អនន្តៈ ទូរ (Pramoedya Ananta Toer) ដែលដាក់ចំណងជើងភាគចុងក្រោយនៃរឿងសោកនាដកម្មដែលគាត់តាក់តែងជា ៤ ភាគ ស្ដីពីសម័យអាណានិគមថា **រូម៉ះកាចា** (*Rumah Kaca*) (ផ្ទះកញ្ចក់) ។ នេះគឺជារូបភាពអំពីគុកកញ្ចក់មួយ ដែលអ្នកទោសអាចត្រូវបានគេឃ្លាំមើលរាល់ពេលវេលាបានដោយអ្នកទោសមិនអាចដឹងបានថា វេលាណាអ្នកយាមឃ្លាំមើលពួកគេ ។

រដ្ឋអំណាចអាណានិគមមិនគ្រាន់តែប្រាថ្នាចង់បង្កើត (នៅក្រោមការត្រួតត្រារបស់ខ្លួន) នូវទស្សនីយភាពមនុស្សជាតិតាមរយៈការមើលឃើញពីគ្រប់ជ្រុងជ្រោយនោះទេ ។ លក្ខខណ្ឌនៃភាពមើលឃើញនេះ គឺថា មនុស្សម្នាក់ វត្ថុអ្វីមួយ មានលេខសំគាល់ខ្លួន(៤៧) ។ ការស្រមើស្រមៃរបៀបនេះមិនមែនចេញមកដោយឯកឯងនោះទេ ។ នោះ គឺជាលទ្ធផលនៃបច្ចេកវិទ្យាក្នុងវិស័យនាវាចរណ៍ តារាសាស្ត្រ បច្ចេកទេសបង្កើតនាឡិកា ការធ្វើអង្កេតវិទ្យាសាស្ត្រថតរូប និងបច្ចេកទេសបោះពុម្ព ជាងនេះទៅទៀតនោះ គឺ ឥទ្ធិពលដ៏ជ្រាលជ្រៅរបស់របបមូលធន-និយម ។

ដូច្នេះ ផែនទីនិងជំរឿនបានបង្កើតទម្រង់មូលដ្ឋានមួយ ដែលអាចបង្កើតឲ្យមាន «ប្រទេសភូមា» និង «ជនជាតិភូមា», «ប្រទេសឥណ្ឌូនេស៊ី» និង «ជនជាតិឥណ្ឌូនេស៊ី» ។ ប៉ុន្តែ ការធ្វើឲ្យលទ្ធភាពទាំងនេះ មានសភាពច្បាស់លាស់ (សភាពច្បាស់លាស់ដែលមានឥទ្ធិពលដូចសព្វថ្ងៃបន្ទាប់ពីរដ្ឋអំណាចអាណានិគមបានរលាយបាត់ទៅ) មានឫសគល់ទៅនឹងការស្រមៃរបស់រដ្ឋអំណាចអាណានិគមអំពីប្រវត្តិសាស្ត្រនិងអំណាច ។ បុរាណវិទ្យា គឺជាវិជ្ជា

*ដែលគេមិនអាចនឹកគិតដល់នៅមុនសម័យអាណានិគមក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ វិជ្ជានេះត្រូវបានគេអនុវត្តយឺតៗនៅប្រទេសសៀមតាមទម្រង់របស់បណ្ដារដ្ឋអំណាចអាណានិគមជិតខាងទាំងឡាយ ។ បុរាណវិទ្យាបានសិក្សាទៅលើបុរាណស្ថានជាបន្តបន្ទាប់ ហើយបែងចែកទៅក្នុងប្រភេទប្រអប់ភូមិសាស្ត្រ-ប្រជាសាស្ត្រដូចជាក្នុងដែនដីអាណានិគមហូឡង់និងដែនដីភូមារបស់អាណានិគមអង់គ្លេសជាដើម ។ ដោយបានចាប់កំណើតនៅក្នុងលំដាប់បំណែងចែកបែបនេះ បុរាណស្ថាននីមួយៗ អាចឲ្យគេធ្វើការអេង្កេតនិងចម្លងដោយគ្មានព្រំដែនបាន ។ នៅពេលដែលផ្នែកថែរក្សាបុរាណវត្ថុរបស់រដ្ឋាភិបាលអាណានិគម អាចប្រមូលផ្ដុំបុរាណស្ថានបន្តបន្ទាប់ទាំងនោះទៅក្នុងទម្រង់ផែនទីនិងរូបថត រដ្ឋនោះអាចចាត់ទុកសេរីទាំងនោះថា ជាកម្រងអាល់ប៊ុមរបស់បុព្វបុរសខ្លួន ។ រឿងដែលសំខាន់នោះមិនដែលជាប្រាសាទ បូរ៉ូប៊ូឌួរ ឬ ពុកាមនោះទេ ។ ទាំងអស់នេះមានជាប់ទាក់ទងតែជាមួយនឹងបុរាណវិទ្យា ហើយមិនមែនជាអ្វីដែលរដ្ឋាភិបាលចាប់អារម្មណ៍នោះឡើយ ។ ប៉ុន្តែ សេរីទាំងអស់នេះបានបង្កើតជម្រៅប្រវត្តិសាស្ត្រមួយដែលត្រូវបានទទួលយកតាមដោយរដ្ឋាភិបាលក្រោយសម័យអាណានិគម ។ លទ្ធផលដ៏សមហេតុផលចុងក្រោយគឺជារូបសញ្ញា (រូបសញ្ញាប្រាសាទពុកាម ឬរូបសញ្ញាប្រជុំកោះហ្វីលីពីន ក៏មិនមានអ្វីខុសប្លែកដែរគ្នាទេ) ដែលភាពទទេស្អាត ភាពគ្មានបរិបទ ភាពដែលអាចនឹកឃើញជារូបរាង និងការផ្សាយបន្តវាដោយឥតព្រំដែនទៅគ្រប់ទិសទី របស់រូបសញ្ញានេះ បាននាំឲ្យជំរឿន និងផែនទី, «អំបោះអន្ទង» (ឥទ្ធិពល) និង «អំបោះចាក់» (លទ្ធផល) ត្រូវឱបក្រសោបគ្នាដោយមិនអាចលុបបំបាត់បានឡើយ ៕*

# ជំពូកទី ៤

## រឿងប្រឌិត ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០-១៩៣០

*ដោយ ផេន្នី អេដ្វឺដ្ស*

*ច្បាប់ដើមនៃនេះបានសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ÷* “Womanizing Indochina : Fiction, Nation and Cohabitation in Colonial Cambodia, 1890-1930” ។

*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **ការបំបាត់បំបបចក្រភព ៖ ពូជសាសន៍ ភេទភាវៈ និងជីវិតគ្រួសារ ក្នុងសម័យអាណានិគមនិយមបារាំងសែសនិងហូឡង់** *(Domesticating the Empire : Race, Gender and Family Life in French and Dutch Colonialism)* ។

*រក្សាសិទ្ធិ គ.ស. ១៩៩៨ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យវើហ្ស៊ីនៀ (ឆាឡុតស៍វិល្ល និង ឡុងដ្រ៍) ។*

# CHAPTER 4:

“Womanizing Indochina :
Fiction, Nation and Cohabitation in Colonial Cambodia, 1890-1930”
Penny Edwards
*(Domesticating the Empire :
Race, Gender and Family Life in French and Dutch Colonialism)*

**Copyright © 1998 by The University Press of Virginia (Charlottesville and London).**

បកប្រែដោយ សុខ លាំង

# ជំពូកទី ៤
# រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា
# គ.ស. ១៨៩០-១៩៣០

## ការធ្វើឲ្យឥណ្ឌូចិនមានសភាពជាស្រី៖ រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នាក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០-១៩៣០

*សូមលោកអ្នកអានស្រមៃថា ដូចជាមានបុរសបារាំងម្នាក់ពាក់អាវព័ណ៌សសុទ្ធ កំពុងប្រទាត់ដៃនៅលើតុសរសេររបស់គាត់នៅឯសន្ធាត់បារាំងសែស ។ គាត់ចាប់ផ្ដើមសរសេរថា «ជូនចំពោះអ្នកម្ដាយជាទីស្រឡាញ់» ហើយបានបញ្ជាក់នៅលើក្បាលសំបុត្រថា គាត់កំពុងស្នាក់នៅភ្នំពេញ រាជធានីនៃប្រទេសកម្ពុជាក្នុងអាណាព្យាបាលរបស់បារាំងសែស ។ កាលបរិច្ឆេទនៃសំបុត្រនេះមិនមានភាពច្បាស់ យើងមិនដឹងថា តើគេបានសរសេរនៅឆ្នាំ ១៩១០, ១៩២០ ឬ ១៩៣០ នោះឡើយ ។ ប៉ុន្តែ នេះមិនមានអ្វីជាបញ្ហានោះទេ ។ ស្ទួរនៃកន្ធាល់ធ្វើឲ្យពិបាកពុន្ធូវប៉ាកកាគូសលើក្រដាស កំពុងរៀបរាប់អំពីផ្លូវរបស់វីរជនម្នាក់ឆ្លងកាត់ទឹកដីកុលសម្ព័ន្ធកំពុងច្បាំងគ្នា សត្វព្រៃដ៏កាចសាហាវ និងជម្ងឺគ្រុនចាញ់ដ៏ធ្ងន់ធ្ងរ ។ ក្រោយមកទៀត នៅក្នុងការិយាល័យប្រៃសណីយ៍ គាត់រាប់លុយរៀលរបស់ខ្មែរដើម្បីបង់ថ្លៃតែមប្រ៍សំបុត្រ ។ នៅលើលុយកាក់នោះមានចារឹកពាក្យស្លោកថា៖ «ប្រទេសបារាំងសែស មានសភាពដូចម្លូកដែកដើម្បីការពារគុណតម្លៃរបស់ខ្លួន ហើយនិងដូចសិង្ហដើម្បីការពារគុណធម៌ ឬព្រហ្មចារិយភាពរបស់ខ្លួន» ។ រូបភាពនេះបានធ្វើឲ្យគាត់ភ្ញាក់ក្នុងចិត្តដោយហេតុថា ធ្វើឲ្យនឹកឃើញដល់ម្ដាយដែលជាស្ត្រីអង់អាចចំណាស់ម្នាក់ ។ ហាក់ដូចជាម្ដាយរបស់គាត់កំពុងស្ថិតនៅក្នុងការិយាល័យនោះ ហើយកំពុងលួចមើលពីខាងលើស្មាគាត់ នៅពេលដែលគាត់កំពុងនិយាយកុហកអំពីភាពលំបាកលំបិននិងដំណើរផ្សងព្រេងរបស់គាត់ ។ ប៉ុន្តែ អារម្មណ៍របស់គាត់ត្រឡប់មកក្នុងសភាពធម្មតាវិញ នៅពេលដែលស្មៀនប្រៃសណីយ៍យកប្រាក់កាក់និងហុចតែមប្រ៍ឲ្យគាត់វិញ ។ គាត់លិឍតែមប្រ៍ ហើយបិទស្បែតទៅលើស្រោមសំបុត្រទាំងញញឹម ។ នៅក្រោមម្រាមដៃរបស់គាត់ មានរូបភាពទេពីខ្មែរដ៏ល្អឆើតឆាយមួយរូបស្ថិតនៅជាអមតៈនៅក្នុងផ្ទៃតែមប្រ៍ព័ណ៌ត្នោតលាយព័ណ៌ពងមាន់នោះ កំពុងញញឹមក្នុងលក្ខណៈជាការអញ្ជើញឲ្យថើបយ៉ាងស្ងៀមស្ងាត់ ។*

*ដោយផ្អែកលើមុមទាំងបីនៃភេទភាវៈបែបនេះ ការបង្កើតរូបភាពអាណានិគមនៃកម្ពុជាបានកើតឡើង ។ មុមទី ១ គឺរូបភាពម្ដាយតំណាងឲ្យមជ្ឈប្រទេស (ប្រទេសបារាំងសែស) ។ រូបតាងនេះ ជារូបស្ត្រី ហៅ «ឡាហ្វ្រង់» (ជានាមឥត្ថីលិង្គ) ឬ «ម៉ារីយ៉ាន្ន» (ជាឈ្មោះខ្លួនរបស់ស្ត្រី) ឃើញនៅតាមស្តូបនិងរូបិយវត្ថុរបស់ពួកអាណានិគមនិយម ។ ទេវកថាជាតិបានកំណត់លក្ខណៈរបស់ប្រទេសបារាំងសែសឲ្យមានភាពជាស្ត្រី ចាប់តាំងពីគ្រិស្តសតវត្សរ៍ទី ១៧ មកម្ល៉េះ[(១)] ។ នៅរយៈពេលដំបូងនៃរបបសាធារណរដ្ឋ គេបានពិព័ណ៌នាប្រទេសបារាំងសែស ប្រៀបប្រដូចទៅនឹងស្រីក្រមុំម្នាក់ «ស្រស់ប្រិមប្រិយនិងមានឆន្ទៈមោះមុត» ។ ប៉ុន្តែ ក្រោយពីបរាជ័យបាត់ខេត្តអាល់ហ្សាស់និងឡូវ៉ែន នៅក្នុងឆ្នាំ ១៨៧០ ប្រទេសបារាំងសែសត្រូវបានគេចាត់ទុកថា មានបុក ៣ «ថ្ងៃថ្នូរ ទទឹងទទែង និងចេះក្រុងគេ»[(២)] ។ នេះគឺជានិមិត្តរូបយ៉ាងបញ្ចិតបញ្ចៀងនៃ «មតេយ្យាធ្វា» (អំណាចរបស់ម៉ែ) ដែលប្រពន្ធរបស់ពួកអាណានិគមនិយម គប្បីតែអនុវត្តតាម ។ ប៉ុន្តែ ប្រសិនបើគេពន្យល់នៅក្នុង*

*បរិបទចក្រពត្តិនិយមវិញ រូបតំណាងនេះមានសភាពស្រពេចស្រពិល ។ អ្នកនិពន្ធសម័យអាណានិគមជាច្រើន បានឲ្យតម្លៃទៅលើលក្ខណៈស្ត្រីអាណានិគមថា «មានលក្ខណៈល្អប្រណីតហួសពេកគួរឲ្យខ្ពើម ... របស់អារ្យធម៌មួយដែលមានភាពល្អិតល្អន់ហួសប្រមាណ ហើយនោះបានធ្វើឲ្យភាពគង់វង្សនៃពូជសាសន៍ស្ថិតក្នុងសភាពបាត់បង់បន្តិចម្តងៗ»[៣] ។ ប្រលោមលោកសម័យអាណានិគមភាគច្រើន បានរៀបរាប់ពីប្រពន្ធជនជាតិបារាំងថា បានក្លាយជាតំណាងឧបទ្រពសាហាវយង់ឃ្នង់ឲ្យប្រទេសកំណើត ដែលលក្ខណៈចម្បងជាស្ត្រីត្រូវបានគ្របដណ្តប់យ៉ាងខ្លាំងដោយភាពទំនើប ។*

*ផ្ទុយទៅនឹងរូបភាពខាងលើ គឺរូបភាពអាណានិគមជនដែលមានភាពជាបុរសមាំមួន សកម្ម និងស្វាហាប់ដែលអាចស្រោចស្រង់ជាតិបាន តាមរយៈការកសាងប្រទេសបារាំងសែសថ្មីមួយនៅប្រទេសខាងក្រៅ ។ ដូចលោក ហ្សក ហារឌី* (Georges Hardy) *ដែលជានាយកបណ្ឌិតសភាអាណានិគមពីឆ្នាំ ១៩២៦ ដល់ ១៩៣៣ បានសរសេរថា៖ «អ្នកធ្វើអាណានិគមត្រូវតែជាមនុស្សប្រុស ជាបុរសពិតប្រាកដ ជាអ្នកដែលខ្លាំងបំផុតក្នុងចំណោមអ្នកខ្លាំងដទៃទៀត» ។*

*ការអះអាងដ៏ខ្លីរបស់លោក ហារឌី នេះ បានបង្ហាញឲ្យឃើញនូវទំនៀមទម្លាប់នៃការសរសើរអស់រយៈពេលជាង ៥០ ឆ្នាំ អំពីលក្ខណៈជាបុរសដ៏មាំមួននៃពួកអាណានិគមនិយម ដោយបង្កើតឲ្យមាននូវភូមិភាគបូព៌ាដ៏កាចសាហាវមួយ ដែលផ្ទុយពីការចុះទន់ខ្សោយដ៏រយីករយាករបស់មជ្ឈប្រទេស (ប្រទេសបារាំងសែស)*[៤] *។ ភាពជាបុរសរបស់ពួកអាណានិគមជន កាន់តែមានភាពច្បាស់ឡើង តាមរយៈការប្រតិស្ឋដែនដីអាណានិគមរបស់ខ្លួនឲ្យស្ថិតក្នុងសភាពជាស្ត្រីភេទ និងជាកន្លែងសម្រាប់ផ្តល់នូវការកម្សាន្តផ្លូវភេទ ។ ផ្ទុយពីរូបតំណាងឲ្យប្រទេសបារាំងសែស ដែលមានស្ត្រីលក្ខណៈជាមេគ្រួសារ ប្រដែងជាមួយភាពជាបុរសរបស់ពួកអាណានិគមជន ស្ត្រីខ្មែរតំណាងឲ្យគំនិតរបស់លោក រូស្សូ* (Rousseau) *ដែលមាននិស្ស័យជាអ្នកបម្រើមនុស្សប្រុស ។ មជ្ឈប្រទេសតំណាងដោយស្ត្រីជាមេគ្រួសារ ពួកអាណានិគមជនដ៏ខេងរ៉ែង និងដែនដីអាណានិគមដែលមានលក្ខណៈដូចទេពអប្សរនេះ ត្រូវបានគេដាក់បញ្ចូលគ្នាជាមុមបី ដែលភាពជាបុរសរបស់ពួកអាណានិគមនិយម គឺជាចំណងយ៉ាងសំខាន់រវាងទឹកដីអាណានិគមដ៏គគ្រាំគគ្រើម និងជីវិតដ៏រាក់ទាក់ស្រស់បំព្រងនៅស្រុកកំណើត ។*

*ជំពូកនេះនឹងពិនិត្យថា តើការយល់ដឹងអំពីពូជសាសន៍ និងយេនឌ័រ (ភេទភាវៈ) ត្រូវបានគេរំលាយចូលគ្នាដោយរបៀបណា ដើម្បីបង្កើតបានជារឿងស្រមើស្រមៃបែបនេះឡើង ? ក៏ប៉ុន្តែ ក្នុងការរើរុះចេញនូវការចាត់ទុកពួកអាស៊ីនេះ មិនបានន័យថា នាងខ្ញុំចង់ពង្រឹងការយល់ឃើញរបស់ពួកបស្ចិមប្រទេសដែលបានលេចឡើងនៅក្នុងអត្ថបទថ្មីៗ ដែលបរិយាយពីពួកបស្ចិមប្រទេសខ្លួនឯងថា ប្រកបដោយតែភាពកំណាចនោះទេ*[៥] *។ ជាងនេះទៅទៀត អត្ថបទនេះនឹងភ្ជាប់រូបភាពរបស់ពួកអាណានិគមនិយមស្តីពីកម្ពុជា ទៅនឹងបរិយាកាសបញ្ញវន្តនៅប្រទេសបារាំងសែសនៅជំនាន់នោះ ។ ការបញ្ចូលគំនិតអរូបីទៅក្នុងតថភាពរបស់រដ្ឋបាលអាណានិគម បានតម្រង់ផ្លូវទស្សនៈឯកជន ហើយនិងការអនុវត្តនៅក្នុងសង្គម ដែលផ្តល់រូបរាងដល់របៀបដែលគេបានប្រតិស្ឋប្រទេសកម្ពុជាឡើង ។*

*ឯកសារដែលនាងខ្ញុំប្រើ ដើម្បីយកមកវិភាគនៅក្នុងអត្ថបទនេះ រួមមាន ប្រលោមលោកនៅក្នុងរបបអាណានិគម សៀវភៅស្តីអំពីការធ្វើដំណើរ សៀវភៅមគ្គុទ្ទេសក៍ទេសចរ ព្រឹត្តិបត្រស្រាវជ្រាវ ព្រឹត្តិបត្រព័ត៌មាន ប័ណ្ណប្រៃសណីយ៍ បូជនីយដ្ឋាន និង បណ្ណសារផ្សេងៗ របស់រដ្ឋបាលបារាំងសែសនៅកម្ពុជា ។ នាងខ្ញុំបានពិនិត្យជាពិសេសទៅលើស្នាដៃរបស់មន្ត្រីដែលជាអ្នកប្រាជ្ញពីររូប ។ ទី ១ គឺលោក រ៉ូឡង់ ម៉េយែរ* (Roland Meyer) *(កើត*

*នៅឆ្នាំ ១៨៨៩) ដែលបានធ្លងកាត់ការងារជាស្មៀនថ្នាក់ទាបម្នាក់នៅប្រទេសកម្ពុជាសម័យអាណានិគម ហើយគាត់ត្រូវអ្នករួមការងារជនជាតិអឺរ៉ុបរបស់គាត់បញ្ឆៀស ដោយហេតុតែគាត់មានឥរិយាបថមិនលម្អៀងទៅខាងបារាំង ឬខាងអ្នកស្រុកដើម ។ គេគិតថា ការបោះពុម្ពផ្សាយប្រលោមលោក ដែលមានលក្ខណៈពាក់កណ្តាលជីវប្រវត្តិរបស់គាត់ ក្រោមចំណងជើងថា* **សារ៉ាម៉ានី** *បានធ្វើឲ្យគាត់បាត់បង់ការងារ ។ ទី ២ គឺលោក ហ្សក ហ្គ្រោលីយេ៉រ៍* (George Groslier) *(កើត គ.ស. ១៨៨៧ អនិច្ចកម្ម គ.ស. ១៩៤៥) គឺជាអ្នកដែលកើតក្នុងដែនដីអាណានិគម ហើយបានចំណាយពេលវេលាជិតសាមសិបឆ្នាំ បំពេញការងារជាមន្ត្រីរដ្ឋបាលថ្នាក់ខ្ពស់ម្នាក់នៅក្នុងប្រទេសកម្ពុជា ។ ប្រលោមលោកទី ២ របស់គាត់ ដែលមានចំណងជើងថា* **ត្រលប់ទៅជាដីឥដ្ឋខញ** *(Le Retour à l'argile)* *បានទទួលរង្វាន់ធំផ្នែកអក្សរសាស្ត្រសម័យអាណានិគម នៅឆ្នាំ ១៩២៩ ។*

*តាមរយៈការសរសេរនេះ ទាំងលោក ម៉ៃយែរ និង ហ្គ្រោលីយេ៉រ៍ បានព្យាយាមបញ្ជាក់ពីសារៈសំខាន់នៃវិស័យអាណានិគម និងភាពចាំបាច់មិនអាចខ្វះបានពីសំណាក់គាត់ទាំងពីរនាក់ ក្នុងឋានៈជាមនុស្សប្រុស ដែលមានសមត្ថភាពឧត្តុង្គឧត្តមនិងវីរកម្មផ្នែកអក្សរសិល្ប៍ ។ ប្រលោមលោករបស់ពួកគាត់ ធ្វើឲ្យគេនឹកស្រមៃឃើញនូវពិភពសុបិនមួយ ដែលមានលក្ខណៈបញ្ច្រាស ដោយមានប្រទេសកម្ពុជានៅចំកណ្តាល និងប្រទេសបារាំងសែសនៅផ្នែក្រៅ ។ នៅលើដែនដីអាណានិគមដ៏សុខក្សេមក្សាន្តនេះ តួអង្គវីរជន គឺជាបុរសបារាំងសែស ។ រីឯអ្នកដែលត្រូវគេត្រួតត្រា គឺជាស្ត្រីខ្មែរដែលស្រេកឃ្លានចំពោះការគ្រប់គ្រងរបស់មនុស្សប្រុស ចំណែកឯមជ្ឈប្រទេសវិញ គឺជាស្រីចំណាស់មុខក្រញូវ ។*

## ការធ្វើអាណានិគមលើប្រទេសកម្ពុជា៖ ពួកអ្នករុករក ពួកម៉ាដាម (លោកស្រី) និងឱនភាព

*នៅក្នុងឆ្នាំ ១៨៦០ ធម្មជាតិវិទូបារាំងសែសឈ្មោះ ហង់រី មូហូត៍* (Henri Mouhot) *បានប្រទះឃើញប្រាសាទបុរាណនៃគ្រិស្តសតវត្សរ៍ទី ១២ នៅតំបន់អង្គរ ។ លោក មូហូត៍ បានស្លាប់នៅក្នុងប្រទេសលាវមួយឆ្នាំក្រោយមក ក៏ប៉ុន្តែការអភិវឌ្ឍបច្ចេកវិទ្យាបោះពុម្ព និងទម្រង់ថ្មីនៃការសរសេរអត្ថបទទាក់ទងទៅនឹងការធ្វើដំណើរ បានធ្វើឲ្យមានការចែកចាយព័ត៌មានយ៉ាងឆាប់រហ័សពីការប្រទះឃើញនេះ ទៅដល់អ្នកអាន ។ កំណត់ហេតុរបស់លោក មូហូត៍ ត្រូវបានគេចេញផ្សាយជាបន្តបន្ទាប់នៅក្នុងព្រឹត្តិបត្រ* **តួរឌុយម៉ុងដ៍** *(Tour du Monde)* *ដោយសារអ្នកនាំផ្លូវជាតិស្រុកដើមដែលបានជូនគាត់ បានស្រោចស្រង់សៀវភៅកត់ហេតុរបស់គាត់ នឹងក្រោយមក ភរិយានិងប្អូនប្រុសរបស់មូហូត៍ បានខិតខំស្វែងរកទីផ្សារ ដោយមានអ្នកនិពន្ធខ្នាចតាក់តែង និងមានការបោះពុម្ពដោយដាក់ថែមនូវរូបភាពបោះពុម្ពដោយវិធីប្រើទឹកក្រូតធម្មតា ។ កំណត់ត្រានៃការធ្វើដំណើរដ៏មានតម្លៃនេះ បានបង្ហាញដល់សាធារណជននិងអ្នកនយោបាយបារាំងសែស «អំពីតម្លៃរបស់ប្រទេសទាំងនេះដែលបណ្តារដ្ឋាភិបាលអឺរ៉ុបទាំងឡាយចង់គ្រប់គ្រង ... អំពីលក្ខណៈរបស់ជាតិសាសន៍ទាំងនោះ ... អំពីអ្វីខ្លះដែលយើងគួរយកឬបោះចោល» ។ ដោយផាត់ព័ណ៌ប្រទេសកម្ពុជាថា ជាទឹកដីដែលសម្បូរដោយធនធានវប្បធម៌និងសម្ភារៈនោះ លោក មូហូត៍ បានជំរុញឲ្យប្រទេសបារាំងសែសយក «គ្រឿងអលង្ការដ៏អស្ចារ្យនោះ» ទៅដាំលើមកុដរបស់ខ្លួន*[៦] *។*

*ការចេញផ្សាយរបស់មូហូត៍ គឺជាការសម្រេចនូវជោគវាសនានយោបាយរបស់ប្រទេសកម្ពុជា ។ ដោយមានការប្រកួតប្រជែងខាងការពារទីអំណាចរបស់ពួកចក្រពត្តិ នៅឆ្នាំ ១៨៦៣ រដ្ឋាភិបាលបារាំងសែសបានដាក់អាណាព្យាបាលលើប្រទេសកម្ពុជា (គ.ស. ១៨៦៣-១៩៥៣) ។ ប្រាសាទអង្គរវត្តស្ថិតនៅក្នុងទឹកដីសៀមនៅឡើយ*

រហូតដល់មានការប្រគល់ខេត្តសៀមរាបមកឲ្យខ្មែរវិញ តាមរយៈសន្ធិសញ្ញាបារាំងសែស-សៀមនៅឆ្នាំ ១៩០៧ ។ រដ្ឋាភិបាលបារាំងសែសបានប្រើប្រាស់មូលដ្ឋានថ្មីរបស់ខ្លួននៅក្នុងតំបន់ ព្រមទាំងសម្ពន្ធមិត្តថ្មី គឺរាជាធិបតេយ្យខ្មែរ ដើម្បីទទួលជ័យជំនះក្នុងការទទួលបានសិទ្ធិចូលដល់ប្រាសាទទាំងនោះវិញ ។ មិនយូរប៉ុន្មាន ប្រទេសបារាំងសែសបានបង្កើតនូវសិទ្ធិផ្តាច់មុខក្នុងការផលិតចំណេះដឹងស្តីអំពីអង្គរនៅប្រទេសលោកខាងលិច ។ ដោយមើលឃើញភាពផ្ទុយគ្នារវាងឱនភាពរបស់កម្ពុជាបច្ចុប្បន្ន ជាមួយនឹងអានុភាពដ៏អស្ចារ្យនៃសម័យអង្គរនោះ ទើបបណ្តាលឲ្យអ្នកប្រាជ្ញ អ្នកស្រាវជ្រាវ ភ្នាក់ងាររដ្ឋបាល និងអ្នកនិពន្ធប្រលោមលោក ជាច្រើន បានធ្វើការសន្និដ្ឋានដោយប្រទ្បុំថា ជនជាតិខ្មែរដែលបានកសាងអង្គរនោះ បានផុតពូជអស់ទៅហើយ ដោយគេបានសម្អាងថា ភាពចុះដុនដាបនោះហើយ ដែលបាននាំឆ្ពោះទៅរកឱនភាពនៃចក្រភពទាំងមូល ព្រមទាំងការរលាយនៃពូជសាសន៍ផង ។ ការសន្និដ្ឋានបែបនេះ គ្រាន់តែជាការឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រកម្ពុជាតែមួយផ្នែកតូចប៉ុណ្ណោះ ប៉ុន្តែជាការឆ្លុះបញ្ចាំងអំពីចិត្តសាស្ត្ររបស់បារាំងសែសកាលពីសម័យនោះច្រើនជាង ។ ដោយឆ្លុះបញ្ចាំងពីការវិនាសរបស់អង្គរធំ អគ្គទេសាភិបាលនៃឥណ្ឌូចិន លោក ប៉ូល ឌូមែរ (Paul Doumer) បានសច្ចាថា នឹងធ្វើអ្វីៗ គ្រប់យ៉ាង ដើម្បីការពារប្រទេសបារាំងសែស «កុំឲ្យធ្លាក់ចុះទៅក្នុងភាពដុនដាប» ដូចនោះ[៧] ។ ដោយមានការរីកដុះដាលនៃការគំរាមកំហែងពីវណ្ណៈកម្មករ ដោយមានសតិអារម្មណ៍ដែលជិតដាមជានិច្ចចំពោះបរាជ័យរបស់បារាំងសែសនៅក្នុងសង្គ្រាមរវាងបារាំងសែសនិងព្រុស្ស៊ី (ពួកអាឡឺម៉ង់) នៅឆ្នាំ ១៨៧០-៧១ និងដោយមានការគំរាមកំហែងពីការធ្លាក់ចុះនៃអត្រាកំណើត វណ្ណៈអ្នកដឹកនាំបារាំងសែសយល់ស្របនឹងការគិតមមៃរបស់លោក ឌូមែរ អំពីភាពមិនមានរបៀបរៀបរយរបស់ជាតិ ។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៨៨០ រហូតដល់សង្គ្រាមលោកលើកទី ១ មានសំឡេងច្រើនរាប់មិនអស់បានព្រមានថា ប្រទេសបារាំងសែសកំពុងស្ថិតនៅលើមាត់ផ្លូវនៃសេចក្តីវិនាសអន្តរាយ[៨] ។

ការភ័យខ្លាចនៅចុងសតវត្សរ៍ទាំងនោះ មានការជាប់ពាក់ព័ន្ធយ៉ាងសាំញ៉ាំទៅនឹងការយល់ឃើញអំពីពូជ-សាសន៍ វណ្ណៈ ភេទ និងយេនឌ័រ (ភេទភាវៈ) ។ ទស្សនៈដាវីននិយម ឬ ទស្សនៈឡាម៉ាកនិយមបែបថ្មីមួយបានផ្សព្វផ្សាយជាទូទៅ ហើយបានលើកឡើងថា «ដូចជាក្រុមគ្រួសារដែរ សង្គមនិងវណ្ណៈទាំងឡាយ សុទ្ធតែអាចប្រឈមនឹងឱនភាពទាំងអស់» ។ នៅទីក្រុងប៉ារីស ទស្សនៈយល់ឃើញរាក់កំភែលចំនួនពីរទៅស្រីពេស្យាដែលមានភាពថោកទាប និងភរិយានៃវណ្ណៈគហបតី ត្រូវគេបង្រួមចូលគ្នា នៅពេលដែលភាពភ័យខ្លាចកើតមកពីការធ្លាក់ចុះអត្រាកំណើតក្នុងវណ្ណៈគហបតី បានគូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីក្នុងឋានៈជាភរិយានិងជាម្តាយ[៩] ។ បន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ ការរួមសង្វាស គឺជា «កាតព្វកិច្ចដើម្បីបន្តពូជសាសន៍» មួយ ។ ប្រឆាំងតបតទៅនឹងបរិយាកាសបញ្ញវន្តនេះ ការស្នើដោយចាត់ទុកថា ស្ត្រី គឺជាម្តាយផង និងជានិមិត្តរូបរបស់ជាតិផងនោះ មានលក្ខណៈសំខាន់ជាពិសេស ពីព្រោះ «នៅពេលដែលស្ត្រីនិងជាតិត្រូវបានគេច្របាច់បញ្ចូលគ្នានោះ សេចក្តីប្រាថ្នាក្នុងការការពារគុណធម៌នៃធាតុណាមួយនោះ នឹងក្លាយទៅជាកាតព្វកិច្ចពលរដ្ឋក្នុងការការពារធាតុមួយទៀត» ។ គ្រួសារនិងពូជសាសន៍ កិច្ចការឯកជននិងកិច្ចការសង្គមសាធារណៈ ត្រូវបានគេសំយោគបញ្ចូលគ្នានៅពេញទ្វីបអឺរ៉ុបនា ស.វ. ទី ១៩ ដែលក្នុងនោះ មានតួអង្គស្ត្រីតំណាងឲ្យជាតិដូចជា ហ្គេរម៉ានីញ៉ា (តំណាងឲ្យជាតិអាឡឺម៉ង់) ប្រ៊ីតានីញ៉ា (តំណាងឲ្យសហអាណាចក្រអង់គ្លេស) ឡាហ្វ្រង្ស ឬ ម៉ារីយ៉ាន្ន (តំណាងឲ្យប្រទេសបារាំងសែស) ហូឡង់ឌីយ៉ា (តំណាងឲ្យប្រទេសហូឡង់) ប៉ូឡូនីញ៉ា (តំណាងឲ្យប្រទេសប៉ូឡូញ) ជាដើម ។ ក្រោយមក រូបសំណាកទាំងនេះ ដែលក្លាយមកពីតួអង្គសន្តកញ្ញា (ព្រះមាតានៃព្រះយេស៊ូ) តែគ្មានលក្ខណៈសាសនាទាំងនេះ

ច្រើនត្រូវបានបំពាក់ដោយដាវនិងខែលដើម្បីការពារភាពបរិសុទ្ធ (ហើយដែលជាភាពបរិសុទ្ធនៃពូជសាសន៍របស់ពួកគេផងនោះ) ពីការធក់ប៉ូន់ពីអ្នកដទៃដែលជាជនបរទេស[១០] ។

ការភ័យខ្លាចអំពីភាពឱនថយនេះ មានឥទ្ធិពលទៅលើគោលនយោបាយអាណានិគមក្នុងវិស័យសំខាន់ពីរ គឺ ការអភិរក្សវប្បធម៌ និងការបន្តពូជបែបជីវសាស្ត្រ ។ ពីកោះហ៊ីដី (ក្នុងមហាសមុទ្រប៉ាស៊ីហ្វិក) រហូតដល់តំបន់តង់ហ្កាញីកា (នៅអាហ្វ្រិកខាងកើត) ភ្នាក់ងាររដ្ឋការនិងអ្នកប្រាជ្ញទាំងឡាយ បានព្រួយបារម្ភអំពីចេតនាយ៉ាងប្រពៃ ក្នុងការជួយស្រោចស្រង់នូវអារ្យធម៌របស់ដែនដីអាណានិគមរបស់ខ្លួន ឲ្យចៀសផុតពីការចុះអន់ថយ តាមរយៈការសិក្សា ការអប់រំផ្នែកសិល្បៈ និងសារមន្ទីរ ។ តែតាមពិតទៅ ការបង្កើតឡើងនូវ «សាលាបារាំងសែសនៅចុងបូព៌ាប្រទេស» (សព្វថ្ងៃ មានឈ្មោះថា «វិជ្ជាស្ថានបារាំងចុងបូព៌ាប្រទេស») នៅទីក្រុងហាណូយនាឆ្នាំ ១៨៩៨ នោះ គឺបានបង្ហាញពីការគិតដែលថា ពូជសាសន៍ខ្មែរបានរលាយផុតពូជរួចទៅហើយ ។ បួនដណ្ដប់ឆ្នាំក្រោយមក លោក ហ្សិក ហ្គ្រោលីយេ៍ បានលើកឡើងថា ល្វោនព្រះរាជទ្រព្យរបស់ខ្មែរកំពុង «ស្ថិតនៅពេលហៀបនឹងរលត់រលាយបាត់ទៅហើយ»[១១] ។ ការភ័យខ្លាចស្រដៀងគ្នាជាច្រើនស្ដីអំពី «ការចុះដុនដាបយ៉ាងរហ័ស» នៃសិល្បៈខ្មែរ «ដែលត្រូវបានបំប្លែងនិងបង្ខាត់» ដោយឥទ្ធិពលលោកខាងលិចនោះ បាននាំទៅដល់ការបង្កើតសមាគមមិត្តអង្គរ ក្នុងគោលបំណងជួយតម្រង់គោលនយោបាយអាណានិគម ទាក់ទងទៅនឹងសារមន្ទីរនិងការអប់រំផ្នែកសិល្បៈ ដើម្បីកុំឲ្យកម្ពុជារលុបបាត់បន្តិចម្តងៗ ។ គោលនយោបាយអាណានិគមចំពោះរាជាធិបតេយ្យនិងគណៈសង្ឃ បានបង្កើតគំនិតដ៏រឹងមាំរបស់បារាំងសែសអំពីខ្លឹមនៃវប្បធម៌ជាតិខ្មែរ ។ ពិធីនិងស្ថាបត្យកម្មអាណានិគម បានលើកសរសើរដល់សញ្ញាលក្ខណ៍និយមផ្នែកវប្បធម៌នៃរាជាធិបតេយ្យខ្មែរ ។ ក្នុងពេលនោះដែរ បារាំងសែសបានដាក់ការរឹតបន្តឹងទៅលើព្រះសង្ឃពុទ្ធសាសនា ដើម្បីកុំឲ្យសាសនាខ្មែរទទួលរងឥទ្ធិពលរបស់សៀមនិងយួន[១២] ។ ដូចនេះហើយ ទើបគេឃើញថា ការភ័យខ្លាចរបស់ពួកអឺរ៉ុបចំពោះឱនភាពវប្បធម៌ ត្រូវបានគេបង្ហាញតាមរយៈប្រទេសកម្ពុជា ។ ផ្ទុយទៅវិញ ការចុះដុនដាបរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ត្រូវបានលើកឡើងជាការព្រមានអំពីកម្រិតនៃការលិចលង់របស់ពូជសាសន៍បារាំងសែស ប្រសិនបើមានឱនភាពនោះ ។

ខណៈពេលដែលវប្បធម៌ក្រោមរបបអាណានិគម ត្រូវគេបង្ហាញឡើងជានិមិត្តរូបនៃការចុះដុនដាបនោះ គេបែរជាមើលឃើញថា ដែនដីអាណានិគមទាំងនោះ គឺជាកន្លែងដែលពួកអាណានិគមនិយមកំពុងបង្កើតពូជសាសន៍បារាំងសែសទៅវិញ ។ ក្នុងការរំលឹកអំពីការបាត់បង់ខេត្តអាល់សាស់-ឡូរ៉ែនដោយសារការចាញ់សង្គ្រាមនោះ អ្នកនិពន្ធ ហ៊ុហ្គ ឡឺ រូ (Hugues le Roux) បានពន្យល់អ្នកអានរបស់គាត់នៅឆ្នាំ ១៨៩៨ ថា «ដើម្បីសង្គ្រោះពូជសាសន៍របស់យើង» ត្រូវបង្កើត «ប្រទេសបារាំងសែសនៅឯនាយសមុទ្រ» ។ ទស្សនាវដ្តី **រឺវ៉ុយអ៊ែងដូស៊ីណ្វាហ្ស៊** (*Revue indochinoise*) (ទស្សនាវដ្តីឥណ្ឌូចិន) ដែលជាទស្សនាវដ្តីនាំមុខគេនៅឥណ្ឌូចិន បានសរសេរយ៉ាងក្អេងក្អាងថា «ស្ត្រីជាតិបារាំងសែសមានសារៈសំខាន់ណាស់ក្នុងការបង្កើតកូនដែលមានសុខភាពល្អនៅដែនដីអាណានិគម ព្រោះថាប្រសិនបើគ្មានមនុស្សស្រីទាំងនោះទេ កូនកាត់ជាច្រើននឹងត្រូវបង្កើតឡើង ដោយនាំយកមកជាមួយនូវភាពខិលខូចនិងបាបធម៌ ដោយថែមទាំងខ្វះខាតគុណធម៌» របស់ជនជាតិបារាំងសែសនិងជនជាតិដើមទាំងនោះ[១៣] ។ លោក ហ្សូសិហ្វ ស្ហាយី-ប៊ែរត៍ (Joseph Chailly-Bert) ដែលជាប្រធានសហជីពដែនអាណានិគមបារាំងសែស ក៏បានគិតដូច្នេះដែរ ។ នៅចុង ស.វ. ទី ១៩ ស្ត្រីភាគច្រើនបានធ្វើអន្តោប្រវេសន៍មករស់នៅប្រទេសកម្ពុជា គឺជាភរិយារបស់ពួករដ្ឋបាលនិងអ្នកវិនិយោគ ហើយមួយភាគតិចជាដូនជីកាតូលិកនិងអ្នករបាំនិងអ្នកចម្រៀងតាម

កប៉ាល់ ។ លោក ស្តាយី-ប៉ែរត៍ បានបន្ទោសទៅដល់ចំនួនដ៏តិចតួចរបស់ស្ត្រីបារាំងត្រឹមត្រូវក្នុងទឹកដីអាណានិគមដែលការណ៍នេះគឺជាមូលហេតុជំរុញឲ្យបុរសបារាំងឡើងលើគ្រែជាមួយស្ត្រីជនជាតិដើម ។ នេះជាហេតុបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ទាំងពូជសាសន៍និងការគ្រប់គ្រងរបស់បារាំងសែស ។ នៅឆ្នាំ ១៨៩៧ គាត់បានបង្កើតសមាគមនិរប្រវេសន៍ស្ត្រីដល់ទឹកដីអាណានិគម (សមាគមសម្រាប់បញ្ជូនស្ត្រីពីប្រទេសកំណើត គឺប្រទេសបារាំងសែស ទៅរស់ក្នុងដែនដីអាណានិគម) ក្នុងគោលបំណងចង់នាំយកស្ត្រីដែលមានគុណធម៌និងអាចរៀបការបាន ទៅរស់នៅក្នុងដែនដីអាណានិគម ដើម្បី «បញ្ចូលទេពកោសល្យនៃពូជសាសន៍របស់យើងនៅលើទឹកដីដ៏ឆ្ងាយនោះ»[១៤] ។

ក្រោយមក នៅឆ្នាំដដែលនោះ រដ្ឋមន្ត្រីក្រសួងអាណានិគម ឈ្មោះ អង់ដ្រេ ឡឺបុង (André Lebon) បានសរសេរទៅកាន់ប្រមុខរដ្ឋាភិបាលទាំងអស់នៅឥណ្ឌូចិន ឲ្យគាំទ្រសំណូមពររបស់សមាគមនេះក្នុងការផ្តល់ការងារដល់ស្ត្រីបារាំងសែសនៅលើដែនដីអាណានិគម ។ ការឆ្លើយតបអវិជ្ជមានចំពោះសំណូមពរនេះ ហើយនិងចំពោះការផ្តួចផ្តើមក្រោយមកទៀត បានបង្ហាញនូវភាពតានតឹងដ៏ស្រួចស្រាល់រវាងសេចក្តីប្រាថ្នារបស់មនុស្សនៅមជ្ឈប្រទេសក្នុងការគ្រប់គ្រងដែនដីអាណានិគម ហើយនិងសុបិនរបស់មន្ត្រីអាណានិគមក្នុងការការពារកន្លែងគ្រប់គ្រងរបស់ពួកគេសម្រាប់ប្រុសៗ បារាំងនោះ ។ មន្ត្រីរបស់អំណាចអាណាព្យាបាលបានឆ្លើយតបថា ការងារដ៏សក្តិសមសម្រាប់ស្ត្រីនោះគឺការងារបង្រៀន ហើយថា គេមិនត្រូវការអ្នកគ្រូបង្រៀនបន្ថែមទៀតទេ ។ ដោយបញ្ជាក់ថា «សមាសភាគស្ត្រី» មិនអាចរួមចំណែកឲ្យមានប្រយោជន៍សម្រាប់នាយកដ្ឋានណាមួយនោះ អគ្គទេសាភិបាលបានបដិសេធមិនទុកកន្លែងណា សូម្បីតែមួយ សម្រាប់ស្ត្រីដែលត្រូវធ្វើនិរប្រវេសន៍នោះឡើយ ។ ដោយមិនមានការរួញរា នៅឆ្នាំ ១៩០៣ ប្រធានសមាគមនេះបានស្នើសុំទៅដល់រដ្ឋបាលឥណ្ឌូចិនឲ្យមានការបម្រុងទុកតំណែងមួយចំនួនសម្រាប់ស្ត្រី ក្នុងតួនាទីជាអ្នកធ្វើការខាងប្រៃសណីយ៍និងទូរលេខ ជាអ្នកវាយអក្សរលេខ និងជាគ្រូបង្រៀន ។ ក៏ប៉ុន្តែ អគ្គទេសាភិបាលឈ្មោះ បូ (Beau) បានឆ្លើយតបថា «ដែនដីឥណ្ឌូចិនមិនមានស្ត្រីអន្តោប្រវេសន៍នោះទេ»[១៥] ។

ថ្វីដ្បិតតែមានការរឹងទទឹងបែបនេះក៏ដោយ ក៏មិនយូរប៉ុន្មាន ស្ត្រីបារាំងសែសបានធ្វើដំណើរមកដល់ឥណ្ឌូចិនយ៉ាងឆាប់រហ័ស ហើយនេះបានបញ្ចប់ «អំណាចរបស់ស្ត្រីម្ចាស់ស្រុកហើយនិងបញ្ចប់របបស្ត្រីកំណាន់ចិត្ត» ។ នៅពេលដែលសហគមន៍អាណានិគមនិយមនៅទីក្រុងភ្នំពេញបានពង្រីកនោះ តម្រូវការគ្រូស្រីនិងគិលានុបដ្ឋាយិកាសម្រាប់ធ្វើជាបុគ្គលិកសាលារៀនសិស្សស្រីនិងមន្ទីរពេទ្យសម្ភពនោះ ក៏មានការកើនឡើងដែរ ។ ក្រោយមកទៀត អ្នករិះគន់បុរសបានបន្ទោសស្ត្រីបារាំងថា បានបង្កើតនូវ «របងលួសបន្លា» រវាងពួកបារាំងនិងពួកអ្នកម្ចាស់ស្រុក[១៦] ។ តាមពិតទៅ គោលនយោបាយនិងផ្នត់គំនិតរបស់ពួករដ្ឋបាលប្រុសៗ ទាំងនោះ បានកំណត់តួនាទីរបស់ស្ត្រីទាំងនោះនៅត្រឹមតែជាអ្នកថែរក្សាផ្ទះក៏ដោយ មិនផ្តល់ផ្លូវផ្សេងទៀត ទោះជាពួកនាងមិនពេញចិត្តជាខ្លាំងក៏ដោយ ។ មុខនាទីរដ្ឋការទាំងអស់ ត្រូវបានគេចាត់ទុកថា ជាការងាររបស់មនុស្សប្រុស ហើយមិនសមរម្យសម្រាប់មនុស្សស្រីទេ ។ នៅចុងទសវត្សរ៍ឆ្នាំ ១៩២០ មនុស្សស្រី គឺជាគោលដៅសំខាន់បំផុតសម្រាប់យុទ្ធនាការឃោសនាក្នុងការបញ្ចុះបញ្ចូលការហូរចូលរបស់ជនជាតិបារាំងសែស កុំឲ្យមកស្វែងរកការងារធ្វើនៅលើទឹកដីឥណ្ឌូចិនទៀត ។ ស្ត្រីបារាំងសែសនៅកម្ពុជាក៏ដូចជានៅមជ្ឈប្រទេសដែរ ត្រូវគេបដិសេធមិនឲ្យមានសិទ្ធិបោះឆ្នោត ។ ដោយសារមានការរើសអើងទាំងផ្នែកវិជ្ជាជីវៈនិងនយោបាយនោះ គេបានជំរុញឲ្យស្ត្រីបារាំងសែសទាំងនោះរួមកម្លាំងគ្នាឲ្យក្លាយទៅជាការខិតខំប្រឹងប្រែង ដូចដែលគេបានបង្កើតសមាគមគាំពារមាតានិងទារកកម្ពុជានៅឆ្នាំ ១៩២៦ ។ ក្នុងនាមជាអាជ្ញាកណ្តាលខាងផ្នែកអនាម័យនិងជាអ្នកឃ្លាំមើលបន្សុទ្ធភាពនៃពូជសាសន៍ ស្ត្រីបារាំងសែស

«ត្រូវបានគេកំណត់ឲ្យភាពស៊ីវិល័យនិងមានរបៀបរៀបរយ មានលក្ខណៈជំរុញចិត្តនិងបន្សុទ្ធ មានថ្លៃថ្នូរនិងបង្កើនអ្វីទាំងអស់ ដែលប្រឈមជាមួយនាង» ។ ក៏ប៉ុន្តែ តួនាទីផ្នែកភេទភាវៈនេះត្រូវបានចងភ្ជាប់ទៅនឹងវណ្ណៈសង្គមដែរ ។ គេមានការភ័យខ្លាចនិងថ្កោលទោសពេញទូទាំងផែនទីអាណានិគម ចំពោះទស្សនីយភាពនៃពួកស្បែកសក្រីក្រ ថា ជាការបំផ្លាញនូវកិត្យានុភាពចក្រពត្តិ ។ ស្ត្រីស្បែកសណាដែលបំពានទៅលើឧត្តមភាពគហបតី ត្រូវគេចាត់ទុកថា ជាការគំរាមកំហែងដ៏មានគ្រោះថ្នាក់ចំពោះឋានានុក្រមសីលធម៌និងពូជសាសន៍ នៃការគ្រប់គ្រងរបស់រដ្ឋអំណាចអាណានិគមនិយមនោះ(១៧) ។

អ្នកកាសែតម្នាក់ ឈ្មោះ ហ្សង់ អាហ្សាល់ប៊ែរត៍ (Jean Ajalbert) បាននិយាយចំអកតាមរយៈអត្ថបទដែលមានចំណងជើងថា «លោកស្រីបារាំងសែសម្នាក់ទៅផ្សារ!» ដោយបានវាយប្រហារដល់ប្រពន្ធជនជាតិស្បែកសក្រីក្រដែលបានទៅកន្លែងរបស់ស្ត្រីម្ចាស់ស្រុកជារឿយៗ ហើយយកលំនាំតាមតួនាទីរបស់ស្ត្រីម្ចាស់ស្រុក ។ «ជនជាតិអាស៊ីមិនយល់ពីការធ្លាក់ចុះបែបនោះទេ» ។ គេមានការភ័យខ្លាចជាពិសេស ចំពោះរូបភាពស្ត្រីស្បែកសជាស្រីពេស្យាដែលជាបណ្តាសាចំពោះក្រុមស្ត្រីស្បែកសស្រគត់ស្រគំនិងបរិសុទ្ធទាំងចិត្តទាំងកាយ ។ នៅឆ្នាំ ១៩០៦ លោកអាហ្សាល់ប៊ែរ បានរិះគន់យ៉ាងខ្លាំងក្លាចំពោះគោលនយោបាយក្នុងការបញ្ជូនមន្ត្រីជនជាតិឥណ្ឌូចិន ទៅកាន់ប្រទេសបារាំងសែសដែលមន្ត្រីទាំងអស់នោះអាចយល់ឃើញថា «យើងជាអ្នកបោកបញ្ឆោតដែលមានសីលធម៌ពុករលួយហើយស្ត្រីរបស់យើងងាយដូចផ្លែត្រី» ។ ជាការបន្ទរចំពោះអារម្មណ៍បែបនេះ អ្នកប្រលោមលោកម្នាក់ឈ្មោះ ព្យែរ មីល្ល (Pierre Mille) បានធ្វើការថ្កោលទោសចំពោះការតាំងពិព័រណ៍របស់ពួកអាណានិគមនិយមជាច្រើន ដែលធ្វើឲ្យពួកម្ចាស់ស្រុកមើលឃើញនូវពិភពលោកមួយ ដែល «គេអាចរកស្ត្រីស្បែកសជាបាវព្រាវបាន ដោយចំណាយតែ ២០ ហ្វ្រង់ប៉ុណ្ណោះ» ។ ដើម្បីរក្សាការបំភាន់ភ្នែកនេះ សម្រាប់ភាពជាម្តាយនិងមារយាទជាសាកលរបស់ស្ត្រីបារាំងសែសទាំងនោះ ពួកអាជ្ញាធរបានទប់ស្កាត់ប័ណ្ណប្រៃសណីយ៍អាសអាភាស ដែលបានផ្ញើមកស្រុកកំណើតដោយកងទ័ពខ្មែរដែលចេញទៅប្រទេសបារាំងសែសនាសម័យសង្គ្រាមលោកលើកទី ១ ។ ផ្ទុយទៅវិញ ពុំមានការហាមប្រាមការផ្ញើចរាចរប័ណ្ណប្រៃសណីយ៍អាសគ្រាមរបស់ស្ត្រីខ្មែរទៅកាន់ប្រទេសបារាំងសែសឡើយ(១៨) ។

ភាពភ័យរន្ធត់របស់ពួកអាណានិគមនិយម អំពីឱនភាពនិងការកាត់ពូជសាសន៍ បានឈានទៅដល់ការគិតពីការត្រួតត្រា តាមរយៈការបង្កើតនិងរក្សាឲ្យមានពីរខាងនៅទល់មុខគ្នា រវាងពួកម្ចាស់ស្រុកនិងពួកបារាំង (អឺរ៉ុប) ប្រៀបដូចជាក្បាលស្ពាននៅត្រើយពីរផ្សេងគ្នានៃភាពបរិសុទ្ធខាងជាតិ ពូជអម្បូរ និងវប្បធម៌ ។ ដោយកត់សម្គាល់ដោយការភ្ញាក់ផ្អើលអំពីរឿងដែលថា មន្ត្រីបារាំងសែសនៅឥណ្ឌូចិនមួយចំនួន ជួនកាលមានការប្រែប្រួលនូវ «ផ្នត់គំនិតថ្មីមួយយ៉ាង ជិតស្និទ្ធជាមួយនឹងមនុស្សនៅក្រោមអាណានិគម ហើយការណ៍នេះ គឺជាការគំរាមកំហែង អាចបំផ្លាញនូវទាំងបុគ្គលិកលក្ខណៈនិងសីលធម៌របស់ពួកនោះបានដែរ» នោះ អ្នកគ្រប់គ្រងខាងរដ្ឋបាលបារាំងសែសម្នាក់ ឈ្មោះ ពីយែរ ប៉ាស្គីយ៉េរ៍ (Pierre Pasquier) (ក្រោយមក បានឡើងឋានៈជាអគ្គទេសាភិបាលនៃឥណ្ឌូចិន) បានជំរុញឲ្យមិត្តភក្តិរបស់គាត់ «អភិរក្សនូវគ្រប់គុណសម្បត្តិពូជអម្បូររបស់ពួកគេ» ក្នុងគោលបំណងដើម្បីការពារកុំឲ្យទទួលឥទ្ធិពលរបស់ពួកម្ចាស់ស្រុក(១៩) ។

ការធ្វើគម្រោងរៀបចំទីក្រុង ផ្តល់នូវការការពារកុំឲ្យទទួលឥទ្ធិពលពីពួកម្ចាស់ស្រុកនេះ ។ ការកើនឡើងនូវចំនួនជនជាតិបារាំងនៅភ្នំពេញ ចាប់ពី ១៥០ នាក់នៅឆ្នាំ ១៩០០ ដល់ប្រមាណ ៥៣០ នាក់នៅឆ្នាំ ១៩០៤ បានបណ្តាលឲ្យមានការសង់វីឡាដាច់ពីគ្នាជាលើកដំបូង សម្រាប់ពួកស្បែកស និងការបង្កើតសង្កាត់បារាំងមួយ

ដែលខណ្ឌដាច់ពីសង្កាត់ខ្មែរដោយគូទឹក ។ ម្ដាយនិងប្រពន្ធដែលជាជនជាតិស្បែកស បានដើរតួនាទីយ៉ាងសំខាន់មួយក្នុងការថែរក្សាគ្រួសារបារាំងសែស ឲ្យនៅមានលក្ខណៈជាបារាំង តាមរយៈការការពារវប្បធម៌ មានដូចជាការរៀបចំគ្រឿងតុទូ ការធ្វើម្ហូប «ការរក្សាចរិយាមារយាទ គុណធម៌ និងស្មារតីជាបារាំងរបស់ពួកគេ» ព្រមទាំងការស្លៀកពាក់ផង ។ ទោះជាការស្លៀកសម្លៀកបំពាក់បែបបូព៌ាប្រទេសក្នុងពិធីជប់លៀង ជាការពេញនិយមនៅទីក្រុងប៉ារីសនៅចុង ស.វ. ទី ១៩ នោះ ក៏ការស្លៀកពាក់របៀបម្ចាស់ស្រុក ត្រូវគេចាត់ទុកជាការទទួលយកសមានកម្មដ៏មានគ្រោះថ្នាក់មួយ នៅប្រទេសដែលពួកបារាំងមានចំនួនតិច ។ ស្ត្រីបារាំងនៅឥណ្ឌូចិន ការពារខ្លួនកុំឲ្យត្រូវពន្លឺថ្ងៃ និងមិនឲ្យពួកម្ចាស់ស្រុកមើលឃើញ ដោយ«ពាក់មួក វ៉ែនតាខ្មៅ ស្បៃបាំងមុខ ឆត្រ និងស្រោមដៃ»(២០) ។ ដោយសារមានការវិវត្តផ្នែកម៉ូតសម្លៀកបំពាក់ គេបានទូន្មានស្ត្រីបារាំងឲ្យពាក់មួកការពារកម្ដៅថ្ងៃជាចាំបាច់ ហើយត្រូវស្លៀកពាក់ឲ្យបានសមរម្យ និងនៅឲ្យឆ្ងាយពីពួកម្ចាស់ស្រុក ។ ព័ណ៌និងម៉ូតសម្លៀកបំពាក់ជួយពង្រឹងដល់ការបន្ថែមទម្ងន់អំពីភាពខុសគ្នានេះ ។ តាមប្រពៃណីខ្មែរ ព័ណ៌សជានិមិត្តរូបនៃអទិស្សមានរូប (អ្នកដែលមានខ្លួនគេមើលមិនឃើញ) ភាពគ្មានមន្ទិល និងភាពឥតខ្ចោះ ។ សម្រាប់ជាគ្រឿងសម្គាល់ពូជសាសន៍និងឋានន្តរសក្តិឯកសណ្ឋានព័ណ៌សរបស់មន្ត្រីអាណានិគម មានភាពខុសគ្នាយ៉ាងខ្លាំងនឹងសម្លៀកបំពាក់ព័ណ៌ខ្មៅរបស់កសិករខ្មែរភាគច្រើន ។ អ្នកប្រលោមលោក ឈ្មោះ ម៉ារហ្គឺរីត ឌុយរ៉ាស (Marguerite Duras) បានសង្កេតឃើញថា «ដោយពឹងផ្អែកលើឯកសណ្ឋានបែបនេះ ជំហានទីមួយបានចាប់ផ្តើមហើយ ហើយចាប់ពីពេលនោះតទៅ គម្លាតនឹងមានកាន់តែខ្លាំងឡើង»(២១) ។ សម្លៀកបំពាក់ព័ណ៌សបានក្លាយទៅជាខែលប្រឆាំងនឹងសមាហរណកម្មរបស់ពួកបារាំងដើម្បីកុំចូលទៅក្នុងវប្បធម៌របស់ពួកម្ចាស់ស្រុក ហើយជាព័ណ៌សម្បុរសង្គមមួយ ដែលត្រូវបានពួកម្ចាស់ស្រុកទទួលស្គាល់និងគោរពជាបន្តបន្ទាប់ មិនថា បារាំងសែសបានប្រព្រឹត្តអំពើអបាយមុខបែបណានោះទេ ។ ប៉ុន្តែ ការថែរក្សាឲ្យបាននូវបរិយាកាសបែបបារាំងនេះ គ្រាន់តែជាសមរភូមិពាក់កណ្ដាលប៉ុណ្ណោះ ។ ការងារសំខាន់ប្រហែលគ្នាមួយទៀត គឺការអភិរក្សប្រទេសកម្ពុជាជារបងការពារនឹងការធ្លាក់ចុះនៃវប្បធម៌របស់ពួកបារាំង ។

ដោយសារស្ត្រីបារាំងមិនគួរធ្លាក់ចុះពីកន្លែងរបស់ពួកគេនោះ ស្ត្រីខ្មែរក៏មិនត្រូវអនុញ្ញាតឲ្យឡើងខ្ពស់ហួសពីកន្លែងរបស់ពួកគេដែរ ។ អ្នកម្ចាស់ស្រុកដែលនិយាយភាសាបរទេស ឬស្លៀកពាក់មិនត្រឹមត្រូវទៅតាមទម្លាប់របស់ជនជាតិខ្លួន ជាការគំរាមកំហែងដល់ការការពារគម្លាតសង្គមនិងភាពខុសប្លែកគ្នារវាងជនជាតិ ។ ការស្រាវជ្រាវនិងការពិសោធការឆ្លងវប្បធម៌ គឺជាឯកសិទ្ធិរបស់ពួកស្បែកសតែប៉ុណ្ណោះ ។ នៅក្នុងពិព័រណ៌ឆ្នាំ ១៩០០ អ្នកចម្រៀងទីក្រុងប៉ារីសម្នាក់ឈ្មោះ ក្លេអូ ដឺ មេរ៉ូដ (Cléo de Mérode) ទទួលបានការអបអរសាទរសម្រាប់ការតែងខ្លួនជាអ្នករបាំខ្មែរ តែម្យ៉ាងវិញទៀត នៅក្នុងពិធីតាំងពិព័រណ៌អាណានិគមនិងអន្តរជាតិ នៅទីក្រុងប៉ារីស ឆ្នាំ ១៩០០ និង ម៉ារសី ឆ្នាំ ១៩០៦ ពួកមន្ត្រីនិងជាងខ្មែរ ត្រូវគេសើចចំអកនិងស្តីបន្ទោសចំពោះការស្លៀកសម្លៀកបំពាក់លោកខាងលិចរបស់ពួកគេ ។ តាមព័ត៌មានខ្លះៗ មានចៅហ្វាយខេត្តជាច្រើននៅឥណ្ឌូចិន បានហាមឃាត់មិនឲ្យអ្នកម្ចាស់ស្រុកដែលនៅក្រោមបង្គាប់របស់ខ្លួន ស្លៀកសម្លៀកបំពាក់ពួកអឺរ៉ុបឡើយ ។ ដើម្បីអភិរក្សទាំងអំណាចរបស់បារាំងសែស និងប្រទេសកម្ពុជាសភាពដើម អ្នកអាណានិគមនិយមភេទប្រុសទាំងឡាយបានតវ៉ាប្រឆាំងយ៉ាងខ្លាំងក្លា ចំពោះផលប៉ះពាល់ជាអកុសលដែលមានការរៀនភាសាបារាំងសែសកើតមានឡើងក្នុងចំណោមស្ត្រីម្ចាស់ស្រុក ដោយអះអាងថា ការរៀនភាសាបារាំងសែសនឹងធ្វើឲ្យបាត់បង់ដល់ភាពជាស្ត្រីដ៏ល្អបំផុត ហើយថា នឹងបង្កើតឲ្យមានអ្នកផ្លាស់វណ្ណៈ និងជាស្ត្រីពេស្យាទៀតផង(២២) ។ ក្តីបារម្ភនេះបានធ្លុះបញ្ជាំងកាន់តែជ្រៅថែមទៀត

អំពីការភ័យខ្លាចទំនាក់ទំនងផ្លូវភេទឆ្លងពូជសាសន៍ ។ ចក្ខុវិស័យរបស់បារាំងសែសអំពីខ្ទឹមដែលជាមោទនភាពវប្បធម៌ជាតិរបស់កម្ពុជានោះ ត្រូវបានបង្កប់នៅក្នុងស្ត្រីម្ចាស់ស្រុក ដែលមានភាពបរិសុទ្ធខាងផ្នែកពូជសាសន៍ ហើយត្រូវបានធ្វើឡើងតាមរយៈគោលនយោបាយ វប្បធម៌ អប់រំ សាសនា និងនយោបាយ ។

សិល្បៈជាផ្លូវការរបស់ចក្រភពនេះ បានបិទបាំងនូវទស្សនាទានទាំងនេះ ក្នុងការធ្វើឲ្យបេសកកម្មផ្នែកវប្បធម៌របស់បារាំងសែសមានភាពស្របច្បាប់ ។ នៅក្នុងសារមន្ទីរនិងនៅក្នុងការពិព័រណ៍ជាលក្ខណៈអន្តរជាតិ ប្រទេសកម្ពុជាដើរតួជាទេពអប្សរ មានបង្កប់នូវ «ភាពបរិសុទ្ធនៃព្រលឹងនិងសម្រស់ជាអមតៈ» ។ នៅក្នុងរបាំព្រះរាជទ្រព្យ អប្សរាតែងតែមានតួនាទីជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងរវាងព្រះមហាក្សត្រនិងពពួកទេវតាឯឋានសួគ៌ ។ ការសម្តែងរបស់ពួកអាណានិគមនិយម បានផ្តាច់ស្រីអប្សរចេញពីបរិបទវប្បធម៌នេះ ដោយប្រើប្រាស់អ្នករាំដែលគេប្រតិដ្ឋឡើងមកនោះ ជាអ្នកកណ្តាលរវាងអាទិទេពបារាំងនិងប្រជាជនខ្មែរទៅវិញ ។ តួល្ខោនខ្មែរដែលជានិមិត្តរូបនៃភាពបុរាណមួយដែលបារាំងបានសច្ចាថា នឹងការពារនោះ ត្រូវបានផ្សព្វផ្សាយដើម្បីតំណាងឲ្យកម្ពុជានៅឯការតាំងពិព័រណ៍អាណានិគមជាច្រើន (គ.ស. ១៩០៦, ១៩២២, ១៩៣១) ។ នៅតាមជញ្ជាំងវិមាន និងលើប័ណ្ណឃោសនាដ៏ច្រើន គេបានគូររូបតួល្ខោនទាំងនោះ លើក្រដាស ឬ ឆ្លាក់លើថ្ម ក្នុងឥរិយាបថលុតជង្គង់ស្ងួយបណ្តាការ ឬខំមើលសៀវភៅបារាំង ក្នុងន័យថា កម្ពុជាជាអ្នកដ៏ក្រខ្សត់ និងប្រកបដោយការដឹងគុណ ចំពោះការទទួលផលពីបារាំងសែស ។ ដោយពាក់មួក ឬពេលខ្លះកាន់ដាវ ប្រទេសបារាំងសែសដ៏មានឥទ្ធិពល ច្រើនតែលេចឡើងយ៉ាងត្រដែតពីលើទេពអប្សរដ៏លុតលុន់ទាំងនេះ[២៣] ។ លក្ខណៈស្រដៀងគ្នានេះ បានកំណត់ទ្រង់ទ្រាយសំណង់រំពុកដ៏ធំរបស់លោក តេអូឌរ រីវីយែរ (Théodore Rivière) ជាទ្រង់ទ្រាយប្រទេសបារាំងសែសដែលបានសាងសង់នៅហាណូយនៅឆ្នាំ ១៩០៨ ហើយនិងរូបសំណាកព្រះបាទ ស៊ីសុវត្ថិ របស់គាត់ដែលបានឆ្លាក់នៅប៉ារីសនិងក្រោយមក បានដឹកមកភ្នំពេញ[២៤] ។ ដោយបានរៀបចំដើម្បីឆ្លុះបញ្ចាំងអំពីឧត្តមគតិមួយនោះ ពិព័រណ៌ទាំងនោះមានលក្ខណៈដូចទៅនឹងស្ត្រីខ្មែរបច្ចុប្បន្នតិចតួចណាស់ ពីព្រោះថា ស្ត្រីខ្មែរសព្វថ្ងៃបិទបាំងផ្ទៃដោះរបស់ពួកគេជិត ហើយកាត់សក់ខ្លីដែលពួកអ្នកនិពន្ធបស្ចិមប្រទេសជាច្រើនចាត់ទុកថា មានលក្ខណៈរបស់ប្រុសផង របស់ស្រីផង ។ ជំនួសមកវិញ និមិត្តរូបសិល្បៈបែបចក្រពត្តិ បានបង្កើតអាស៊ីបែបទេវកថា ដែលដោកដាំទៅដោយភាពជាស្ត្រីរវើរវាយ ហើយដែលមានលក្ខណៈជាអ្នកបបួលផង ជាអ្នកផ្តល់រង្វាន់ផង ។

ក្រៅពីនៅទីសាធារណៈទាំងនេះ គឺថា នៅចន្លោះរវាងក្របសៀវភៅប្រលោមលោករបស់ពួកអាណានិគមនិយម និងអាល់ប៊ុមកាតជូនពរ ស្ត្រីខ្មែរបានបាត់បង់លក្ខណៈទិព្វរបស់ទេពអប្សរ ហើយត្រូវបានបង្ហាញជារបស់លេងសើចសម្រាប់ផ្លូវភេទ ។ ការបង្ហាញបែបនេះបានគូសបញ្ជាក់ពីឱនភាពនៃឋានៈបច្ចុប្បន្នរបស់ប្រទេសកម្ពុជា តែក៏បានគូសបញ្ជាក់អំពីបេសកកម្មរបស់បារាំងសែសក្នុងការស្តារកម្ពុជាឡើងវិញផង ។ រូបភាពទាំងនេះជាការពណ៌នាប្រៀបស្ត្រីខ្មែរទៅនឹង «កនហ្កាយ» ដែលមានភាពស្រើបស្រាល[២៥] (កនហ្កាយ con gái ជាពាក្យយួនមានន័យថា ក្មេងស្រី, ក្រមុំ ដែលបារាំងសែសប្រើសំដៅទៅលើស្ត្រីកំណាន់ជនជាតិអាស៊ីនៅឥណ្ឌូចិន) ។ នៅក្នុងគំរូភេទភាវៈ តួនាទីរបស់នាង គឺត្រូវបញ្ជូនអាថ៌កំបាំងនៃវប្បធម៌របស់នាង តាមរយៈការរួមស្នេហាដ៏ងប់ងុលជាមួយពួកបារាំង ។ នាងគឺជា «វចនានុក្រមស្បែក» ដែលតាមរយៈនេះ អាចធ្វើឲ្យជនជាតិបារាំងសែសមានការរីកចម្រើនខាងផ្នែកភាសានិងវប្បធម៌របស់ជនជាតិ ដែលពួកគេកាន់កាប់និងគ្រប់គ្រង ។ ដូចទៅនឹងពាក្យសម្រាលរបស់ពួកអាណានិគមនិយមអង់គ្លេសនិងហូឡង់ថា ជា «វចនានុក្រមដេក» និង «វចនានុក្រមដើរ»

នោះ ពាក្យនេះមានអត្ថន័យប្រៀបធៀបការរួមសង្វាសរបស់ពួកអាណានិគមនិយមទៅនឹងចំណេះដឹងអំពីដែនដីអាណានិគម[២៦] ។ ភាពមិនចេះភ្ញាំងភ្ញាត់របស់បុរស ត្រូវបានធានាតាមរយៈទស្សនាទានមួយថា ជនជាតិអឺរ៉ុបបានបង្រៀនអំពីតណ្ហាដល់ស្ត្រីអាស៊ី ។ ការយល់ឃើញបែបនេះ បានជំរុញឲ្យមានការគាំទ្រចំពោះគំនិតស្តីអំពីវីរកម្មផ្នែកផ្លូវភេទរបស់បុរសស្បែកសទាំងឡាយ ហើយបន្តុះបង្អាប់ចំពោះបុរសអាស៊ី ហើយចាត់ទុកស្រីកំណាន់ទាំងឡាយនោះថា ជាវត្ថុសុទ្ធសាធដែលមិនមានសមត្ថភាពខាងផ្នែកអារម្មណ៍ទន់ភ្លន់ និងសភាវៈជាម្តាយដូចស្រីបារាំងសែស ។ នៅមុនឆ្នាំ ១៩០០ ទំនាក់ទំនងរវាងបុរសបារាំងនិងស្ត្រីខ្មែរ គឺជាទ្រង់ទ្រាយជីវិតមួយដែលអាចទទួលយកបានក្នុងការរស់នៅក្នុងប្រទេសកម្ពុជា ។ លោក ហ្គាស់ប៉ារ ហ្វារ៉ូត៍ (Gaspard Faraut) ដែលជាអ្នកគាំទ្រម្នាក់របស់សហគមន៍បារាំងសែស បានផ្លាស់ទៅរស់នៅក្នុងវត្តខ្មែរមួយដើម្បីសិក្សាវប្បធម៌និងភាសា ហើយក៏បានរៀបការជាមួយស្ត្រីលាវម្នាក់ដែលបានបង្កើតកូនប្រុសឲ្យគាត់ពីរនាក់ ។ ភាពលេចធ្លោរបស់លោក ហ្វារ៉ូត៍ក្នុងលោកអាណានិគមនៅចុង ស.វ. ទី ១៩ បានបង្ហាញថា មិនមានការរិះគន់ណាបានកើតឡើងជុំវិញការវិវត្តខ្លួនគាត់ឲ្យទៅជាជនជាតិដើមពាក់កណ្តាលនោះទេ[២៧] ។ មានអ្នកមានមុខមាត់ជាច្រើនទៀត បានរស់នៅក្នុងប្រទេសកម្ពុជាជាមួយប្រពន្ធជាស្ត្រីខ្មែរដែរ ។ បេសកកម្មសាសនានៅឥណ្ឌូចិនចុង ស.វ. ទី ១៩ បានជួយឲ្យការមានសភាពជាស្ត្រីកំណាន់ មានភាពធម្មតា តាមរយៈការមើលការខុសត្រូវទៅលើស្រីទាំងនេះ ក្នុងអំឡុងពេលដែលប្តីបារាំងត្រឡប់ទៅសម្រាកមួយរយៈពេលនៅឯប្រទេសបារាំងសែស ។ ទោះបីជាយ៉ាងនោះក៏ដោយ ក៏នៅទសវត្សរ៍ឆ្នាំ ១៩២០ មានពួកអាណានិគមនិយមតែមួយចំនួនតូចប៉ុណ្ណោះ ដែលមានទំនាក់ទំនងជាសាធារណៈជាមួយស្ត្រីម្ចាស់ស្រុក ។ អ្នកដែលនៅតែធ្វើបែបនោះ ត្រូវបានគេចាត់ទុកថា ជាជនក្បត់ចំពោះក្រុមជនបារាំង[២៨] ។

ការផ្លាស់ប្តូរគំនិតទាំងនេះ អាចកើតឡើងនៅក្នុងជំនាន់លោក ឌូមែរ ជាអគ្គទេសាភិបាល (គ.ស. ១៨៩៧–១៩០២) ។ ពីទសវត្សរ៍ឆ្នាំ ១៨៦០ ដល់ ១៨៩០ ប្រទេសកម្ពុជាត្រូវបានត្រួតត្រាដោយពួកជនប្រដាប់អាវុធ អ្នកផ្សាយសាសនាកាតូលិក អ្នកផ្សងព្រេង និងពួកឆក់ឱកាស ដែលចាប់អារម្មណ៍ទៅលើការបន្តទទួលផលផ្នែកយោធា ផ្នែកសាសនា និងផ្នែកពាណិជ្ជកម្ម តាមរយៈអ្នកតំណាងប្រមុខរដ្ឋាភិបាលបារាំង ។ ដោយមានភាពស្អប់ខ្ពើមចំពោះរឿងទាំងនេះ លោក ឌូមែរ បានធ្វើការកែរុះរដ្ឋបាលនៅកម្ពុជា ដែលកំពុងទន់ខ្សោយស្រាប់នោះ ហើយបានធ្វើមជ្ឈការអំណាចចំពោះសហព័ន្ធឥណ្ឌូចិន បង្រួបបង្រួមនីតិវិធីការិយាធិបតេយ្យ ព្រមទាំងបង្កើតការសិក្សារបៀបអាណានិគម ។ ដូនគ្នាជាមួយការសម្ពោធសាលាអាណានិគមនៅទីក្រុងប៉ារីស សម្រាប់ហ្វឹកហ្វឺនដល់អ្នកបម្រើការរដ្ឋបាលថ្មីរបស់ប្រទេសបារាំងសែសនោះ គោលនយោបាយរបស់លោក ឌូមែរ បានរឹតបន្តឹងទំនាក់ទំនងទៅកាន់មជ្ឈប្រទេស និងបានធ្វើច្បាប់គ្រប់គ្រងរួមមួយនៅពេញឥណ្ឌូចិនទាំងមូល ហើយព្រមទាំងប្តូរព័ណ៌សម្បុររបស់សង្គមអាណានិគមនិយមទាំងស្រុងនៅក្នុងប្រទេសកម្ពុជា[២៩] ។

នៅក្នុងការចាប់ផ្តើមធ្វើការផ្លាស់ប្តូរដោយចាកចេញពីគោលនយោបាយមើលបំណាំនោះ លោក ឌូមែរ បានជ្រើសរើសយកជំហានបន្ទាន់មួយចំនួន ដើម្បីត្រួតពិនិត្យជីវិតឯកជនរបស់អ្នករដ្ឋបាលបារាំងសែស ។ គាត់បានអនុវត្តយ៉ាងឆាប់រហ័ស ដើម្បីបញ្ចប់នូវទំនាក់ទំនងរវាងរ៉េស៊ីដង់ស៊ុបេរីយើរ (ឯកាធិបតី) ប្រចាំនៅកម្ពុជា ឈ្មោះ ហ៊ុយ៉ាំង ដឺ វែរណឺវីល្ល (Huyn de Verneville) ជាមួយនឹងស្រីកំណាន់ជាតិខ្មែរវណ្ណៈខ្ពស់ម្នាក់ឈ្មោះ នាងរឿង ដែលក្រោយមក នាងត្រូវបានគេចាប់ដាក់គុក[៣០] ។ សម្ពន្ធភាពអន្តរពូជសាសន៍ត្រូវស្ថិតនៅក្រោមការតាមដានដ៏តឹងរ៉ឹងពេញឥណ្ឌូចិន ។ នៅឆ្នាំ ១៨៩៨ អគ្គសុភាចារបុរសប្រចាំនៅកម្ពុជានិងឥណ្ឌូចិន បានព្រមានដល់

អ្នកនៅក្រោមបង្គាប់របស់ខ្លួន មិនឲ្យយកស្រីកំណាន់ជាម្ចាស់ស្រុក បើសិនពួកគេមិនចង់ប្រឈមនឹងការបណ្តេញចេញពីតំណែង ។ ក្រោយពីនោះបន្តិច លោក ឌូមែរ បានបង្គាប់បញ្ជាដល់មន្ត្រីបារាំងសែសទាំងឡាយឲ្យចៀសវាងទំនាក់ទំនងជាមួយស្រីកំណាន់ជាជនម្ចាស់ស្រុកហើយដែលឥទ្ធិពលរបស់ពួកម្ចាស់ស្រុកទាំងនោះ «អាចជាមហន្តរាយស្ទើរតែគ្រប់ពេល» ។ នៅអំឡុងឆ្នាំ ១៩០៨ អគ្គសុភាចារបុរសបានព្រមានតាមសារាចរដល់មន្ត្រីផ្នែកច្បាប់របស់បារាំងសែសទូទាំងឥណ្ឌូចិន ឲ្យយកចិត្តទុកដាក់ឃ្លាំមើលប្រឆាំងនឹងឥទ្ធិពលអាក្រក់របស់ស្ត្រីម្ចាស់ស្រុក បើមិនដូច្នេះទេ គេនឹងត្រូវទទួលពិន័យយ៉ាងធ្ងន់ ។ ប៉ុន្តែ ផ្ទុយទៅវិញ ច្បាប់នោះបែរជាមានភាពមេត្តាធម៌ចំពោះបុរសអាណានិគមនិយម ដែលមិនមែនជាមន្ត្រី ដែលបានប្រព្រឹត្តអំពើមិនគួរគប្បីចំពោះប្រពន្ធឥតខាន់ស្លារបស់ពួកគេទៅវិញ សូម្បីពេលដែលពួកគេបានបញ្ចប់រឿងរ៉ាវទំនាក់ទំនងរបស់ខ្លួនដោយឃាតកម្មក៏ដោយ[៣១] ។

ថ្វីដ្បិតតែមានវិធានការបែបនេះក៏ដោយ ក៏ការសម្រុះសម្រួលឆ្លងវប្បធម៌ នៅតែបន្តរហូតដល់មានការបង្កើតឲ្យមានសមាគមសម្រាប់ការការពារកុមារនៅប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩១៣ ដើម្បីថែរក្សាកូនដែលត្រូវគេបោះបង់ចោល ដោយមានម្តាយជាស្ត្រីម្ចាស់ស្រុកនិងឪពុកអឺរ៉ុប ។ ការលេចធ្លោរបស់ «កនហ្គាយ» ដែលបន្តនៅក្នុងប្រលោមលោកនិងកំណត់ប្រវត្តិនៅរវាងទសវត្សរ៍ឆ្នាំ ១៩១០ និង ១៩២០ បានលើកឡើងថា ទំនាក់ទំនងផ្លូវភេទរវាងបារាំងនិងម្ចាស់ស្រុក មិនមានការចុះថមថយឡើយ ប៉ុន្តែបានបង្វែរពីក្របខ័ណ្ឌសាធារណៈទៅក្នុងក្របខ័ណ្ឌឯកជនវិញ ។ នៅក្នុងជីវិតពិត ក៏ដូចជានៅក្នុងអត្ថបទអក្សរសិល្ប៍ដែរ វត្តមានរបស់កនហ្គាយបានបណ្តេញអារម្មណ៍ផ្លូវភេទរបស់បុរសបារាំងចេញពី «ប្រពន្ធរបស់យើង ដែលជាស្ត្រីបារាំងសែសគ្រប់ល័ក្ខណ៍»[៣២] ។ តែនៅពេលជាមួយគ្នានោះដែរ ការបណ្តេញកនហ្គាយទៅភាគខាងក្នុងបំផុតនៃផ្ទះ និងតាមផ្លូវតូចតាចនៃទីក្រុង បានការពារកុំឲ្យសេចក្តីស្នេហាសៅហ្មងបែបរើសអើងចំពោះពួកនាង ប្រឡាក់ដល់មុខមាត់ខាងក្រៅរបស់ពួករដ្ឋបាលបារាំងសែស ។ ការយល់ឃើញបែបអក្សរសិល្ប៍ដ៏មានប្រជាប្រិយភាពមួយថា ស្ត្រីខ្មែរជាអ្នករស់នៅក្នុងបន្ទប់សម្រាប់ស្រីនោះ គឺជាសក្ខីភាពចំពោះការគិតដែលនាំឲ្យមានការបង្កើតឡើងទាំងអម្បាលម៉ាននេះ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ស្ត្រីខ្មែរមានភាពសកម្មជាងស្ត្រីបារាំងដែលស្ថិតក្នុងស្ថានភាពដូចគ្នាទាំងក្នុងសេដ្ឋកិច្ចទីក្រុងនិងវិស័យកសិកម្ម ។ នៅក្នុងផ្ទះ គេមានអំណាចក្នុងការគ្រប់គ្រងប្រាក់កាស និងសិទ្ធិលើទ្រព្យសម្បត្តិនៅក្នុងសង្គមមាតាធិបតេយ្យ ហើយដែលការណ៍នេះមានលក្ខណៈខុសគ្នាទៅនឹងមនោគមវិជ្ជាខាងភេទភាវៈរបស់ពួកបារាំងសែសទាំងក្នុងដែនដីអាណានិគមនិងមជ្ឈប្រទេសផង ។ ក៏ប៉ុន្តែ អ្នកធ្វើការអប់រំនិងអ្នករដ្ឋការរបស់អាណានិគម បានជំរុញស្ត្រីបារាំងឲ្យបញ្ចុះបញ្ចូលនិងជួយតម្លើងស្ត្រីម្ចាស់ស្រុក[៣៣] ។ ខណៈពេលដែលរំកិលសន្សឹមៗ ឆ្លងកាត់សតវត្សរ៍នោះ ការដើរតួនាទីទាំងអស់នោះ ប្រែក្លាយទៅជាមានភាពប្រែប្រួលជាលំដាប់ ដោយយោងទៅតាមការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសបារាំងសែស ។ សង្គ្រាមលោកលើកទី ១ បានកែនមនុស្សស្រីក្នុងចំនួនដែលមិនធ្លាប់មានពីមុនមក ឲ្យចូលបម្រើការងារនៅអឺរ៉ុប ។ ក៏ប៉ុន្តែ សង្គមអាណានិគមនៅតែជារង្វង់អំណាចរបស់បុរសមួយផ្នែកចុងក្រោយបំផុត ។ នៅក្នុងបរិបទនេះ អ្នកនិពន្ធដែលជាបុរស មានចំណាប់អារម្មណ៍យ៉ាងខ្លាំងជាពិសេស ចំពោះការពណ៌នាប្រៀបប្រដូចស្ត្រីខ្មែរទៅនឹងក្អមដ៏ងាយបែក និងជាក្មេងឥតពំនឹង ។

ដូចនេះ ការរក្សាបាននូវស្ថានភាពទាំងនេះ ត្រូវពឹងផ្អែកទាំងស្រុងទៅលើការបង្កើត និងការអតិរេក្សអត្តសញ្ញាណពូជសាសន៍ វប្បធម៌ និងភេទ តាមរយៈការអនុវត្តយ៉ាងតឹងរ៉ឹងទៅលើចក្ខុវិស័យទាំងបីនៃភេទភាវៈ ។ នៅក្នុងផ្ទះប្រពន្ធនិងម្តាយរបស់ពួកអាណានិគមនិយម បានលើកតម្កើងភាពសក្តិសិទ្ធិរបស់ពូជអម្បូរនិងជាតិបារាំងសែស ។

*នៅពីក្រោយឆាកសាធារណៈ ស្ត្រីកំណាន់ខ្មែរបានប្រគល់ចំណេះដឹងខាងផ្លូវភេទ ផ្នែករាងកាយនិងវប្បធម៌របស់នាង ទៅឲ្យម្ចាស់ដែលជាជនជាតិបារាំងសែស ។ ហើយនៅក្នុងការិយាល័យធ្វើការរបស់រដ្ឋបាលបារាំងសែស បុរសដូចជាលោក ម៉ៃយែរ និង ក្រោលីយេរ៍ បានពន្យល់យ៉ាងច្បាស់និងបានអភិរក្សនូវវប្បធម៌អ្នកម្ចាស់ស្រុក ។*

## លោក រ៉ូឡង់ ម៉ៃយែរ និងហានិភ័យនៃការធ្វើរចាំងវប្បធម៌

*លោក រ៉ូឡង់ ម៉ៃយែរ* (Roland Meyer) *ដែលកើតនៅទីក្រុងម៉ូស្គូ និងទទួលការអប់រំនៅទីក្រុងប៉ារីសនោះ បានចូលមកបម្រើការនៅក្នុងរបបអាណានិគមនៅឥណ្ឌូចិននាឆ្នាំ ១៩០៨ ។ បន្ទាប់ពីធ្វើការបានបីខែនៅខុទ្ទកាល័យរបស់អគ្គទេសាភិបាល ឈ្មោះ ប៉ូល បូ* (Paul Beau) *នៅទីក្រុងព្រៃនគរនោះ លោក ម៉ៃយែរ បានបម្រើការចំនួន ១០ ឆ្នាំនៅក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មក គាត់បានផ្លាស់ទៅប្រទេសលាវ ដែលក្រោយមក គាត់ក្លាយទៅជាប្រធានកិច្ចការសន្តិសុខនិងនយោបាយ និងជាលេខាធិការអចិន្ត្រៃយ៍របស់អគ្គស្នងការដ្ឋានទន្លេមេគង្គបារាំងសែស-សៀម ។ គាត់បានទទួលម៉េដាយឡេហ្សីយ៉ុងដូណ្ណើរ ហើយបានទទួលតំណែងក្នុងខុទ្ទកាល័យរបស់រដ្ឋមន្ត្រីក្រសួងអាណានិគមនៅទីក្រុងប៉ារីស នៅឆ្នាំ ១៩៣៣ ។ ក្រោយមកទៀត លោក ម៉ៃយែរ បានទទួលតំណែងជាប្រធានរដ្ឋបាលបារាំងសែសនៅឯនាយសមុទ្រ ។ ស្របគ្នាជាមួយនឹងអាជីពការិយាធិបតេយ្យរបស់គាត់ លោក ម៉ៃយែរ ក៏បាននិពន្ធស្នាដៃស្រាវជ្រាវនិងរឿងប្រតិដ្ឋមួយចំនួន ។ ស្នាដៃដំបូងរបស់គាត់ គឺ* **មេរៀនភាសាខ្មែរ** *(Cours de Cambodgien) នៅឆ្នាំ ១៩១២ ហើយបន្ទាប់មក មានសៀវភៅមួយចំនួន ដូចជា ប្រលោមលោកពាក់កណ្ដាលជីវប្រវត្តិ រឿង* **សារ៉ាម៉ានី ៖ អ្នករបាំខ្មែរ** *(Saramani : danseuse cambodgienne) (គ.ស. ១៩២២)* **មេរៀនភាសាលាវ** *(Cours de laotien) (គ.ស. ១៩២៤) កម្រងរឿងប្រតិដ្ឋនិងតែងសេចក្ដី រឿង* **កំលោះ ៖ ចក្ខុវិស័យអំពីអាស៊ី** *(Kamloh : Visions d'Asie) (គ.ស. ១៩២៩) និង* **ឥណ្ឌូចិនបារាំងសែស ៖ ប្រទេសលាវ** *(Indochine française : Le Laos) (គ.ស. ១៩៣១) ។ នៅក្នុងឆ្នាំ ១៩៥២ លោក ម៉ៃយែរ បានបោះពុម្ពសារណា (រឿងចងចាំ) របស់គាត់ក្រោមចំណងជើងថា* **ពាក្យសម្ដីរបស់អ្នកអាណានិគមនិយមចំណាស់មួយ** *(Propos du vieux colonial) ដែលបង្ហាញនូវការការពារដ៏ស្មោះស្ម័គ្រចំពោះរបបអាណានិគមនិយម ហើយនេះជាការពង្រឹងនូវទិដ្ឋភាពនៃបុរសម្នាក់ដែលលះបង់ទាំងស្រុងចំពោះគម្រោងរបស់អាណានិគមកិច្ចបារាំងសែស*(៣៤) *។*

*កំប៉ុន្តែ បើអានស្នាដៃរបស់ ម៉ៃយែរ ដោយល្អិតល្អន់នោះ នឹងបង្ហាញនូវរូបភាពដ៏ស្មុគស្មាញជាច្រើនទៀត ។ កាលនៅជាក្មេងប្រុស គាត់ចូលចិត្តស្រមើស្រមៃតាមការអានប្រលោមលោកអំពីការផ្សងព្រេងនានា ដូចជា រឿង* **រ៉ូប៊ិនសុន គ្រូសូ** *(Robinson Crusoe) របស់ ដានីយែល ឌីហ្វូ* (Daniel Defoe) *និងស្នាដៃរបស់ ហ្ស៊ុល វែន* (Jules Verne) *និង ចែម្ស ហ្វេនីមរ គូពរ៍* (James Fenimore Cooper) *។ នៅវ័យ ១៨ ឆ្នាំ គាត់ទៅដើរផ្សងព្រេង ដោយមានតែលុយ ៦០០ ហ្វ្រង់នៅក្នុងហោប៉ៅ ព្រមទាំងហិបធំមួយ និងមួកក្រឡោះកោះ (មួកបារាំង) មួយ ។ បំណងប្រាថ្នាយុវវ័យរបស់គាត់ មិនមែនទទួលតំណែងជារដ្ឋមន្ត្រីរបស់អាណានិគមនោះទេ តែគាត់ចង់ក្លាយទៅជា «បុរសបារាំងសែសម្នាក់ដែលមានការចេះដឹងច្រើនបំផុតពីអាស៊ីនៅក្នុងទ្វីបអាស៊ី» ហើយនិងចង់ «សរសេរសៀវភៅស្ដីអំពីអង្គរ» ។ នៅទីក្រុងភ្នំពេញ លោក ម៉ៃយែរ បានរកឃើញថា ប្រទេសមួយ មនុស្ស ភាសាច្រើនភាសា ប្រវត្តិសាស្ត្រ សាសនា ប្រពៃណី អក្សរសាស្ត្រ និងសិល្បៈ ទាំងនេះ កំពុងតែរង់ចាំ «ឲ្យមានការគ្រប់គ្រង»* (**ពាក្យសម្ដី** *ទំ. ៣៤-៣៥) ។*

ក្នុងអំឡុងទសវត្សរ៍បន្ទាប់ លោក ម៉ៃយែរ បានប្រព្រឹត្តបំពានចំពោះក្របខ័ណ្ឌនៃជីវិតអាណានិគម ។ គាត់ធ្វើការនៅការិយាល័យរដ្ឋបាលនៅសង្កាត់បារាំង តែរស់នៅក្នុងសង្កាត់ខ្មែរ ។ អ្នកធ្វើការជាមួយគាត់ជាតិបារាំងបានចាត់ទុកគាត់ថា «ជាអ្នកវណ្ណៈទាបបំផុត ជាមនុស្សអោប់ឱន» ដោយសារ «ការចូលទៅរស់នៅយ៉ាងចម្លែករបស់គាត់» នៅក្នុងតំបន់របស់ពួកម្ចាស់ស្រុក ។ ជាការវាយបកមកវិញ លោក ម៉ៃយែរ បានចំអកចំពោះ «ពួកអាស្បែកសដែលគ្មានស្រុក» ហើយដែលបាន «ប្រមាថមើលងាយនិងមិនទទួលស្គាល់» ប្រទេសកម្ពុជា ដោយកំណត់ផ្តាច់ចេញសង្កាត់របស់ពួកបារាំង ដែលនៅទីនោះ គេ «អភិរក្សទម្លាប់ឆ្កួតៗ មិនបានការនៃជីវិតស៊ីវិល័យរបស់ពួកគេ» (**តំលោះ** ទំ. ៩៧) ។ តាមរយៈការកំណត់នូវបេសកកម្មរបស់គាត់ សម្រាប់តែបញ្ហាមនុស្សធម៌និងចំណេះដឹងនោះ លោក ម៉ៃយែរ នឹកឃើញទៅដល់ការធ្វើនិរទេសខ្លួនឯង ឲ្យចេញផុតពីអន្ទាក់សម្ភារៈនៃជីវិតអាណានិគម ដែលជាការលះបង់ដ៏ចាំបាច់បំផុតសម្រាប់បញ្ចប់សៀវភៅរបស់គាត់ ។ នៅឆ្នាំ ១៩១៨ លោក ម៉ៃយែរ បានឡើងឋានៈអាណានិគមជាច្រើនលើក ។ គាត់ក៏មានភាពស្ទាត់ជំនាញខាងផ្នែកភាសាខ្មែរផង ។ នៅពេលដែលគាត់បញ្ចប់ប្រលោមលោករបស់គាត់នោះ បញ្ហាសុខភាពទ្រុឌទ្រោមបានបង្ខំគាត់ឲ្យចាកចេញពី «ខ្ទមដ៏សាមញ្ញ» របស់គាត់ ហើយបន្ទាបខ្លួនទៅរក «ភាពអន់ដ៏សាបរលាប» របស់សហសេវិករបស់គាត់ ដោយការជ្រើសរើសផ្ទះថ្ម ដែលជាកន្លែងមានផាសុកភាពសម្រាប់អ្នករាល់គ្នា ។ គឺនៅទីនោះហើយ ដែលគាត់បានបញ្ចប់រឿង **សារ៉ាម៉ានី** របស់គាត់ ។

ដោយយោងទៅតាមដំណើរជីវិតផ្ទាល់ខ្លួនរបស់លោក ម៉ៃយែរ រឿង **សារ៉ាម៉ានី** បានរៀបរាប់ពីរឿងរ៉ាវរបស់បុរសបារាំងសែសម្នាក់ឈ្មោះ កំលោះ ដែលជាតួយ៉ាងអំពីអតីតសញ្ញាណទូទៅមួយរបស់បេសកកម្មរបស់បារាំងសែសនៅកម្ពុជា ។ កំលោះបានលង់ស្នេហ៍ទៅលើអ្វីដែលគាត់មើលឃើញថា ជាប្រទេសកម្ពុជា ។ គាត់បានបូជាខ្លួនគាត់ទៅលើការរៀនភាសានិងប្រវត្តិសាស្ត្រខ្មែរ ក្នុងគោលបំណងសង្គ្រោះភាសានិងប្រវត្តិសាស្ត្រនេះដើម្បីមនុស្សជំនាន់ក្រោយៗ ទៀត ។ ដូចលោក ម៉ៃយែរ ដែរ តួអង្គឯកកំលោះដែលមានឈ្មោះប្រៀបបានទៅនឹងការដាក់សញ្ញាសួរមួយក្នុងភាពជាបារាំងសែសរបស់គាត់ពេញក្នុងរឿងនោះ បានលង់ស្នេហ៍យ៉ាងខ្លាំងចំពោះប្រទេសកម្ពុជាដែលគាត់បានរស់នៅ ។ ជាបន្តបន្ទាប់មកទៀត គាត់បានបំភ្លេចនូវដើមកំណើត អម្បូរ និងសូម្បីតែភាសារបស់គាត់ ហើយបានក្លាយទៅជាកូនចិញ្ចឹមរបស់ជនជាតិខ្មែរ ។

កំលោះបានរៀបការជាមួយសារ៉ាម៉ានី ដែលជាអ្នករបាំខ្មែរ តំណាងឲ្យ «ពូជសាសន៍មួយដែលមានការធ្លាក់ចុះពីភាពដ៏អស្ចារ្យ ហាក់ដូចជាអណ្តាតភ្លើងសក្តិសិទ្ធិភ្លឺបភ្លែតចុងក្រោយ ដែល កំលោះ នឹងសង្គ្រោះ» (**សារ៉ាម៉ានី** ទំ. ២៣-២៥) ។ ម្យ៉ាងសលាបមុខរបស់សារ៉ាម៉ានី បានបិទបាំងនូវអាថ៌កំបាំងរបស់ពូជសាសន៍បុរាណ ដែលកំពុងស្ថិតនៅលើវិថីនៃការផុតពូជ ហើយនោះ គឺជាភាពទាក់ទាញដែលបានលួងលោមនិងជំរុញឲ្យកំលោះរៀបការជាមួយសារ៉ាម៉ានី ដោយលះបង់ចោលអតីតភាពរបស់គាត់ ។ ប៉ុន្តែ ក្តីសង្ឃឹមរបស់គាត់ត្រូវរលាយសូន្យ ។ ការប៉ុនប៉ងរបស់កំលោះក្នុងការសម្របខ្លួនទៅតាមវប្បធម៌ខ្មែរ ត្រូវបញ្ចប់ដោយភាពបរាជ័យ ។ គាត់ធ្លាក់ខ្លួនឈឺ ដោយសារឥទ្ធិពលជុំវិញមានសភាពខ្លាំងពេក ហើយគាត់វិលត្រឡប់ទៅកាន់ប្រទេសបារាំងវិញ ដើម្បីបញ្ឈប់ការហូរច្រោះនូវបុគ្គលិកលក្ខណៈលោកខាងលិចរបស់គាត់តាម «រយៈធាតុខូចសតិរបស់ព្រលឹងខ្មែរនិងព្រលឹងពុទ្ធសាសនា» (**សារ៉ាម៉ានី** ទំ. ៤១) ។ នាងសារ៉ាម៉ានីស្លាប់តែម្នាក់ឯង ហើយមិត្តភក្តិនិងក្រុមគ្រួសារបានចេញពីនាងដោយសារការក្បត់ពូជសាសន៍និងវប្បធម៌របស់នាង ។ តាមរយៈរឿងរ៉ាវនេះ សាររបស់ម៉ៃយែរ មានលក្ខណៈអភិរក្សយ៉ាង

ជ្រាលជ្រៅ ដោយបានបង្ហាញថា ៖ ការប៉ុនប៉ងធ្វើវិទ្ធង្សនាណាមួយចំពោះអ្វីដែលកំពុងតែកើតមានស្រាប់ គឺជាការដើរទៅរកភាពមហន្តរាយ ។

រឿងនេះ ក៏អាចចាត់ទុកជារឿងសាមញ្ញមួយ ដែលបង្ហាញពីគ្រោះថ្នាក់នៃឱនភាពរបស់ពួកលោកខាងលិចដែរ ។ នៅក្នុងចំណុចមួយនៃរឿងនេះ មានក្សត្រខ្មែរមួយអង្គបានទិញរូបថតបង្ហាញស្ត្រីបារាំងដែលពត់ខ្លួនតាមក្បាច់នានា «ដែលស្រីពេស្យានៅស្រុកខ្មែរមិនដែលស្រមៃដល់» ។ លោក ម៉ៃយែរ បានបម្រើការជាអ្នកបង្រៀនភាសាខ្មែរដល់អ្នករាជការជាតិបារាំង ។ ប៉ុន្តែ នៅពេលដែលសារ៉ាម៉ានីសុំឲ្យកំលោះបង្រៀនភាសាបារាំងដល់នាង នោះកំលោះបានបដិសេធពីព្រោះវាគឺជា «ថ្នាំពុលដែលមានគ្រោះថ្នាក់ដល់ជីវិតសម្រាប់ស្រីខ្មែរ» ហើយវានឹងបង្កឲ្យមាន «គំនិតនិងភាពខិលខូចជាច្រើន ដែលពុំមានពាក្យសម្រាប់ដាក់ឲ្យត្រូវក្នុងភាសារបស់អូន» (**សារ៉ាម៉ានី** ទំ. ១៥២-៥៧) ។ គោលរឿងនៅក្នុងស្នាដៃក្រោយមកទៀតរបស់ម៉ៃយែរ បានលើកឡើងថា ទាំងភាសានិងភាពទំនើបរបស់បារាំងសែស អាចប្រៀបធៀបបានថា ជាឥទ្ធិពលដែលមានលក្ខណៈបំផ្លិចបំផ្លាញនៃសេរីភាពរបស់មនុស្សស្រីនៅក្នុងពិភពលោកខាងលិច ។ នៅក្នុងឆ្នាំ ១៩៥២ លោក ម៉ៃយែរ បានលើកឡើងថា ស្ត្រីដែលមានសេរីភាពនៅលោកខាងលិច បានជ្រៀតជ្រែកចូលទៅក្នុងពិភពរបស់មនុស្សប្រុស ដោយមិនបាននាំមកនូវអ្វីក្រៅតែពីភាពរញ៉េរញ៉ៃនិងតណ្ហា៖ «សេចក្តីស្នេហា គឺជាមុខងារនិងឧបនិស្ស័យរបស់មនុស្សស្រី ។ នៅពេលបើកទ្វារទ្រុងរបស់នាងហើយនោះ តើនាងនឹងធ្វើអ្វីជាមួយសេរីភាពរបស់នាង? នាងនឹងបង្កើតសេចក្តីស្នេហានិងភាពស្មុគស្មាញនៃសេចក្តីស្នេហានោះ... ។ មនុស្សស្រីជាជនដែលមានរាងកាយនិងបញ្ញាខ្សោយជាងមនុស្សប្រុស ហើយជាញឹកញយ ជាមនុស្សដែលមិនចេះទទួលខុសត្រូវ ហើយក៏ជាជនរងគ្រោះដោយសារភាពទន់ខ្សោយរបស់ពួកគេផង ។ ពួកបូព៌ាប្រទេសបានយល់ដឹងពីមនុស្សស្រីបានយ៉ាងច្បាស់ ហើយបានទុកភាពទន់ខ្សោយនោះនៅពីក្រោយជញ្ជាំង ។ សម្រាប់ពួកបូព៌ាប្រទេសនិងសម្រាប់ពួកយើងដែរនោះ ការដោះលែងមនុស្សស្រីឲ្យមានសេរីភាព គឺជាការបាត់បង់រូបនាង» (**ពាក្យសម្តី** ទំ. ៣៣) ។

ដូចគ្នានេះដែរ រឿង **សារ៉ាម៉ានី** ក៏បានបង្កប់ការបង្ហាញថា ការដែលទុកឲ្យប្រជាជនខ្មែរមានសេរីភាព គឺជាការបាត់បង់ពួកគេ ។ មានតែកំលោះប៉ុណ្ណោះ ដែលឈរនៅចន្លោះរវាងពូជសាសន៍ខ្មែរនិងការបាត់បង់ជនជាតិនេះពីប្រវត្តិសាស្ត្រ ដោយធ្វើជាតួអង្គតំណាងឲ្យបេសកកម្មរបស់បារាំងសែស ក្នុងនាមជាអ្នកសង្គ្រោះនិងជាអ្នកអភិរក្សអតីតកាលរបស់ប្រទេសកម្ពុជា ។ នៅក្នុងចិត្តរបស់លោក ម៉ៃយែរ ប្រទេសកម្ពុជាមានលក្ខណៈជាមនុស្សស្រី ដោយមិនអាចប្រកែកបាន និងមិនចេះសាបសូន្យ ។ ទឹកដីនេះបានអូសទាញគាត់ដោយ «មន្តស្នេហ៍ដ៏សក្តិសិទ្ធិ» លួងលោមគាត់ឲ្យចូលទៅក្នុងយ៉ាងជ្រៅ រហូតដល់ទីដែលត្រូវគេកាន់កាប់បានទាំងខ្លួនប្រាណនិងវិញ្ញាណ» (**សារ៉ាម៉ានី** ទំ. ១០-១១) ។ តួអង្គឯកដែលជាម្ចាស់ស្រុកនៅក្នុងប្រលោមលោករបស់គាត់ គឺជាមនុស្សស្រីដែលដឹកនាំជីវិតរបស់ខ្លួនតាមទំនោរសភាវគតិ ។ តាមរយៈការបញ្ចូលប្រទេសកម្ពុជាទៅក្នុងរឿង **សារ៉ាម៉ានី** ដែលបង្ហាញពីអ្នករបាំពេញក្រមុំម្នាក់ បានស្លាប់ក្រោយពេលដែលត្រូវប្តីបារាំងរបស់នាងបោះបង់ចោលនោះ លោក ម៉ៃយែរ បានគូសបញ្ជាក់ពីភាពងាយរងគ្រោះ និងការនៅក្នុងបន្ទុករបស់ប្រទេសកម្ពុជា ។

ប្រលោមលោករបស់លោក ម៉ៃយែរ ក៏បានផ្តល់នូវសក្ខីភាពដ៏សំខាន់មួយ ស្តីអំពីលទ្ធផលដែលទទួលបានក្រោយពីការបំពារបំពានក្របខណ្ឌអាណានិគម ។ ការបោះពុម្ពរឿង **សារ៉ាម៉ានី** បានបង្កឲ្យមានកំហឹងជាសាធារណៈនៅក្នុងសហគមន៍អាណានិគមនិយម ។ គេជឿថា លោក ម៉ៃយែរ ត្រូវបានចោទថ្កោលទោសឲ្យធ្វើ

និរទេស ។ «ក្នុងអំឡុងពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ អ្វីៗ សព្វបែបយ៉ាងត្រូវបានគេបំផ្លាញ ÷ ស្នាដៃ កិត្តិយស ទ្រព្យសម្បត្តិល្អៗ … អាជីព និងអនាគតរបស់គាត់» ។ លោក ម៉ៃយែរ បានចោទប្រកាន់ទៅលើការពួតដៃគ្នារបស់ពួកមនុស្សខ្មៅ និងមនុស្សដែលមានការច្រណែនឈ្នានីស» ពីបទរួមគំនិតក្បត់ក្នុងការបំផ្លាញគាត់ និងពីបទក្លែងរឿង **សារ៉ាម៉ានី** ដើម្បីធ្វើឲ្យអ្នកអានអាណានិគមមានការចូលចិត្តរឿងនោះ (**ដំណោះ** ទំ. ២៥, ២៤) ។ យើងពិបាកដឹងថា ការអះអាងរបស់លោក ម៉ៃយែរ ត្រឹមត្រូវកម្រិតណា ។ ប៉ុន្តែ យើងមានភាពងាយស្រួលក្នុងការមើលឃើញពីមូលហេតុ ដែលរឿង **សារ៉ាម៉ានី** នេះធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍របស់ពួកអាណានិគមនិយម ។ សាច់រឿងលម្អិតនៅក្នុងប្រលោមលោកស្តីពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជានេះ អាចជាការគំរាមកំហែងដល់កិត្យានុភាពរបស់មន្ត្រីអ្នកប្រាជ្ញដែលមានឥទ្ធិពល ដូចជាលោក ក្រោលីយ៉េរ៍ ជាដើម(៣៥) ។ ការពណ៌នាសង្គមអាណានិគមនៅក្នុងរឿងនេះ បានបង្កជាវិវាទបន្ថែមទៀតដល់ភាពស្របច្បាប់របស់មន្ត្រីរាជការបារាំងសែស ដែលបានប្រកាសខ្លួនថា ជាតំណាងឲ្យផលប្រយោជន៍របស់ប្រជាជនខ្មែរ ប៉ុន្តែរស់នៅដាច់ដោយឡែកនៅក្នុងសំបុកប្រកបដោយសុវត្ថិភាពនិងស្រស់ស្អាត នៅក្នុងសង្កាត់បារាំងទៅវិញនោះ ។ អ្នកនិពន្ធដូចជា ពីយែរ ឡូទី (Pierre Loti) ពីយែរ មីល្ល (Pierre Mille) និង អេមីល ពិស្ការី (Émile Pischari) មានឈ្មោះល្បីល្បាញ ដោយសារការវាយប្រហារទៅលើភាពសើនៃការរស់នៅបែបអាណានិគមនិយមនោះ ។ រីឯលោក ម៉ៃយែរ វិញ បានប្រព្រឹត្តល្មើសទៅនឹងច្បាប់សង្គមទាំងនោះ ដោយធ្វើការវាយប្រហារអាកប្បកិរិយាទាំងនោះពីខាងក្នុងមក(៣៦) ។

លោក ម៉ៃយែរ ថែមទាំងបានប្រព្រឹត្តខុសពីទំនៀមទម្លាប់របស់ពួកអាណានិគមនិយម តាមរយៈការពិពណ៌នាឲ្យឃើញថា ស្ត្រីម្ចាស់ស្រុកជាមនុស្សដែលមានសីលធម៌និងមានចរិតល្អ ។ នាងសារ៉ាម៉ានី ពោរពេញទៅដោយការស្រឡាញ់ងប់ងុល តែមានភាពទៀងត្រង់ ហើយបានប្រឈមចំពោះរូបមន្តច្រាំដែលរបស់ស្ត្រីអាស៊ីឈាមត្រជាក់ ។ ការលះបង់របស់នាងចំពោះស្វាមីនោះ គឺមិនមានអ្វីគួរឲ្យឆ្ងល់នោះទេ ហើយមានលក្ខណៈស្រដៀងនឹងការលះបង់របស់ប្រពន្ធស្បែកសដែរ ។ ការពិពណ៌នារបស់លោកម៉ៃយែរ អំពីការរួមភេទរបស់នាងសារ៉ាម៉ានីជាមួយស្ត្រីបំរើក្មេងម្នាក់នៅក្នុងវាំងនោះ ក៏បានគូសបញ្ជាក់អំពីសមត្ថភាពរបស់នាងចំពោះមនោសញ្ចេតនាដ៏ទន់ភ្លន់ដែរ ។ ការបកស្រាយប្រកបដោយភាពហ្មត់ចត់និងមិនមានការរិះគន់នេះ ប្រហែលជាបានធ្វើឲ្យសាច់រឿងនេះបង្កឡើងនូវសេចក្តីធុញទ្រាន់ក្នុងចំណោមអ្នកអានរបស់គាត់ តាមរយៈការពណ៌នាអំពីពិភពចំណង់របស់ស្ត្រី ដែលប្រុសៗ បារាំងលូកមិនចុះ ។

លោក ម៉ៃយែរ បានប្រឈមមុខជាមួយពួកអាណានិគមនិយមក្នុងរឿងមួយទៀត គឺបានពិពណ៌នាថា មន្ត្រីអាណានិគម គឺជាអ្នករើសអើងពូជសាសន៍ និងជាតួកកំប្លែង ។ នាល្ងាចមួយ នៅវេលាដែលកំលោះបានដើរលេងជាមួយសារ៉ាម៉ានីក្បែរសង្កាត់បារាំង គាត់បានពុពាក្យសម្តីដ៏គួរឲ្យឈឺចាប់និងបានឃើញ «ពួកបារាំងមួយក្រុម … កំពុងសើចពីការចំអកគ្មានមេត្តានិងគួរឲ្យស្អប់របស់ពួកគេ … ពួកគេមានរូបរាងអាក្រក់និងខុសធម្មតានៅក្នុងខោអាវពណ៌សមានពុកមាត់ពុកចង្កា ញើសប្រឡាក់ថ្ងាសនិងភ្នែក ក្លិនអសោចដែលសក្តិសមចំពោះសាច់ឈាមដ៏សោះកក្រោះរបស់ពួកគេ សាយភាយជុំវិញខ្លួនពួកគេនោះ ។ មានស្រីម្នាក់ក្នុងចំណោមនោះ ពាក់រុំដោយគ្រឿងរឹតចង្កេះដ៏អាក្រក់ សក់របស់នាងនោះបំពាក់ទៅដោយគ្រឿងតែងលម្អម៉ូតរញ៉េរញ៉ៃយ៉ាងចម្លែក ។ នៅពីក្រោមសក់កន្ទ្រើងរបស់ស្ត្រីនោះ ភ្នែកនាងឃោរឃៅដូចភ្នែកខ្លារខិន បានសម្លឹងមើលមកកំលោះនិងសារ៉ាម៉ានី ដែលជាជនរងគ្រោះពីការមាក់ងាយរបស់នាង ដោយគ្មានដឹងអ្វីទាំងអស់» (**សារ៉ាម៉ានី** ទំ. ១៩០) ។ ដោយសារតែសារ៉ាម៉ានីតំណាងឲ្យសម្រស់

*ដ៏ស្រស់បរិសុទ្ធប្រិមប្រិយ និងភាពស្លូតត្រង់នៅយុគមាសនៃពូជសាសន៍របស់នាងនោះ លោកស្រីម៉ាដាមរបស់ពួកអាណានិគមនិយម គឺតំណាងឲ្យសេចក្តីអាក្រក់នៃភាពទំនើបទាំងឡាយ ។ តាមរយៈការដាក់ភាពសាមញ្ញពីធម្មជាតិរបស់សារ៉ាម៉ានី នៅជាមួយនិមិត្តរូបគួរឲ្យស្អប់ខ្ពើមរបស់ស្ត្រីបារាំងម្នាក់ដែលមានសេរីភាពពេញលេញនោះ លោកម៉ៃយែរ បានផ្ទុះបញ្ជាំងថា តើសារ៉ាម៉ានី (ហើយនិងប្រទេសកម្ពុជា) នឹងអាចក្លាយទៅជាអ្វី ប្រសិនបើប្រទេសបារាំងសែសខកខានមិនបានគោរព និងបង្ការទំនៀមទម្លាប់ដើមរបស់ពួកម្ចាស់ស្រុកទេនោះ ។*

*តាមរយៈការសម្លឹងមើលរបស់ពួកអឺរ៉ុបទាំងនេះ កំលោះបានលើកដឹងពីរូបរាងខាងក្រៅរបស់សារ៉ាម៉ានីដែលមានភាពខុសប្លែកពីគេ ។ រំពេចនោះ គាត់ក៏ចាប់ផ្តើមនឹកឃើញទៅដល់រូបរាងតូចល្អិត និងសម្បុរខ្មៅរបស់នាង ។ ដោយចាប់ភ្ញឹកថា កូនរបស់គាត់អាចនឹងត្រូវដាប់ឈ្មោះដោយសារពណ៌សម្បុររបស់ពួកគេ ហើយអាចនឹងត្រូវបន្ទោសដោយសារការប្រមាថមើលងាយរបស់ពួកបារាំងក្នុងមួយជីវិតនោះ កំលោះបានប្រឈមមុខជាមួយនឹងការបរាជ័យនៅក្នុងបេសកកម្មរបស់គាត់ ។ នៅចន្លោះការស្អប់របស់គាត់ចំពោះពួកស្បែកស និង «ភាពគ្មានសង្ឃឹមក្នុងការផ្លាស់ប្តូរ» នោះ បង្កើតឲ្យមាន «ចន្លោះដ៏គួរឲ្យខ្លាចមួយ» គឺជាគម្លាតដ៏ធំធេងរវាងពួកបារាំងនិងបរិស្ថានសង្គមរបស់ពួកម្ចាស់ស្រុក (**សារ៉ាម៉ានី** ទំ. ១៩៥) ។*

## លោក ហ្សក ហ្គ្រោលីយេរ៍ និងបរាជ័យនៃភាពទំនើប

*ហ្សក ហ្គ្រោលីយេរ៍* (George Groslier) *គឺជាកូនប្រុសរបស់អ្នករដ្ឋបាលអាណានិគមដែលមានប្រពន្ធបារាំងសែស ។ គាត់បានកើតនៅក្នុងទីក្រុងភ្នំពេញ នាឆ្នាំ ១៨៨៧ ។ នៅឆ្នាំ ១៨៩១ ឪពុកម្តាយរបស់គាត់បានបញ្ជូនគាត់ឲ្យទៅរៀននៅប្រទេសបារាំងសែស*(៣៧) *។ គាត់បានត្រឡប់មកប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩០៩ ហើយប្រាំឆ្នាំក្រោយមក ក្រសួងសិក្សាធិការបានផ្តល់កិច្ចការជាច្រើនដល់គាត់ ។ ដោយសារការយកចិត្តទុកដាក់ជានិច្ចចំពោះមរតកវប្បធម៌របស់គាត់ លោក ហ្គ្រោលីយេរ៍ «រក្សានូវទម្លាប់ដ៏ស៊ីវិល័យយ៉ាងក្រៃលែងរបស់គាត់ នៅក្នុងព្រៃស្ងាត និងស្លៀកសម្លៀកបំពាក់រាត្រីរបស់គាត់ មុនពេលអង្គុយតែម្នាក់ឯង នៅពីមុខតុបោះដំរំដ៏ផុយស្រួយមួយ»*(៣៨) *។ នៅឆ្នាំ ១៩១៣ គាត់ជាជនអឺរ៉ុបដំបូង ដែលបោះពុម្ពការស្រាវជ្រាវអំពីក្រុមល្ខោនព្រះរាជទ្រព្យ ។ ស្នាដៃទីពីររបស់គាត់ គឺជាសៀវភៅស្តីពីការធ្វើដំណើរបែបរ៉ូម៉ង់ទិចមួយដែលមានចំណងជើងថា* **នៅក្នុងស្រមោលអង្គរ** (*À l'ombre d'Angkor*)(៣៩) *។ នៅពេលដែលគាត់ត្រឡប់មកពីបំពេញភារកិច្ចក្នុងសង្គ្រាមលោកលើកទី ១ នៅអឺរ៉ុបវិញ នៅឆ្នាំ ១៩១៧ លោក អាល់ប៊ែរត៍ សារ៉ូត៍* (Albert Sarraut) *អគ្គទេសាភិបាលនៅឥណ្ឌូចិន បានប្រគល់តំណែងឲ្យគាត់ធ្វើជារដ្ឋមន្ត្រីទទួលខុសត្រូវខាងផ្នែកអប់រំសិល្បៈនៅប្រទេសកម្ពុជា ។ លោក សារ៉ូត៍ ដែលជាអ្នកគាំទ្រនាំមុខគេម្នាក់ ចំពោះគោលនយោបាយរួបរួមនិយមនោះ ជឿជាក់ថា អនាគតនៃការគ្រប់គ្រងរបស់ពួកអាណានិគមនិយម មិនមែនស្ថិតតែនៅលើការលាយបញ្ចូលវប្បធម៌នោះទេ ប៉ុន្តែ គឺស្ថិតនៅលើការអនុញ្ញាតឲ្យវប្បធម៌ទាំងនោះមានការវិវត្ត «ក្រោមការទំនុកបម្រុងរបស់ពួកយើង នៅក្នុងក្របខណ្ឌនៃអរិយធម៌របស់ពួកគេ»*(៤០) *។ គោលការណ៍ទាំងនោះបានណែនាំផែនការរបស់លោក ហ្គ្រោលីយេរ៍ ក្នុងការដឹកនាំសាលារចនានៅភ្នំពេញដែលបានបើកនៅឆ្នាំ ១៩១៩ និងការពង្រីកសារមន្ទីរជាតិឲ្យក្លាយទៅជាសារមន្ទីរ អាល់ប៊ែរត៍ សារ៉ូត៍ ដែលបើកនៅឆ្នាំ ១៩២០ ។ តាមរយៈស្ថាប័នទាំងនេះ ពួកបារាំងសែសបានគ្រប់គ្រងទៅលើសិល្បៈចម្លាក់និងស្ងូនរូប ។ ចាប់តាំងពីឆ្នាំ ១៩១៩ រហូតដល់មរណភាពរបស់គាត់នៅទីក្រុងភ្នំពេញ នាឆ្នាំ ១៩៤៥ លោក ហ្គ្រោលីយេរ៍ បានបន្ត*

*ដឹកនាំសារមន្ទីរនិងគោលនយោបាយអប់រំសិល្បៈនៅក្នុងប្រទេសកម្ពុជា ។ គាត់បានសរសេរអត្ថបទស្រាវជ្រាវជាច្រើនស្តីពីរបាំខ្មែរ សិល្បៈ ប្រពៃណីខ្មែរ និងស្ថាបត្យកម្មអាណានិគម ដែលមានចេញផ្សាយជាទៀងទាត់នៅក្នុង* **ទិនានុប្បវត្តិអាស៊ីបូព៌ា** *។ ចំណែកឯគំនិតប្រឌិតរបស់គាត់វិញ គាត់បានចេញផ្សាយជារឿងប្រលោមលោក ។*

*ចក្ខុវិស័យផ្នែកសិល្បៈរបស់លោក ហ្គ្រោលីយេ៉ រ ផ្តោតទៅលើការជំនួសអ្នកគាំទ្រសិល្បៈក្នុងស្រុក គឺពួកស្តេច និងពួកនាម៉ឺនខ្មែរ ដែលនៅជំនាន់នោះ បានវិនិយោគទ្រព្យសម្បត្តិទៅលើការនាំចូលពីលោកខាងលិចដោយអ្នកគាំទ្រថ្មីមួយបែបទៀត ដូចជាអ្នកទេសចរនិងពួកអាណានិគមនិយមនៅក្នុងស្រុក ។ ក៏ប៉ុន្តែ ដើម្បីផ្គត់ផ្គង់នូវតម្រូវការដែលលោក ហ្គ្រោលីយេ៉ រ បានទស្សន៍ទាយដ៏ត្រឹមត្រូវ ទៅលើការធ្វើបដិមានិងគ្រឿងអលង្ការកំប៉ិកកំប៉ុកតាមរចនាបថសម័យអង្គរនោះ គាត់ត្រូវបង្កើតនូវក្រុមជាងដែលមាន «ឈាមជ័រសុទ្ធសាធ» អាចជួយសង្គ្រោះសិល្បៈខ្មែរឲ្យចៀសផុតពី «ភាពដុនដាប» និង «ការក្លាយ» បាន(៤១) ។ ក្រៅពីជ្រើសរើសសិប្បករនិងគ្រូដែលមានចំនួនដ៏តិចតួចនៅកម្ពុជារួចហើយនោះ លោក ហ្គ្រោលីយេ៉ រ ក៏បានបញ្ជូនសិស្សឲ្យទៅតំបន់អង្គរ ដើម្បីចម្លងនិងកាន់តែធ្វើឲ្យមានភាពសុក្រឹតបន្ថែមទៀត ចំពោះក្បាច់ចម្លាក់ទាំងឡាយសម្រាប់ការផលិតឡើងវិញ ។*

*មានអ្នកមួយចំនួនសរសើរថា ការធ្វើបែបនេះ គឺជាសកម្មភាពមិនគិតពីផលកម្រៃ និងមានភាពសប្បុរស ។ អ្នកមួយចំនួនទៀតថ្កោលទោសថា នេះជាកលល្បិចដ៏អាក្រក់ក្នុងការដកហូតការរីកចម្រើនរបស់បស្ចិមប្រទេសពីដែនដីអាណានិគម ដោយផ្តល់ឲ្យពួកគេនូវតែប្រពៃណីរបស់ខ្លួនគេវិញនោះ បេសកកម្មសង្គ្រោះសិល្បៈខ្មែររបស់លោក សារ៉ូត៍ និងលោក ហ្គ្រោលីយេ៉ រ ស្ថិតនៅលើផ្លូវដែលប្រកបដោយភាពរន្ធត់អំពីទំនើបភាព ដែលបានដិតជាប់មកជាយូរមកហើយ(៤២) ។ ការសម្លាប់រង្គាលនៅក្នុងសង្គ្រាមលោកលើកទី ១ បានធ្វើឲ្យភាពរន្ធត់នោះ កាន់តែមានសភាពធ្ងន់ឡើងៗ ។ លោក ហ្គ្រោលីយេ៉ រ និងបញ្ញវន្តបារាំងសែសជាច្រើនផ្សេងទៀត បានខិតខំស្វែងរកគំរូនៃអរិយធម៌នៅក្នុងបូព៌ាប្រទេស ដែលអាចផ្តល់ប្រយោជន៍សម្រាប់ប្រទេសនៅអឺរ៉ុប ។ ការមើលឃើញបែបមនោសញ្ចេតនាដ៏ជ្រាលជ្រៅអំពីប្រទេសកម្ពុជា បានផុសឡើង ហើយជារឿយៗ ផុសឡើងជាមួយនឹងលក្ខណៈអភិរក្សយ៉ាងស្មុគស្មាញ ។ លោក ហ្គ្រោលីយេ៉ រ ក៏មានគំនិតដូចលោក ម៉ៃយេរ ដែរ ។ គាត់យល់ឃើញថា ការដោះលែងឲ្យស្ត្រីមានសេរីភាព គឺជាសារធាតុដែលជំរុញឲ្យបស្ចិមប្រទេសចុះអន់ថយ ។ ចក្ខុវិស័យចំពោះប្រាសាទអង្គរវត្ត ថា ជាតំណាងឲ្យភាពបរិសុទ្ធនិងឥតខ្ចោះបំផុតរបស់ប្រទេសកម្ពុជានោះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការងារនៅក្នុងជីវិតរបស់លោក ហ្គ្រោលីយេ៉ រ ។ ប្រលោមលោករបស់គាត់បានបញ្ចូលនូវខ្លឹមនៃជាតិសាសន៍មួយទៅក្នុងទម្រង់មនុស្សស្រី ។ ដូច្នេះហើយ ទើបបានជារឿងប្រតិដ្ឋរបស់លោក ហ្គ្រោលីយេ៉ រ ឆ្លុះបញ្ចាំងយ៉ាងច្បាស់និងយ៉ាងសំខាន់ អំពីរបៀបដែលគាត់ប្រមើលគិតចំពោះប្រទេសកម្ពុជា ហើយដែលគាត់បានជួយដើម្បីឲ្យការគិតនោះក្លាយជាការពិតតាមរយៈគោលនយោបាយវប្បធម៌របស់គាត់នោះ ។*

*ប្រលោមលោកទាំងពីរ គឺរឿង* **ផ្លូវរបស់អ្នកខ្លាំងបំផុត** *(La Route du plus fort) (គ.ស. ១៩២៥) និងរឿង* **ក្លាយទៅជាដីឥដ្ឋវិញ** *(Le Retour à l'argile) (គ.ស. ១៩២៩) គឺជាកញ្ចក់ឆ្លុះបញ្ចាំងមុមបីនៃភេទភាវៈ ។ រឿង* **ផ្លូវរបស់អ្នកខ្លាំងបំផុត** *មិនមែនចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជាទេ តែវាចាប់ផ្តើមនៅទីក្រុងប៉ារីស ជាទីកន្លែងដែលនាង ហេឡែន (Hélène) ចាប់ចិត្តស្នេហាលោក ទែរនីញ៉េរ (Ternier) ដែលជាអ្នករដ្ឋបាលអាណានិគម ដែលទៅសម្រាកវិស្សមកាលនៅស្រុកកំណើត ។ ទែរនីញ៉េរ តំណាងឲ្យពួកអាណានិគមនិយមដែលជា «ម៉ាស៊ីនដ៏មានអំណាច» បញ្ជាដោយ «អត្តទត្តភាពរបស់អ្នកខ្លាំង និងទម្ងន់នៃការគិតប្រកបដោយការត្រិះរិះ*

*ពិចារណាដ៏ត្រឹមត្រូវ» (**ផ្លូវ** ទំ. ២៣៥) ។ ហៅឡែន ដែលជាតួអង្គតំណាងឲ្យប្រទេសបារាំងសែស មានការស្រេកឃ្លានចង់ចេញឲ្យផុតពីភាពសោះកក្រោះនៃមជ្ឈប្រទេស និងចង់ធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បីរុករកភាពប្លែកៗ និងសារជាតិនៃជីវិតអាណានិគម ។ នាងបានយល់ឃើញថា ទេសភាពប្រទេសកម្ពុជាពោរពេញទៅដោយជោគជ័យក្រោមកិច្ចប្រឹងប្រែងរបស់ពួកបុរសអាណានិគមនិយម ដែលជាមោទនភាពនិងក្តីត្រេកអរសប្បាយរបស់ ទែរនីញ៉េរ៍ ឧទាហរណ៍ដូចជា ផ្លូវដែលទើបនឹងសង់ហើយពីសន្តែទៅស៊ីសូផុន ។ នៅក្នុងសេចក្តីសំបុត្រមួយ ហៅឡែន បានប្រៀបធៀបខ្លួនរបស់នាងទៅនឹងដែនដីអាណានិគមថា ៖ «ខ្ញុំ គឺជាខេត្តមួយក្នុងចំណោមខេត្តទាំងឡាយដែលគាត់បានបុករុកចូលទៅដល់ ... ខ្ញុំមានសភាពស្ងប់ស្ងាត់ មានភាពរីករាយ និងមានទម្លាប់ជាប្រចាំមួយចំនួន ដូចខេត្តមួយអ៊ីចឹងដែរ ... ហើយគាត់បានថែចង់ខ្ញុំ ។ គាត់បានធ្វើឲ្យខ្ញុំវង្វេងវង្វាន់ ដោយសារគំនិតនិងការងប់ងុលរបស់គាត់ ទាំងនោះបានធ្វើឲ្យខ្ញុំស្រេកឃ្លាននូវភាពមានបាន ដែលខ្ញុំមិនធ្លាប់បានឃើញកន្លងទៅ ។ គ្រប់គំនិតដ៏អន់ថយរបស់ខ្ញុំ គម្រោងរបស់ខ្ញុំ ហើយនិងសូម្បីតែការចងចាំរបស់ខ្ញុំ ក៏ត្រូវលែងស្គាល់ ប្រៀបដូចទៅនឹងភូមិជាច្រើន ដែលត្រូវផ្លូវរបស់គាត់បានរុញច្រាននិងលេបទៅ ។ ខ្ញុំមានអារម្មណ៍ថា បានរីកធំឡើង ថ្វីដ្បិតតែរឿងទាំងនោះធ្វើឲ្យខ្ញុំមានការឈឺចាប់ និងទម្លាប់ដែលខ្ញុំមានជាយូរ ដែលបានហែកហួរខ្ញុំយ៉ាងណាក៏ដោយ» ។ ភាពរឹងមាំ រឹងប៉ឹង និងខ្លាំង ដែលជាលក្ខណៈសំខាន់របស់ភាពជាបុរស តំណាងឲ្យផ្លូវដែលកាត់ដីខ្មែរដ៏មានផលដោយដីនោះតំណាងឲ្យភាពជាស្ត្រី «ដែលបានចេញពន្លកដោយមិនចេះហត់នឿយ អស់ជាច្រើនសតវត្សរ៍មក» (**ផ្លូវ** ទំ. ២៣២) ។*

*ស្ត្រីខ្មែរមិនមានភាពផ្លាស់ប្តូរដូចទៅនឹងទេសភាពទាំងនោះដែរ ។ ស្ត្រីខ្មែរត្រូវបានតំណាងដោយនាងវេទនា ដែលជាប្រពន្ធលួចលាក់របស់ទែរនីញ៉េរ៍ ។ ហាក់បីដូចជាអ្នកនិពន្ធបានជ្រើសរើសឈ្មោះវេទនានេះដើម្បីគូសបញ្ជាក់ពីចរិតលក្ខណៈដែលពោរពេញទៅដោយកលឧបាយ ហើយនិងដើម្បីសុំការសន្តោសប្រណីចំពោះបុរសបារាំងអកត័ញ្ញូ ដែលធ្លាក់ចូលទៅក្នុងភាពទុក្ខសោក ដោយសារកលល្បិចរបស់ស្ត្រីខ្មែរនោះ ។ វេទនាគឺជាតួអង្គបន្ទាប់បន្សំ ជាតួអង្គមួយសម្រាប់បង្កើតបរិយាកាសប្លែកៗ ហើយនិងដើម្បីបង្ហាញពីភាពជិតដិតរបស់ទែរនីញ៉េរ៍ ជាមួយនឹងមនុស្សដែលគាត់គ្រប់គ្រង ។ ក្នុងនាមជាមូលរូបនៃប្រពន្ធឥតខាន់ស្លាប្រពន្ធលួចលាក់នោះ នាងតំណាងឲ្យទាំងក្តីសង្ឃឹមរបស់បុរសស្បែកស និងបន្ទុករបស់បុរសនោះ ។*

*លើសពីនេះទៅទៀត វេទនាគឺជាកូនកាត់ខ្មែរ–សៀមដែលត្រូវឪពុកបោះបង់ចោល ។ តាមរយៈការទទួលយកបេសកកម្មអាណានិគមរបស់ប្រទេសបារាំងសែស ម៉ៃយែរ ពិព័ណ៌នា ទែរនីញ៉េរ៍ ជាអ្នកការពារដ៏ក្លាហានដែលបានសង្គ្រោះវេទនា ហើយព្រមទាំងបាន «លើកនាងដាក់លើបល្ល័ង្កនិងនៅលើគ្រែរបស់គាត់» ។ ការបែងចែកទីកន្លែង និងតួនាទីរបស់ការបែងចែកនេះនៅក្នុងការបង្កើតដែនដីអាណានិគម ត្រូវបានសង្កត់ធ្ងន់នៅពេលដែលទែរនីញ៉េរ៍បញ្ជាឲ្យ «ប្រពន្ធ» ខ្មែរថ្មីរបស់គាត់ អនុលោមទៅតាមច្បាប់ចរិយាធម៌នៅក្នុងផ្ទះរបស់គាត់ ។ នាងត្រូវតែនៅក្នុងបន្ទប់ទាំងបីនៅផ្នែកខាងក្រោយ នាងមិនអាចបង្ហាញមុខនៅតាមបង្អួចខាងមុខណាមួយឡើយ ហើយនាងមិនអាចស៊ីស្លានៅផ្ទះ ឬទទួលភ្ញៀវខ្មែរឡើយ ។ ការដាក់ទណ្ឌកម្មទៅលើការបំពាន មានចាប់ពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ចរហូតដល់ «ការលែងលះ» ហើយដែលនេះ គឺជាការបង្ហាញបន្ថែមទៀតពីការត្រួតត្រារបស់ពួកអាណានិគមទៅលើឋានានុក្រមពូជសាសន៍និងទីកន្លែង (**ផ្លូវ** ទំ. ៧៦, ៧៩) ។*

*លោក ហ្គ្រោលីយេរ៍ បានពន្យល់ថា ស្រីកំណាន់ជាម្ចាស់ស្រុកទាំងអស់ ឋិតនៅក្រោមឥទ្ធិពលនៃទំនោរ*

*ធម្មជាតិដែលជាប់ទាក់ទិនទៅនឹងឧបាយកលនិងការបោកបញ្ឆោត ។ ដូចនេះហើយ គ្មានអ្វីមួយអាចកំណត់ពីជម្រៅនៃមនោសញ្ចេតនារបស់នាងវេទនាបានឡើយ ។ ក្នុងអំឡុងពេលតែប៉ុន្មានខែប៉ុណ្ណោះ នាងវេទនាបានបញ្ចប់ការប្រែក្លាយទៅជាស្រីកំណាន់ដ៏សាមញ្ញម្នាក់ ។ នាងរង់ចាំបម្រើបុរសស្បែកសទាំងដៃទាំងជើង ដូចនេះហើយគ្មាននរណាម្នាក់អាចគេចផុតពីមន្តស្នេហ៍របស់នាងឡើយ ។ តាមរយៈការលួងលោមដោយអវយវៈល្វត់ល្វន់ និងការបញ្ឆោរដោយការយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួននោះ មិនយូរប៉ុន្មាន បុរសទាំងនេះមានការធុញទ្រាន់ចំពោះស្ត្រីបារាំងដែលគិតតែពីរញ៉ាំរញ៉ូវយ៉ាងរឹងរូស និងអាកប្បកិរិយាដែលគិតតែពីខ្លួនឯង គឺថា «បើប្រៀបទៅនឹងរូបកាយរាងរាវ ល្វតល្វន់ និងមិនចេះប្រកែកតវ៉ានៅមុខអ្នក ជាប្រចាំនេះ ស្ត្រីបារាំងមើលទៅហាក់ដូចជាធ្ងន់ ធាត់គ្រោតគ្រាត រអ៊ូច្រើន … បែកញើសដោយសារអាកាសធាតុ និងមានរោមខ្លួន ធ្វើឲ្យអ្នកខ្ពើមរអើម ឯស្ត្រីម្ចាស់ស្រុកវិញ រក្សាបាននូវភាពស្រស់ ស្ងួត និងទន់ភ្លន់ដូចក្លុក» (**ផ្លូឌ** ទំ. ១៣៧, ៨៣) ។ មានតែពេលវេលាកន្លងប៉ុណ្ណោះ ដែលអាចបង្ហាញពីឧបាយកលបោកបញ្ឆោតរបស់ស្រីកំណាន់ទាំងនោះបាន ។ នៅក្នុងរយៈពេលនោះ នាងកាន់តែរឹងមាំឡើង ហើយតួនាទីរបស់នាង មានការផ្លាស់ប្តូរ÷ ពេលនេះ ស្រីដែល «ចេះខ្មាសអៀន» របស់អ្នកបានត្រួតត្រាលើអ្នក ។ នេះ គឺជាអ្វីដែល ក្រោលីយ៉េរ៍ បានព្រមានអ្នកអានដែលជាបុរសអាណានិគមនិយមបារាំងសែស ។ មន្តស្នេហ៍ដែលពោរពេញទៅដោយសេចក្តីស្រឡាញ់នោះ បញ្ជាក់យ៉ាងច្បាស់ពីមាយាស្រី ។ អ្នកត្រូវចេះគោរពពេល ហើយពុំហ៊ានចូលផ្ទះយប់ជ្រៅពេកទេ ពីព្រោះ «ប្រសិនបើអ្នកធ្វើអ្វីមួយឲ្យស្រីបម្រើរបស់អ្នកទើសចិត្តនោះ នាងនឹងបដិសេធមិនព្រមស្រាតសំពត់របស់នាងឡើយនៅយប់នេះ» ។ មិនយូរប៉ុន្មាន នាងដឹងទាំងអស់ពីហិរញ្ញវត្ថុរបស់អ្នក នាងមានសោផ្ទាល់ខ្លួនទាំងអស់ ហើយនាងគ្រប់គ្រងអ្នកបម្រើដទៃទៀតនៅក្នុងផ្ទះ ។ ក៏ប៉ុន្តែ មិនមែនមានតែអ្នកម្នាក់នោះទេ ដែលធ្លាក់ចូលទៅក្នុងអន្ទាក់នេះ ពីព្រោះនៅពេញផ្ទៃឥណ្ឌូចិន គេឃើញមាន «បុរសគ្រប់វ័យនិងគ្រប់តំណែង … មិនមាននៅសល់អ្វីឡើយ និងចុះទន់ខ្សោយ ដោយសារប្រពន្ធខ្មែរ … ដែលចេះអត់ធ្មត់ និងប៉ិនប្រសប់ ដូចកណ្តូបសេះ ហើយបានទទួលជោគជ័យក្នុងការធ្វើឲ្យបុរសរបស់ខ្លួនវិនាស» (**ផ្លូឌ** ទំ. ៨៣, ៨៥) ។ នេះជាសម្តីរបស់លោក ក្រោលីយ៉េរ៍ ។ ទែរនីញ៉េរ៍ បានធ្វើយ៉ាងណាកុំឲ្យរឿងនេះមិនអាចកើតឡើងចំពោះគាត់ឡើយ ដោយសារគាត់បានគ្រប់គ្រងវេទនាដោយដៃដ៏រឹងមាំរបស់គាត់ ហើយគាត់បានទុកនាងនៅកន្លែងសមនឹងឋានៈរបស់នាង ។ ការស្លាប់របស់ ហេឡែន បានធ្វើឲ្យឃើញកាន់តែច្បាស់ អំពីចំណុចខ្សោយរបស់មជ្ឈប្រទេស និងគំនិតដែលថា អ្វីៗដែលទាក់ទិននឹងស្រី ត្រូវស្ថិតនៅកន្លែងដែលបានកំណត់ នៅពេលដែលបុរសតែម្នាក់ឯងអាចប្រើប្រាស់អំណាចដោយសេរី ដើម្បីផ្លាស់ប្តូរពិភពលោកនោះ ។ នាង ហេឡែន មិនត្រឹមតែមិនព្រមស្តាប់ការទូន្មានរបស់ ទែរនីញ៉េរ៍ ដែលថា តំបន់នោះមានការពិបាកខ្លាំងណាស់សម្រាប់ស្ត្រីប៉ារីសនោះទេ ថែមទាំងបានអូសទាញ ទែរនីញ៉េរ៍ ឲ្យយល់ព្រមយកនាងទៅធ្វើដំណើរកម្សាន្តតាមផ្លូវ រហូតដល់នាងធ្លាក់ខ្លួនឈឺស្លាប់នៅទីបំផុត ។ វេទនាគោរពតាមច្បាប់ទម្លាប់ ដោយស្នាក់នៅកន្លែងដែលទែរនីញ៉េរ៍ បានកំណត់ទុកនោះ មានជីវិតរស់រានតទៅមុខទៀត ។ រីឯ ហេឡែន បានធ្វើដំណើរចេញផុតពីដែនកំណត់របស់មនុស្សស្រីនោះ ហើយបានស្លាប់ ។*

*ប្រលោមលោកទីពីររបស់ ក្រោលីយ៉េរ៍ ដែលបានទទួលរង្វាន់នោះ ក៏បានយកលំនាំតាមបរិស្ថានភេទភាវៈ (យេនឌ័រ) ដូចគ្នា ។ រឿង* **ក្លាយទៅជាដីឥដ្ឋខញ្ញ** *រៀបរាប់ពីការមើលឃើញរបស់លោក ក្លូដ រ៉ូឡាំង* (Claude Rollin) *ដែលជាវិស្វករបារាំងសែសរស់នៅទីក្រុងភ្នំពេញជាមួយប្រពន្ធរបស់គាត់ឈ្មោះ រ៉េម៉ុងដ៍* (Raymonde) *។*

វែម៉ុងដ៏ ដែលតំណាងឲ្យមជ្ឈប្រទេស គឺជាស្ត្រីទន់ខ្សោយនិងមិនមានសមត្ថភាពខ្ពស់ ហើយនាងបាននឹកឃើញតែអ្វីដែលកើតមាននៅទីក្រុងប៉ារីសតែប៉ុណ្ណោះ ដោយមិនមានឆន្ទៈទទួលយកអ្វីដែលកើតឡើងនៅក្នុងប្រទេសក្រោមអាណានិគមឡើយ ។ ផ្ទុយទៅវិញ ក្លូដ បានក្រសោបយកនូវជីវិតថ្មីរបស់គាត់ជាមួយនឹងភាពរឹងប៉ឹងជា «បុរស» (**ក្លាយទៅជាជីឥដ្ឋ** ទំ. ១៦) ។ ប្រទេសកម្ពុជាតំណាងឲ្យភាពជាស្រីកំណាន់ម្តងទៀត តាមរយៈនាងកម្ញាំង និងនាង ណាគ្រី ដែលជាប្រពន្ធលួចលាក់របស់ ក្លូដ ។

ប្រលោមលោកនេះបានភ្ជាប់ទំនាក់ទំនងរវាងការបំពានរបស់ ក្លូដ ទៅលើនារីរបស់សង្គមអាណានិគម ទៅនឹងការផ្លាស់ប្តូរជាបន្តបន្ទាប់របស់គាត់ ពីអ្នកកែប្រែប្រទេសកម្ពុជា ទៅជារបស់លេងមិនចេះតវ៉ានៃប្រពន្ធលួចលាក់របស់គាត់ទៅវិញ ។ ដោយងាកចេញពីការលើកតម្កើងតួនាទីនៃប្រទេសបារាំងសែសនៅតណ្ហាចិនរបស់លោក ហ្គ្រោលីយេ៉រ៍ រឿង **ក្លាយទៅជាជីឥដ្ឋខ្មៅ** បានធ្វើឲ្យអ្នកអាននិងអ្នកបញ្ចេញយោបល់ ភ្ញាក់ផ្អើលយ៉ាងខ្លាំង⁽⁴³⁾ ។ បន្ទាប់ពីរស់នៅប្រទេសកម្ពុជាអស់រយៈពេលពីរឆ្នាំ លោក ក្លូដ ដែលធ្លាប់បានរៀបការយ៉ាងសប្បាយចិត្ត និងខំប្រឹងធ្វើការនោះ បានបោះបង់កិរិយាស្របច្បាប់ មិត្តកក្តិ សម្លៀកបំពាក់របស់ពួកអាណានិគមនិយម ទំនៀមទម្លាប់អាណានិគមនិយម និងភាពសុខស្រួលរបស់គាត់ចោល ដើម្បីទៅរស់នៅក្នុងសង្កាត់ខ្មែរ ។ តាមរយៈការរៀបរាប់អំពីការធ្លាក់ចុះផ្នែកសង្គមនិងលំឱនទៅរកភាពអន់ថយនោះ ប្រលោមលោកមួយនេះ អាចបកស្រាយជាការព្រមានមួយអំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការមានសម្ពន្ធភាពជាមួយសង្គមម្ចាស់ស្រុក ។ ប៉ុន្តែ នៅចុងបញ្ចប់នៃរឿងនោះ ក្លូដ មិនបានរាវែកគំនិតផ្នែកសីលធម៌ទេ ។ ផ្ទុយទៅវិញ ក្លូដ បានដកដង្ហើមធំនៅជំពូកចុងក្រោយ ហើយលាន់មាត់ថា ៖ «ស្លាប់ស្វាត់អីក៏ស្លាប់ស្វាត់ម៉្លេះទេ !» ។ ហើយគាត់ក៏បាននិយាយទៀតថា ៖ «អញពិតជាមានមោទនភាព ដែលបានបោះបង់ភាពជាបុរសស៊ីវិល័យដែលគិតថា ខ្លួនឯងជាមនុស្សលេខមួយក្នុងលោក ចោលទៅនោះ» (**ក្លាយ** ទំ. ២៦៩) ។

តាមរយៈការសរសេរត្រាប់តាមប៉ែបអំពីសង្គមអាណានិគមថា ជាអាកប្បកិរិយារាក់កំភែលនោះ លោក ហ្គ្រោលីយេ៉រ៍ បានលើកតម្កើងវប្បធម៌ខ្មែរ ចំពោះភាពសាមញ្ញនិងភាពជិតស្និទ្ធទៅនឹងធម្មជាតិ ។ ជាងនេះទៅទៀត លោក ហ្គ្រោលីយេ៉រ៍ បានលើកឡើងថា ប្រទេសបារាំងសែសត្រូវរៀនច្រើនពីប្រទេសកម្ពុជា ជាពិសេសរឿងរ៉ាវដែលទាក់ទងទៅនឹងតួនាទីស្ត្រី ។ ជាការវាយប្រហារមួយទៅលើអរិយធម៌បស្ចិមប្រទេស និងការសន្មតរបស់ពួកគហបតីនោះ រឿង **ក្លាយទៅជាជីឥដ្ឋខ្មៅ** បានថ្កោលទោសយ៉ាងដូរចត់ចំពោះ «ការធ្វើឲ្យបាត់បង់ភាពជាស្ត្រី» របស់ស្ត្រីនៅបស្ចិមប្រទេស ។ នៅប្រទេសបារាំង ការរីកចម្រើនបានប្រែក្លាយម្តាយពីធម្មជាតិឲ្យទៅជាមនុស្សកំណាច និងអាត្មានិយម ដែលការទាមទារដើម្បីភាពស្មើគ្នារបស់ពួកគេបានធ្វើឲ្យសង្គមនិងគ្រួសារមានការបែកបាក់ ។ លោក ហ្គ្រោលីយេ៉រ៍ បានអះអាងបន្តទៀតថា ដូចដែលការរីកចម្រើនបានលុបបំបាត់ភាពជាស្ត្រីនៅប្រទេសបារាំងសែសនោះ ការរីកចម្រើននេះក៏អាចបណ្តាលឲ្យមានការបំផ្លាញនូវខ្លឹមរបស់ប្រទេសកម្ពុជាដែរ ។ ពេលដែលកំពុងតែស្ងើចសរសើរ «តួស្ពានដ៏រឹងមាំ» ដែលសង់ជិតហើយរបស់គាត់នោះ ស្រាប់តែលោក ក្លូដ មានការសោកស្តាយថា «គាត់បានវាយម្តងទៀតទៅលើប្រទេសដ៏បរមបុរាណ ដែលត្រូវបំផ្លិចបំផ្លាញដោយបស្ចិមប្រទេសនេះ» (**ក្លាយ** ទំ. ១៩១) ។

ក្លូដ បានសងចំពោះកំហុស ដែលគាត់បានធ្វើឲ្យខូចទេសភាពរបស់ប្រទេសកម្ពុជា តាមរយៈការការពារស្រីកំណាន់ស្ងាររបស់គាត់ ឲ្យចេញផុតពីភាពទំនើប ។ គាត់បានសង់ផ្ទះខ្មែរធ្វើពីឈើមួយខ្នងសម្រាប់នាង ដោយ

មានកន្ទេលផ្តៅ និងគ្រែឈើរឹង ហើយព្រមទាំងទទូចសុំឲ្យនាង កម្ញាំង ស្លៀកសម្លៀកបំពាក់ និងពាក់គ្រឿងមាសពេជ្របស់ខ្មែរសុទ្ធ ។ ចំពោះក្លូដ នាងមិនដែលបានចេញពីអន្ទាក់ជីវិតបែបអាស៊ី ដែលគាត់បានតាក់តែងឡើងឡើយ ។ ប៉ុន្តែ នាង កម្ញាំង ចង់បានរបៀបរបបបែបប៉ារីស ហើយនិងផ្ទះថ្មបែបចិននៅតាមផ្លូវទាន់សម័យ ។ ខណៈពេលដែល ក្លូដ បណ្តោយតាមចំណូលចិត្តរបស់គាត់ឲ្យទៅតាមភាពប្លែកៗ នោះ កម្ញាំងបែរជាត្រូវគាបសង្កត់ចំណង់ឲ្យឃ្លានទៅរកភាពចម្រុះរបស់នាងទៅវិញ ។ អនុត្តរភាពខាងផ្នែកសោភណភាពរបស់ ក្លូដ គឺជាកញ្ចក់ឆ្លុះបញ្ចាំងពីការឆ្ងាក់អត្តសញ្ញាណសិល្បៈខ្មែរ តាមរយៈសាលារចនារបស់លោក ហ្គ្រោលីយេ៉រ៍ ។ សំពត់អាវតាមរបៀបខ្មែររបស់កម្ញាំង ក្លាយទៅជាលក្ខណៈពិសេសកំណត់ពីអត្តសញ្ញាណរបស់នាង ហើយនិងជានិមិត្តរូបនៃបំណងប្រាថ្នារបស់ ក្លូដ ។ ដូចដែលលោក ហ្គ្រោលីយេ៉រ៍ ថ្កោលទោសការនាំចូលរបស់បស្ចិមប្រទេសថា ជាគ្រឿងចម្លងរោគទៅឲ្យវប្បធម៌ខ្មែរនោះ ដូច្នេះហើយទើបប្រលោមលោករបស់គាត់សំញែងស្ត្រីបារាំងថា ជាគ្រោះកម្មអាក្រក់ដែលកំពុងរង់ចាំនាងកម្ញាំង ប្រសិនបើនាងទទួលយករបៀបរបបពួកបស្ចិមប្រទេស ។ អ្នកស្រី វែរម៉ុងដ៍ គឺជាតួអង្គតំណាងឲ្យស្ត្រីបារាំងដែលចូលចិត្តនិយាយច្រំដែល និយាយរអ៊ូរទាំ ឆេវឆាវ ឆ្លើងក្ជិចក្ជក់ មានចិត្តខ្លាំង ចូលចិត្តជិះជាន់ទៅលើអ្នកបម្រើ ហើយនិងមិនចាប់អារម្មណ៍ចំពោះការងាររបស់ប្តី ។ ប្រសិនបើនាងមិនរវល់ចំពោះគោលការណ៍រស់នៅបែបគហបតី ចេះស្រឡាញ់ប្រទេសកម្ពុជាដូចជាស្វាមីរបស់នាង និងពេញចិត្តចំពោះសម្រស់របស់ប្រទេសខ្មែរនោះ គូប្តីប្រពន្ធនេះប្រហែលជាមិនបានលែងលះគ្នា ។ ផ្ទុយទៅវិញ ការដែលនាងខកខានមិនបានដើរតួនាទីជាភរិយា ដែលចេះគាំទ្រស្វាមីនេះ បានបង្កើតឲ្យមាន «ទីទំនេរមួយដែលកនហ្គាយ (ស្រីកំណាន់) អាចចូលលុកលុយបាន» (**ឆ្លាយ** ទំ. ១២៦-២៧, ១៤២, ៣៨, ៩៧) ។

នៅពេលដែល ក្លូដ ត្រឡប់ទៅដល់ធាតុដើម (ដីឥដ្ឋ) នៃប្រទេសកម្ពុជាប្រតិដ្ឋមួយ ដែលមានស្ត្រីជាមនុស្សដ៏ស្លូតបូត រស់នៅដើម្បីបម្រើមនុស្សប្រុសវិញ ភ្លាមនោះ គាត់ក៏មានសេរីភាពរួចផុតពីខ្នោះអរិយធម៌បស្ចិមប្រទេសវិញភ្លាមដែរ ។ ទោះបីជាមានការលះបង់ចោលនូវគ្រឿងតុបតែងកាយតាមបែបអាណានិគមនិយមមកជារបៀបខ្មែរក៏ដោយ ក៏ ក្លូដ នៅតែតាមសង្កេតមើលការរស់នៅរបស់អ្នកដទៃ ។ ស្ត្រីខ្មែរនិងទេសភាពត្រូវកម្រិតនិងបញ្ចូលទៅក្នុងភពត្រេកត្រអាល ដែលពោរពេញទៅដោយភាពកក់ក្តៅនិងមានពន្លឺ ។ ប្រៀបប្រដូចទៅនឹងដៃវិស្វកររបស់គាត់ ដែលបានបំបាក់បំបបធម្មជាតិនៅពេលសង់ស្ពាននោះ លោក ក្លូដ កំពុងតែកែប្រែវត្ថុធាតុដើមរបស់ស្ត្រីខ្មែរថា ÷ «នាងគឺជាសាច់ ខ្ញុំជាវិញ្ញាណ ។ នាងជាចំណុចខ្សោយ ហើយខ្ញុំជាចំណុចខ្លាំង ... ខ្ញុំមិនឃើញមានទ្រឹស្តីណាដែលមិនច្បាស់រវាងនាងនិងខ្ញុំឡើយ ។ ខ្ញុំមើលឃើញបុរសម្នាក់និងនារីម្នាក់ ព្រមទាំងដៃនិងដីឥដ្ឋ» (**ឆ្លាយ** ទំ. ១៩៣, ១៣៧) ។

លោក ហ្គ្រោលីយេ៉រ៍ បានលើកឡើងថា តាមរយៈការបើកចិត្តទូលាយ ដើម្បីរស់នៅជាមួយស្រីកំណាន់ជាជនជាតិខ្មែរ ដែលបានប្រគល់ខ្លួនឲ្យគាត់មួយថ្ងៃប្អូនប្រាំដងនោះ លោក ក្លូដ សុខចិត្តទទួលយកគំរូថ្ងៃថ្នូរហើយបដិសេធល្បិចកលរបស់ពួកបស្ចិមប្រទេស ។ សម្រាប់រឿងនេះ គាត់ទទួលបាននូវការកោតសរសើរ មិនមែនជាការចំអកមើលងាយឡើយ ។ ផ្ទុយទៅវិញ គោលដៅនៃការចំអកមើលងាយរបស់លោក ហ្គ្រោលីយេ៉រ៍ នោះ គឺ វែរម៉ុងដ៍ ។ ដោយសារនាងមិនបានរក្សាប្តីរបស់នាងឲ្យបានស្ថិតស្ថេរនៅក្នុងបរិដ្ឋានម្ចាស់ស្រុកនោះ នាងបានរុញ ក្លូដ ចូលទៅក្នុងរង្វង់ដៃរបស់ស្រីកំណាន់ម្ចាស់ស្រុកហើយនិងវប្បធម៌ខ្មែរ ។

## សេចក្ដីសន្និដ្ឋាន

ប្រលោមលោករបស់លោក ហ្គ្រោលីយេ៉ រ៍ និងលោក ម៉េយែរ ធ្វើឲ្យរឹតតែមានភាពតានតឹងឡើងរវាងមជ្ឈប្រទេសសង្គមអាណានិគមនិយមរបស់បារាំងសែស និងបរិស្ថានម្ចាស់ស្រុក ។ អ្នកនិពន្ធទាំងពីរកំណត់ព្រំដែននៃការបែងចែកសង្គមទាំងនេះជាមួយនឹងគំនិតស្ដីអំពីពូជសាសន៍និងយេនឌ័រ (ភេទភាវៈ) តាមការផ្ទុះបញ្ឆាំងពីការគិតមមៃស្ដីពីការកម្រិតព្រំដែន និងការអតិរេក្សវប្បធម៌ខ្មែរនោះ ។ ប៉ុន្តែ ហេតុអ្វីបានជាគេតំណាងប្រទេសខ្មែរក្នុងភាពជាស្ត្រី? មានការពន្យល់មួយបានលើកឡើងថា ស្រីកំណាន់ គឺជាចំណុចទាក់ទងតែមួយគត់រវាងពួករដ្ឋបាលបារាំងសែសនិងប្រជាជនខ្មែរ ។ ផែនការរៀបចំទីក្រុងជានាឲ្យមានការចែកដាច់ពីគ្នារវាងកន្លែងសម្រាប់ខ្មែរនិងបារាំង ហើយគោលការណ៍ជ្រើសរើសបុគ្គលិកបានគាំទ្រដល់ពួកយួនជាងខ្មែរនោះ មានន័យថា មន្ត្រីអាណានិគមកម្របានជួបជាមួយជនជាតិខ្មែរនៅម៉ោងធ្វើការណាស់ ។ ប៉ុន្តែ ការជជែកវែកញែកនេះ មិនអាចចាត់ទុកថាពិតចំពោះលោក ហ្គ្រោលីយេ៉ រ៍ ឬក៏លោក ម៉េយែរ ទេ ។ ព្រោះថា នៅឆ្នាំ ១៩៣១ សាលារចនារបស់លោក ហ្គ្រោលីយេ៉ រ៍ មានសិស្សប្រុសជាច្រើនរយនាក់ ។ កំណត់ហេតុរបស់ ម៉េយែរ បានបញ្ជាក់ថា គាត់បានជួបជាមួយព្រះសង្ឃនិងប្រុសខ្មែរជាច្រើនអ្នកផ្សេងទៀត ។ ការបង្ហាញក្នុងភាពជាស្ត្រីនេះ ក៏អាចជារង្វាន់សម្រាប់ចរិតល្អរបស់កម្ពុជាក្នុងឋានៈជាអាណានិគម ដែលចេះស្ដាប់បង្គាប់ និងមិនរឹងរូស[៤៤] ។ តាមរយៈការផ្ទុះបញ្ឆាំងពីភាពមិនស្មើគ្នា ដែលគេបង្កើតឡើងនៅក្នុងការតាំងពិព័រណ៍អាណានិគមនិងអន្តរជាតិពីឆ្នាំ ១៨៨៩ ដល់ ១៩៣៧ នោះ គេឃើញថា ប្រទេសកម្ពុជាមានភាពលើសគេក្នុងសំណង់រំលឹកឆ្លាក់ដោយលោក លូវី បូទីណេលី (Louis Botinelly) ក្នុងឆ្នាំ ១៩២៧ ដែលតម្កល់ទុកនៅក្រុងម៉ារសី ហើយដែលមានឈ្មោះថា «ស្រុកចំណុះរបស់យើងនៅទ្វីបអាស៊ី» ។ ប្រទេសកម្ពុជាតំណាងដោយស្ត្រីមួយរូបពាក់មកុដតាមរចនាបថសម័យអង្គរ តែស្លៀកសំពត់តាមម៉ូតប៉ារីស ដែលទម្រេត ដោយមានក្រមុំពីររូបចាំបម្រើ តំណាងឲ្យប្រទេសលាវ និងប្រទេសយួន ។ អាណានិគមទាំងបីនេះ ត្រូវគេបង្ហាញក្នុងភាពជាស្ត្រី ។ គេបានបំផ្លើសពីសម្រស់របស់កម្ពុជា ជានិមិត្តរូបនៃភាពល្អនិងភាពបរិសុទ្ធរបស់ប្រទេសនេះ ។ លោក ដេវិឌ ឆាណ្ឌលរ័ បានវិភាគទៅលើភាពលម្អៀងនេះថា ជារបៀបដែលបារាំងសែសផ្ដល់រង្វាន់ដល់ប្រទេសកម្ពុជា ដែលជាប្រទេសក្នុងអាណាព្យាបាលស្លូតជាងគេនិងចាស់ជាងគេ[៤៥] ។

ប៉ុន្តែ សម្មតិកម្មទាំងអស់នេះ មិនស៊ីជាមួយនឹងលក្ខខណ្ឌប្រវត្តិសាស្ត្រពិតនៅក្នុងប្រទេសកម្ពុជានោះឡើយ ។ ការបង្ហាញពីសំបកខាងក្រៅអំពីភាពរាបសា ស្ងប់ស្ងៀម និងលក្ខណៈជាស្រី នៅក្នុងអក្សរសិល្ប៍អាណានិគម និងនិមិត្តរូបទាំងឡាយនោះ គឺគ្រាន់តែដើម្បីបង្វែរចំណាប់អារម្មណ៍ពីការឆក់ប្លន់ទាំងប៉ុន្មានទសវត្សរ៍នោះនៅក្នុងដែនដីខាងក្នុងដ៏ធំធេងរបស់ប្រទេសកម្ពុជា ពីក្រោយព្រំដែនព័ទ្ធជុំវិញសន្ដាត់របស់ពួកបារាំងដ៏តូចចង្អៀតនោះតែប៉ុណ្ណោះ[៤៦] ។ ដូចនេះហើយ ការសម្រេចថា ការតំណាងឲ្យប្រទេសនៅក្រោមអាណានិគម ឬជាតិណាមួយក្នុងលក្ខណៈជាស្ត្រីនោះ មិនមែនជាការផ្ដល់រង្វាន់ ដែលមានភាពចាំបាច់ ដោយសារអាកប្បកិរិយាមិនចេះតវ៉ានោះទេ ។ ហើយការបង្ហាញពីភេទភាវៈ (យេនឌ័រ) បែបនេះ ក៏មិនអាចពន្យល់តែម្ដងអំពីឆន្ទៈរបស់ពួកអាណានិគមនិយមក្នុងការត្រួតត្រានិងលុកលុយបានដែរ ។ ការវិភាគបែបនេះ គឺជាការមិនយកចិត្តទុកដាក់ចំពោះវិធី ដែលប្រទេសអ្នកដាក់អាណានិគមខ្លួនឯងនោះ បានយកឈ្មោះស្ត្រីដើម្បីតំណាងឲ្យប្រទេសរបស់ខ្លួន ដូចជា ប្រ៊ីតានីញ៉ាសក់ទង់ដែង ឬ ម៉ារីយ៉ាន្ន ។

មានកត្តាជាច្រើន ដែលបានចូលរួមក្នុងការបង្កើតនូវការយល់ឃើញពីភាពជាស្ត្រីរបស់ប្រទេសខ្មែរ ក៏ប៉ុន្តែ

កត្តាចម្បងមួយក្នុងចំណោមកត្តាទាំងនោះ គឺភាពអន្ទះសារបស់ពួកមន្ត្រីបារាំងសែស ចំពោះអនាគតនៃបញ្ហាបុរសភេទតែម្តង ។ ដោយសារមានការភ័យខ្លាចចំពោះសេរីភាពរបស់ស្ត្រីបស្ចិមប្រទេសនោះ អ្នកអាណានិគមនិយម ដូចជាលោក ម៉ៃយែរ និង ក្រោលីយ៉េរ៍ បានដកខ្លួនចូលទៅក្នុងពិភពប្រតិដ្ឋកថាមួយ ដែលបង្ហាញពីតួនាទីរបស់មនុស្សស្រី គឺត្រូវបម្រើនិងស្តាប់បង្គាប់ ។ ថ្វីដ្បិតតែគេមានការខំប្រឹងប្រែង ដើម្បីដកខ្លួនចេញពីមជ្ឈប្រទេសក៏ដោយ ក៏អ្នកនិពន្ធទាំងពីររូបនេះ បានទទួលឥទ្ធិពលយ៉ាងជ្រាលជ្រៅពីបរិយាកាសបញ្ញវន្តរបស់អឺរ៉ុប ។ ដោយបានផ្ទុះបញ្ចាំងក្នុងក្រុមប្រាសាទ ការតាំងពិព័រណ៍ និងសារមន្ទីរនោះ គេអាចមើលឃើញថា ការបង្ហាញដដែលដាដដែលពីប្រទេសកម្ពុជាក្នុងលក្ខណៈជាស្ត្រីនោះ មានបុសគល់ចេញមកពីទស្សនាទានជាទូទៅមួយរបស់ពួកបស្ចិមប្រទេសស្តីអំពីស្ត្រីអាស៊ីដ៏ល្អឥតខ្ចោះ ។ និមិត្តរូបយេនឌ័របែបនេះ មានតែនៅក្នុងសម័យអាណានិគមតែប៉ុណ្ណោះ ដូច–មានភស្តុតាងអំពីភាពទាក់ទាញមិនចេះសាបសូន្យក្នុងរឿងល្ខោនច្រៀង **ម៉ាដាមបាត់តឺរហ្វ្លាយ** (*Madame Butterfly*) ដែលជាស្នាដៃរបស់លោក ពូឈីណី (Puccini) និងរឿងច្រៀងដ៏មានប្រជាប្រិយភាពជាថ្មីៗ នេះ ក្រោមចំណងជើងថា **កញ្ញាសាយហ្គន** (*Miss Saigon*) រៀបចំដោយលោក អាន់ឌ្រូ លូយដ៍ វ៉េប្ប៊ែរ (Andrew Lloyd Webber) ។ ក៏ប៉ុន្តែ ការយល់ឃើញអំពីភាពជាស្ត្រីនៅអាស៊ីនេះ មានការបំផ្លើសយ៉ាងមហិមានៅក្នុងសង្គមអាណានិគម ដែលផ្តល់ឲ្យបុរសនូវអំណាចនិងបុព្វសិទ្ធិកាន់តែច្រើនឡើងនៅក្នុងឋានានុក្រមហួសសម័យមួយក្នុងការបែងចែកកន្លែងនិងលំហសម្រាប់ការរស់នៅរបស់ស្ត្រី (និងបុរស) ម្ចាស់ស្រុក ។ ការមកដល់របស់ស្ត្រីស្បែកសនៅក្នុងប្រទេសកម្ពុជា បានទប់ស្កាត់នូវសេរីភាពទាំងអស់នេះ និងបានបង្ហាញឲ្យគេដឹងពុំពីជំនឿខុសលើបុរិសលក្ខណៈរបស់បុរសអាណានិគមនិយម ។ ហើយនេះក៏បានបង្ហាញថា ស្ត្រីស្បែកស ក៏អាចរស់នៅក្នុងដែនដីអាណានិគមដូចបុរសដែរ ។ ដោយការស្ទាក់ស្ទើរមិនចុះចាញ់ចំពោះមតិបែបនេះ អ្នកនិពន្ធដូចជា ម៉ៃយែរ និង ក្រោលីយ៉េរ៍ បានតម្រែតម្រង់ឲ្យស្ត្រីបារាំងនៅក្នុងរឿងប្រតិដ្ឋរបស់ពួកគាត់ ស្ថិតនៅក្នុងរូបភាពតំណាងឲ្យមជ្ឈប្រទេស ដែលមានលក្ខណៈផុនដាប និងជាស្ត្រីទាមទារសិទ្ធិបោះឆ្នោតដ៏ឆ្គួតលីលា ។

ទោះបីជាតាមរយៈផែនការដែលបានគ្រោងទុកជាមុន ឬតាមរយៈទំនើងដោយមិនសូវដឹងខ្លួនក៏ដោយ ក៏ការព័ណ៌នាប្រទេសកម្ពុជាក្នុងលក្ខណៈជាស្រីនេះ បានបំពេញនូវគំនិតរើរវាយរបស់អ្នកប្រាជ្ញ អ្នកសិល្បៈ និងអ្នករដ្ឋបាលជាបុរសទាំងឡាយ ។ នៅក្នុងកណ្តាប់ដៃរបស់ពួកគេ ប្រទេសកម្ពុជាដែលជាពិភពប្រកបដោយគ្រោះថ្នាក់គ្រប់បែបយ៉ាង បានក្លាយជាមនុស្សស្រីដែលមានភាពស្ងៀមស្ងាត់និងងាយគ្រប់គ្រង ។ គំនិតរបស់ ម៉ៃយែរ និង ក្រោលីយ៉េរ៍ អំពីភាពជាស្ត្រីដែលមានលក្ខណៈចាំបាច់នោះ បានរំលាយបញ្ចូលគ្នាជាមួយនឹងភាពភ័យតក់ស្លុតចំពោះភាពទំនើប ក្នុងរូបភាពជាស្ត្រីខ្មែរដែលបុរសបារាំងសែសដ៏ក្លាហាន ត្រូវតែការពារឲ្យចៀសផុតពីកម្លាំងវាយប្រហារនៃពិភពទំនើប ។ ក៏ប៉ុន្តែ វាមានគុណវិបត្តិមួយ ចំពោះការស្រមើស្រមៃយទាំងនេះ ។ លោក ម៉ៃយែរ បានព្រមានតាមរយៈតួអង្គកំលោះ ពីសក្តានុពលរបស់ប្រទេសកម្ពុជា ដែលអាចធ្វើឲ្យប្រទេសបារាំងសែស «ដាប់គាំង» និង «មិនអាចអភិវឌ្ឍទៅមុខ» បាន (**សាវ៉ាម៉ានី** ទំ. ៤១) ។ លោក ក្រោលីយ៉េរ៍ បានសង្កត់ធ្ងន់ទៅលើការស្រេកឃ្លានដែលមានលក្ខណៈបំផ្លាញ របស់ស្ត្រីខ្មែរ ដែល «បានធ្វើឲ្យចៅហ្វាយរបស់ខ្លួនវិនាសនោះ» (**ធ្លាយ** ទំ. ៨៥) ។ ទោះជាបានគូសបញ្ជាក់អំពីស្ត្រីលក្ខណ៍របស់ប្រទេសក្រោមអាណានិគមនោះ អ្នកទាំងពីរក៏បានសង្កត់ធ្ងន់ទៅលើសក្តានុពលភាព ដែលអាចធ្វើឲ្យអ្នកនៅក្រោមអាណានិគម មិនព្រមស្តាប់បញ្ជា ប្រសិនបើគ្មានការបង្ក្រាបឲ្យបានសមស្រប និងការគ្រប់គ្រងឲ្យបានរឹងមាំនោះទេ ៕

# កំណត់ចំណាំ

## ជំពូកទី ១ ៖ តួអង្គក្សត្រាលោតទេតើ! ៖ ការសម្តែងភាពជាបុរសនៅម៉ាន់ជាលេ

### កំណត់ចំណាំ

(១) ខ្ញុំមិនសូវស្គាល់តួឯកច្បាស់ប៉ុន្មានទេ ដើម្បីនិយាយឲ្យច្បាស់លាស់អំពីរឿងស្រឡាញ់ប្រតិព័ទ្ធផ្លូវភេទរបស់ពួកគេ តែខ្ញុំបានជួបគូកំណាន់ចិត្តស្រីរបស់តួឯកនោះមួយចំនួន ។
(២) តាមពិត ការប្រើប្រាស់ពាក្យផ្សេងៗគ្នា សំដៅលើន័យតែមួយអំពី « ខ្ទើយ» ដើម្បីកំណត់នូវចំណាត់ថ្នាក់រឿងផ្លូវភេទរបស់ពួកគេនោះ ជាប្រធានបទផ្សេងមួយទៀត ដែលខ្ញុំមិនបានលើកយកមកពិភាក្សានោះទេ ។ ដូច្នេះ សូមមើលសៀវភៅរបស់ ហ្សាក់សុន (Jackson) និង គូក (Cook) (ឆ្នាំ ១៩៩៩) ដែលបានរៀបរាប់ពីករណីពួកខ្ទើយនៅប្រទេសថៃ ។
(៣) តួអង្គក្សត្រីពិតជាបង្វិលខ្លួនមែន យ៉ាងហោចណាស់នៅក្នុងការសម្តែងរបាំបែបបច្ចុប្បន្ន តែមិត្តភក្តិជាតិភូមាចំណាស់ៗ របស់ខ្ញុំមួយចំនួន គិតថា ការសម្តែងរៀបនេះ វាប្លែកនិងអាសអាភាស ។
(៤) ខ្ញុំច្រើនប្រើពាក្យ « ជនជាតិភូមា» សំដៅទៅលើពូជសាសន៍ភូមា មិនសូវសំដៅទៅលើសញ្ជាតិភូមា (នៅក្នុងប្រទេសភូមា មានសមាសភាពជាតិសាសន៍ជាច្រើន ទាំងជនជាតិភូមា និងមិនមែនជនជាតិភូមា) ។
(៥) ទាក់ទងនឹងរឿងការស្លៀកខោនៅក្នុងប្រទេសភូមាបច្ចុប្បន្ននិងអតីតកាល សូមមើលសៀវភៅរបស់ ម៉ារស្ហាល្ល (Marshall) *The Trouser People* [**ពួកអ្នកស្លៀកខោ**] ។
(៦) មានការសិក្សាកើនឡើងយ៉ាងច្រើនស្តីអំពីភាពជាបុរសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាឧទាហរណ៍ សូមមើលអត្ថបទរបស់ ហ្វដហាម (Fordham) (ឆ្នាំ ១៩៩៨) និង ភីឡេត្ស (Peletz) (ឆ្នាំ ១៩៩៥) ។
(៧) លោក បួរឌីយើ (ឆ្នាំ ១៩៨៤ ទំព័រ ១១-៩៦) បានវិភាគការសម្តែងជាលក្ខណៈវប្បធម៌ ដោយពន្យល់ថា នៅក្នុងប្រទេសបារាំង ឋានៈខ្ពង់ខ្ពស់ជាប់ទាក់ទងជាមួយនឹងកិរិយាមារយាទសុភាពរាបសា តាំងពីកំណើត ។
(៨) ការផ្លាស់ប្តូរបានកើតឡើងសន្សឹមៗ ប៉ុន្តែក្នុងរយៈពេលយ៉ាងវែង ។ ការបង្កើតថ្មីសំខាន់ជាច្រើន បាននាំមករួចហើយដោយលោក មហាផូសែន (မဟာဖိုးစိန် មហាផ៊ុះចិន៍) នៅក្នុងដើមសតវត្សរ៍ទី ២០ ។ សូមមើលអត្ថបទរបស់អ្នកនិពន្ធសែន (Sein) និង វិធេយ៍ (Withey) (ឆ្នាំ ១៩៦៥) ។
(៩) សូមមើលអត្ថបទរបស់អ្នកនិពន្ធ ស៊ីងហ្គ័រ (Singer) (ឆ្នាំ ១៩៩២) ដែលរៀបរាប់ជាទូទៅអំពីអាយ៉ងនិងតុក្កតាភូមា ។
(១០) អ្នកស្រី គ្រីស្ទីណា ហ្វីង្គ (Christina Fink) (ឆ្នាំ ២០០១) បានផ្តល់នូវការរៀបរាប់យ៉ាងរស់រវើកអំពីជីវភាពរស់នៅរបស់ប្រជាជនភូមានាពេលបច្ចុប្បន្ន ។
(១១) មិត្តភក្តិខ្លះបានផ្តល់យោបល់មកខ្ញុំ ថា អ្វីដែលយើងបានឃើញនោះមិនមែនជា « អ្វីដែលអ្នកទស្សនាចង់បាននោះទេ» (ព្រោះគេមិនចង់បាននូវអ្វីដែលតួឯកក្មេងៗ ដែលទទួលការបង្ហាត់បង្រៀនមិនសូវបានល្អអាចសម្តែងនោះទេ ។ ការសម្តែងរវាងពួកគេមិនដូចគ្នាទាល់តែសោះ) ។ ពួកគេបានប្រាប់ខ្ញុំថា លោក ឆាន់ត្សា (ချမ်းသာ « ខ្យម៉ះសា») ដែលជាកូនប្រុសរបស់អ្នកសម្តែងដ៏ល្បីនៅពាក់កណ្តាលសតវត្សរ៍ទី ២០ ដែលមានឈ្មោះថា ស្វេមាំងទេនម៉ោង (ရွှေမန်းတင်မောင် « ហ្វ្រេមនិះតង់មោង៉») នៅតែសម្តែងតាមលក្ខណៈបុរាណច្រើនជាងហើយ គឺជាតួឯកដ៏ល្បីបំផុតនៅសព្វថ្ងៃនេះ ដែលអាចទាក់ទាញមនុស្សឲ្យមកចូលទស្សនាពេញៗ រោងនៅពេលគាត់សម្តែង ។ បញ្ហានេះបានធ្វើឲ្យគិតថា មានអ្នកទស្សនា

ការសម្តែង ដែលមានលក្ខណៈបុរាណច្រើនជាងមនុស្សដែលចូលចិត្តមើលការសម្តែងដែលខ្ញុំបានរៀបរាប់ ។ តែខ្ញុំមិនមានឱកាសទៅមើលការសម្តែងរបស់គាត់ ដូច្នេះ មិនអាចរៀបរាប់អំពីគាត់និងអ្នកនិយមគាត់បាននោះទេ ។

**(១២)** វិល្លៀម ភីថឺរសុន (William Peterson) (ឆ្នាំ ២០០១ ជាពិសេសនៅទំព័រទី ១០៣ និង ១២៨) បានរៀបរាប់អំពីរបៀបដែលអ្នកសម្តែងសិង្ហបុរីមួយចំនួន បានគិតគូរអំពីបញ្ហាថា តើវាមានន័យយ៉ាងដូចម្តេចសម្រាប់ស្ត្រីណាម្នាក់ក្នុងការធ្វើខ្លួនឲ្យទំនើបនៅក្នុងសង្គមបិតាធិបតេយ្យផ្សេងមួយទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

**(១៣)** ការផ្លាស់ប្តូរស្ថានភាពនិងល័ក្ខខ័ណ្ឌ សម្រាប់ស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានគេសរសេរឡើងនៅក្នុងអត្ថបទសំខាន់ៗ ជាច្រើន ។ សូមមើលអត្ថបទសិក្សារបស់ អេរិងតុន (Errington) និង អាត់គិន្សុន (Atkinson) (ឆ្នាំ ១៩៩០) អុង (Ong) និង ភីឡេត្ស (Peletz) (ឆ្នាំ ១៩៩៥) និង វ៉ាន់អេស្តេរិក (Van Esterik) (ឆ្នាំ ១៩៩៦) ។ ខ្ញុំគិតថា អត្ថបទរបស់ មីលស៍ (Mills) (ឆ្នាំ ១៩៩៧) អំពីករណីប្រទេសថៃ និងអត្ថបទរបស់ ប្រេណ្ណឺរ (Brenner) អំពីករណីកោះជ្វា ក៏បំភ្លឺឲ្យយល់កាន់តែច្បាស់ទៀតផងដែរ ។

**(១៤)** លោក សៃម៉ុន ហារឌី (Simon Hardy) បានវិភាគរឿងអាសអាភាស ដែលបង្ហាញរូបរាងកាយខ្លះៗ របស់អង់គ្លេសដោយចង្អុលបង្ហាញពីភាពផ្ទុយគ្នានេះផងដែរ (ហារឌី ឆ្នាំ ២០០២) ៕

# ឯកសារពិគ្រោះ


◉ ចាដារជី, បាថ៌ះ (Chatterjee, Partha) គ.ស. ១៩៩៣ *The Nation and Its Fragments: Colonial and Postcolonial Histories* [**ប្រទេសជាតិ និងបំណែករបស់ប្រទេសជាតិ ៖ ប្រវត្តិសាស្ត្រសម័យអាណានិគម និងក្រោយអាណានិគម**] ព្រីនស្តុន (Princeton) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ ព្រីនស្តុន ។

◉ ប៊ឺត្លឺរ, ជូឌីថ (Butler, Judith) គ.ស. ១៩៩០ "Performative Acts and Gender Constitution: Essay in Phenomenology and Feminist Theory" «[មាត្រានៃការសម្តែង និងការតែងតាំងភេទភាវៈ ៖ ការសាកល្បងវិភាគនៅក្នុងទ្រឹស្តីបាតុភូតវិទ្យា និងស្ត្រីនិយម]» នៅក្នុងសៀវភៅរបស់ ស៊ូ-អេឡែន ខេស (Sue-Ellen Case) ៖ *Performing Feminisms: Feminist Critical Theory and Theatre* [**ការសម្តែងស្ត្រីនិយមច្រើនបែបច្រើនយ៉ាង ៖ ទ្រឹស្តីវិភាគស្ត្រីនិយម និងល្ខោន**] បាល់ទីម័រ គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ ចនស៍ ហាប់គីនស៍ (Johns Hopkins University Press) ទំព័រ ២៧០-៨២ ។

◉ បួរឌីយើ, ព្យែរ (Bourdieu, Pierre) គ.ស. ១៩៨៤ *Distinction: A Social Critique of the Judgement of Taste* [**ភាពខុសប្លែកគ្នា ៖ ការរិះគន់សង្គមនៃការវិភាគអំពីចំណូលចិត្ត**] បកប្រែពីភាសាបារាំងដោយលោក រីឆាដ ណៃស៍ (Richard Nice) ខេមប្រ៊ីដហ្ស៍ (Cambridge) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវវ៉ាដ (Harvard University Press) ។

◉ *ដដែល* គ.ស. ១៩៩៣ *The Field of Culture Production: Essays on Art and Literature* [**ខស័យនៃការបង្កើតវប្បធម៌ ៖ ការសាកល្បងវិភាគនៅលើសិល្បៈនិងអក្សរសាស្ត្រ**] គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យកូឡុំបៀ (Columbia University Press) ។

◉ ប្រេណ្ណឺរ, ស៊ូហ្សាន្ន (Brenner, Suzanne) គ.ស. ១៩៩៥ "Why Women Rule the Roost: Rethinking Javanese Ideologies of Gender and Self-Control" «[ហេតុអ្វីស្រីគ្រប់គ្រងសំបុក ៖ ការគិតគូរឡើងវិញអំពីមនោគមវិជ្ជានៃភេទភាវៈ និងការគ្រប់គ្រងខ្លួននៅជ្វា]» ក្នុងសៀវភៅរបស់ អៃវ៉ា អុង ( Aihwa Ong) និង ម៉ៃខល ភីឡេត្ស (Michael Peletz) (បណ្ណាធិការ) *Bewitching women, Pious Men: Gender and Body Politics in Southeast Asia* [**ស្ត្រីជាមារ និងបុរសជាអ្នកថ្វាយខ្លួនចំពោះសាសនា ៖ ភេទភាវៈនិងអង្គនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍**] ប៊ឺឃ្លេយ៍ (Berkeley) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យខាលីហ្វ័រនៀ ទំ. ១៩-៥០ ។

◉ *ដដែល* គ.ស. ១៩៩៦ "Reconstructing Self and Society: Javanese Muslim Women and 'the Veil'" «[ការបង្កើត

ឡើងវិញនូវអត្តសញ្ញាណខ្លួនឯង និងសង្គម ៖ ស្ត្រីមុស្លិមនៅជ្វា និង «សំពត់បាំងមុខទទូរក្បាល]» *American Ethnologist* ទិនានុប្បវត្តិ [ជាតិពន្ធុវិទូអាមេរិកាំង] ក្បាលទី ២៣ លេខ ៤ (វិច្ឆិកា) ទំ. ៦៧៣-៩៧ ។

⊚ ភីថឺរសុន, វិល្លៀម (Peterson, William) គ.ស. ២០០១ *Theater and the Politics of Culture in Contemporary Singapore* «[ល្ខោននិងការលើកស្ទួយវប្បធម៌នៅប្រទេសសិង្ហបុរីសព្វថ្ងៃ]» មិដ្ដិលថោន (Middletown) រដ្ឋខណ្ឌិកទិខឹត គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យវ៉េស្លេយ៉ាន (Wesleyan University Press) ។

⊚ ភីលេត្ស, ម៉ៃខល (Peletz, Michael) គ.ស. ១៩៩៥ "Neither Reasonable nor Responsible : Constrasting Representations of Masculinity in a Malay Society" «[ភាពមិនសមហេតុផលនិងមិនទទួលខុសត្រូវ ៖ ការតំណាងផ្ទុយគ្នាឲ្យភាពជាបុរសនៅក្នុងសង្គមមឡាយូ]» នៅកក្នុងសៀវភៅរបស់ អៃវ៉ា អុង ( Aihwa Ong) និង ម៉ៃខល ភីឡេត្ស (Michael Peletz) (បណ្ណាធិការ) *Bewitching women, Pious Men : Gender and Body Politics in Southeast Asia* [ស្ត្រីជាមារ និងបុរសជាអ្នកថ្វាយខ្លួនចំពោះសាសនា ៖ ភេទភាពនិងអង្គនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍] បឺរឃ្លេយ៍ (Berkeley) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យខាលីហ្វ័រនៀ ទំ. ៧៦-១២៣ ។

⊚ ម៉ារស្ហាល្ល, អាន់ឌ្រូ (Marshall, Andrew) គ.ស. ២០០២ *The Trouser People : The Quest for the Victorian Footballer Who Made Burma Play the Empire's Game* [ពួកអ្នកស្លៀកខោ ៖ ការស្វែងរកអ្នកទាត់បាល់នៅសម័យព្រះមហាក្សត្រិយានីវិកតូរីយ៉ា ដែលធ្វើឱ្យប្រទេសភូមាលេងល្បែងរបស់ចក្រភព] ឡុងដ្រ៍ ផេនគ្វីនប៊ុកស៍ (Penguin Books) ។

⊚ មីល្លស៍, ម៉ារី បិថ (Mills, Mary Beth) គ.ស. ១៩៩៧ "Contesting the Margins of Modernity : Women, Migration, and Consumption in Thailand" «[ការប្រឆាំងនឹងការរើសអើងនៃភាពទំនើប ៖ ស្ត្រី ការផ្លាស់ស្រុក និងការឧបភោគបរិភោគនៅក្នុងប្រទេសថៃ]» បោះពុម្ពនៅក្នុងទិនានុប្បវត្តិ (*American Ethnologist*) [ជាតិពន្ធុវិទូអាមេរិកាំង] ក្បាលទី ២៤ លេខ ១ ទំ. ៣៧-៦១ ។

⊚ វ៉ាន់អេស្តេរិក, ផេន្នី (Van Esterik, Penny) គ.ស. ១៩៩៦ "Women of Southeast Asia" «[ស្ត្រីនៅអាស៊ីអាគ្នេយ៍]» កែសម្រួលរួចហើយ មជ្ឈមណ្ឌលសិក្សាអំពីតំបន់អាស៊ីអាគ្នេយ៍នៅសាកលវិទ្យាល័យ អ៊ីល្លីណយស៍ខាងជើង ឯកសារមិនទាន់បោះពុម្ព ស្តីពីតំបន់អាស៊ីអាគ្នេយ៍ ឯកសារលេខ ១៧ ឌីកាល្ប (De Kalb) រដ្ឋអ៊ីល្លីណយស៍ ។

⊚ ស៊ីងហ្គ័រ, ណូអែល អេហ្វ. (Singer, Noel. F) គ.ស. ១៩៩២ *Burmese Puppets* [អាយ៉ងភូមា] សិង្ហបុរី គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ សិង្ហបុរី ។

⊚ សែន , កេណ្ណិថ (Sein, Kenneth) និង ហ្សូសិហ្វ អា. វិធេយ៍ (Joseph A. Withey) គ.ស. ១៩៦៥ *The Great Po Sein : A Chronicle of the Burmese Theater* [មហា ផូសែន ៖ ពង្សាវតារល្ខោនភូមា] ប៊្លូមីងតុន (Bloomington) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ អ៊ិណ្ឌាណា (Indiana University Press) ។

⊚ ហារឌី, សៃម៉ុន (hardy, Simon) គ.ស. ២០០២ *The Reader, The Author, His Woman and Her Lover : Soft-Core Pornography and Heterosexual Men* [អ្នកអាន អ្នកនិពន្ធ ស្រីញីរបស់គាត់ និងសហាយរបស់នាង ៖ រូបអាសអាភាសដែលបញ្ចេញរាងកាយតែបន្តិច ៗ និងបុរសប្រុសភេទផ្សេង] ឡុងដ្រ៍ ក្រុមបោះពុម្ពផ្សាយ ខេស្សេល (Cassel) ។

⊚ ហារលេយ៍, បារបារ៉ា (Harley, Barbara) គ.ស. ១៩៩០ "Theatrical Imagery and Gender Ideology in Java" «[ការពិព័ណ៌នាអំពីការសម្តែងល្ខោន និងមនោគមវិជ្ជាភេទភាវៈនៅស្រុកជ្វា]» នៅក្នុងសៀវភៅរបស់ ចេន អាត់គិន្សុន (Jane Atkinson) និង ស្ហេល្លី អេរីងតុន (Shelly Errington) ៖ *Power and Difference : Gender in Island Southeast Asia* [អំណាចនិងភាពខុសប្លែកគ្នា ៖ ភេទភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដីកោះ] ស្តេនហ្វឌ (Stanford) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ ស្តេនហ្វឌ ទំ. ១៧៧-២០៧ ។

⊚ ហ្វដហាម, ក្រ្ហាហាំ (Fordham, Graham) គ.ស. ១៩៩៨ "Northern Thai Male Culture and the Assessment of HIV Risk" «[វប្បធម៌របស់ពួកបុរសនៅប្រទេសថៃភាគខាងជើង និងការវាយតម្លៃពីការឆ្លងមេរោគអេដស៍]» នៅក្នុង

ទិនានុប្បវត្តិ **គ្រូសរោដស៍ (ផ្លូវបែក)** (Crossroads) ១២:១ ទំ. ៧៧-១៤១ ។
◉ ហ្វ៊ិង្ក, គ្រីស្ទីណា (Fink, Christina) គ.ស. ២០០១ *Living Silence: Burma Under Military Rule* [**ការរស់នៅដោយស្ងៀមស្ងាត់ ៖ ប្រទេសភូមានៅក្រោមការគ្រប់គ្រងរបស់អំណាចយោធា**] ញូយ៉ក ក្រុមហ៊ុនបោះពុម្ពហ្សិដប៊ុកស៍ (Zed Books) ។
◉ ហ្សាក់សុន, ភីធឺរ (Jackson, Peter) និង ណេរីដា គូក (Nerida Cook) (បណ្ណាធិការ) គ.ស. ១៩៩៩ *Genders and Sexualities in Modern Thailand* [ភេទភាវៈ និងលិង្គភាពនៅប្រទេសថៃសម័យទំនើប] ឈៀងម៉ៃ ស៊ិលក៍វ៉ឺមប៊ុកស៍ (Silkworm Books) ។
◉ អាត់គិន្សុន, ចេន (Atkinson, Jane) និង ស្ហេល្លី អេរិងតុន (Shelly Errington) (បណ្ណាធិការ) គ.ស. ១៩៩០ *Power and Difference: Gender in Island Southeast Asia* [**អំណាចនិងភាពខុសប្លែកគ្នា ៖ ភេទភាវៈនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដីកោះ**] ស្ដេនហ្វដ គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ ស្ដេនហ្វដ ។
◉ អេវើន, ស្ទួត (Ewen, Stuart) និង អេលីហ្សាបិថ អេវើន (Elizabeth Ewen) គ.ស. ១៩៩២ *Channels of Desire: Mass Images and the Shaping of American Consciousness* [**ការបង្ហាញពីតម្រេក ៖ រូបភាពជាទីនិយមរបស់មហាជន និងការបង្កើតនូវមនសិការអាមេរិកាំង**] មីនៀប៉ូលីស គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យ មីណេសូតា ៕

## ជំពូកទី ២ ៖ ប្រលោមលោកក្នុងរជ្ជកាលទី ៦ ៖ យេនឌ័រ អារម្មណ៍ផ្លូវភេទ និងគំនិតជាតិនិយមសៀម

### កំណត់ចំណាំ

**(១)** កំណត់អ្នកបកប្រែ ៖ តាមការកំណត់អត្ថន័យនៅក្នុង **សទ្ទានុក្រមយេនឌ័រ** របស់ក្រសួងកិច្ចការនារី (គ.ស. ២០០៦) « យេនឌ័រ » [ភេទភាវៈ] គឺសំដៅយកតួនាទី ឥរិយាបថ និងគុណតម្លៃនានា ដែលវប្បធម៌និងសង្គមដាក់កំណត់ឲ្យបុរសនិងស្ត្រីអនុវត្តដោយឡែកពីគ្នា ។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និងទំនាក់ទំនងរវាងបុរសនិងស្ត្រី ។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះ ត្រូវបានបង្កើតឡើង និងថែរក្សា ដោយស្ថាប័នសង្គមនានា ដូចជាគ្រួសារ រដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និងសារព័ត៌មាន ។ល។ ដោយសារយេនឌ័រនេះហើយ ទើបបានជាតួនាទីនិងលក្ខណៈសម្គាល់មួយចំនួន ត្រូវបានកំណត់ឡើងផ្សេងពីគ្នានិងតឹងរ៉ឹងសម្រាប់បុរសនិងស្ត្រី ។

កំណត់បណ្ណាធិការមជ្ឈមណ្ឌលខេមរសិក្សា ៖ ដើម្បីពន្យល់អំពីបញ្ញត្តិ (គំនិត) ដែលបង្កប់ក្នុងពាក្យ « យេនឌ័រ » នេះ ភាសាថៃបានបង្កើតពាក្យថា « ភេទភាវៈ » ដែលជាសមាសនាមប្រកបដោយខ្លឹមសារជ្រាលជ្រៅគួរឲ្យចាប់អារម្មណ៍ ។ យើងខ្ញុំក៏ស្នើសុំដាក់ពាក្យនេះជាវេវចនៈនឹងពាក្យ « យេនឌ័រ » ក្នុងវង់ក្រចក អមពាក្យ « យេនឌ័រ » នឹងរង់ចាំដល់ថ្ងៃដែលរាជបណ្ឌិតសភាកម្ពុជានឹងបង្កើតពាក្យផ្លូវការសម្រាប់សំដៅលើ « យេនឌ័រ » នោះ ។

**(២)** កំណត់អ្នកបកប្រែ ៖ « អារម្មណ៍ផ្លូវភេទ » គឺជាអារម្មណ៍ ការគិត និងចំណង់ផ្លូវភេទរបស់បុគ្គលម្នាក់ៗ ។ មនុស្សម្នាក់ៗ មានអារម្មណ៍ផ្លូវភេទផ្សេងៗ ពីគ្នា ដូចជាអ្នកខ្លះមានអារម្មណ៍ផ្លូវភេទទៅលើមនុស្សភេទដូចគ្នា ឯអ្នកខ្លះទៀត មានអារម្មណ៍ផ្លូវភេទទៅលើមនុស្សភេទផ្សេងគ្នា ។ល។

**(៣)** កំណត់បណ្ណាធិការមជ្ឈមណ្ឌលខេមរសិក្សា ៖ ពួកបស្ចិមប្រទេសហៅស្ដេចអង្គនេះថា ព្រះរាជាវជិរាវុធ ។ រីឯជនជាតិសៀមហៅព្រះអង្គថា ព្រះអង្គម្ចាស់វជិរាវុធ (วชิราวุธ) តែនៅសម័យកាលដែលព្រះអង្គនៅមានឋានៈនិងងារជាព្រះអង្គម្ចាស់ ។ ចាប់ពីវេលាព្រះអង្គបានឡើងសោយរាជ្យមក ប្រជារាស្ត្រហៅព្រះអង្គថា ព្រះបាទសម្ដេចព្រះមង្កុដក្លៅចៅយូហួ (พระบาทสมเด็จพระมงกุฎเกล้าเจ้าอยู่หัว ព្រះបាទសម្ដេចព្រះមង្កុដក្លៅចៅអ្យូហ្វ័) ឬហៅដោយខ្លីថា ព្រះមង្កុដក្លៅ (พระ

មង្កុដ្ឋកេល៉ា ព្រះមង្កុដក្លៅ) ឬ ព្រះរាមទី ៦ (พระรามที่ ๖) ព្រោះជាស្តេចគ្រងរាជ្យទី ៦ នៃរាជវង្សចក្រី ។ ក្លៅ (អានថា ក្លៅ) មានន័យថា បង្ហើយ (ទីបំផុតនៃរលាក្បាល) ឬ ផ្នួងសក់ ។ ចៅ (អានថា ចៅ) មានន័យថា អម្ចាស់ ។ អ្យូហ្វ (អាន ថា យូហួ) មានន័យថា នៅ(លើ)ក្បាល, នៅ(លើ)ត្បូង(យើង) ។

**(៤)** កំណត់បណ្ណាធិការមជ្ឈមណ្ឌលខេមរសិក្សា៖ សម្រាប់ការបកប្រែរាល់ការដកស្រង់សម្ដីពីសាច់រឿង **ហ្វាថៃឆាយន៉ំ** នេះ គឺជាអ្នកពិនិត្យផ្ទៀងផ្ទាត់ការបកប្រែជាភាសាខ្មែរមួយរូប ដែលបានបកប្រែពីអត្ថបទដើមជាភាសាសៀមតែម្ដង ។

**(៥)** នៅជំនាន់ដែលអ្នករាជវង្ស គឹកប្ញ ប្រាមោជ្ជ បានតែងរឿង **ស៊ីផែនឌិន** លោក ប្លែក ពិបូលសង្គ្រាម (แปลก พิบูลสงคราม) (ជានាយករដ្ឋមន្ត្រីរវាងឆ្នាំ ១៩៣៨-១៩៤៤ និងរវាងឆ្នាំ ១៩៤៨-១៩៥៧) បានបង្កើតដំណាក់កាលថ្មីនៃជាតិនិយមថៃ ។ ចំពោះអត្ថបទសិក្សា ដែលផ្ដោតលើអត្តសញ្ញាណកម្មជាតិថៃនៅពេលនោះ សូមមើលសៀវភៅអត្ថបទរបស់លោក រ៉ីយ៍ណូលដ្ស៍ (Reynolds) គ.ស. ១៩៩១ និងអត្ថបទរបស់លោកលោក ទែរវីយែល (Terwiel) គ.ស. ១៩៩១ ។

**(៦)** កំណត់អ្នកបកប្រែ៖ គឺព្រះចៅមង្កុដក្លៅចៅយូហួ ដែលបានបង្កើតកងខ្លាព្រៃនៅខែឧសភា ឆ្នាំ ១៩១១ ដែលជាកងយោធាប្រតិព័ទ្ធ (ពួកប៉ារ៉ា) ។ ការបង្កើតនេះមានគោលបំណង ៤ យ៉ាង៖

-ទី ១៖ បុរសថៃទាំងឡាយដែលត្រូវរួចខ្លួនពីការបម្រើក្នុងកងទ័ពជាតិ ជាពិសេសអ្នករាជការថ្នាក់កណ្ដាលនិងថ្នាក់លើ អាចទទួលបានការហ្វឹកហាត់ផ្នែកយោធា ។

-ទី ២៖ ជួយធ្វើឲ្យមានឯកភាពសង្គម ដោយនាំមនុស្សមកពីវណ្ណៈខុស ៗ គ្នា ជួបជុំគ្នាក្នុងអង្គភាពតែមួយ ។

-ទី ៣៖ រក្សាសន្តិសុខនិងសណ្ដាប់ធ្នាប់ផ្ទៃក្នុង និងជួយទាហានពេលមានសង្គ្រាម ។

-ទី ៤៖ ជាឈ្លបយកការណ៍ឲ្យកងទ័ព ស្រាវជ្រាវរកសត្រូវ ទីកន្លែងសត្រូវ និងរាយការណ៍ពីសកម្មភាពរបស់ខ្មាំងសត្រូវ ។

កងខ្លាព្រៃត្រូវបង្កើតឡើង ដើម្បីជួយកងទ័ពដែលមានស្រាប់ មិនមែនជំនួសទ័ពដែលមានស្រាប់នោះទេ ។

**(៧)** លោក វ៉េល្លា (Vella) គ.ស. ១៩៧៨-១៩៧៩ អះអាងថា «ទ្រង់វជិរាវុធ គឺជាព្រះអង្គម្ចាស់ជាតិសៀមមួយអង្គ ដែលមានអាកប្បកិរិយាដូចពួកអភិជនអង់គ្លេសនៅសម័យព្រះមហាក្សត្រិយានីអង់គ្លេស វិកតូរៀ (សោយរាជ្យ គ.ស. ១៨៣៧-១៩០១) ... ទ្រង់វជិរាវុធស្គាល់និងលើកតម្កើងចរិតលក្ខណៈទាំងឡាយនៃសុភាពបុរសអង់គ្លេស» ។ ព្រះអង្គក៏យកព្រះទ័យទុកដាក់ទៅលើមធ្យោបាយដែលពួកអង់គ្លេសបានលៃលក ដើម្បីឲ្យប្រទេសអង់គ្លេសលូតលាស់យ៉ាងប្រសើរបំផុតនោះ ។

**(៨)** លោក ស្គិន្ន័រ (Skinner) គ.ស. ១៩៥៧ បានផ្ដល់ទិន្នន័យយ៉ាងសំខាន់ និងការវិភាគចំពោះអន្តោប្រវេសន៍ជាតិចិនក្នុងប្រទេសសៀម ។

**(៩)** យើងនឹងឃើញនូវសេចក្ដីសម្ដែងរបស់ព្រះរាមទី ៦ ចំពោះឋានៈនៃប្រទេសសៀមទៅក្នុង «ក្រុមគ្រួសារ» នៃប្រជាជាតិនានា ក្នុងចុតហ្មាយផ្ញើទៅព្រះអនុជរបស់ទ្រង់ គឺ ព្រះចៅហ្វា (ព្រះអង្គម្ចាស់) ចក្រពង្សភូវនាថ នៅថ្ងៃដែលទ្រង់បានទទួលរាជាភិសេក (ចុល្លចក្រពង្ស គ.ស. ១៩៦០, ២៧២) ។ នៅលើឆាកអន្តរជាតិវិញ បញ្ហាពេស្យាចារ ឬ ទាសភាពស្បែកស បញ្ហាការជួញដូរស្ត្រីនិងកុមារ ក្លាយជាកម្មបទនៃអនុសញ្ញាអន្តរជាតិនា គ.ស. ១៩០៤, ១៩១០ និង ១៩២២ ហើយក៏លេចឡើងតាមរយៈរបាយការណ៍នានាដែលចេញផ្សាយដោយសមាគមប្រជាជាតិដែរ (សូមមើលរបាយការណ៍ផ្លូវការក្នុងសមាគមប្រជាជាតិ ខែកក្កដា គ.ស. ១៩២៥ ទំ. ៩៣២ សម្រាប់របាយការណ៍ស្ដីពីប្រទេសសៀម) ។ គ្រានោះដែរ ប្រទេសសៀមក៏ជាអ្នកចុះហត្ថលេខាលើអនុសញ្ញាចំនួនពីរដែរ ដើម្បីប្រឹងប្រែងឲ្យសៀមស្ថិតជាប្រជាជាតិមួយក្នុងចំណោមប្រជាជាតិដទៃ ។ ប៉ុន្តែ ពុំមានការបង្ហាញណាមួយថា ព្រះរាមទី ៦ បានទ្រង់ចំណាយព្រះកាយពលយ៉ាងសន្ធឹកសម្រាប់ដោះស្រាយបញ្ហាទាំងនេះឡើយ ។

**(១០)** ទំនាក់ទំនងបញ្ហានៃភាពថ្លៃថ្នូរ និងការលេចឡើងនៃសកម្មភាពនៅទីសាធារណៈនិងឯកជន គឺជាចំណុចស្នូលនៃការវិភាគរបស់លោក ម៉ូស្ស (Mosse) នៅ គ.ស. ១៩៨៥ ទៅលើបញ្ហាជាតិនិយមនិងអារម្មណ៍ផ្លូវភេទនៅអឺរ៉ុប ។

**(១១) បទលោខនិយាយរឿង ទ.គ.ល. នន្ទ្រី និង មហាត្ត** និង **ហ្វាថៃឆាយន៉ំ** ជារឿងដែលរាប់បញ្ចូលជាស្នាព្រះហស្តចង

ក្រុងរបស់ព្រះរាមទី ៦ ក្រោយពេលសោយទិវង្គតនៃព្រះអង្គ ដែលបោះពុម្ពនៅ គ.ស. ១៩៦៦ ។ កំណត់បណ្ណាធិការមជ្ឈមណ្ឌលខេមរសិក្សា ៖ រ.ត.ល. ជាអក្សរកាត់របស់ « เรือตรวจลาดตระเวน រ្វើត្រួចលាតត្រះវេន (អានថា រឿត្រួតលាតត្រះវ៉េន) » មានន័យថា កប៉ាល់ត្រួតល្បាតក្រវែល គឺ នាវាល្បាត ។

**(១២)** លោក វិភា (Wibha) បានបកប្រែអត្ថបទនេះជាភាសាអង់គ្លេស (គ.ស. ១៩៧៥ ទ. ៧៧) ។

**(១៣)** ដោយយកខ្លឹមសារពីអត្ថបទរបស់ពួកប្រឆាំងទ្រឹស្តីសារវន្តនិយម (Essentialism) របស់លោក ភាភា (Bhabha) គ.ស. ១៩៩០ និង ហាល់ប៉ឺរិន (Halperin) គ.ស. ១៩៩០ ដែលជាបណ្ណាធិការនៃសៀវភៅ *Nationalisms and Sexualities* [**ជាតិនិយមនិងសម្ពន្ធភាពផ្លូវភេទនានាំឡាយ**] (ប៉ារកឺរ និងអ្នកដទៃ) បានអះអាងក្នុងអារម្ភកថាថា ៖ ជាតិនិយមនិងសម្ពន្ធភាពផ្លូវភេទ មានភាពប្រែប្រួលផ្នែកវប្បធម៌ និងបង្កើតឡើងដោយស្ថិតក្នុងបរិបទនៃប្រវត្តិសាស្ត្រជាក់លាក់ ក្រោមទម្រង់នៃពហុចម្រុះធាតុផ្សេងៗ គ្នា ។

**(១៤)** គួរតែមើលអត្ថបទវៀលត្នះខ្លី និពន្ធដោយព្រះរាមទី ៦ ក្នុង គ.ស. ១៩១៤ ក្រោមចំណងជើងថា **ជនជាតិជ្វីហ្វនៃបូព៌ាទិស** ដែលបានចេញជាភាសាសៀម ៖ *ยิวแห่งบูรพาทิศ* និងជាភាសាអង់គ្លេស ៖ *Jews of the Orient* ដើម្បីពិនិត្យពីវោហារសាស្ត្រនៃគំនិតជាតិនិយមរបស់ព្រះអង្គ ដែលប្រឆាំងទៅនឹងពួកចិន (និងពួកសាធារណរដ្ឋនិយម) នាគ្រានោះ ៕

## ឯកសារពិគ្រោះ


៙ គឹកប្ញទ្ធិ ប្រាមោជ្ជ (អ្នករាជវង្ស) (หม่อมราชวงศ์ [ហ្មុំមរាជវង្ស] คึกฤทธิ์ ปราโมช Kukrit Pramoj) គ.ស. [១៩៥១] ១៩៨១ *สี่แผ่นดิน* **សីផែនឌិន** (ស៊ីផែនឌិន) [**បួនផែនដី**] (សៀវភៅដើមតែងជាភាសាសៀម) មានការបកប្រែជាភាសាអង់គ្លេសដោយ តុលចន្ទ្រ (Tulachandra) (ភាគទី ២) បាងកក គ្រឹះស្ថានបោះពុម្ពផ្សាយដួងកមល (Duang Kamol) ។

៙ ចុល្លចក្រពង្ស (អ្នកអង្គម្ចាស់) (พระองค์เจ้า [ព្រះអង្គចៅ] จุลจักรพงษ์ Chula Chakrabongse) គ.ស. ១៩៦០ *Lords of Life: The Paternal Monarchy of Bangkok, 1782-1932* [**ម្ចាស់ជីវិត ៖ បិតុរាជាធិបតេយ្យនៃក្រុងបាងកក (គ.ស. ១៧៨២-១៩៣២)**] ឡុងដ្រ៍ រ៉េដម៉ែន លីមីធិត (Alvin Redman Limited) ។

៙ ទែរវីយែល, ប៊ី.ចេ. (Terwiel, B.J.) គ.ស. ១៩៩១ “Thai Nationalism and Identity : Popular Themes of the 1930s” «[ជាតិនិយមនិងអត្តសញ្ញាណថៃ ៖ គោលរឿងប្រជាប្រិយក្នុងទសវត្សរ៍ ១៩៣០]» នៅក្នុង *National Identity and Its Defenders, Thailand 1939-1989* [**អត្តសញ្ញាណជាតិនិងអ្នកការពារអត្តសញ្ញាណនេះ ៖ ប្រទេសថៃ (គ.ស. ១៩៣៩-១៩៨៩)**] ម៉ិលប៊ន (Melbourne) អត្ថបទពីម៉ូណាស្ហ (Monash) អំពីអាស៊ីអាគ្នេយ៍ លេខ ២៥ ទំ. ១៣៣-១៥៤ ។

៙ ទ្រឿង ថាញ់ដាម (Truong, Thanh-dam) គ.ស. ១៩៩០ *Sex, Money and Morality : Prostitution and Tourism in South-east Asia* [**បញ្ហាផ្លូវភេទ បញ្ហាលុយ និងបញ្ហាសីលធម៌ ៖ ពេស្យាចារនិងទេសចរណ៍នៅអាស៊ីអាគ្នេយ៍**] ញូចឺរសើយ៍ ហ្សិដប៊ុក្ស (Zed Books) ។

៙ ប៉ារកឺរ, អាន់ឌ្រូ (Parker, Andrew), ម៉ារី រូស្សូ (Mary Russo), ដូរិស សូម្ម័រ (Doris Summer), ប៉ាទ្រីស្យា យ៉ែហ្គឺរ (Patricia Yaeger) និងអ្នកដទៃទៀត គ.ស. ១៩៩២ *Nationalisms and Sexualities* [**ជាតិនិយមនិងសម្ពន្ធភាពផ្លូវភេទនានាំឡាយ**] ញូយ៉ក រូតឡិដហ្ស៍ (Routledge) ។

៙ **ប្រវត្តព្រះភិក្ខុ ព្រះយ៉ានរតនរាជមានិត** *ประวัติพระภิกษุพระยานรรัตนราชมานิต* (ប្រវ័ត្តិព្រះភិក្ខុ ព្រះយានរវ័តនរាជមានិត) គ.ស. ១៩៧១ បាងកក យុវពុទ្ធិកសមាគមជលបុរី ។

៙ ភាភា, ហោមិ ក. (Bhabha, Homi K.) គ.ស. ១៩៩០ *Nation and Narration* [**ជាតិ និងនិទានកថា**] ញូយ៉ក រូតឡិដហ្ស៍ (Routledge) ។

៙ ម៉ស្ស, ហ្សក (Mosse, George) គ.ស. ១៩៨៥ *Nationalism and Sexuality : Middle-Class Morality and Sexual Norms in Modern Europe* [**ជាតិនិយមនិងសម្ពន្ធភាពផ្លូវភេទ ៖ សីលធម៌របស់វណ្ណៈថ្នាក់កណ្តាលនិងបទដ្ឋានផ្លូវភេទនៅអឺរ៉ុប**

**ទំនើប]** ម៉ាឌីហ្សុន គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យវិស្កុន្ស៊ិន ។
◉ រ៉ីណូលដ្ស៍, គ្រែហ្គ ចេ. (Reynolds, Craig J.) គ.ស. ១៩៩១ *National Identity and Its Defenders, Thailand 1939-1989* **[អត្តសញ្ញាណជាតិនិងអ្នកការពារអត្តសញ្ញាណនេះ ៖ ប្រទេសថៃ (គ.ស. ១៩៣៩-១៩៨៩)]** ម៉ិលប៊ន អត្ថបទពីម៉ូណាស្ហ (Monash) អំពីអាស៊ីអាគ្នេយ៍ លេខ ២៥ ។
◉ វជិរាវុធ (ព្រះមហាក្សត្រនៃស្យាមប្រទេស) (วชิราวุธ) (រហស្សនាម ៖ รามจิตติ រាមចិត្តិ) គ្មានចុះឆ្នាំ *หัวใจชายหนุ่ม ហ្វ៉ា ចៃជាយហ្នុំ* (ហួចៃឆាយនុំ) **[បេះដូងកំលោះ]** បាងកក រឿងភាគក្នុងកាសែត *ดุสิตสมิต* **ឌុសិតសមិត** ។
◉ វជិរាវុធ គ.ស. ១៩១៤ *ยิวแห่งบูรพาทิศ* *The Jews of the Orient* **[ជ្វីហ្វនៃបូព៌ាទិស]** បាងកក ស្យាមអុបសឺវវ៉ឺរ ។
◉ វជិរាវុធ គ.ស. ១៩៦៦ *ชุมนุมนิทานนายอินทร์ พระราชนิพนธ์ในพระบาทสมเด็จพระมงกุฎเกล้าเจ้าอยู่หัว* (ជុមនុមនិទាននាយឥន្ទ្រ ព្រះរាជនិពន្ធនៃព្រះបាទសម្ដេចព្រះមង្កុដក្លៅចៅអ្យូហ៊ួ) **[ប្រជុំនិទាននាយឥន្ទ្រ ព្រះរាជនិពន្ធនៃព្រះបាទសម្ដេចព្រះមង្កុដក្លៅចៅយូហ្វ]** ធនបុរី បណ្ណាគារ ។
◉ វិភា សេនានាញ កង្កន័ន្ទន៍ (วิภา เสนานาญ กงกะนันทน์ Wibha Senanan Kongkananda) គ.ស. ១៩៧៥ *The Genesis of the Novel in Thailand* **[ដើមកំណើតនៃប្រលោមលោកនៅប្រទេសថៃ]** បាងកក គ្រឹះស្ថានបោះពុម្ពថៃវឌ្ឍនាពាណិជ្ជ ។
◉ វេល្លា, វ៉ល់ទ័រ អិហ្វ. (Vella, Walter. F) គ.ស. ១៩៧៨ *Chaiyo! King Vajiravudh and the Development of Thai Nationalism* **[ជយោ ! ព្រះមហាក្សត្រវជិរាវុធ និងការអភិវឌ្ឍជាតិនិយមថៃ]** ហូណូលូលូ គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យហាវ៉ៃ ។
◉ វ៉ៃយ៉ុត្ត, ដេវិឌ ខេ. (Wyatt, David K.) គ.ស. ១៩៦៩ *The Politics of Reform in Thailand : Education in the Reign of King Chulalongkorn* **[នយោបាយកែទម្រង់នៅប្រទេសថៃ ៖ ការអប់រំក្នុងរាជ្យនៃព្រះចៅចុឡាលង្ករណ៍]** ញូហេវិន (New Haven) គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយែល (Yale Univeristy Press) ។
◉ វ៉ៃយ៉ុត្ត, ដេវិឌ ខេ. គ.ស. ១៩៨២ *Thailand : A Short History* **[ប្រទេសថៃ ៖ ប្រវត្តិសាស្ត្រសង្ខេប]** ញូហេវិន គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយែល ។
◉ សមាគមប្រជាជាតិ (League of Nations) គ.ស. ១៩២៥ *Official Journal* **[ទស្សនាវដ្ដីផ្លូវការ]** ខែកក្កដា ទំ. ៩៣២ ។
◉ សូម្ម័រ, ដូរិស (Sommer, Doris) គ.ស. ១៩៩១ *Foundational Fictions : The National Romances of Latin America* **[ប្រតិដ្ឋកម្មមូលដ្ឋាន ៖ ប្រលោមលោកថ្នាក់ជាតិនៅអាមេរិកឡាទីន]** ប៊ើរឃ្លេយ៍ គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យកាលីហ្វរនៀ ។
◉ ស្គិន្ន័រ, ជី. វិល្លៀម (Skinner, G. William) គ.ស. ១៩៥៧ *Chinese Society in Thailand : An Analytical History* **[សង្គមចិននៅប្រទេសថៃ ៖ ប្រវត្តិសាស្ត្របែបវិភាគ]** អ៊ីថាកា (Ithaca) រដ្ឋញូយ៉ក គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយ៉េនែល្ល ។
◉ ហាល់ប៉ឺរិន, ដេវិឌ អិម. (Halperin, David M.) គ.ស. ១៩៩០ *One Hundred Years of Homosexuality* **[មួយរយឆ្នាំនៃភាពស្រឡាញ់ភេទដូចគ្នា]** ញូយ៉ក រូតឡិដហ្ស៍ (Routledge) ។
◉ ហ៊ិគ្គ្លិង, រ៉េជិនណលដ៍ ហ. (Hickling, Reginald H.) គ.ស. ១៩៧០ "The Codification of Siamese Law 1897-1935" «[ការប្រមូលច្បាប់សៀម គ.ស. ១៨៩៧-១៩៣៥]» និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យឡុងដ្រ៍ ។
◉ ហៃយ៉ាំ, រ៉ូណាល់ដ៍ (Hyam, Ronald) គ.ស. ១៩៩០ *Empire and Sexuality : The British Experience* [ចក្រភព និងសម្ព័ន្ធផ្លូវភេទ ៖ បទពិសោធន៍របស់ពួកអង់គ្លេស] ញូយ៉ក គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យម៉ែនឆេស្ទ័រ ។
◉ ហ្គ្រីន្ន, ស្ទេហ្វិន (Greene, Stephen) គ.ស. ១៩៧១ "Thai Government and Administration in the Reign of Rama VI (1910-1925)" «[រដ្ឋាភិបាលនិងរដ្ឋបាលសៀមក្នុងរាជ្យនៃព្រះរាមទី ៦ (គ.ស. ១៩១០-១៩២៥)]» និក្ខេបបទថ្នាក់បណ្ឌិត

សាកលវិទ្យាល័យឡុងដ្រ៍ ។
៙ អាន់ដឺរសុន, បេនេឌិកត៍ (Anderson, Benedict) គ.ស. ១៩៨៣ *Imagined Communities : Reflections on the Origin and Spread of Nationalism* [**សហគមន៍ស្រមើស្រមៃ ៖ ការត្រិះរិះពិចារណាអំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម**] ញូយ៉ក វែរសូ (Verso) ៕

## ជំពូកទី ៣ ៖ ជំរឿន ការគូសផែនទី និងការតាំងបង្ហាញ

## កំណត់ចំណាំ

**(១)** ពាក្យសម្ដីនេះ មានសរសេរនៅទំព័រទី ១១៣-១៤ នៃសៀវភៅ [**សហគមន៍ស្រមើស្រមៃ ៖ ការត្រិះរិះពិចារណាអំពីដើមកំណើតនិងការផ្សព្វផ្សាយនៃជាតិនិយម**] *(Imagined Communities : Reflections on the Origin and Spread of Nationalism)* ច្បាប់ដើមជាភាសាអង់គ្លេស គ.ស. ២០០៦ ដោយគ្រឹះស្ថានបោះពុម្ពវែរសូ (Verso) (ឡុងដ្រ៍) ។
**(២)** កំណត់អ្នកបកប្រែ ៖ ប្រទេស ដែន ឬរដ្ឋអាណានិគម គឺជាប្រទេស ដែន ឬរដ្ឋដែលតាំងនៅក្នុងអំណាចនៃបរទេសជាស្រុកចំណុះគេ ។
**(៣)** កំណត់អ្នកបកប្រែ ៖ រដ្ឋអំណាចអាណានិគម ឬ រដ្ឋាភិបាលអាណានិគម គឺជារដ្ឋអំណាចឬរដ្ឋាភិបាល ដែលជ្រៀតជ្រែកវាយដណ្ដើមប្រទេសដទៃមកធ្វើជាស្រុកចំណុះរបស់ខ្លួន ។
**(៤)** កំណត់អ្នកបកប្រែ ៖ ទីតាំងនិងកំពង់ផែទាំងនោះ គឺជាផ្នែកមួយនៃដែនដីអាណានិគមមឡាយូរបស់អង់គ្លេស ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៨២៦ ដោយក្រុមហ៊ុនឥណ្ឌាខាងកើតរបស់អង់គ្លេស ។ ដែនដីទាំងនេះ រួមមាន ទាំងសិង្ហបុរី មល្លកា ពិណាំង-វេល្លេស្លេយ៍ ហើយនិងតំបន់ឌិនឌិង ។ កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា ៖ ភាសាមឡាយូហៅកំពង់ផែទាំងនោះថា « នគរី ៗ សិឡាត់» បានជាក្នុង ស.វ. ទី ១៩ ខ្មែរធ្លាប់ហៅតំបន់នេះថា « ស្រុកស្លាត់» ។
**(៥)** ឆាលស៍ ហឺរឈ្មែន (Charles Hirschman) "The meaning and measurement of Ethnicity in Malaysia : An Analysis of Census Classifications" «[អត្ថន័យនិងការប្រមាណជាតិសាសន៍នៅក្នុងប្រទេសម៉ាឡេស៊ី ៖ ការវិភាគអំពីការចែកចំណាត់ថ្នាក់ជំរឿន]» *Journal of Asian Studies* [**ព្រឹត្តិបត្រសិក្សាអាស៊ី**] ៤៦:៣ (សីហា ១៩៨៧) ទ. ៥៥២-៨២ ; ហើយនិង "The making of Race in Colonial Malaya : Political Economy and Racial Ideology" «[ការបង្កើតជាតិសាសន៍នៅក្នុងរដ្ឋអាណានិគមម៉ាឡាយ៉ា ៖ សេដ្ឋកិច្ចនយោបាយ និងមនោគមវិជ្ជាពូជសាសន៍]» *Sociological Forum* [**វេទិកាសង្គមវិទ្យា**] ១:២ (និទាឃរដូវ ១៩៨៦) ទំ. ៣៣០-៦២ ។
**(៦)** ប្រភេទនៃជនជាតិអឺរ៉ុបប្លែក ៗ ត្រូវបានគេរៀបរាប់នៅក្នុងអំឡុងសម័យអាណានិគម ។ នៅក្នុងឆ្នាំ ១៨៨១ ពួកគេត្រូវនៅក្នុងប្រភេទចម្បងមួយចំនួនដូចជា « អ្នកតាំងលំនៅប្រចាំ», « អ្នកដើរទៅដើរមក» និង « អ្នកទោស» ។ តែលុះដល់ឆ្នាំ ១៩១១ ពួកគេត្រូវបានដាក់ថា ជាសមាជិកក្រុមជនជាតិស្បែកសតែមួយ ។ រហូតដល់សម័យចុងបញ្ចប់ មានការយល់ស្របគ្នាមួយថា អ្នកធ្វើជំរឿនមានភាពមិនងាយស្រួលសោះ ពីការឲ្យចំណាត់ថ្នាក់ទៅលើអ្នកដែលជាជនជាតិ « ជ្វីហ្វ» ។
**(៧)** កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា ៖ ពួកប៉ារស៊ីជាក្រុមមនុស្សកាន់សាសនាប៉ារស៊ី ដែលធ្លាប់ជាសាសនាភាគច្រើននៅប្រទេសពែក្ស (អ៊ីរ៉ង់) រហូតដល់ការចូលដល់របស់សាសនាអ៊ីស្លាមនៅគ្រិស្តសតវត្សរ៍ទី ៨ ដោយបានបង្ខំឲ្យសាសន៍ប៉ារស៊ីរត់ទៅជ្រកកោននៅឧបទ្វីបឥណ្ឌា ។ សាសនាប៉ារស៊ីជឿថា ពិភពលោកចែកជា ២ ភាគ មួយជាភាគល្អ មួយជាភាគអាក្រក់ ។ ក្នុងជីវិត ត្រូវធ្វើយ៉ាងណាដើម្បីជួយពង្រីកភាគល្អ ។
**(៨)** កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា ៖ ពួកសិខជាមនុស្សមួយក្រុម កាន់សាសនាសិខឬសិក្ខ ដែលគ្រូ

នានកទេវ បានបង្កើតឡើងនៅ ស.វ. ទី ១៥ នៅក្នុងតំបន់បញ្ជាពនៅភាគខាងកើតនៃប៉ាគីស្ថានបច្ចុប្បន្ន និងភាគខាងលិចឆៀងខាងជើងនៃប្រទេសឥណ្ឌា ។ សាសន៍នេះជឿថា មានព្រះអាទិទេពបង្កើតលោកាតែមួយព្រះអង្គ ។

**(៩)** កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា៖ តាម **វចនានុក្រមខ្មែរ** របស់ពុទ្ធសាសនបណ្ឌិត ក្រុងភ្នំពេញ គ.ស. ១៩៦៧ ទ. ៨៥៧ មឡាយូ ឬ ម៉ាឡាយូ (**វចនានុក្រមខ្មែរ** សរសេរថា មល៉ាយូ) «ជាជាតិមនុស្សនៅមលក្កា» ។ សព្វថ្ងៃជនជាតិមឡាយូជាជនជាតិភាគច្រើននៅក្នុងប្រទេសម៉ាឡេស៊ី ខេត្តមួយចំនួននៅភាគខាងត្បូងនៃប្រទេសថៃ (ខេត្តនរាធិវាស យ៉ះឡា បត្តានី និង សុងខ្លា) ភាគខាងកើតនៃកោះស៊ុម៉ាត្រា និងផ្នែកខ្លះនៃកោះបរនេអូ ។ ជនជាតិមឡាយូស្ទើរតែទាំងអស់កាន់សាសនាអ៊ិស្លាម ហើយក្នុងភាសាមឡាយូ «ចូលសាសនាអ៊ិស្លាម» គេច្រើននិយាយថា «ម៉ាស៊ុកមឡាយូ» (ចូលមឡាយូ) ។ ខ្មែរសព្វថ្ងៃមិនសូវចងចាំឈ្មោះមឡាយូ ហើយច្រើនហៅ ម៉ាឡេ ៗ វិញតាមភាសាបារាំង ។

**(១០)** កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា៖ រហូតដល់ពាក់កណ្ដាលទី ១ នៃ ស.វ. ទី ២០ ខ្មែរហៅជនជាតិហូឡង់ថា «លន្ទា» ជាពាក្យក្លាយមកពី «ហូឡាន់ដា» ។

**(១១)** វិល្លៀម ហេនរី ស្កុត្ត *Cracks in the Parchment Curtain and Other Essays in Philippine History* [**ស្នាមប្រេះលើរបាំងសំណៅស្បែកសត្វ និងបទសាតល្បងផ្សេង ៗ ទៀតស្ដីពីប្រវត្តិសាស្ត្រហ្វីលីពីន**] គ.ស. ១៩៨២ កេសុនស៊ីធី (Quezon City) ញូដីប៉ាប់ប្លីស្ស៊័រ (New Day Publisher) ជំពូកទី ៧៖ “Filipino Class Structure in the Sixteenth Century” «[រចនាសម្ព័ន្ធវណ្ណៈរបស់ហ្វីលីពីន នៅគ្រិស្តសតវត្សរ៍ទី ១៦]» ។

**(១២)** នៅក្នុងពាក់កណ្ដាលទី ១ នៃ ស.វ. ទី ១៧ ការតាំងទីកន្លែងរបស់អេស្ប៉ាញក្នុងប្រជុំកោះនេះ ឋិតនៅក្រោមការវាយប្រហារម្ដងហើយម្ដងទៀត ពីសំណាក់កងកម្លាំងរបស់ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់លន្ទា (Vereenigde Oost Indische Compagnie) ដែលជាក្រុមហ៊ុនឆ្លងកាត់ប្រទេសដ៏ធំបំផុតជាងគេ នៅក្នុងយុគសម័យនោះ ។ ដើម្បីរក្សាជីវិតរបស់ខ្លួន អ្នកមកតាំងលំនៅជាតិអេស្ប៉ាញដែលជាអ្នកកាន់សាសនាកាតូលិក បានផុតពីគ្រោះថ្នាក់បង្កដោយពួកលន្ទា (ហូឡង់) ដោយសារលោក អូលីវ័រ ក្រុំម្វែល្ល (Oliver Cromwell) ។ [កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌមរសិក្សា៖ លោក ក្រុំម្វែល្ល ជាអភិជនអង់គ្លេសមួយរូប ដែលបានគ្រប់គ្រងប្រទេសអង់គ្លេសក្នុងសម័យ ដែលគេបានទម្លាក់ព្រះរាជា និង ប្រកាសសាធារណរដ្ឋ ។ លោក ក្រុំម្វែល្ល ស្អប់អ្នកកាន់សាសនាកាតូលិកណាស់ (លោកកាន់សាសនាប្រូតេស្តង់ ១ និកាយ ដែលមានសីលធម៌តឹងរ៉ឹងបំផុត) ហើយមូលហេតុដែលពួកអ្នកកាន់សាសនាកាតូលិកនៅហ្វីលីពីន បានផុតពីការវាយរបស់ពួកលន្ទា គឺដោយសារតែលោក ក្រុំម្វែល្ល បានធ្វើយ៉ាងណាកុំឲ្យពួកលន្ទាមានប្រៀបលើផ្ទៃសមុទ្រ ព្រោះថា នៅសម័យកាលនោះ មហាអំណាចលន្ទានិងមហាអំណាចអង់គ្លេស ជាគូប្រកួត ។] ប្រសិនបើពួកលន្ទាទទួលបានជោគជ័យ ទីក្រុងម៉ានីលទំនងជាបានក្លាយជាមជ្ឈមណ្ឌលនៃការតាំងអំណាចរបស់លន្ទានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាជាងក្រុងបាតាវីយ៉ា (ហ្សាការតា) ។ ក្នុងឆ្នាំ ១៧៦២ ពួកអង់គ្លេសបានវាយយកទីក្រុងម៉ានីលពីអេស្ប៉ាញ ហើយគ្រប់គ្រងទីក្រុងនេះអស់រយៈពេលជាង ២ ឆ្នាំ ។ ប្រទេសអេស្ប៉ាញអាចគ្រប់គ្រងទីក្រុងនេះវិញបាន ដោយការដោះដូរជាមួយនឹងអង់គ្លេស នូវតំបន់ដទៃទៀតដូចជា ហ្វ្លរីដា និងស្រុកដទៃទៀតនៅភាគខាងកើតទន្លេមីស៊ីស៊ីពី (នៅទ្វីបអាមេរិកខាងជើង) ។ បើសិនជាពេលនោះ មានការបន្តការចរចាផ្សេងទៀត ប្រហែលជាប្រជុំកោះនេះអាចភ្ជាប់បានជាមួយមឡាយ៉ា (ជ្រោយមឡាយូ) និងសិង្ហបុរីនៅក្នុង ស.វ. ទី ១៩ ។

**(១៣)** ម៉ាសុន ស៊ី. ហោដលេយ៍ (Mason C. Hoadley) “State vs. Ki Aria Marta Ningrat (1696) and Tian Siangko (1720-21)” «[ក្ដីរដ្ឋប្រឆាំងនឹង គី អារ្យៈ ម៉ាត៌ា នីងរ៉ាត (គ.ស. ១៦៩៦) និង ទីយ៉ាន់ សៀងកូ (គ.ស. ១៧២០-២១)]» (អត្ថបទមិនទាន់ចេញផ្សាយ គ.ស. ១៩៨២) ។

**(១៤)** ជាឧទាហរណ៍ សូមមើល អិដហ្គារ វិកប៊ឺក (Edgar Wickberg) *The Chinese in Philippine Life, 1850-1898* [**ជនជាតិចិននៅក្នុងជីវភាពហ្វីលីពីន គ.ស. ១៨៥០-១៨៩៨**] ញូហេវិន គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយែល គ.ស. ១៩៦៥ ជំពូកទី ១ និង ២ ។

**(១៥)** ការធ្វើពាណិជ្ជកម្មតាមកប៉ាល់ បាននាំយកកំណាត់សូត្រហើយនិងចានក្បានរបស់ចិន មកដូរជាមួយនឹងលោហៈប្រាក់

របស់ម៉ិចស៊ិច ។ ក្នុងការធ្វើពាណិជ្ជកម្មនេះ ទីក្រុងម៉ានីល គឺជាឃ្លាំងអស់រយៈពេលជាង ២ សតវត្សរ៍ ។

**(១៦)** សូមអានជំពូកទី ៧ ទំ. ១២៥ សម្រាប់អត្ថាធិប្បាយអំពីការតស៊ូរបស់បារាំងសែស ដើម្បីកាត់ផ្ដាច់វិស័យពុទ្ធសាសនារបស់កម្ពុជាចេញពីសៀម ។

**(១៧)** សូមអាន វិល្លៀម រហ្វហ្វ៍ (William Roff) *The origins of Malay Nationalism* **ប្រភពដើមនៃគំនិតជាតិនិយមមឡាយូ** ញូហេវិន គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យយែល គ.ស. ១៩៦៧ ទំ. ៧២-៤ ។

**(១៨)** សូមអាន ហារី ចេ. បែនដា (Harry J. Benda) *The Crescent and the Rising Sun; Indonesian Islam Under the Japanese Occupation, 1942-1945* [**អឌ្ឍចន្ទនិងឧទ័យ ៖ អ៊ិស្លាមឥណ្ឌូនេស៊ីនៅជំនាន់ជប៉ុនកាន់កាប់ គ.ស. ១៩៤២-១៩៤៥**] ក្រុងឡាអេ ដាប៊ លយូ. វ៉ាន់ ហ៊ូវ៉ឺ (W. van Hoeve) ជំពូកទី ១-២ ។

**(១៩)** កំណត់អ្នកបកប្រែ ៖ ផែនទីមែរកាទរ គឺជាប្រភេទផែនទីដំបូងបង្អស់ បង្កើតឡើងដោយភូមិវិទូជនជាតិហ្វ្លង់ដ្រ៍ (ជាតំបន់មួយនៅចន្លោះប្រទេសបែលហ្ស៊ិក បារាំងសែស និងហូឡង់សព្វថ្ងៃ) ឈ្មោះ ហ្សេរ៉ារឌូស មែរកាទរ (Gerardus Mercator) នៅក្នុងឆ្នាំ ១៥៦៩ ។ ផែនទីបែបនេះគូសលើរាងបំពង់ រួចត្រូវគេលា ។ ការគូសផែនទីបែបនេះហៅថា ចំណោលមែរកាទរ ។

**(២០)** ទង់ជ័យ វិនិច្ឆកូល (ថុងឆៃ វិនិច្ឆគូន) (Thongchai Winichakul) (Siam Mapped: A History of the Geo-Body of Siam) «[ការគូសផែនទីប្រទេសសៀម ៖ ប្រវត្តិនៃភូមិរូបរបស់ប្រទេសសៀម]» និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យស៊ីដនេយ៍ គ.ស. ១៩៨៨ ។

**(២១)** រីឆាដ ម្យួរ (Richard Muir) *Modern Political Geography* [**ភូមិសាស្ត្រនយោបាយទំនើប**] ឡុងដ្រ៍ ម៉ាក់មិល្លាន់ (Macmillan) គ.ស. ១៩៧៥ ទំ. ១១៩ ។

**(២២)** ទង់ជ័យ «[ការគូសផែនទីប្រទេសសៀម]» ទំ. ១០៥-១០, ២៨៦ ។

**(២៣)** សម្រាប់ការពិភាក្សាពេញលេញមួយអំពីទស្សនាទានចាស់អំពីអំណាចនៅជ្វា (ដែលមានលក្ខណៈខុសគ្នាតិចតួចទៅនឹងអ្វីដែលមាននៅក្នុងប្រទេសសៀមនាសម័យបុរាណ) សូមអានជំពូកទី ១ ក្នុងសៀវភៅរបស់ខ្ញុំដែលស្ដីអំពីភាសានិងអំណាច ។

**(២៤)** ទង់ជ័យ «[ការគូសផែនទីប្រទេសសៀម]» ទំ. ១១០ ។

**(២៥)** ដេវីឌ អេស. ឡែនដិស (David S. Landes) *Revolution in Time: Clocks and the Making of the Modern World* [**បដិវត្តន៍ពេលវេលា ៖ នាឡិកានិងការបង្កើតពិភពលោកទំនើប**] ខេមប្រ៊ីដហ្ស៍ រដ្ឋម៉ាស្សាឈូស្សិត្ស រោងពុម្ពបែលក៍ណាប់របស់គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យខេមប្រ៊ីដហ្ស៍ គ.ស. ១៩៨៣ ជំពូកទី ៩ ។

(២៦) ទង់ជ័យ «[ការគូសផែនទីប្រទេសសៀម]» ទំ. ៣១០ ។

**(២៧)** ខ្ញុំមិនសំដៅតែទៅលើការស្ទង់មតិកនិងការលក់សម្បត្តិបុគ្គលជាដីធ្លីនៅក្នុងន័យសាមញ្ញនោះទេ ។ សំខាន់ជាងនេះនោះ គឺថា ទំនៀមទម្លាប់អឺរ៉ុបក្នុងការអនុវត្តនូវនយោបាយផ្ទេរដែនដីជាមួយនឹងប្រជាជនដែលរស់លើដែនដីនោះ តាមរយៈពិធីរៀបអាពាហ៍ពិពាហ៍របស់ពួកស្ដេច ។ ព្រះអង្គម្ចាស់ក្សត្រីនៅពេលរៀបការ ធ្លាប់នាំស្រុកនិងតំបន់តូចៗ មកថ្វាយព្រះស្វាមី ហើយការផ្ទេរប្រគល់សិទ្ធិទាំងអស់នេះសុទ្ធតែធ្វើឡើងដោយការចរចាជាផ្លូវការនិងការចុះហត្ថលេខា ។ ទំនៀមទម្លាប់នេះមិនធ្លាប់មានក្នុងរដ្ឋទាំងអស់នៅទ្វីបអាស៊ីនាមុនសម័យអាណានិគម ។

**(២៨)** សូមមើល ទង់ជ័យ «[ការគូសផែនទីប្រទេសសៀម]» ទំ. ៣៨៧ ស្ដីអំពីអ្នកវណ្ណៈថ្នាក់ដឹកនាំរបស់សៀមក្នុងការស្រូបយករបៀបប្រតិដ្ឋបែបនេះ ៖ « យោងទៅលើ "ផែនទីប្រវត្តិសាស្ត្រ" ទាំងនេះ ភូមិរូបនេះពុំមែនមានលក្ខណៈទំនើបទេ ប៉ុន្តែបានកើតឡើងអស់រយៈពេលជាងមួយពាន់ឆ្នាំកន្លងទៅហើយ ។ ផែនទីប្រវត្តិសាស្ត្របានជួយបដិសេធនូវរាល់សេចក្ដីស្នើទាំងឡាយណាដែលថា ភាពជាជាតិទើបតែកើតនាពេលថ្មីៗ នេះ ។ ហើយការយល់ឃើញដែលថា ប្រទេសសៀមបច្ចុប្បន្ន គឺជាលទ្ធផលនៃការកាត់ផ្ដាច់ពីអតីតកាលនោះ គឺជាអ្វីដែលមិនបានកើតឡើងនោះទេ» ។ ដូច្នេះ គំនិតដែលថា

ទំនាក់ទំនងរវាងសៀមនិងមហាអំណាចអឺរ៉ុប បាននាំឲ្យមានប្រទេសស្យាមដូចនៅសព្វថ្ងៃនេះ ក៏ត្រូវបានបដិសេធផងដែរ ។
**(២៩)** ការយកមកប្រើនេះមិនមែនជាកលល្បិចវៀចវេរទាល់តែសោះ ។ ការយល់ដឹងរបស់អ្នកជាតិនិយមដំបូងៗ នៅក្នុងប្រទេសអាណានិគមនាអាស៊ីអាគ្នេយ៍ បានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីទម្រង់រដ្ឋាភិបាលនិងស្ថាប័នរបស់អាណានិគមនិយម ។ សូមមើលជំពូកទី ៧ នៃសៀវភៅរបស់ខ្ញុំជាភាសាអង់គ្លេស ។
**(៣០)** នៅក្នុងអត្ថបទរបស់លោក និក ហូអាគីន (Nick Joaquín) ដែលជាអ្នកនិពន្ធដ៏ប្រសើរមួយ និងជាអ្នកស្នេហាជាតិដែលមិនអាចសង្ស័យបាន យើងអាចឃើញនូវរបៀបដែលនិមិត្តសញ្ញាមានឥទ្ធិពលយ៉ាងខ្លាំងក្លាក្នុងការបញ្ចុះបញ្ចូលមនុស្សណា ទោះជាមានប្រាជ្ញាច្រើនក៏ដោយ ។ លោក ហូអាគីន បានសរសេរពីមេទ័ព អាន់តូនីយោ លូណា ដែលជាវីរបុរសដ៏កម្សត់ក្នុងការតស៊ូនឹងពួកអាមេរិកាំងនៅឆ្នាំ ១៨៩៨-៩៩ ដោយរៀបរាប់ថា មេទ័ពនោះប្រញាប់ « បំពេញតួនាទីដែលពួកក្រេអូល (កូនកាត់ហ្វីលីពីននិងអេស្ប៉ាញ) ធ្លាប់តែបំពេញដោយមិនបានគិត អស់រយៈ ៣ សតវត្សរ៍មកហើយ គឺការការពារ "ទ្រង់ទ្រាយ" នៃប្រទេសហ្វីលីពីន កុំឲ្យពួកបរទេសដណ្ដើមយកបាន» (ក្នុងសៀវភៅ *A Question of Heroes* [**អំពីឧទរបុរស**] គ.ស. ១៩៧៧ ទ. ១៦៤) ។ នៅក្នុងវគ្គមួយទៀត គាត់បានសង្កេតទាំងងឿងឆ្ងល់ថា សម្ព័ន្ធមិត្ត អ្នកចុះចូលសាសនា និងទាហានស៊ីឈ្នួលជាតិហ្វីលីពីនដែលគាំទ្រពួកអេស្ប៉ាញ ហើយដែលត្រូវបញ្ជូនដើម្បីច្បាំងពួកបះបោរជាតិហ្វីលីពីន បានធ្វើឲ្យប្រជុំកោះហ្វីលីពីននៅតែក្នុងកណ្ដាប់ដៃរបស់អេស្ប៉ាញនិងពួកកាតូលិកអឺចឹងមែន តែម្យ៉ាងទៀត ក៏បានធ្វើឲ្យប្រជុំកោះនេះមិនបែកបាក់ ហើយពួកគេបានតស៊ូ (ទោះជាពួកអេស្ប៉ាញមានបំណងយ៉ាងម៉េច) ដើម្បីឲ្យហ្វីលីពីននៅតែមានឯកភាព ។ ដដែល ទំ. ៥៨ ។
**(៣១)** កំណត់បណ្ណាធិការ ៖ កោះនេះឈ្មោះ នូវែលហ្គីនេ (ហ្គីនេថ្មី) ជាភាសាបារាំង និង ញូហ្គីនេ (ហ្គីនេថ្មី) ជាភាសាអង់គ្លេស ។ កោះនូវែលហ្គីនេនេះ ជាកោះធំជាងគេលំដាប់ទី ២ ក្នុងពិភពលោក ក្រោយពីដែនដីគ្រីនឡែនដ៍ (គ្រូអិនឡង់) ឬលំដាប់ទី ៣ បើសិនជាចាត់ទុកទ្វីបអូស្ត្រាលីជាកោះដែរ ។ បច្ចុប្បន្ននេះ កោះនូវែលហ្គីនេ ចែកជាពីរភាគ ។ ភាគខាងលិចជាអាណាខេត្តរបស់ឥណ្ឌូនេស៊ី រីឯភាគខាងកើត ជារដ្ឋទទួលបានឯករាជ្យក្នុងឆ្នាំ ១៩៧៥ មានឈ្មោះថា ប៉ាពួស៊ីនូវែលហ្គីនេ ជាភាសាបារាំង និង ប៉ាពួញូហ្គីនេ ជាភាសាអង់គ្លេស (និង ប៉ាពួនិវហ្គីនី ជាភាសាតុកពីស៊ីន) ។
**(៣២)** សូមអាន រ៉ូប៊ិន អូស្ប៊ន (Robin Osborne) *Indonesia's Secret War, The Guerrilla Struggle in Irian Jaya* [**សង្គ្រាមសម្ងាត់របស់ឥណ្ឌូនេស៊ី, ការតស៊ូរបស់ទ័ពព្រៃនៅអ៊ីរៀនជ័យា**] ស៊ីដនេយ៍ អាល្លែន និង អាន់វិន (Allen & Unwin) គ.ស. ១៩៨៥ ទំ. ៨-៩ ។
**(៣៣)** តាំងពីឆ្នាំ ១៩៦៣ មក មាននូវហេតុការណ៍បង្ហូរឈាមជាច្រើននៅនូវែលហ្គីនេខាងលិច (ឥឡូវត្រូវដូរឈ្មោះទៅជា អ៊ីរៀនជ័យា) ។ មូលហេតុមួយប្រការដែលនាំឲ្យមានការបង្ហូរឈាមនេះ គឺជាលទ្ធផលនៃការរៀបចំរដ្ឋតាមរបៀបយោធារបស់ឥណ្ឌូនេស៊ីតាំងពីឆ្នាំ ១៩៦៥ មក ។ មូលហេតុមួយប្រការទៀត គឺដោយសារមានសកម្មភាពវាយឆ្មក់ (ប្រកបដោយប្រសិទ្ធភាពនៅពេលខ្លះ) របស់អង្គការរំដោះប៉ាពួ ។ ប៉ុន្តែ អំពើសាហាវយង់ឃ្នងទាំងនេះ មានសភាពតិចតួចបើប្រៀបធៀបជាមួយអំពើហិង្សាដ៏សាហាវឃោរឃៅរបស់រដ្ឋាភិបាលហ្សាការតា ទៅលើអតីតទឹកដីទីម័រខាងកើតរបស់ព័រទុយហ្គាល់ ។ ក្នុងអំឡុងពេលបីឆ្នាំដំបូងបន្ទាប់ពីការឈ្លានពាននៅឆ្នាំ ១៩៧៦ មក នៅតំបន់ទីម័រខាងកើតនោះ មានមនុស្សប្រហែល ៦០០.០០០ នាក់ (ប្រហែល ១ ភាគ ៣) ត្រូវស្លាប់ដោយសារសង្គ្រាម គ្រោះទុរ្ភិក្ស ជម្ងឺ និងការជន្លៀស ។ ខ្ញុំមិនគិតថា ជាកំហុសក្នុងការលើកឡើងថា ភាពខុសប្លែកគ្នាចំពោះទីម័រខាងកើតនេះ កើតឡើងដោយសារដែនដីនេះមិនបានឋិតនៅក្នុងផែនទីឥណ្ឌាខាងកើតរបស់ហូឡង់ ហើយនិងរបស់ឥណ្ឌូនេស៊ីរហូតដល់ឆ្នាំ ១៩៧៦ នោះ ។
**(៣៤)** សូមអាន រ៉ូប៊ិន អូស្ប៊ន (Robin Osborne) *Indonesia´s Secret War, The Guerrilla Struggle in Irian Jaya* [**សង្គ្រាមសម្ងាត់របស់ឥណ្ឌូនេស៊ី, ការតស៊ូរបស់ទ័ពព្រៃនៅអ៊ីរៀនជ័យា**] ទំ. ២ ។
**(៣៥)** សូមអាន ទំ. ១១០ ក្នុងសៀវភៅដើមនេះជាភាសាអង់គ្លេស ។
**(៣៦)** សញ្ញាដ៏ល្អមួយសម្រាប់បង្ហាញរឿងនេះ គឺជាឈ្មោះរបស់អង្គការទ័ពព្រៃជាតិនិយមប្រឆាំងឥណ្ឌូនេស៊ី ដែលមានឈ្មោះ

ថា អ័រហ្គានីសាស៊ីប៉ាពួម៉េរដេកា (Organisasi Papua Merdeka ~ OPM) ។ ឈ្មោះនេះមកពីពាក្យភាសាឥណ្ឌូនេស៊ី ។

**(៣៧)** ក្នុងឆ្នាំ ១៨១១ កងកម្លាំងរបស់ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់អង់គ្លេស បានរឹបអូសនូវរាល់ទ្រព្យសម្បត្តិរបស់ហូឡង់ក្នុងដែនដីអាណានិគមនេះ (ស្តេចណាប៉ូឡេអុងបានបញ្ចូលដែនដីអាណានិគមរបស់ហូឡង់ទៅជារបស់បារាំងសែសនៅឆ្នាំមុន) ។ លោក រ៉ាហ្វលស៍ គ្រប់គ្រងកោះជ្វារហូតទល់តែឆ្នាំ ១៨១៥ ។ ស្នាដៃដ៏ធំរបស់លោក គឺការសរសេរប្រវត្តិសាស្ត្ររបស់កោះជ្វា នៅក្នុងឆ្នាំ ១៨១៩ គឺរយៈពេល ២ ឆ្នាំមុនគាត់បានស្ថាបនារដ្ឋស្រុកសិង្ហបុរី ។

**(៣៨)** ការតាំងបង្ហាញប្រាសាទបូរ៉ូប៊ូឌួរ ដែលជាចេតិយពុទ្ធសាសនាដ៏ធំជាងគេនៅលើពិភពលោក គឺជាឧទាហរណ៍អំពីដំណើរការនេះ ។ ក្នុងឆ្នាំ ១៨១៤ របបរ៉ាហ្វលស៍បានប្រទះឃើញប្រាសាទនេះ ហើយបានកាប់ឆ្ការសម្អាតព្រៃដែលនៅរុំព័ទ្ធអស់ ។ ក្នុងឆ្នាំ ១៨៤៥ អ្នកផ្សងព្រេងនិងជាអ្នកគំនូរជនជាតិអាឡឺម៉ង់ម្នាក់ឈ្មោះ ស្ហែហ្វេរ (Schaefer) បានបញ្ចុះបញ្ចូលឲ្យពួកហូឡង់នៅបាតាវីយ៉ា ចំណាយឲ្យរូបគាត់ថតរូបប្រាសាទនេះជាលើកដំបូង ។ ក្នុងឆ្នាំ ១៨៥១ រដ្ឋបាលបាតាវីយ៉ា បានបញ្ជូនក្រុមមន្ត្រីដែលដឹកនាំដោយលោកវិស្វករសំណង់ស៊ីវិលឈ្មោះ អេហ្វ.សេ. វិល្សិន (F.C. Wilsen) ធ្វើការសិក្សាអំពីចម្លាក់ហើយនិងផ្តិតយកសិលាចារឹកនៅលើថ្មប្រាសាទទាំងនោះ ចងក្រងជាលក្ខណៈវិទ្យាសាស្ត្រ ។ ក្នុងឆ្នាំ ១៨៧៤ លោកបណ្ឌិត ឡេម៉ុន្ស (Leemans) នាយកសារមន្ទីរបុរាណវត្ថុនៅក្នុងទីក្រុងឡីដិន បានទទួលបញ្ជាពីរដ្ឋមន្ត្រីអាណានិគមឲ្យបោះពុម្ពផ្សាយនូវសំណេរសិក្សាលម្អិតដ៏ធំដំបូងមួយ ។ គាត់ពឹងផ្អែកទាំងស្រុងទៅលើការផ្តិតសិលាចារឹករបស់លោក វិល្សិន ហើយមិនដែលបានទៅពិនិត្យមើលតំបន់ដែលគាត់សិក្សានោះដោយផ្ទាល់ភ្នែកទេ ។ នៅក្នុងទសវត្សរ៍ ១៨៨០ អ្នកជំនាញខាងថតរូបម្នាក់ឈ្មោះ សេផាស (Cephas) បានធ្វើការពិនិត្យមើលដោយថតរូបយ៉ាងទំនើបត្រួស ៗ ។ នៅក្នុងឆ្នាំ ១៩០១ របបអាណានិគមនិយមបានបង្កើតគណៈកម្មការបុរាណវត្ថុ ។ នៅរវាងឆ្នាំ ១៩០៧ និង ១៩១១ គណៈកម្មការនេះមើលខុសត្រូវលើការជួសជុលរូបសំណាក ដោយបញ្ជូនក្រុមមួយ ដឹកនាំដោយវិស្វករស៊ីវិលម្នាក់ឈ្មោះ វ៉ាន់អេប (Van Erp) និងទទួលការឧបត្ថម្ភថវិកាពីរដ្ឋអំណាច ។ ដោយទទួលបានជោគជ័យយ៉ាងពេញលេញនេះ គណៈកម្មការនេះបានទទួលការតម្លើងទៅជាផ្នែកថែររក្សាបុរាណវត្ថុនៅក្នុងឆ្នាំ ១៩១៣ ។ ស្ថាប័ននេះថែរក្សាប្រាសាទនេះឲ្យមានសភាពស្អាតល្អនិងមានសណ្តាប់ធ្នាប់រហូតទល់ចុងបញ្ចប់នៃសម័យអាណានិគម ។ សូមអាន សេ. ឡេម៉ុន្ស (C. Lememans) *Bôrô-Boudour, dans l'île de Java, dessiné par ou sous la direction de F. C. Wilsen, avec texte descriptif et explicatif, rédigeé d'après les mémoires manuscrits et imprimés de F. C. Wilsen [et] J. F. G. Brumund et autres documents* [**បូរ៉ូប៊ូឌួរនៅកោះជ្វា គូរដោយឬក្រោមការដឹកនាំរបស់ អេហ្វ.សេ. វិល្សិន ជាមួយនឹងអត្ថបទរៀបរាប់និងពន្យល់ គាត់តែងតាមសារណាសរសេរដោយដៃនិងបោះពុម្ពរបស់ អេហ្វ.សេ. វិល្សិន (និង) ហ្ស៊ី.អេហ្វ.ហ្សេ. ប្រ៊ូមូនដ៍ និងតាមឯកសារផ្សេងទៀត**] ឡីដិន អ៊ី.ហ្ស៊ី. ប្រ៊ីល្ល គ.ស. ១៨៧៤ ទំ. ii-lv និង អិន.ហ្ស៊ី. ក្រុម (N. J. Krom) *Inleiding tot de Hindoe-Javaansche Kunst* [**លំនាំដើមអំពីសិល្បៈជ្វា-ហិណ្ឌូ**] ឆ្នាំ ១៩២០ ភាគទី ១ ជំពូកទី ១ ។

**(៣៩)** ឧបរាជ ខឺហ្សុន (Curzon) (គ្រប់គ្រងឥណ្ឌា គ.ស. ១៨៩៩-១៩០៥) ជាអ្នកចាប់អារម្មណ៍និងមានចំណេះដឹងដ៏ជ្រាលជ្រៅ អំពីបុរាណវត្ថុដែលបានធ្វើឲ្យការសិក្សាបុរាណវត្ថុនៅឥណ្ឌា មានការចាប់អារម្មណ៍កាន់តែខ្លាំងនោះ បានមានបន្ទូលយ៉ាងល្អថា គឺជាកាតព្វកិច្ចរបស់យើងក្នុងការជីកនិងរុករក ធ្វើចំណាត់ថ្នាក់ ចម្លងនិងពិព័ណ៌នា ចម្លងនិងបកប្រែ ហើយថែរក្សានិងការពារ ។ នៅក្នុងឆ្នាំ ១៨៩៩ គេបានបង្កើតនាយកដ្ឋានបុរាណវិទ្យាប្រទេសភូមា (ជាផ្នែកមួយនៃដែនដីអណានិគមអង់គ្លេស) ហើយភ្លាមនោះចាប់ផ្តើមធ្វើការជួសជុលប្រាសាទនៅតំបន់ពុកាម (បាហ្គាន) ។ នៅមួយឆ្នាំមុននោះ គេបានបង្កើតសាលាបារាំងសែសនៅចុងបូព៌ាប្រទេសនៅព្រៃនគរ ហើយក្រោយមក បានបង្កើតជានាយកដ្ឋានសារមន្ទីរនិងប្រាសាទប្រវត្តិសាស្ត្រនៃឥណ្ឌូចិន ។ បន្ទាប់ពីបារាំងសែសបានដណ្តើមកាន់កាប់ខេត្តសៀមរាបនិងបាត់ដំបងពីសៀមនៅក្នុងឆ្នាំ ១៩០៧ មក ពួកគេបានបង្កើតមន្ទីរអភិរក្សអង្គរដើម្បីអភិរក្សប្រាសាទបុរាណទាំងឡាយដ៏អស្ចារ្យបំផុតរបស់តំបន់អាស៊ីអាគ្នេយ៍នេះ ។ សូមអាន ប៉ែរណារដ៍ ហ្វីលីព្ព ហ្គ្រោលីយ៉េរ៍ **ឥណ្ឌូចិន** ឡុងដ្រ៍ មូល្ល័រ គ.ស. ១៩៦៧ ទំ. ១៥៥-១៥៧, ១៧៤-១៧៧ ។ ដូចដែលបានលើកឡើងថា គណៈកម្មការបុរាណវត្ថុរបស់អាជ្ញាធរអាណានិគមហូឡង់ បានបង្កើត

ឡើងនៅក្នុងឆ្នាំ ១៩០១ ។ ព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ ១៨៩៩, ១៨៩៨ និង ១៩០១ មិនមែនជាការគាប់ជួនប៉ុណ្ណោះទេ តែបង្ហាញពីភាពឈ្លាសវៃដែលពួកអាណានិគមនិយមដែលប្រកួតប្រជែងគ្នា បានឃ្លាំមើលគ្នាទៅវិញទៅមកនោះទេ ថែមទាំងបង្ហាញពីការផ្លាស់ប្តូរនៃរបបវាតទីអំណាចនៅពេលឆ្លងសតវត្សរ៍ ។ ដូចដែលគេគិតទុកយ៉ាងដូច្នេះ រដ្ឋសៀមឯករាជបានធ្វើដំណើរយ៉ាងយឺត ៗ ទៅរកភាពដូចគ្នាដូច្នេះដែរ ។ ផ្នែកថែរក្សាបុរាណវត្ថុរបស់ស្យាមប្រទេសបានបង្កើតឡើងនៅឆ្នាំ ១៩២៤ ហើយសារមន្ទីរជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩២៦ ។ សូមអាន ឆាលស៍ ហៃហាំ (Charles Higham) *The Archaeology of Mainland Southeast Asia: From 10,000 B.C. to the Fall of Angkor* [**បុរាណវត្ថុវិទ្យានៃតំបន់អាស៊ីអាគ្នេយ៍ដីគោក ៖ ពីរយៈពេល ១ ម៉ឺនឆ្នាំមុនគ្រិស្តសករាជរហូតដល់ការធ្លាក់របស់អង្គរ**] ញូយ៉ក គ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យខេមប្រ៊ីដហ្ស៍ គ.ស. ១៩៨៩ ទំ. ២៥ ។

**(៤០)** ក្រុមហ៊ុនឥណ្ឌាខាងកើតរបស់ហូឡង់បានដួលរលំក្នុងឆ្នាំ ១៧៩៩ ។ តែប្រជុំកោះឥណ្ឌាខាងកើតរបស់ហូឡង់បានបង្កើតឡើងនៅឆ្នាំ ១៨១៥ នៅពេលដែលប្រទេសលន្ទា (ប្រទេសហូឡង់) បានទទួលឯករាជ្យឡើងវិញដោយសារការគាំទ្រពីសន្តសម្ព័ន្ធភាព ហើយព្រះវិល្លែមនៃសន្តតិវង្សអូរ៉ង់ហ្ស៍ បានឡើងលើរាជបល្ល័ង្ក ដែលព្រះអធិរាជបារាំងសែសណាប៉ូឡេអុង ទី ១ បានបង្កើតមុនដំបូងនៅឆ្នាំ ១៨០៦ ដើម្បីដាក់ព្រះអនុជនៃព្រះអង្គ ព្រះនាម ល្វី ។ រីឯក្រុមហ៊ុនឥណ្ឌាខាងកើតរបស់អង់គ្លេស អាចគង់នៅបានរហូតដល់ឆ្នាំ ១៨៥៧ ពេលដែលមានការបះបោរដ៏ធំមួយនៅឥណ្ឌា ។

**(៤១)** គណៈកម្មការបុរាណវត្ថុ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩០១ ស្របពេលដែលមានការចាប់ផ្តើមដំណើរការ «នយោបាយអប់រំសីលធម៌» (នយោបាយដែលមានគោលបំណងដំបូងបង្កើតប្រព័ន្ធអប់រំតាមរបៀបបស្ចិមប្រទេស) នៅក្នុងដែនដីអាណានិគមហូឡង់ ។ អគ្គទេសាភិបាល ប៉ូល ឌូមែរ (គ្រប់គ្រង គ.ស. ១៨៩៧-១៩០២) បានបង្កើតទាំងនាយកដ្ឋានសារមន្ទីរនិងប្រាសាទប្រវត្តិសាស្ត្រនៃតំបន់ឥណ្ឌូចិនបារាំងសែស និងប្រព័ន្ធអប់រំទំនើបសម្រាប់ដែនដីអាណានិគម ។ នៅក្នុងប្រទេសភូមា ការពង្រីកការអប់រំថ្នាក់ខ្ពស់បានចាប់ផ្តើមយ៉ាងសម្បើម (រវាងឆ្នាំ ១៩០០-១៩៤០ មានការកើនឡើងនៃចំនួននិស្សិតថ្នាក់មធ្យមសិក្សាពី ២៧.៤០១ ទៅ ២៣៣.៥៤៣ នាក់ ហើយនិស្សិតមហាវិទ្យាល័យពី ១១៥ ទៅ ២៣៦៥ នាក់) ស្របពេលដែលនាយកដ្ឋានបុរាណវិទ្យារបស់ភូមាចាប់មានដំណើរការ ។ សូមអាន រ៉ូបឺត អេជ. ថីល័រ *The State in Burma* [**រដ្ឋអំណាចនៅភូមា**] ឡុងដ្រ៍ ស៊ី. ហឺស្ត និង កូ. (C. Hurst & Co.) គ.ស. ១៩៨៧ ទំ. ១១៤ ។

**(៤២)** ដោយទទួលឥទ្ធិពលមួយផ្នែកពីការគិតបែបនេះ ទើបអ្នកប្រាជ្ញថៃបែបអភិរក្ស អ្នកបុរាណវិទូ និងមន្ត្រីមួយចំនួនបានទទូចរហូតទល់សព្វថ្ងៃនេះថា អ្នកកសាងអង្គរ គឺជាជនជាតិខម ដែលត្រូវបានរលាយផុតពូជអស់ដោយគ្មានដានស្នាមហើយមិនមានខ្សែស្រឡាយអ្វីជាប់នឹងជនជាតិខ្មែរសព្វថ្ងៃនេះដែលគួរឲ្យមាក់ងាយទេ ។

**(៤៣)** ឧទាហរណ៍ដ៏ល្អមួយពីការរីកដុះដាលនេះ មានសរសេរនៅក្នុងសៀវភៅ *Ancient Indonesian Art* [**សិល្បៈឥណ្ឌូនេស៊ីបុរាណ**] អាំស្ទែរដាំ សេ.ប៉េ.ហ្ស៊ី. វ៉ាន់ដេរប៉េត (C. P. J. van der Peet) គ.ស. ១៩៥៩ និពន្ធដោយអ្នកប្រាជ្ញហូឡង់ឈ្មោះ អូហ្គុស្ត យ៉ូហាន់ បេរណិត កិម្ប៉ែរស៍ (August Johan Bernet Kempers) ដែលពិព័ណ៌នាពីខ្លួនឯងថា ជាអតីតប្រធានផ្នែកបុរាណវិទ្យានៅក្នុងប្រទេសឥណ្ឌូនេស៊ី ។ នៅក្នុងទំព័រទី ២៤-៥ មានផែនទីមួយបង្ហាញអំពីតំបន់បុរាណស្ថានជាច្រើន ។ ផែនទីទី ១ មានសារប្រយោជន៍ណាស់ ដោយសារវាមានរាងបួនជ្រុង (ដែលនៅគែមខាងកើត គឺជាខ្សែបណ្តោយទី ១៤១) ។ ដោយចៃដន្យ មានរួមបញ្ចូលទាំងកោះមិណ្ដាណាវរបស់ហ្វីលីពីន កោះប៊រនេអូខាងជើងរបស់ដែនដីអាណានិគមអង់គ្លេស ជ្រោយម៉ាឡាយ៉ា និងសិង្ហបុរី ។ ដែនដីទាំងនេះ ពុំមានដាក់ឈ្មោះទីស្ថានណាមួយ លើកលែងតែឈ្មោះ កិដះ (ក្រៃបុរី) តែមួយគត់ ។ ការផ្លាស់ប្តូរពីសាសនាព្រាហ្មណ៍-ពុទ្ធមកអិស្លាម ឃើញមានក្រោយរូបភាពលេខ ៣៤០ ។

**(៤៤)** សូមអាន **កម្ពុជា** លេខ ៤៥ (១៥ ធ្នូ ១៩៦៨) ដើម្បីមើលរូបថតប្លែក ៗ នេះ ។

**(៤៥)** ការពិភាក្សានៅទីនេះ ប្រើប្រាស់នូវការវិភាគពេញលេញនៅក្នុងជំពូកទី ៥ «ភាសានិងអំណាច» ក្នុងសៀវភៅដើមជាភាសាអង់គ្លេស ។

**(៤៦)** កំណត់បណ្ណាធិការនៃមជ្ឈមណ្ឌលខេមរសិក្សា ៖ សូមរំឭកអ្នកអានថា ម្យ៉ាងទៀត ក្នុងនិកាយអិស្លាមដែលមាន

ក្រឹត្យវិន័យយ៉ាងតឹងរ៉ឹងមួយចំនួន គេហាមមិនឲ្យព័ណ៌នាដោយគូរ គូស ឬ ឆ្លាក់ នូវរូបមនុស្ស ។

**(៤៧)** ជាឧទាហរណ៍មួយនៃលទ្ធផលគោលនយោបាយនៃការស្រមើស្រមៃក្នុងរឿង **ផ្ទះគុក** (ជាលទ្ធផលដែលអតីតអ្នកទោសនយោបាយ លោក ប្រាមូទ្យ: ដឹងយ៉ាងឈឺចាប់) គឺជាប័ណ្ណសម្គាល់ខ្លួន ដែលមនុស្សវ័យចំណាស់ឥណ្ឌូនេស៊ីសព្វថ្ងៃត្រូវតែកាន់តាមខ្លួនរៀងរាល់ថ្ងៃ ។ ប័ណ្ណសម្គាល់ខ្លួននេះមានរូបរាងជាជំរឿនមួយប្រភេទ ដែលតំណាងឲ្យប្រភេទជំរឿននយោបាយមួយ ដែលមានលក្ខណៈពិសេសសម្រាប់អ្នកទាំងឡាយដែលឋិតនៅក្នុងប្រភេទ «អ្នកធ្វើវិទ្ធង្សនា» ឬ «អ្នកក្បត់» ។ គួរឲ្យកត់សម្គាល់ថា ជំរឿនប្រភេទនេះមានលក្ខណៈឥតខ្ចោះបន្ទាប់ពីការទទួលបាននូវឯករាជ្យជាតិ ៕

# ជំពូកទី ៤ ៖ រឿងប្រតិដ្ឋ ជាតិ ហើយនិងការរស់នៅរួមគ្នា ក្នុងដែនដីអាណានិគមកម្ពុជា គ.ស. ១៨៩០–១៩៣០

## កំណត់ចំណាំ

**(១)** ហ្ស៊ុល មីស្លឺឡេត៍ (Jules Michelet) *Jeanne d'Arc* [**ហ្សាន ដាក**] (ប៉ារីស គ.ស. ១៩៧៤) ទំ. ១៥១ ។

**(២)** អ៊ីហ្សាបែល ជូលីយ៉ា (Isabelle Julia) "Daughters of the Century" «[ពួកបុត្រីនៃសតវត្សរ៍]» នៅក្នុង *La France: Images of Women and Ideas of Nation, 1789-1989* [**ឡាហ្វ្រង់ ៖ រូបភាពរបស់ស្ត្រី និងគំនិតរបស់ជាតិ គ.ស. ១៧៨៩-១៩៨៩**] (ឡុងដ្រ៍ គ.ស. ១៩៨៩) ទំ. ៩០-៩១ ។

**(៣)** អា. រ. ឡឺបែល (A. R. Lebel) *Histoire de la littérature coloniale en France* [**ប្រវត្តិសាស្ត្រអក្សរសិល្ប៍អាណានិគមនៅប្រទេសបារាំងសែស**] (ប៉ារីស គ.ស. ១៩៣១) ទំ. ១៧២ ។

**(៤)** ហ៊ុហ្គ ឡឺ រូ (Hugues le Roux) *Nos filles : Qu'en ferons-nous ?* [**កូនស្រីរបស់យើង ឱ្យយើងនឹងរើសអនាគតអ្វីចំពោះពួកនាង ?**] (ប៉ារីស គ.ស. ១៨៩៨) ទំ. ១, ២១១ ; ហ្សក ហារឌី (Georges Hardy) *Ergaste ou la vocation coloniale* [**លោក អេរហ្គាស្ត៍ ឬ ការស្ដីពីឧបនិស្ស័យអាណានិគម**] (ប៉ារីស គ.ស. ១៩២៩) ទំ. ៧៦ ; រ៉ូហ្សឺរ ម៉ាហ្គ្រ៍ (Roger Magraw) *France, 1815-1914: The Bourgeois Century* [**ប្រទេសបារាំងសែស គ.ស. ១៨១៥-១៩១៤ ៖ សតវត្សរ៍វណ្ណៈគហបត**] (ឡុងដ្រ៍ គ.ស. ១៩៨៣) ទំ. ២៣៨-៣៩ ; ភីធឺរ ប៊ហ្គឺរ (Peter Baugher) "The Contradiction of Colonialism: The French Experience in Indochina" «[ភាពផ្ទុយគ្នានៃអាណានិគមនិយម ៖ បទពិសោធន៍បារាំងសែសនៅឥណ្ឌូចិន]» (និក្ខេបបទ សាកលវិទ្យាល័យវិស្កុន្ស៊ិន គ.ស. ១៩៨៩) ទំ. ១២២-៨៨ ។

**(៥)** អេដ្វឹដ សែដ (Edward Said) "East Isn't East: The Impending Age of the Age of Orientalism" «[បូព៌ាមិនមែនជាបូព៌ា ៖ អវសានហៀបនឹងមកដល់នៃយុគបូព៌ានិយម]» ក្នុង *Times Literary Supplement* [**ទំព័រអក្សរសិល្ប៍បន្ថែមនៃសារព័ត៌មានតៃមស៍**] ថ្ងៃទី ៣ កុម្ភៈ ១៩៩៥ ទំ. ៥ ; នីកូឡាស់ ថូម៉ាស់ (Nicholas Thomas) *Colonialism's Culture, Anthropology, Travel, and Government* [**វប្បធម៌អាណានិគមនិយម នរវិទ្យា ការធ្វើដំណើរ និងរដ្ឋាភិបាល**] (ម៉ិលប៊ន គ.ស. ១៩៩៤) ទំ. ៣៣-៦០ ។

**(៦)** សេ. ឡាវ៉ូល្លេ (C. Lavollée) "Le Tour du monde" «[ដំណើរជុំវិញពិភពលោក]» *Revue des Deux Mondes* [**ទស្សនាវដ្ដីពិភពលោកទាំងពីរ**] (ប៉ារីស គ.ស. ១៨៨៩) ទំ. ៩០៦-១៧ ; ហង់រី មូហូត៍ (Henri Mouhot) *Travels in Indo-China, Siam, Cambodia, and Laos* [**ការធ្វើដំណើរនៅឥណ្ឌូចិន ប្រទេសសៀម កម្ពុជា និងលាវ**] (បាងកក គ.ស. ១៩៨៦) ទំ. ២៧៥-៧៧ ។

**(៧)** អាន់ថូនី បារណិត្ត (Anthony Barnett) "Cambodia Will Never Disappear" «[ស្រុកខ្មែរមិនដែលសូន្យទេ]» *New*

*Left Review* [ទស្សនាវដ្ដីមតិខាងឆ្វេងថ្មី] (ឧសភា-មេសា គ.ស. ១៩៩០) ទំ. ១០១-១២៥ ; ប៉ូល ឌូមែរ (Paul Doumer) *L'Indochine française (souvenirs)* [ឥណ្ឌូចិនបារាំងសែស (អនុស្សាវរីយ៍)] (ប៉ារីស គ.ស. ១៩៣០) ទំ. ២៩០ ។

(៨) ឌូមែរ [ឥណ្ឌូចិនបារាំងសែស...] ទំ. ៩-២៦, ២១៥ ។

(៩) ដដែល ទំ. ១៣ ; អាឡាំង គរបាំង (Alain Corbin) *Women for Hire: Prostitution and Sexuality in France after 1850* [ស្រីឈ្នួល ៖ ពេស្យាចារនិងភេទវិថីនៅប្រទេសបារាំងសែស ក្រោយ គ.ស. ១៨៥០] (ខេមប្រ៊ីដហ្ស៍ រដ្ឋម៉ាស្សាឈូសិត្ស គ.ស. ១៩៩០) ទំ. ៣៣១ ; កាទ្រីន ហ្វូកេត៍ (Catherine Fouquet) *L'Histoire des mères du Moyen Âge à nos jours* [ប្រវត្តិសាស្ត្រពួកម្ដាយពីមជ្ឈិមសម័យរហូតដល់សព្វថ្ងៃ] (ប៉ារីស គ.ស. ១៩៨០) ទំ. ១៣៨-៧៨ ។

(១០) អាន្ន-ម៉ារី វិល្លិស (Anne-Marie Willis) *Illusions of Identity: The Art of Nation* [មាយាការនៃអត្តសញ្ញាណ ៖ សិល្បៈរបស់ជាតិ] (ស៊ីដនេយ៍ គ.ស. ១៩៩៣) ទំ. ៩៩ ; ហ្សក ម៉ូស្ស (George Mosse) *The Nationalization of the Masses* [ជាតូបនីយកម្មរបស់ប្រជានិករ] (ញូយ៉ក គ.ស. ១៩៧៤) ទំ. ៧៨ ; អាសា ប្រិគ្ស (Asa Briggs) *Victorian Things* [វត្ថុជំនាន់វិចតូរីយ៉ា] (ឡុងដ្រ៍ គ.ស. ១៩៨៨) ទំ. ១២៨ ; ដូណាល់ដ៍ ហ៊ន (Donald Horne) *The Great Museum: The Re-Presentation of History* [មហាសារមន្ទីរ ៖ ការសម្ដែងប្រវត្តិសាស្ត្រ] (ឡុងដ្រ៍ គ.ស. ១៩៨៤) ទំ. ៤ ។

(១១) ឡេណារដ៍ បិល្ល (Leonard Bell) *Colonial Constructs: European Images of Maori* [ការសាងក្នុងគំនិតសម័យអាណានិគម ៖ រូបភាពរបស់ពួកអឺរ៉ុបអំពីជនជាតិម៉ាអូរី] (ម៉ិលប៊ន គ.ស. ១៩៩២) ទំ. ៧០, ១៤៧-៤៨, ១៥០-៥២ ; ថូម៉ាស់ *Colonialism's Culture...* [វប្បធម៌អាណានិគមនិយម...] ទំ. ១១២-១១៣ ; អាន្នី គូម្បស៍ (Annie Coombes) *Reinventing Africa: Museums, Material Culture, and Popular Imagination* [ការប្រឌិតអាហ្វ្រិកឡើងវិញ ៖ សារមន្ទីរ វប្បធម៌សម្ភារៈ និងប្រឌិតញ្ញាណប្រជាប្រិយ] (ញូហេវិន គ.ស. ១៩៩៤) ទំ. ៨៩-១០៥, ១៨៧-២១៣ ; អាន្ន ម៉ាក់គ្លិន្តុក (Anne McClintock) "Maidens, Maps, and Mines: King Solomon's Mines and the Reinvention of Patriarchy in Colonial South Africa" «[ស្រីក្រមុំ ផែនទី និងអណ្ដូងរ៉ែ ៖ អណ្ដូងរ៉ែនៃព្រះរាជា សាឡូម៉ូន និងការប្រឌិតឡើងវិញនូវបេត្តេយកា (អំណាចរបស់បិតា) នៅក្នុងដែនដីអាហ្វ្រិកខាងត្បូងសម័យអាណានិគម]» ក្នុង *Women and Gender in South Africa to 1945* [ស្ត្រីនិងភេទភាវៈនៅអាហ្វ្រិកខាងត្បូង រហូតដល់ គ.ស. ១៩៤៥] បណ្ណាធិការ ៖ ឆេរិល វ៉ល់ក៏រ (Cheryl Walker) (កែបថោន គ.ស. ១៩៩០) ទំ. ៩៧-១២៤ ; ឌូមែរ [ឥណ្ឌូចិនបារាំងសែស...] ទំ. ២៦៩-៧៩ ; ហ្សក ហ្គ្រោលីយ៉េរ៍ (George Groslier) *Danseuses cambodgiennes, anciennes et modernes* [ស្ត្រីរបាំខ្មែរ សម័យបុរាណ និងសម័យបច្ចុប្បន្ន] (ប៉ារីស គ.ស. ១៩១៣) ទំ. ១២០ ។

(១២) ហ្សក ហ្គ្រោលីយ៉េរ៍ (George Groslier) "Les arts indigènes au Cambodge" «[សិល្បៈម្ចាស់ស្រុកនៅប្រទេសកម្ពុជា]» ក្នុង *L'Indochine française : Recueil de notices rédigées à l'occasion du X*[e] *congrès de la Far Eastern Association of Tropical Medicine, Hanoi, 24-30 novembre 1938* [ឥណ្ឌូចិនបារាំងសែស ៖ ប្រជុំនិវេទន៍ ដែលតែងឡើងនៅក្នុងឱកាសនៃសមាជទី ១០ របស់សមាគមបូព៌ាសម្រាប់វេជ្ជវិជ្ជាប្រទេសក្ដៅ ហាណូយ ២៤-៣០ វិច្ឆិកា ១៩៣៨] (ហាណូយ គ.ស. ១៩៣៨) ទំ. ១៦១ ; មិលតុន អុស្ប៊ន (Milton Osborne) *The French Presence in Cochinchina and Cambodia, 1859-1905* [វត្តមានបារាំងសែសនៅកូសាំងស៊ីននិងកម្ពុជា គ.ស. ១៨៥៩-១៩០៥] (អ៊ីថាកា រដ្ឋញូយ៉ក គ.ស. ១៩៦៩) ទំ. ២៥៧ ; *Sihanouk: Prince of Light, Prince of Darkness* [ព្រះសីហនុ ៖ ស្ដេចនៃពន្លឺ ស្ដេចនៃភាពអន្ធការ] (ស៊ីដនេយ៍ គ.ស. ១៩៩៤) ទំ. ១៦ ; អេលីហ្សាបិថ បេកឺរ (Elisabeth Becker) *When the War Was Over: The Voices of the Cambodian Revolution and Its People* [ពេលដែលសង្គ្រាមបានចប់ទៅ ៖ សម្លេងរបស់បដិវត្តន៍កម្ពុជានិងរបស់ប្រជាជនបដិវត្ត] (ញូយ៉ក គ.ស. ១៩៨៦) ទំ. ៥៥ ; បេន គៀរណាន់ (Ben Kiernan) *How Pol Pot Came to Power* [របៀបដែល ប៉ុល ពត បានឡើងកាន់អំណាច] (ឡុងដ្រ៍ គ.ស. ១៩៨៥) ទំ. xi, ៣-៧ ។

(១៣) ឡឺ រូ (le Roux) *Nos filles...* [កូនស្រីរបស់យើង...] (ប៉ារីស គ.ស. ១៨៩៨) ទំ. ១, ២១១ ; អឺ. ហ្ស៊ីរ៉េត៍ (E. Giret)

"La femme au Colonies" «[ស្ត្រីនៅដែនដីអាណានិគម]» *Revue Indochinoise* **[ទស្សនាវដ្ដីឥណ្ឌូចិន]** លេខ ១១៧ (១៤ មករា គ.ស. ១៩០១) ទំ. ១ ។

**(១៤)** ហ្សូសែហ្វ ស្ហាយី-ប៊ែរត៍ (Joseph Chailly-Bert) *L'Émigration des femmes aux colonies* **[និរប្រវេសន៍ស្ត្រីនៅដែនដីអាណានិគម]** (ប៉ារីស គ.ស. ១៨៩៦) ; សហភាពអាណានិគមបារាំងសែស សមាគមបារាំងសែសនិរប្រវេសន៍ស្ត្រី ១-៣ បណ្ណសារដ្ឋានឯនាយសមុទ្រ ឥណ្ឌូចិន អគ្គទេសាភិបាលឥណ្ឌូចិន (AOM INDO GGI) ៧៦៦១ ។

**(១៥)** សារាចរដោយលោក អង់ដ្រេ ឡឺបុង (André Lebon) រដ្ឋមន្ត្រីក្រសួងអាណានិគម ៣១ កក្កដា ១៨៩៧, សំបុត្ររបស់រ៉េស៊ីដង់ស៊ុប៉េរីយើរនៅតុងកឹង ផ្ញើជូនអគ្គទេសាភិបាល ចុះថ្ងៃទី ២៣ កញ្ញា ១៨៩៧ ហើយនិងកំណត់ហេតុរបស់លោក ស្ហេនីញ៉ើ (Chénieux) ការិយាល័យទី ១ ប្រចាំកូសាំងស៊ីន គ្មានចុះកាលបរិច្ឆេទ, សំបុត្ររបស់អគ្គទេសាភិបាលផ្ញើជូនរដ្ឋមន្ត្រីក្រសួងអាណានិគម ពុំមានចុះកាលបរិច្ឆេទ, លោកស្រីកុងតេស្ស ដឺ គុយស្ទីន (Comtesse de Custine) ប្រធានសមាគមនិរប្រវេសន៍ស្ត្រី ផ្ញើជូនអគ្គទេសាភិបាល ចុះថ្ងៃទី ២៨ ធ្នូ ១៩០៣, សំបុត្ររបស់អគ្គទេសាភិបាល ឈ្មោះ បូ (Beau) ផ្ញើជូនលោកស្រី ដឺ គុយស្ទីន ចុះថ្ងៃទី ២២ មីនា ១៩០៤, AOM INDO GGI ៧៦៦៣ ។

**(១៦)** ហ្សង់ អាហ្សាល់ប៊ែរត៍ (Jean Ajalbert) *L'Indochine en péril* **[ឥណ្ឌូចិនក្នុងគ្រោះហានិភ័យ]** (ប៉ារីស គ.ស. ១៩០៦) ទំ. ២៦ ; អឺហ្សែន ពុយហ្សារនីស្គុល (Eugène Pujarniscule) *Philoxène ou de la littérature coloniale* **[ការចូលចិត្តជនបរទេស ឬ ក្នុងគ្រប់ដណ្ដប់នៃអក្សរសិល្ប៍អាណានិគម]** (ប៉ារីស គ.ស. ១៩៣១) ទំ. ១០៦-៧, ១៥៥ ។

**(១៧)** អគ្គទេសាភិបាល ទីភ្នាក់ងារសេដ្ឋកិច្ច "Renseignements sur les emplois privés ou administratifs en Indo-Chine" «[ព័ត៌មានអំពីមុខរបរឯកជនឬរដ្ឋបាលនៅឥណ្ឌូចិន]» គ្មានចុះកាលបរិច្ឆេទ (ប្រហែលដើមទសវត្សរ៍ឆ្នាំ ១៩២០) ទំ. ១ ; អគ្គទេសាភិបាល នាយកដ្ឋានសិក្សាធិការសាធារណៈ "Situation des fonctionnaires de l'enseignement en Indochine" «[ស្ថានភាពរបស់អ្នករាជការក្នុងវិស័យសិក្សាធិការនៅឥណ្ឌូចិន]» គ្មានចុះកាលបរិច្ឆេទ (ប្រហែលចុងទសវត្សរ៍ឆ្នាំ ១៩២០) ទំ. ៥, ៧ ; អគ្គទេសាភិបាលផ្ញើជូនរដ្ឋមន្ត្រីក្រសួងអាណានិគម ថ្ងៃទី ៩ ធ្នូ ១៩២៧ AOM FM INDO NF ៨៧៣ ; ហារី ហ្វ្រែងក៍ (Harry Franck) *East of Siam: Ramblings in the Five Divisions of French Indo-China* **[ភាគខាងកើតនៃស្យាមប្រទេស ៖ ការដើរចរច្រប់ក្នុងតំបន់ទាំងប្រាំរបស់ឥណ្ឌូចិនបារាំងសែស]** (ញូយ៉ក គ.ស. ១៩២៦) ទំ. ២៣៩ ; សមាគមគាំពារមាតានិងទារកកម្ពុជា (Société de Protection Maternelle et Infantile du Cambodge) AOM INDO អគ្គស្នងការដ្ឋានប្រចាំកម្ពុជា (Haut Commissariat au Cambodge) ១៣ (គេបានបោះពុម្ពផ្សាយនូវលក្ខន្តិកៈរបស់សមាគមនេះនៅភ្នំពេញ នាឆ្នាំ ១៩២៧) ; ហ្សីរ៉េត៍ (Giret) "La femme..." «[ស្ត្រី...]» ទំ. ១ ; ហ្សានីស ប្រោនហ្វ៊ូត (Janice Brownfoot) "Memsahibs in Colonial Malaya: A Study of European Wives in a British Colony and Protectorate, 1900-1940" «[មែមសាហ៊ីបនៅមាឡាយ៉ាសម័យអាណានិគម ៖ ការសិក្សាស្រាវជ្រាវ អំពីប្រពន្ធអឺរ៉ុបនៅក្នុងដែនដីអាណានិគមនិងប្រទេសក្នុងអាណាព្យាបាលរបស់អង់គ្លេស គ.ស. ១៩០០-១៩៤០]» ក្នុង *The Incorporated Wife* **[ប្រពន្ធរួមបញ្ចូល]** បណ្ណាធិការ ៖ ហ៊ិល្លារី កាល្លាន់ (Hillary Callan) និង ស្ហឺរលេយ៍ អារដឺណឺរ (Shirley Ardener) (ឡុងដ៍ គ.ស. ១៩៨៤) ទំ. ១៩១ ។

**(១៨)** អាហ្សាល់ប៊ែរត៍ (Ajalbert) *L'Indochine...* **[ឥណ្ឌូចិន...]** ទំ. ៣១-៣២ ; ពីយែរ មីល្ល (Pierre Mille) *Sur la vaste terre* **[នៅលើដែនដីដ៏ធំធេង]** (ប៉ារីស គ.ស. ១៩០៦) ទំ. ១៧៥-៨៥ ។

**(១៩)** ពីយែរ ប៉ាស្គីយេរ៍ (Pierre Pasquier) "Rapport sur l'Indochine" «[របាយការណ៍អំពីឥណ្ឌូចិន]» ក្នុង *Compte rendu des travaux du Congrès colonial de Marseille* **[សេចក្ដីរាយការណ៍អំពីកិច្ចការរបស់សមាជអាណានិគមនៅម៉ារសី]** ២ ភាគ (ម៉ារសី គ.ស. ១៩០៦) ភាគទី ២ ទំ. ៥៣៣ ។

**(២០)** ឡាហ្គ្រីល្លីយែរ-បូក្លែរ (Lagrillière-Beauclerc) *À travers l'Indochine: Études coloniales* **[នៅទូទាំងឥណ្ឌូចិន ៖ ការសិក្សាស្រាវជ្រាវអាណានិគម]** (ប៉ារីស គ.ស. ១៩០០) ទំ. ១៣៤ ; ប៉ូល ប៊ែរហ្គ (Paul Bergue) "L'habitation eu-

ropéenne au Cambodge" «[លំនៅឋានអឺរ៉ុបនៅប្រទេសកម្ពុជា]» *Revue Indochinoise* **ទិដ្ឋភ័យអាំងដូស្ហ៊ីណ្វាហ្សីវ៍ [ទស្សនាវដ្ដីឥណ្ឌូចិន]** លេខ ៧ (១៥ មេសា គ.ស. ១៩០៥) ទំ. ៤៩០-៩៩ ; ប៉ូល អ៊ីហ្គូត៍ (Paul Igout) *Phnom Penh Then and Now* **[ភ្នំពេញក្នុងជំនាន់នោះ និងជំនាន់នេះ]** (បាងកក គ.ស. ១៩៩៣) ទំ. ៧៧, ១៣៧-៣៨ ; ក្លូទីលដឺ ស្ហ៊ីវ៉ាស-បារ៉ុង (Clothilde Chivas-Baron) ដកស្រង់ពី ប៊ហ្គ័រ (Baugher) "The Contradiction of Colonialism..." «[ភាពផ្ទុយគ្នានៃអាណានិគមនិយម...]» ទំ. ១៥១ ; ម៉ារហ្គឺរីត ឌុយរ៉ាស (Marguerite Duras) និង មីស្ហែល្ល ពត (Michelle Porte) *Les Lieux de Marguerite Duras* **[ទីកន្លែងដែល ម៉ារហ្គឺរីត ឌុយរ៉ាស ធ្លាប់នៅ]** (ប៉ារីស គ.ស. ១៩៧៧) ទំ. ៥៦ ; ហ្សង់ អាហ្សាល់បែរត៍ (Jean Ajalbert) *Ces phénomènes, artisans de l'empire* **[មនុស្សដ៏អស្ចារ្យទាំងនោះ ដែលជាជាងរបស់ចក្រភព]** (ប៉ារីស គ.ស. ១៩៤១) ទំ. ១១០ ។

**(២១)** ហ្សង់ ម៉ារកេត៍ (Jean Marquet) *La France mondiale au XXᵉ siècle, Indochine* **[ប្រទេសបារាំងសែសនៃពិភពលោកក្នុងសតវត្សរ៍ទី ២០ ៖ ឥណ្ឌូចិន]** (ប៉ារីស គ.ស. ១៩៣១) ទំ. ១៧៥ ; លួី ម៉ាល្ល៉េរ៉េត៍ (Louis Malleret) *L'Exotisme Indochinois dans la littérature française depuis 1860* **[លក្ខណៈដ៏ប្លែករបស់ឥណ្ឌូចិនក្នុងអក្សរសិល្ប៍បារាំងសែសតាំងពីឆ្នាំ ១៨៦០]** (ប៉ារីស គ.ស. ១៩៣៤) ទំ. ២២៤ ; ម៉ារហ្គឺរីត ឌុយរ៉ាស (Marguerite Duras) *The Sea Wall* (ញូយ៉ក គ.ស. ១៩៨៥) ទំ. ១៣៥-៣៧ បកប្រែពីសៀវភៅដើមជាភាសាបារាំង *Un Barrage contre le Pacifique* **[ទំនប់ទប់ទល់មហាសមុទ្រប៉ាស៊ីហ្វិក]** (ប៉ារីស គ.ស. ១៩៥០) ។

**(២២)** "L'exposition de l'Indochine" «[ពិព័រណ៍ឥណ្ឌូចិន]» ក្នុង *L'Illustration* **[ខចិត្រូប]** (ប៉ារីស) ១ កញ្ញា ១៩០០ ទំ. ១៣៤-៣៥ ; "L'état des esprits en Indochine" «[ស្ថានភាពមតិទាំងឡាយ នៅឥណ្ឌូចិន]» *Bulletin mensuel du comité de l'Asie française* **[ព្រឹត្តិបត្រប្រចាំខែរបស់គណៈកម្មាធិការអាស៊ីបារាំងសែស]** កញ្ញា ១៩០៦ ទំ. ៣៣៤, ២៥៣ ; ព្រះអង្គម្ចាស់ អរេណូ យុគន្ធរ (Areno Iukanthor) *Destin de l'Empire* **[វាសនារបស់ចក្រភព]** (ប៉ារីស គ.ស. ១៩៣៥) ទំ. ៨៦-៨៨ ; លោកស័ក្តិ ៣ ចាន់ រាយការណ៍ដល់អគ្គទេសាភិបាល ថ្ងៃទី ១ កក្កដា ១៩០៦ ទំ. ២៤-២៧ AOM INDO GGI ៥៨៨១ ; អាហ្សាល់បែរត៍ (Ajalbert) *L'Indochine...* **[ឥណ្ឌូចិន...]** ទំ. ២៦-២៧ ។

**(២៣)** ប៉ូល រ៉ាស្សិល ក្រាវ៉ាត់ (Paul Russel Cravath) "Earth in Flower: An Historical and Descriptive Study of the Classical Dance Drama of Cambodia" «[ដីមានផ្កា ៖ ការសិក្សាផ្នែកប្រវត្តិនិងផ្នែកពណ៌នា អំពីល្ខោនព្រះរាជទ្រព្យខ្មែរ]» (និក្ខេបបទ សាកលវិទ្យាល័យហាវ៉ៃ គ.ស. ១៩៨៥) ទំ. ១៧៣-៧៤ ; *Les Actualités diplomatiques et coloniales, numéro spécial : l'Exposition de Hanoi en 1902* **[បច្ចុប្បន្នភាពផ្នែកទូត និងផ្នែកអាណានិគម លេខពិសេស ៖ ពិព័រណ៍នៅហាណូយក្នុងឆ្នាំ ១៩០២]** លេខ ១ (កញ្ញា ១៩០២) ទំ. ៣៥-៣៨ ។

**(២៤)** ហ្សង់ នូរី (Jean Noury) *L'Indochine avant l'ouragan* **[ឥណ្ឌូចិនមុនព្យុះសង្ឃរា គ.ស. ១៩០០-១៩២០]** (ស្ត្រាស្ប៊ួរ ១៩៨៤) ទំ. ១៥៦ ។

**(២៥)** ពាក្យ កនហ្កាយ ឬ កងហ្កាយ នេះ ជាពាក្យយួន មានន័យថា ក្មេងស្រី ដែលពួកបារាំងធ្លាប់ប្រើប្រាស់នៅទូទាំងឥណ្ឌូចិនបារាំងសែសក្នុងន័យបង្អាប់ សម្រាប់សំដៅទៅលើស្រីកំណាន់ឬប្រពន្ធឥតខាន់ស្លា ជាតិយួន ខ្មែរ លាវ ជប៉ុន និងចិន របស់ពួកបារាំង ។ សូមមើល ម៉ាល្ល៉េរ៉េត៍ (Malleret) *L'Exotisme...* **[លក្ខណៈដ៏ប្លែករបស់...]** ទំ. ២១៧ និងតទៅ ; ស្ហាល ម៉េយែរ (Charles Meyer) *La Vie quotidienne des Français en Indochine* **[ជីវិតប្រចាំថ្ងៃរបស់ពួកបារាំងសែសនៅឥណ្ឌូចិន]** (ប៉ារីស គ.ស. ១៩៨៥) ទំ. ២៦៥ និងតទៅ, ២៨៨ ។

**(២៦)** អាហ្សាល់បែរត៍ (Ajalbert) *Ces phénomènes...* **[មនុស្សដ៏អស្ចារ្យ...]** ទំ. ១៤៣-៤៤ ; ម៉ាល្ល៉េរ៉េត៍ (Malleret) *L'Exotisme...* **[លក្ខណៈដ៏ប្លែករបស់...]** ទំ. ២១៧ ; ដេវិឌ ស្ពឺរ៍ (David Spurr) *The Rhetoric of Empire: Colonial Discourse in Journalism, Travel Writing, and Imperial Administration* **[វោហារសាស្ត្ររបស់ចក្រភព ៖ សេចក្ដីថ្លែងបែបអាណានិគមក្នុងសារព័ត៌មាន អត្ថបទអំពីការធ្វើដំណើរ និងរដ្ឋបាលចក្រភព]** (ដឺរ៉ុម រដ្ឋការ៉ូឡៃណាខាងជើង គ.ស.

១៩៩៣) ទំ. ១៧១ ។

**(២៧)** អាល់ប៊ែរត៍ ដឺ ពូវួរវីល្ល (Albert de Pouvourville) *Le Cinquième bonheur* **[សុភមង្គលទីប្រាំ]** (ប៉ារីស គ.ស. ១៩២២) និង *L'Heure silencieuse* **[ម៉ោងស្ងាត់]** (ប៉ារីស គ.ស. ១៩២៦) ; ម៉ាល្លឺរ៉េត៍ (Malleret) *L'Exotisme...* **[លក្ខណៈដីប្លែកទបស់...]** ; ហ្ស៊ីរ៉េត៍ (Giret) "La femme..." «[ស្ត្រី...]» ទំ. ១ ; អាហ្សាល់ប៊ែរត៍ (Ajalbert) *Ces phénomènes...* **[មនុស្សដ៏អស្ចារ្យ...]** ទំ. ១៦៩-៧១ ។

**(២៨)** ម៉េយែរ (Meyer) *La Vie...* **[ជីវិត...]** ទំ. ២៦៨ ; ពុយហ្សារនីស្គុល (Pujarniscule) *Philoxène...* **[ការចូលចិត្តជនបរទេស...]** ទំ. ១០៧ ។

**(២៩)** ឌូមែរ (Doumer) *L'Indochine...* **[ឥណ្ឌូចិន...]** ទំ. ២៥៣-៥៤ ; ហ្សង់ ម៉េយែរ (Jean Meyer) និងអ្នកដទៃ *Histoire de la France coloniale des origines à 1914* **[ប្រវត្តិសាស្ត្រប្រទេសបារាំងសែសអាណានិគមពីដើមដំបូងដល់ឆ្នាំ ១៩១៤]** (ប៉ារីស គ.ស. ១៩៩០) ទំ. ៦៩៧-៩៩ ; ប៉ាទ្រីស ម៉ូរីយ៉ាត៍ (Patrice Moriat) *Les Affaires politiques de l'Indochine (1895-1923) : Les grands commis : du savoir au pouvoir* **[កិច្ចការនយោបាយរបស់ឥណ្ឌូចិន (គ.ស. ១៨៩៥-១៩២៣) ៖ មន្ត្រីជាន់ខ្ពស់ ៖ ពីចំណេះដឹងដល់អំណាច]** (ប៉ារីស គ.ស. ១៩៩៥) ទំ. ១៩-២០ ។

**(៣០)** អាឡាំង ហ្វូរ៉េស្ត (Alain Forest) *Le Cambodge et la colonisation française : Histoire d'une colonisation sans heurts (1897-1920)* **[ប្រទេសកម្ពុជានិងអាណានិគមកិច្ចបារាំងសែស ៖ ប្រវត្តិសាស្ត្រអាណានិគមកិច្ចឥតភាពទាស់គ្នា (គ.ស. ១៨៩៧-១៩២០)]** (ប៉ារីស គ.ស. ១៩៨០) ទំ. ២២៥ ។

**(៣១)** អិម. អឺ. អាស្សូដ៍ (M. E. Assaud) អគ្គរដ្ឋអាជ្ញា ចៅហ្វាយផ្នែកតុលាការនៅកូសាំងស៊ីននិងកម្ពុជា «សារាចរសម្ងាត់» ព្រៃនគរ ថ្ងៃទី ១៨ កញ្ញា ១៨៩៧ ទំ. ១ ; ប៉ូល ឌូមែរ «សារាចរសម្ងាត់» AOM INDO GGI ៧៧៧០ ; អគ្គរដ្ឋអាជ្ញា ចៅហ្វាយផ្នែកតុលាការនៅឥណ្ឌូចិន សារាចរ ព្រៃនគរ ថ្ងៃទី ១៩ កញ្ញា ១៩០៨ AOM INDO GGI ៤៦៨០ ; អគ្គទេសាភិបាលផ្ញើជូនរដ្ឋមន្ត្រីក្រសួងអាណានិគម ថ្ងៃទី ៧ វិច្ឆិកា ១៩១០ AOM FM INDO NF ៧៦ (១) ។

**(៣២)** "Les métis et l'œuvre de la protection de l'enfance au Cambodge" «[កូនកាត់និងស្នាដៃក្នុងការការពារកុមារនៅប្រទេសកម្ពុជា]» *Revue Indochinoise* **រ៉ឺវុយអាំងដូស្ស៊ីណ្វាហ្ស៍ [ទស្សនាវដ្តីឥណ្ឌូចិន]** មករា គ.ស. ១៩១៣ ទំ. ៣១; ហង់រី ឆំព្លី (Henry Champly) *The Road to Shanghai : White Slave Traffic in Asia* **[ផ្លូវទៅសៀងហៃ ៖ ការជួញដូរទាសករស្បែកសនៅអាស៊ី]** (ប៉ារីស គ.ស. ១៩៩៥) ទំ. ៨៣ ។

**(៣៣)** ជាឧទាហរណ៍ សូមមើល អេឌូអារដ៍ ហេកេល (Édouard Heckel) និង ស៊ីព្រីយ៉ាំង ម៉ង់ឌីន (Cyprien Mandine) *L'Enseignement colonial en France et à l'étranger* **[ការអប់រំអាណានិគមនៅប្រទេសបារាំងសែស និងនៅបរទេស]** (ម៉ារសី គ.ស. ១៩០៧) ទំ. ៤៤-៤៥ ។

**(៣៤)** ម៉ាល្លឺរ៉េត៍ (Malleret) *L'Exotisme...* **[លក្ខណៈដីប្លែកទបស់...]** ទំ. ៤១ និងតទៅ ; ម៉េយែរ (Meyer) *Saramani : Danseuse cambodgienne* **[សារ៉ាម៉ានី ៖ ស្ត្រីរបាំខ្មែរ]** (ប៉ារីស គ.ស. ១៩២២) ; ម៉េយែរ *Cours de laotien* **[មេរៀនភាសាលាវ]** (ប៉ារីស គ.ស. ១៩២៤) ; ម៉េយែរ *Indochine française : Le Laos* **[ឥណ្ឌូចិនបារាំងសែស ៖ប្រទេសលាវ]** (ហាណូយ គ.ស. ១៩៣១) ; ម៉េយែរ *Propos du vieux colonial* **[ពាក្យសម្តីរបស់អ្នកអាណានិគមនិយមចំណាស់មួយ]** (គ.ស. ១៩៥២ បោះពុម្ពឡើងវិញ ប៉ារីស គ្មានចុះកាលបរិច្ឆេទ ក្របខាងក្រោយ) ។

**(៣៥)** ស្នាដៃរបស់លោក ម៉េយែរ បង្ហាញពីឆន្ទៈទាក់ទងសង្គមអាណានិគមច្រើនជាងលោក ហ្គ្រោលីយេរ៍ ។ សៀវភៅរបស់លោក ហ្គ្រោលីយេរ៍ គឺ *Danseuses cambodgiennes, anciennes et modernes* **[ស្ត្រីរបាំខ្មែរ សម័យបុរាណ និងសម័យបច្ចុប្បន្ន]** គ្មានភាពស៊ីជម្រៅ និងភាពលម្អិតដូចរឿង **សារ៉ាម៉ានី** ។ សូមមើល ក្រាវ៉ាត់ (Cravath) "Earth in Flower..." «[ដីមានផ្កា...]» ទំ. ៧៣-៧៤ ។

**(៣៦)** រ៉ាហ្វាអែល បារគីស្សូ (Rafael Barquisseau) *Le Roman colonial français* **[ប្រលោមលោកអាណានិគមបារាំងសែស]**

(ហាណូយ គ.ស. ១៩២៦) ទំ. ៣ ។

**(៣៧)** ហ្គ្រោលីយេ៉រ៍ ផ្ញើជូនអគ្គលេខាធិការ ហាណូយ ថ្ងៃទី ២៥ មិថុនា ១៩០៦ AOM INDO GGI ២៣៩៧ ។

**(៣៨)** អិល. ហ្វរ៉េស្ទីយេ៉រ៍ (L. Forestier) "George Groslier : Prix de la littérature coloniale 1929 : *Le retour à l'argile*" «[ហ្សក ហ្គ្រោលីយេ៉រ៍ ៖ រង្វាន់អក្សរសិល្ប៍អាណានិគម គ.ស. ១៩២៩ ៖ **ត្រឡប់ទៅជាដីឥដ្ឋវិញ**]» ក្នុង *Extrême-Asie, Revue Indochinoise illustrée* [**អាស៊ីចុងបំផុត ទស្សនាវដ្ដីឥណ្ឌូចិនមានរូបភាព**] លេខ ៣៨ (សីហា គ.ស. ១៩២៩) ទំ. ៦០២ ។

**(៣៩)** ក្រាវ៉ាត់ (Cravath) "Earth in Flower..." «[ដីមានផ្កា...]» ទំ. ១៧៣-៧៤ ; ហ្សក ហ្គ្រោលីយេ៉រ៍ (George Groslier) *À l'ombre d'Angkor* [**នៅក្នុងស្រមោលអង្គរ**] (ប៉ារីស គ.ស. ១៩១៦) ។

**(៤០)** អាល់ប៊ែរត៍ សារ៉ូត៍ (Albert Sarraut) *La Mise en valeur des colonies françaises* [**ការធ្វើឱ្យប្រសើរឡើងនូវដែនដីអាណានិគមបារាំងសែស**] (ប៉ារីស គ.ស. ១៩២៣) ទំ. ១០៤ ។

**(៤១)** ហ្សក ហ្គ្រោលីយេ៉រ៍ (George Groslier) "Les arts indigènes au Cambodge" «[សិល្បៈរបស់ម្ចាស់ស្រុកនៅប្រទេសកម្ពុជា]» ; *La Route du plus fort* [**ផ្លូវរបស់អ្នកខ្លាំងបំផុត**] (ប៉ារីស គ.ស. ១៩២៥) ; *Le retour à l'argile* [**ត្រឡប់ទៅជាដីឥដ្ឋវិញ**] ។ សូមមើល ហារីយែត ប៉ុណ្ដឺរ (Harriet Ponder) *Cambodian Glory* [**ភាពរុងរឿងខ្មែរ**] (ឡុងដ៍ គ.ស. ១៩៣៦) ទំ. ១៧០-៧១ ។

**(៤២)** បេកឺរ (Becker) *When the War Was Over...* [**ពេលដែលសង្គ្រាមបានចប់ទៅ...**] ទំ. ៥៤-៥៥ ; ម៉ារីអាឡិចសង់ឌ្រីន ម៉ារតាំង (Marie Alexandrine Martin) *Cambodia: A Shattered Society* [**កម្ពុជា ៖ សង្គមបែកខ្ញែកមួយ**] (បឺរឃ្លេយ៍ រដ្ឋកាលីហ្វរនៀ គ.ស. ១៩៩៤) ទំ. ៣៤ ; អាឡិក ហារហ្គ្រីវស៍ (Alec Hargreaves) *The Colonial Experience in French Fiction* [**បទពិសោធន៍អាណានិគមក្នុងរឿងប្រឌិតបារាំងសែស**] (ឡុងដ៍ គ.ស. ១៩៨៨) ទំ. ១៣-១៤ ។

**(៤៣)** ហ្វរ៉េស្ទីយេ៉រ៍ (Forestier) "George Groslier ..." «[ហ្សក ហ្គ្រោលីយេ៉រ៍...]» ទំ. ៦០៤ ។

**(៤៤)** ដើម្បីដឹងពីការវិភាគស្ដីពីការពិព័ណ៌នាប្រជាជននៅក្នុងចំណុះ ថា ជាភរិយាដ៏ «ល្អ» ប្រកបដោយស្ត្រីលក្ខណ៍ សូមមើលរឿងល្ខោន *M. Butterfly* [**ម្សៀរ បាត់តឺរហ្វ្លាយ**] និពន្ធដោយ ដេវិឌ ហេនរី ហ្វាង (David Henry Hwang) (ឡុងដ៍ គ.ស. ១៩៨៨) ទំ. ៩៩ ។

**(៤៥)** ដេវិឌ ឆាណ្ឌលឺរ (David Chandler) *A History of Cambodia* [**ប្រវត្តិសាស្ត្រប្រទេសកម្ពុជា**] (ប៊ូលឌ័រ រដ្ឋកូឡូរ៉ាដូ គ.ស. ១៩៩២) ទំ. ១៥៦ ។

**(៤៦)** សូមមើល ហ្វរ៉េស្ត (Forest) *Le Cambodge...* [**ប្រទេសកម្ពុជា...**] ទំ. ៩២, ១១៧, ១៣០, ១៤៦, ៣៧៦-៨៤ ; ចន ទុល្លី (John Tully) *Cambodia Under the Tricolor: King Sisowath and the 'Mission Civilisatrice' 1904-1907* [**ប្រទេសកម្ពុជាក្រោមទង់ត្រៃរង្គ ៖ ព្រះបាទ ស៊ីសុវត្ថិ និងបេសកកម្មផ្ដល់អារ្យធម៌ គ.ស. ១៩០៤-១៩០៧**] (ក្លីតុន រដ្ឋវិកតូរីយ៉ា អូស្ត្រាលី គ.ស. ១៩៩៦) ទំ. ១៤៩-៧៦ ; កៀរណាន់ (Kiernan) *How Pol Pot...* [**របៀបដែល ប៉ុល ពត...**] ទំ. ១៤ ៕

## Original Articles in English

Chapter I : "'But Princes Jump!' : Performing Masculinity in Mandalay," by Ward Keeler, in *Burma at the Turn of the Twenty-first Century*, Honolulu: University of Hawai'i Press, Edited by Monique Skidmore, 2005.

Chapter II : "Romances of the Sixth Reign : Gender, Sexuality, and Siamese Nationalism," by Thamora V. Fishel," in *Genders and Sexualities in Modern Thailand*, Chiang Mai: Silkworm Books, Edited by Peter A. Jackson & Nerida M. Cook, 1999.

Chapter III : "Census, Map, Museum," by Benedict Anderson, in *Imagined Communities : Reflections on the Origin and Spread of Nationalism*, by Benedict Anderson, London: Verso, 2006 (1st Edition: 1983, Verso).

Chapter IV : "Womanizing Indochina : Fiction, Nation and Cohabitation in Colonial Cambodia, 1890-1930," by Penny Edwards, in *Domesticating the Empire : Race, Gender and Family Life in French and Dutch Colonialism*, Charlottesville (VA) & London: The University Press of Virginia, edited by Julia Clancy-Smith & Frances Gouda,1998.

**Copyright © 2008 Center for Khmer Studies for the Khmer translation.**

## TABLE OF CONTENTS


Preface 7

Note on the Definition, Concept, and Translation of "Gender" 11

**Chapter I: But Princes Jump!: Performing Masculinity in Mandalay** ..................................13

Performing Gender 16

A Performance of Za' Pwè 17

*The Opening* 17

*The Opera* 18

*The Stage Show* 19

*The Straight Play* 19

*The Duet* 20

The Significance of Costumes 21

Alternative Masculinities 23

The Classical Style 27

Stylized Aggression and Powerlessness 30

Disappearing Females 33

Maculinitiy, Sexuality, and the Saṅgha 36

**Chapter II: Romances of the Sixth Reign: Gender, Sexuality, and Siamese Nationalism** ......39

King Vajiravudh and the Question of National Identity 42

Women and Westernization 45

Love of Nation 50

Conclusion 53

**Chapter III: Census, Map, Museum** ..........................................................................................55

Census 58

Map 62

Museum 67

**Chapter IV: Fiction, Nation, and Cohabitation in Colonial Cambodia, 1890-1930** ..................73

Womanizing Indochina: Fiction, Nation, and Cohabitation
in Colonial Cambodia, 1890-1930 75

Colonizing Cambodia: Discoverers, Dames, and Degeneration 77

Roland Meyer: The Perils of Crossing Cultural Barriers 86

George Groslier: The Perils of Modernity 90

Conclusions 96

NOTES 99
Chapter I 99
Chapter II 102
Chapter III 106
Chapter IV 112